ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍ស្តីពី
# ស្ថានភាពកុមារកម្ពុជា
# ២០២៣





ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

ខែឧសភា ឆ្នាំ២០២៤

# មាតិកា


មាតិកា ............ 1
អក្សរកាត់ ............ 4
អារម្ភកថា ............ 5
I. សេចក្តីផ្តើម ............ 7
II. សមិទ្ធផលសំខាន់ៗពាក់ព័ន្ធការអនុវត្តសិទ្ធិកុមារ ............ 9
១. ក្របខ័ណ្ឌច្បាប់និងគោលនយោបាយ ............ 9
១.១. ក្របខ័ណ្ឌច្បាប់ ............ 9
១.២. ក្របខ័ណ្ឌគោលនយោបាយ ............ 10
២. ការរស់រានមានជីវិត ............ 13
២.១. សុខភាព និងសុខុមាលភាពមូលដ្ឋាន ............ 13
ក. ធនធានមនុស្សសុខាភិបាល ............ 13
ខ. ស្ថិតិមូលដ្ឋានសុខាភិបាលសាធារណៈ ............ 13
គ. មូលដ្ឋានសុខាភិបាលឯកជន ............ 13
ឃ. ដំណើរឆ្ពោះទៅរកការគ្រប់ដណ្តប់សុខភាពជាសាកល ............ 13
ង. ភាពប្រសើរឡើងនៃស្ថានភាពសុខភាព ............ 15
ច. សុខភាពបន្តពូជ ............ 15
ឆ. សុខភាពមាតា និងទារក ............ 16
ជ. សុខភាពកុមារ ............ 18
ឈ. ការកែលម្អកង្វះអាហារូបត្ថម្ភ ............ 20
២.២. កាកបាទក្រហមកម្ពុជា ............ 21
២.៣. ការចុះអត្រានុកូលដ្ឋាន ............ 22
ក. ការចុះបញ្ជីកំណើត ............ 22
២.៤. បរិយាកាសគ្រួសារ ............ 23
ក.ការថែទាំជំនួស ............ 23
ខ.ការសុំកូន ............ 24
គ.កូនតាមឪពុកម្តាយក្នុងពន្ធនាគារ ............ 24
២.៥. បទដ្ឋាននៃការរស់នៅ ............ 24
ក. ទឹកស្អាត និងអនាម័យ ............ 24
ខ. បង្គន់អនាម័យ ............ 24
គ. វឌ្ឍនភាពការតភ្ជាប់បណ្តាញអគ្គិសនីតាមភូមិ និងការតភ្ជាប់ចរន្តអគ្គិសនីតាមខ្នងផ្ទះ ............ 25
៣. ការអភិវឌ្ឍកុមារ ............ 26
៣.១. ការអប់រំ ............ 26
ក. ធនធានមនុស្សផ្នែកអប់រំ ............ 26
ខ. សាលាចំណេះទូទៅ និងមត្តេយ្យសិក្សា ............ 26
គ. ការអប់រំកុមារតូច ............ 27

ឃ. ការអប់រំបឋមសិក្សា ........ 29
ង. ការអប់រំមធ្យមសិក្សា ........ 32
ច. ការអប់រំក្រៅប្រព័ន្ធ ........ 36
៣.២. ការបណ្តុះបណ្តាលវិជ្ជាជីវៈ ........ 37
៤. ការការពារកុមារ ........ 38
៤.១.ការបង្ការ ទប់ស្កាត់ ........ 38
ក. ការលើកកម្ពស់កិច្ចការពារ ........ 38
ខ. ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ ........ 40
គ. អំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ ........ 40
ឃ. ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ........ 41
ង. ការទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនិងការងារដោយបង្ខំ ........ 41
៤.២.ការអន្តរាគម និងឆ្លើយតប ........ 42
ក. អំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ ........ 42
ខ. ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ........ 42
គ. បណ្តាញទូរសព្ទទាន់ហេតុការណ៍ និងការរាយការណ៍តាមអនឡាញ ........ 43
ឃ. កិច្ចអន្តរាគមន៍ក្នុងការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ........ 44
៤.៣. កិច្ចការយុត្តិធម៌ ........ 44
ក. អំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ ........ 44
ខ. ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ........ 45
៤.៤. ការផ្តល់ជំនួយ និងសេវាគាំទ្រ ........ 45
ក. ការងារសង្គមកិច្ច ........ 45
ខ. អំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ ........ 48
គ. ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ........ 49
ឃ. កម្មវិធីជំនួយសង្គម ........ 50
៥. ការចូលរួមរបស់កុមារ ........ 52
៥.១. ក្រុមប្រឹក្សាកុមារកម្ពុជា ក្រុមប្រឹក្សាយុវជនកម្ពុជា និងកាយរឹទ្ធិជាតិកម្ពុជា ........ 52
៥.២. បណ្តាញយុវជន បណ្តាញកុមារ និងក្លឹបកុមារ ........ 52
៦. កិច្ចសហប្រតិបត្តិការលើវិស័យកុមារ ........ 53
៦.១.កិច្ចប្រតិបត្តិការរបស់អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ........ 53
ក. អង្គការភ្លែន ........ 53
ខ. អង្គការឆាលហ្វានកម្ពុជា ........ 54
គ. អង្គការដែនដីមនុស្សហូឡង់ដ៍-ប្រចាំកម្ពុជា ........ 56
ឃ. អង្គការសកម្មភាពដើម្បីកុមារ (APLE) ........ 57
ង. អង្គការមូលនិធិហាការអន្តរជាតិ (Hagar International Foundation) ........ 59
ច. អង្គការសម្ព័ន្ធចាប់ដៃ ........ 61
ឆ. អង្គការសង្គ្រោះកុមារ (Save the Children) ........ 63

ជ. អង្គភាពការពារកុមារ (CPU) ..... 69
ឈ. អង្គការបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា ..... 69
ញ. អង្គការជីវិតថ្លៃថ្នូរ (Life With Dignity-LWD) ..... 73
ដ. អង្គការសម្ពន្ធដើម្បីសិទ្ធិកុមារកម្ពុជា ..... 75
ឋ. សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ ..... 77
III. បញ្ហាប្រឈម ..... 81
IV. ទិសដៅអនុវត្តបន្ត ..... 85
V. សេចក្តីសន្និដ្ឋាន ..... 89

# អក្សរកាត់

| | |
|---|---|
| ក.ជ.ក. | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ក.ក្រ.ក. | កាកបាទក្រហមកម្ពុជា |
| ក.ប. | ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| គ.ជ.ប.ជ. | គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |
| គ.ជ.ព. | គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ |
| គ.ស.ម.ក. | គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា |
| ប.ស.ស. | បេឡាជាតិសន្តិសុខសង្គម |
| ម.ផ. | មហាផ្ទៃ |
| ស.អ.យ. | សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| អ.ជ.ប.គ.ញ. | អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន |
| អ.យ.ក. | អប់រំ យុវជន និងកីឡា |

# អារម្ភកថា

ការរក្សាបាននូវសន្តិភាព និងការពង្រឹងស្ថិរភាពសង្គម នយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជាបានរួមចំណែកយ៉ាងធំធេងក្នុងការរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងធានាបាននូវកំណើនសេដ្ឋកិច្ចរបស់កម្ពុជាគួរឱ្យកត់សម្គាល់។ តាមរយៈការអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៩-២០២៣ ប្រកបដោយចក្ខុវិស័យច្បាស់លាស់ កម្ពុជាបានឈានដល់ឋានៈជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបកាលពីឆ្នាំ២០១៥ និងមានគោលដៅសម្រេចឱ្យបានជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ វឌ្ឍនភាពគួរជាទីមោទនៈនេះ គឺជាការបង្ហាញនូវជំហរ និងជំហានយុទ្ធសាស្ត្រដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលក្នុងការដឹកនាំ និងអភិវឌ្ឍប្រទេសប្រកបដោយសុខដុម។ នៅក្នុងគ្រប់ដំណាក់កាលទាំងអស់ នៃការអនុវត្តយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល បានកំណត់យក **"មនុស្ស"** ជាវិស័យអាទិភាពចម្បងបំផុត ហេតុនេះ ការយកចិត្តទុកដាក់ចំពោះសុខុមាលភាព សុវត្ថិភាព និងការអភិវឌ្ឍកុមារ គឺជាគ្រឹះដ៏សំខាន់ក្នុងការកសាងមូលធនមនុស្សប្រកបដោយសក្តានុពលសម្រាប់ការអភិវឌ្ឍកម្ពុជានាពេលអនាគត។ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តយ៉ាងពេញលេញ និងមានចក្ខុវិស័យច្បាស់លាស់ក្នុងការលើកកម្ពស់សិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ ដោយធ្វើយ៉ាងណាឱ្យកុមារ ក្រុមគ្រួសារ និងសហគមន៍ ទទួលបាននូវគុណភាព និងគុណតម្លៃនៃការរស់នៅក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ សមភាព និងសុវត្ថិភាពស្របតាមរដ្ឋធម្មនុញ្ញ និងគោលការណ៍នីតិរដ្ឋ ដោយមានការចូលរួមយ៉ាងសកម្មពេញលេញស្មើភាពគ្នាក្នុងការអភិវឌ្ឍគ្រប់វិស័យ និងគ្រប់កម្រិត។

របាយការណ៍ស្តីពីស្ថានភាពកុមារ គឺជាឯកសារដ៏សំខាន់មួយដែលបង្ហាញពីសមិទ្ធផលសម្រេចបានលើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនៅកម្ពុជា ដែលបង្ហាញពីការយកចិត្តទុកដាក់លើការលើកកម្ពស់សុខុមាលភាព ការពង្រឹងកិច្ចការពារ ការផ្តល់អំណាច និងការរក្សាឧត្តមប្រយោជន៍កុមារ។ របាយការណ៍នេះ គឺជាការវាស់វែង និងបង្ហាញពីវឌ្ឍនភាពនៃការងារវិស័យកុមារ និងជាឯកសារសម្រាប់ចង្អុលបង្ហាញពីការទទួលខុសត្រូវ ការតស៊ូមតិ និងជាមូលដ្ឋានសម្រាប់រៀបចំគោលនយោបាយ និងផែនការផងដែរ។ តាមរយៈរបាយការណ៍នេះ នឹងជួយបង្កើនការយល់ដឹងអំពីភាពទន់ខ្សោយរបស់កុមារ និងសិទ្ធិកុមារ ដើម្បីឱ្យយើងគ្រប់គ្នាជួយជំរុញការការតស៊ូមតិ និងបង្កើនការយល់ដឹងអំពីការផ្លាស់ប្តូរចាំបាច់នានា នៅក្នុងគោលនយោបាយ ការអនុវត្ត និងអាកប្បកិរិយាសង្គម។ របាយការណ៍នេះ មិនត្រឹមតែបង្ហាញពីការអនុវត្តរបស់រាជរដ្ឋាភិបាលនោះទេ តែក៏ជាកញ្ចក់ឆ្លុះបញ្ចាំង និងវាយតម្លៃលើការអនុវត្តរបស់អង្គការសង្គមស៊ីវិល និងផ្នែកពាក់ព័ន្ធនានាផងដែរ ដោយបង្ហាញពីការធានានូវការអនុវត្តពេញលេញចំពោះអនុសញ្ញាស្តីពីសិទ្ធិកុមារ។ លទ្ធផលនៃរបាយការណ៍នេះនឹងក្លាយជាមូលដ្ឋាននៃការពិចារណាក្នុងការសម្រេចចិត្តរៀបចំយុទ្ធសាស្ត្រ កម្មវិធី សកម្មភាព និងការបែងចែកធនធានសម្រាប់ធ្វើអន្តរាគមន៍ចំគោលដៅ ជាពិសេសគឺជាកាតាលីករសម្រាប់ការផ្លាស់ប្តូរវិជ្ជមាន តាមរយៈការផ្តល់តឹកតាងសម្រាប់ការពិនិត្យតាមដានលើការរីកចម្រើន ឬតម្រូវការបន្ទាន់ណាមួយរបស់កុមារ។ យើងត្រូវពិចារណា និងចងចាំថានៅពីក្រោយ នៃរាល់ស្ថិតិក្នុងរបាយការណ៍នេះ គឺជាក្តីសុបិន និងសក្តានុពលរបស់កុមារ។ ដូច្នេះយើងត្រូវរួមគ្នាបង្កើតនូវពិភពមួយដែលសិទ្ធិកុមារ ត្រូវបានគោរពនិងគាំទ្រ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងសូមកោតសរសើរដោយស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ អង្គការសង្គមស៊ីវិល ឪពុកម្តាយ អាណាព្យាបាល និងក្មួយៗកុមារទាំងអស់ ដែលបានរួមសហការប្រកបដោយការទទួលខុសត្រូវ និងការប្តេជ្ញាខ្ពស់ ក្នុងការដោះស្រាយបញ្ហាប្រឈមនានា ដើម្បីផ្តល់កិច្ចការពារកុមារពីអំពើហិង្សា ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទគ្រប់ទម្រង់។

ថ្ងៃ ចន្ទ ៥រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ២០២៤

**ជ.ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

**ប្រធាន**

**ជា_សុមេធី**

# I. សេចក្តីផ្តើម

១. ព្រះរាជាណាចក្រកម្ពុជាមានរាជធានី១ ខេត្ត២៤ ក្រុង៣១ ស្រុក១៦៣ ខណ្ឌ១៤ ឃុំ១ ៣៨៥ សង្កាត់ ២៦៧ និងភូមិ១៤ ៥៦៧។[1] យោងតាមរបាយការណ៍ព្យាករណ៍ប្រជាជនឆ្នាំ២០២៣ កម្ពុជាមានប្រជាជនសរុបចំនួនប្រមាណ ១៧ ០៩១ ៤៦៤នាក់ ក្នុងនោះបុរសមានចំនួនប្រមាណ ៨ ៣៥៥ ៤៤៣នាក់ (៤៨.៩០%) ស្ត្រីមានចំនួនប្រមាណ ៨ ៧៣៦ ០២១នាក់ (៥១.១០%)។[2] ប្រជាជន ៣៩% រស់នៅទីប្រជុំជន និង ៦១% រស់នៅជនបទ។[3] យោងតាមរបាយការណ៍ជំរឿនប្រជាជនឆ្នាំ២០១៩ មានកុមារចំនួនប្រមាណ ៦ ០០០ ០០០នាក់ (៣៦% នៃចំនួនប្រជាជនសរុប)។ អត្រាកំណើនប្រជាជននៅកម្ពុជាបានធ្លាប់ចុះ ០,១% គឺពី ១,៥% មក ១,៤% បណ្តាលមកពីការធ្លាក់ចុះអត្រាកំណើត។ អត្រាកំណើនប្រជាជនប្រចាំឆ្នាំបានប្រែប្រួលគួរឱ្យកត់សម្គាល់រវាងទីប្រជុំជន និងជនបទ ៧,៨% ក្នុងទីប្រជុំជន និង ១,២% នៅជនបទ។ ដង់ស៊ីតេប្រជាជនមានចំនួន ៨៧នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ កើនឡើង ១២នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ ពី ៧៥នាក់ ក្នុងឆ្នាំ២០០៨។ អាយុសង្ឃឹមរស់ក្នុងចំណោមប្រជាជនបានកើនឡើងពី ៦២,៤ឆ្នាំ នៅឆ្នាំ២០០៨ ទៅ ៧៥,៥ឆ្នាំ នៅឆ្នាំ២០១៩។ របាយការណ៍ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានឱ្យដឹងថា ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់នៅកម្ពុជាត្រូវបានព្យាករណ៍ថានឹងកើនឡើងដល់ ២ ០៧១ ដុល្លារក្នុងឆ្នាំ២០២៤ ពោលគឺកើនឡើងពី ១ ៩១៧ដុល្លារក្នុងឆ្នាំ២០២៣[4]។

២. ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ រាជរដ្ឋាភិបាលកម្ពុជា បានរក្សានិងពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ ធ្វើឱ្យសេដ្ឋកិច្ចមានកំណើនខ្ពស់គួរឱ្យកត់សម្គាល់។ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល បានចូលរួមចំណែកធ្វើឱ្យរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងធានាបាននូវស្ថេរភាពកំណើនសេដ្ឋកិច្ចរឹងមាំប្រកបដោយចីរភាព។ កម្ពុជាបានឈានដល់ឋានៈជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបកាលពីឆ្នាំ២០១៥ ដោយផ្អែកលើកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស និងការវិនិយោគគួរឱ្យកត់សម្គាល់ទៅលើការអភិវឌ្ឍសង្គម ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៩០ និងមានមហិច្ឆតាក្នុងការសម្រេចបានឋានៈ ជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ កម្ពុជាបានក្លាយទៅជាប្រទេសមួយ នៃប្រទេសដែលមានកំណើនសេដ្ឋកិច្ចលឿនបំផុតនៅក្នុងពិភពលោក ដោយមានអត្រាកំណើនសេដ្ឋកិច្ចជាមធ្យមមានចំនួន ៨% នៅរវាងឆ្នាំ១៩៩៨ និងឆ្នាំ២០១៨ ដែលនៅតែមានភាពខ្លាំងផងដែរនៅឆ្នាំ២០១៩ (៧,១%)។[5] នៅឆ្នាំ២០២៣ យោងតាមរបាយការណ៍របស់ធនាគារពិភពលោកបង្ហាញថា សេដ្ឋកិច្ចកម្ពុជាមានកំណើនប្រមាណ៥,៤% ដែលជាកំណើនមួយខ្ពស់បើធៀបកំណើនមធ្យមក្នុងតំបន់ និងត្រូវបានព្យាករថា នឹងមានកំណើនប្រមាណ ៦,១%[6] ក្នុងឆ្នាំ២០២៤ ដែលនិន្នាការនេះបង្ហាញថា កម្ពុជាបាននិងកំពុងបោះជំហានទៅរកស្ថានភាពល្អប្រសើរ។

---

[1] របាយការណ៍លទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤របស់ក្រសួងមហាផ្ទៃ

[2] Ministry of Planning, National Institute of Statistics, Population Projection 2020-2033, July 2023

[3] របាយការណ៍អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០២១

[4] របាយការណ៍៖ ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់នៅកម្ពុជានឹងកើមឡើងដល់ ២,០៧១ ដុល្លារនៅឆ្នាំក្រោយ - Khmer Times (khmertimeskh.com) ចុះផ្សាយថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣

[5] The World Bank, Cambodia Economic Updated: Recent Economic Developments and Outlook, May 2019

[6] International Monetary Fund (IMF)October 2023 Outlook and January 2024 update

៣. ដើម្បីធានានូវឧត្តមប្រយោជន៍របស់កុមារ កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅឆ្នាំ ១៩៩២ ពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារនៅឆ្នាំ២០០២ និងស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធនៅឆ្នាំ២០០៤ អនុសញ្ញាអន្តរជាតិខាងការងារលេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅឆ្នាំ២០០៥ អនុសញ្ញាអន្តរជាតិខាងការងារលេខ១៣៨ ស្តីពីការកំណត់អាយុអប្បបរមាសម្រាប់ការចូលធ្វើការងារនៅឆ្នាំ១៩៩៩ អនុសញ្ញាអន្តរជាតិខាងការងារលេខ២៩ ស្តីពីការងារដោយបង្ខំឬជាកាតព្វកិច្ចនៅឆ្នាំ១៩៦៩ អនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសឆ្នាំ២០០៧ ពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែន ដែលមានអង្គការចាត់តាំងស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារឆ្នាំ២០០៦ និងអនុសញ្ញាស្តីពីសិទ្ធិជនពិការឆ្នាំ២០១២។ល។

៤. ទន្ទឹមនឹងនេះដែរ រាជរដ្ឋាភិបាលបានបន្តយកចិត្តទុកដាក់ និងលើកកម្ពស់ការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ច្បាប់ជាតិ និងច្បាប់អន្តរជាតិពាក់ព័ន្ធ ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ និងការប្តេជ្ញាចិត្តក្នុងការគោរព ការពារ បំពេញសិទ្ធិនានាចំពោះប្រជាពលរដ្ឋ ជាពិសេសចំពោះកុមារ ដើម្បីរស់នៅក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ សមភាព និងសុវត្ថិភាព ស្របតាមរដ្ឋធម្មនុញ្ញ និងគោលការណ៍នីតិរដ្ឋ ដោយបានដាក់ចេញនូវវិធានការជាច្រើន រួមមាន៖ ការអនុម័តច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋាន យន្តការ កិច្ចសហការថ្នាក់ជាតិនិងអន្តរជាតិ ដើម្បីធានាឲ្យបាននូវសុខុមាលភាព និងការគាំពារសង្គមចំពោះកុមារកម្ពុជា។ ជាមួយគ្នានេះដែរ ក្រសួង ស្ថាប័ន អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការ ដៃគូអភិវឌ្ឍ អង្គការជាតិនិងអន្តរជាតិ ប្រជាជន សហគមន៍ ព្រះសង្ឃ ព្រឹទ្ធាចារ្យ មាតាបិតា និងកុមារខ្លួនឯងផ្ទាល់ បានចូលរួមចំណែកក្នុងការអនុវត្តសិទ្ធិកុមារនៅកម្ពុជា សម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើន។

# II. សមិទ្ធផលសំខាន់ៗពាក់ព័ន្ធការអនុវត្តសិទ្ធិកុមារ

## ១. ក្របខ័ណ្ឌច្បាប់និងគោលនយោបាយ

### ១.១. ក្របខ័ណ្ឌច្បាប់

៥. ចាប់ពីឆ្នាំ២០២០ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បាននិងកំពុងបន្តរៀបចំសេចក្តីព្រាងច្បាប់ **ស្តីពីកិច្ចការពារកុមារ នៃព្រះរាជាណាចក្រកម្ពុជា**។ សេចក្តីព្រាងច្បាប់នេះ មានគោលបំណងដើម្បីការពារ លើកកម្ពស់សុខុមាលភាពកុមារ ផ្តល់អំណាចក្នុងការចូលរួម រក្សាឧត្តមប្រយោជន៍របស់កុមារ និងពង្រឹងការអនុវត្តសិទ្ធិកុមារនៅកម្ពុជា។

៦. ទន្ទឹមនឹងការរីករចម្រើនខ្លាំង នៃបច្ចេកវិទ្យាឌីជីថល ការព្រួយបារម្ភចំពោះបទល្មើស និងឧក្រិដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់ផងដែរពីរាជរដ្ឋាភិបាល។ បច្ចុប្បន្ននេះ ក្រសួងមហាផ្ទៃបាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ **ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន** ក្នុងគោលបំណងធានាសុចរិតភាព នៃការប្រើប្រាស់ ការគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ ទិន្នន័យកុំព្យូទ័រ និងការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងការការពារសិទ្ធិ សេរីភាពបុគ្គល ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសបច្ចេកវិទ្យាព័ត៌មាន។

៧. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ **ស្តីពីសន្តិសុខសាយប័រ**។ សេចក្តីព្រាងច្បាប់នេះ ត្រូវបានរៀបចំឡើងស្របតាមការកំណត់ក្នុងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល និងគោលនយោបាយរដ្ឋាភិបាលឌីជីថល។ សេចក្តីព្រាងច្បាប់នេះ មានគោលបំណងកំណត់នូវគោលការណ៍ វិធាននិងយន្តការគ្រប់គ្រង និងថែរក្សាសន្តិសុខសាយប័រ នៃហេដ្ឋារចនាសម្ព័ន្ធព័ត៌មានសំខាន់ៗ ស្របតាមនិន្នាការតំបន់ និងសកលលោក។

៨. ក្រសួងព័ត៌មាន បាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ **ស្តីពីសិទ្ធិទទួលព័ត៌មាន** ក្នុងគោលបំណងធានាដល់សាធារណជនគ្រប់រូបនូវសិទ្ធិ សេរីភាពក្នុងការទទួលបានព័ត៌មានពីស្ថាប័នសាធារណៈ ស្របតាមស្មារតីនៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

៩. ក្រសួងយុត្តិធម៌ បាននិងកំពុងបន្តពិនិត្យសេចក្តីព្រាងច្បាប់ **ស្តីពីការប្រឆាំងអំពើរត់ពន្ធមនុស្ស** និងសេចក្តីព្រាងច្បាប់ **ស្តីពីអំពើពពោះជំនួស**។

១០. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាននិងកំពុងសិក្សារៀបចំ (១) សេចក្តីព្រាងច្បាប់ស្តីពីទេសន្តរប្រវេសន៍ការងារ ក្នុងគោលបំណងលើកកម្ពស់សិទ្ធិនិងអត្ថប្រយោជន៍របស់ពលករទេសន្តរប្រវេសន៍ និងចូលរួមទប់ស្កាត់ការជួញដូរមនុស្សខុសច្បាប់ (២) សេចក្តីព្រាងច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដើម្បីពង្រឹងយន្តការក្នុងការគ្រប់គ្រង ការដឹកនាំ និងសម្របសម្រួលកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជាប្រកបដោយគុណភាព ប្រសិទ្ធភាព និងប្រសិទ្ធផល និង (៣) សេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពនិងសុខភាពការងារ ក្នុងគោលបំណងធានាលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ របស់បុគ្គលដែលបំពេញការងារ តាមរយៈការបង្កើតប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពការងារ សំដៅបង្កើតឱ្យមានបរិយាកាសការងារល្អ លើកកម្ពស់ផលិតភាពការងារ និងចូលរួមជំរុញកំណើនសេដ្ឋកិច្ចជាតិ។

## ១.២. ក្របខ័ណ្ឌគោលនយោបាយ

១១. ចក្ខុវិស័យសម្រាប់អនាគតរបស់កម្ពុជា គឺធានាឱ្យកុមារគ្រប់រូបទទួលបាននូវសិទ្ធិស្មើៗគ្នា ដូចមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ រួមមានៈ សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបាននូវការការពារ សិទ្ធិក្នុងការអភិវឌ្ឍ និងសិទ្ធិចូលរួម។ នៅខែឧសភា ឆ្នាំ២០២០ រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តគោលនយោបាយជាតិ **ស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩**។ គោលនយោបាយជាតិនេះ បានកំណត់នូវសសរស្តម្ភជាយុទ្ធសាស្ត្រចំនួន៣ ដោយផ្តោតលើការបង្ការទប់ស្កាត់ ការអន្តរាគមន៍ និងការផ្តល់សេវាឆ្លើយតប។ ដើម្បីឆ្លើយតបចំពោះការអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឱ្យទទួលបានជោគជ័យ ក.ជ.ក. បានរៀបចំផែនការអនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ ដោយបានកំណត់នូវសកម្មភាពជាក់លាក់សម្រាប់ក្រសួងស្ថាប័ន ដែលត្រូវបំពេញការងារក្នុងការលើកកម្ពស់សិទ្ធិកុមារ។ ផែនការនេះត្រូវបានចុះហត្ថលេខាដាក់ឱ្យប្រើប្រាស់ កាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១។

១២. ក្នុងគោលបំណងរៀបចំប្រព័ន្ធកិច្ចការពារកុមារមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីបង្ការ ទប់ស្កាត់ អន្តរាគមន៍ និងការផ្តល់សេវាឆ្លើយតបនៅគ្រប់កម្រិតប្រកបដោយប្រសិទ្ធភាពក្នុងការការពារកុមារគ្រប់ទម្រង់ នៃការរំលោភបំពាន និងការអនុវត្តប្រកបដោយគ្រោះថ្នាក់ នៅខែវិច្ឆិកា ឆ្នាំ២០២២ ក្រសួងមហាផ្ទៃ និងក្រសួង ស.អ.យ. បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ ឆ្នាំ២០២២-២០២៦។

១៣. ក្រសួង ស.អ.យ. បានបញ្ចប់ការពិនិត្យ និងកែសម្រួលឡើងវិញគោលនយោបាយ**ស្តីពីការថែទាំជំនួសចំពោះកុមារ ឆ្នាំ២០០៦** ឱ្យស្របនឹងស្ថានភាពសេដ្ឋកិច្ច-សង្គម ច្បាប់ និងគោលនយោបាយរបស់កម្ពុជានាពេលបច្ចុប្បន្ន និងស្របតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ ស្តីពីការថែទាំជំនួសចំពោះកុមារ។

១៤. ក្រសួង ស.អ.យ. បានដាក់ឱ្យអនុវត្ត និងផ្សព្វផ្សាយផែនការសកម្មភាពស្តីពីការធ្វើឱ្យប្រសើរឡើងនូវការថែទាំជំនួសចំពោះកុមារ ឆ្នាំ២០២៣-២០២៧ ព្រមទាំងបានដាក់ឱ្យអនុវត្តប្រកាសលេខ២៣៣ ស.អ.យ. ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីក្រមសីលធម៌សម្រាប់កិច្ចការពារកុមារ និងបានបញ្ចប់ការពិនិត្យ និងកែសម្រួលសេចក្តីព្រាងបទដ្ឋានស្តីពីអង្គការសុវត្ថិភាពកុមារ និងសៀវភៅបណ្តុះបណ្តាល ព្រមទាំងសេចក្តីព្រាងប្រកាសស្តីពីការបង្កើតគណៈកម្មការដឹកនាំ និងគ្រប់គ្រងគុណវុឌ្ឍនៃអង្គការសុវត្ថិភាព។

១៥. ដោយអនុវត្តតាមផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (២០២១-២០២៥) នៅក្នុងឆ្នាំ ២០២៣ ក.ជ.ក. បានរៀបចំគោលការណ៍ណែនាំជាតិស្តីពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ ទន្ទឹមនេះ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ក៏បានដាក់ចេញនូវគោលការណ៍ណែនាំស្តីពីកិច្ចការពារកុមារនៅកម្ពុជាតាមប្រព័ន្ធអនឡាញសម្រាប់ក្រុមហ៊ុនឧស្សាហកម្មបច្ចេកវិទ្យាឌីជីថលផងដែរ។

១៦. នៅឆ្នាំ២០២១ ក្រសួង ស.អ.យ. បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រ ដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គម ឆ្នាំ២០២១-២០២៥ ដោយផ្តោតលើការពង្រឹងសមត្ថភាពកម្លាំងសេវាសង្គមឱ្យមានកម្រិតចំណេះដឹង និងកម្រិតជំនាញពិតប្រាកដ ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ ដើម្បីផ្តល់សេវាសង្គមកិច្ចជូនអតិថិ

ជន ដែលជាជនរងគ្រោះ និងងាយរងគ្រោះធានាបានប្រសិទ្ធភាពខ្ពស់។ ផែនការយុទ្ធសាស្ត្រនេះ មានគោលដៅយុទ្ធសាស្ត្រចំនួន ៣ គឺ៖ (១). អភិវឌ្ឍន៍កម្មវិធីសិក្សា និងកញ្ចប់មេរៀនបណ្តុះបណ្តាលកម្លាំងសេវាសង្គម (២). បណ្តុះបណ្តាលកម្លាំងសេវាសង្គម និងបង្កើនប្រសិទ្ធភាព (៣). ពង្រឹងសមត្ថភាពគ្រឹះស្ថានអប់រំបណ្តុះបណ្តាលកម្លាំងសេវាសង្គម។ កម្លាំងសេវាសង្គមរួមមាន៖ អ្នកអាជីពសង្គមកិច្ច (បុគ្គលិកសង្គមអាជីព) អ្នកអាជីពសង្គមកិច្ចរង (បុគ្គលិកសង្គមប៉ារ៉ាអាជីព) អ្នកអាជីពសង្គមកិច្ចមិនអាជីព (បុគ្គលិកសង្គមប៉ារ៉ាវិជ្ជាជីវៈ) និងអ្នកសង្គមកិច្ចសម្ពន្ធ (បុគ្គលិកសម្ពន្ធសង្គមកិច្ច)។

១៧. ក្រសួង ស.អ.យ. បាននិងកំពុងរៀបចំសេចក្តីព្រាងសៀវភៅណែនាំស្តីពីការអនុវត្តស៊ុំកូនក្នុងប្រទេស ក្នុងគោលបំណងណែនាំដល់ភ្នាក់ងារសង្គមកិច្ច មន្ត្រីសង្គមកិច្ច បុគ្គលិកសង្គម អាជ្ញាធរ មានសមត្ថកិច្ច និងភាគីពាក់ព័ន្ធ អំពីគោលការណ៍ លក្ខណៈវិនិច្ឆ័យកុមារជាកម្មវត្ថុស៊ុំកូន ដើម្បីធានាថាការអនុវត្តស៊ុំកូនក្នុងស្រុកត្រូវអនុវត្តតាមគោលការណ៍នៃការធ្វើផែនការអចិន្ត្រៃយ៍ ដូចមានចែងក្នុងជំពូកទី៧ នៃប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ គោលការណ៍ណែនាំសម្រាប់ការថែទាំជំនួសចំពោះកុមាររបស់អង្គការសហប្រជាជាតិ និងក្រមរដ្ឋប្បវេណី តាមរយៈស៊ុំកូនក្នុងប្រទេស។

១៨. នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០២៤ ក្រសួងមហាផ្ទៃសហការជាមួយក្រសួង ស.អ.យ. បានដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំ ស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារកុមារសម្រាប់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ។ ការរៀបចំសៀវភៅណែនាំនេះមានគោលបំណងដើម្បី (១.) ផ្តល់កិច្ចការពារកុមារនៅក្នុងប្រទេសកម្ពុជា (២.) ពង្រឹងយន្តការកិច្ចការពារកុមារ ដោយកំណត់ជំហានដែលអង្គភាពផ្សេងៗបង្កើតជាប្រព័ន្ធដើម្បីការពារកុមារពីគ្រប់ទម្រង់នៃអំពើហិង្សា ការរំលោភបំពាន ការមិនអើពើ ឬការកេងប្រវ័ញ្ច។

១៩. ប្រព័ន្ធគាំពារសង្គមត្រូវបានកសាងឡើង ដើម្បីកាត់បន្ថយនិងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះនិងវិសមភាព ព្រមទាំងរួមចំណែកដល់ការអភិវឌ្ឍ និងគាំពារធនធានមនុស្សឱ្យកាន់តែរឹងមាំ និងទូលំទូលាយ និងជំរុញកំណើនសេដ្ឋកិច្ចជាតិ។ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ មានគោលដៅចម្បង គឺធ្វើការបន្ស៊ី ប្រមូលផ្តុំ និងពង្រឹងកម្មវិធីដែលមានស្រាប់ ដើម្បីបង្កើនប្រសិទ្ធភាព តម្លាភាព និងសង្គតិភាព នៃរបបឬកម្មវិធីទាំងឡាយ ក្នុងប្រព័ន្ធគាំពារសង្គមទាំងមូល រួមទាំងការពង្រីកវិសាលភាព ដែលនៅតូចចង្អៀតនៅឡើយ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនគ្រប់ស្រទាប់ស្របតាមការរីកចម្រើនសេដ្ឋកិច្ចជាតិ និងធានាបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រង និងបង្កើនប្រសិទ្ធភាពចំណាយថវិកា។ ក្របខ័ណ្ឌគោលនយោបាយនេះ មានវិសាលភាពគ្របដណ្តប់លើប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម ដែលប្រព័ន្ធទាំងពីរនេះ មានលក្ខណៈបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក។

២០. នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៣ រាជរដ្ឋាភិបាលបានប្រកាសជាផ្លូវការដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំស្តីពីក្របខ័ណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ និងគោលការណ៍ណែនាំស្តីពីក្របខ័ណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន។ កម្មវិធីជំនួយសង្គមក្នុងកញ្ចប់គ្រួសារ គឺជាបណ្តុំកម្មវិធីជាតិជំនួយសង្គមចំនួន ៥ រួមមាន៖ (១.) កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ០២ឆ្នាំ (២.) កម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្រនៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ (៣.) កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព (៤.) កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរា (អាយុ ៦០ឡើង) និង (៥.) ការឧបត្ថម្ភសម្រាប់គ្រួសារដែលមានបណ្ណសមធម៌ទាំងអស់ និងគិតគូរដល់សមាជិក

គ្រួសារដែលរស់នៅជាមួយមេរោគអេដស៍/ជំងឺអេដស៍។ ចំពោះកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ នឹងត្រូវចាប់ផ្តើមចាប់ពីខែមេសា ឆ្នាំ២០២៤ តទៅ។

២១. នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ រាជរដ្ឋាភិបាលបានប្រកាសជាផ្លូវការដាក់ឱ្យអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ។ កម្មវិធីនេះ មានគោលបំណងផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់យុវជនគោលដៅមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស ដែលមានចំនួនប្រមាណ ១,៥ លាននាក់ នៅតាមបណ្តាគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនានារបស់រដ្ឋ ក្នុងកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ (C1) ដើម្បីឱ្យយុវជនគោលដៅទាំងនោះ ទទួលបានចំណេះដឹង ជំនាញ ឥរិយាបថការងារ សីលធម៌វិជ្ជាជីវៈ និងផលិតភាព លើមុខជំនាញអាទិភាពដែលមានសក្តានុពល និងតម្រូវការខ្ពស់ក្នុងទីផ្សារការងារ សម្រាប់ផ្តល់លទ្ធភាពដល់ពួកគាត់ឱ្យទទួលបានការងារធ្វើ និង/ឬបង្កើតមុខរបរដោយខ្លួនឯង ប្រកបដោយភាពម្ចាស់ការក្នុងការបង្កើនប្រាក់ចំណូល និងលើកកម្ពស់កម្រិតជីវភាពរស់នៅកាន់តែល្អប្រសើរ។

២២. នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ រាជរដ្ឋាភិបាលបានប្រកាសជាផ្លូវការដាក់ឱ្យអនុវត្តកម្មវិធីរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត ក្នុងគោលបំណងពង្រីកសេវាថែទាំសុខភាពឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល ដែលក្នុងនោះបុគ្គលស្វ័យនិយោជន៍ និងអ្នកនៅក្នុងបន្ទុកសមាជិក ប.ស.ស. (សហព័ទ្ធ និងកូន) អាចទទួលបានសេវាថែទាំសុខភាព ដោយបង់ភាគទានត្រឹមតែ ១៥ ៦០០រៀល ក្នុង១ខែ តែប៉ុណ្ណោះ។ ប្រជាជនគ្របដណ្តប់ដោយប័ណ្ណមូលនិធិសមធម៌សុខាភិបាល និងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព (ប.ស.ស.) មានចំនួន ១ ៩៦៥ ៧៤២នាក់ នៅឆ្នាំ ២០២២ និងកើនឡើងដល់ ២ ១២៥ ២៨៩នាក់ នៅឆ្នាំ២០២៣ ស្មើនឹង ៨.១២%។

២៣. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្តួចផ្តើមរៀបចំសេចក្តីព្រាងប្រកាសស្តីពី ការហាមឃាត់ការប្រើប្រាស់កម្មករនិយោជិតវ័យក្មេងនៅតាមសហគ្រាស គ្រឹះស្ថាននាំចេញផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប និងធ្វើបច្ចុប្បន្នភាពប្រកាសស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការជ្រើសរើសកម្មករនិយោជិតវ័យក្មេងនៅតាមសហគ្រាស គ្រឹះស្ថាន ដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងលើកកម្ពស់លក្ខខណ្ឌការងារ និងលក្ខខណ្ឌសុវត្ថិភាពនិងសុខភាពការងារសម្រាប់កម្មករនិយោជិតវ័យក្មេង។

## ២. ការរស់រានមានជីវិត[7]

### ២.១. សុខភាព និងសុខុមាលភាពមូលដ្ឋាន[8]

#### ក. ធនធានមនុស្សសុខាភិបាល

២៤. ធនធានមនុស្សសុខាភិបាលសាធារណៈមានសរុបចំនួន ៣១ ៤៥២នាក់ ដោយត្រូវបានបែងចែកទៅតាមប្រភេទបុគ្គលិកសុខាភិបាលសាធារណៈ រួមមាន៖ វេជ្ជបណ្ឌិត/ឯកទេសសរុបចំនួន ៤ ៥៩១នាក់ គ្រូពេទ្យមធ្យមចំនួន ៤២៤នាក់ ឱសថការីបណ្ឌិត/ឱសថការីឧត្តម/មធ្យម/បឋមសរុបចំនួន ៩៣៨នាក់ ទន្តបណ្ឌិត/ទន្តពេទ្យ/ទន្តគិលានុបដ្ឋាកសរុបចំនួន ៦១២នាក់ បរិញ្ញាបត្រឆ្មបចំនួន ៦៣២នាក់ ឆ្មបមធ្យមចំនួន ៥ ៨២០នាក់ ឆ្មបបឋមចំនួន ២ ១៦៦នាក់ បរិញ្ញាបត្រគិលានុបដ្ឋាកចំនួន ៦៨៥នាក់ គិលានុបដ្ឋាកមធ្យមចំនួន ៩ ៨១២នាក់ គិលានុបដ្ឋាកបឋមចំនួន ២ ៥៦៩នាក់ បរិញ្ញាបត្រ/បរិញ្ញាបត្ររងបច្ចេកទេសមន្ទីរពិសោធន៍សរុបចំនួន ១ ២៥៩នាក់ អ្នកបច្ចេកទេសព្យាបាលដោយចលនាចំនួន ២៤៤នាក់ វិទ្យុសាស្ត្រចំនួន ១៤៥នាក់ និងជំនាញក្រៅសុខាភិបាលចំនួន ១ ៥៥៥នាក់។

#### ខ. ស្ថិតិមូលដ្ឋានសុខាភិបាលសាធារណៈ

២៥. នៅឆ្នាំ២០២៣ មូលដ្ឋានសុខាភិបាលសាធារណៈសរុបនៅទូទាំងប្រទេសមានចំនួន ១ ៥៧០កន្លែង ក្នុងនោះ ប៉ុស្តិ៍សុខភាពចំនួន ១៣២កន្លែង មណ្ឌលសុខភាពមានចំនួន ១ ៣០៥កន្លែង និងមន្ទីរពេទ្យចំនួន ១៣៣កន្លែង។

#### គ. មូលដ្ឋានសុខាភិបាលឯកជន

២៦. សេវាសុខាភិបាលឯកជនបានរួមចំណែកគួរឱ្យកត់សម្គាល់ ក្នុងការផ្តល់សេវាសុខភាពជូនប្រជាជន នៅទូទាំងប្រទេស។ អាជីវកម្មផ្នែកវេជ្ជសាស្ត្រ ឬការប្រកបមុខរបរពេទ្យ ក្នុងវិស័យឯកជនស្វែងរកកម្រៃ និងឱសថស្ថាន/ឱសថស្ថានរង បានរីកដុះដាលយ៉ាងលឿននៅក្នុងទីផ្សារសុខភាពនៃប្រទេសកម្ពុជា។ នៅក្នុងឆ្នាំ២០២៣ មូលដ្ឋានសុខាភិបាលឯកជនគ្រប់ប្រភេទមានចំនួនសរុប ១៧ ៩៨៨កន្លែង។

#### ឃ. ដំណើរឆ្ពោះទៅរកការគ្រប់ដណ្តប់សុខភាពជាសាកល

២៧. ការអនុវត្តអភិក្រមអាទិភាពរូបនីយកម្មប្រជាជនគោលដៅ ឆ្ពោះទៅកាន់ការគាំពារសុខភាពសង្គមជាសកល ដោយផ្តោតលើការពង្រីកការគ្របដណ្តប់ប្រព័ន្ធគាំពារសុខភាពសង្គមដល់បុគ្គលគ្រប់រូប ការពង្រឹងការអនុវត្តយន្តការគាំពារសុខភាពសង្គម ការធ្វើស្ថាបនូបនីយកម្មវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅក្នុងប្រព័ន្ធគាំពារសង្គម និងការកសាងហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុមានចីរភាពសម្រាប់ការគ្របដណ្តប់សុខភាពជាសកល។

២៨. ប្រជាជនគ្រប់ដណ្តប់ដោយមូលនិធិសមធម៌សុខាភិបាល និងបេឡាជាតិសន្តិសុខសង្គមផ្នែកថែទាំសុខភាព (ប.ស.ស.) បានកើនឡើងពី ៦ ២១៩ ៨៦២នាក់ នៅឆ្នាំ២០២២ ដល់ ៨ ៤៤៧ ៥៣៣នាក់នៅ

---

[7] កុមារត្រូវមានជីវិតរស់នៅ មានសុវត្ថិភាព និងមានអ្វីៗចាំបាច់សម្រាប់រស់នៅ ដូចជាចំណីអាហារមានជីវជាតិ មានឈ្មោះ មានសញ្ជាតិ ការព្យាបាលសុខភាព សម្លៀកបំពាក់ ជម្រកស្នាក់នៅ និងជីវភាពសមរម្យ ព្រមទាំងទទួលបានការថ្នាក់ថ្នមពីឪពុកម្តាយ អាណាព្យាបាល និងសង្គម

[8] របាយការណ៍សមិទ្ធផលសុខាភិបាលឆ្នាំ២០២៣ ទិសដៅការងារឆ្នាំ២០២៤ និងឆ្នាំបន្ត របស់ក្រសួងសុខាភិបាល

ឆ្នាំ២០២៣ ឬកើនឡើងពី ៣៦,៩៣% ទៅ ៤៩,៤៣% នៃប្រជាជនកម្ពុជាសរុប។ មូលនិធិសមធម៌ គឺជាក្រុមគោលដៅ នៃកម្មវិធីមូលនិធិសមធម៌សុខាភិបាល ក្នុងនោះរួមមាន៖ (១.) គ្រួសារក្រីក្រដែលបានចុះបញ្ជី និងមានបណ្ណសមធម៌ផ្តល់ដោយក្រសួងផែនការ និងប្រជាជនដែលកំណត់អត្តសញ្ញាណក្រីក្រនៅមូលដ្ឋានសុខាភិបាល។ (២.) គ្រួសារងាយរងហានិភ័យ ដែលប្រកាសដាក់ឱ្យអនុវត្តដោយសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣។ (៣.) ក្រុមគោលដៅផ្សេងទៀត ដូចជា មេភូមិ អនុភូមិ ជំនួយការភូមិ ក្រុមប្រឹក្សាឃុំ សង្កាត់ កីឡាករ កីឡាការនី បុគ្គលិកអ្នកជំនាញដោះមីន កម្មការធាក់ស៊ីក្លូ អ្នករស់នៅជាមួយមេរោគអេដស៍ និងបុគ្គលិកបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ប.ស.ស. ផ្តោតលើក្រុមគោលដៅដែលជាសមាជិករបស់ ប.ស.ស. រួមមាន៖ កម្មករ និយោជិតក្នុងវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ មន្ត្រីរាជការសាធារណៈ អតីតមន្ត្រីរាជការសាធារណៈ អតីតមន្ត្រីរាជការស៊ីវិល អតីតយុទ្ធជន បុគ្គលស្វ័យនិយោជន៍ និងអ្នកនៅក្នុងបន្ទុកសមាជិក ប.ស.ស.។

២៩. សន្ទស្សន៍គ្រប់ដណ្តប់សេវាសុខភាព នៃការគ្រប់ដណ្តប់សុខភាពជាសកលនៅកម្ពុជាបានកើនឡើងពី ៦០ នៅឆ្នាំ២០១៨ ដល់ ៦៦,៩ នៅឆ្នាំ២០២២ ប៉ុន្តែបានធ្លាក់ចុះបន្តិចរវាងឆ្នាំ២០២០-២០២១ (ពី ៦៤,៤-៦៤) ដោយសារផលវិបាកនៃជំងឺកូវីដ-១៩។ និន្នាការនេះបញ្ជាក់ពីវឌ្ឍនភាពជាវិជ្ជមានក្នុងដំណើរឆ្ពោះទៅកាន់ការគ្រប់ដណ្តប់សុខភាពជាសកលនៅកម្ពុជា។

៣០. ការប្រើប្រាស់សេវាសុខភាពក្រោមប្រព័ន្ធគាំពារសុខភាពសង្គមរវាងឆ្នាំ២០២២ និងឆ្នាំ២០២៣ បានកើនឡើង ៤៩,៨៨%។ ករណីប្រើប្រាស់សេវាក្រោមកម្មវិធីមូលនិធិសមធម៌កើនឡើង ៨,៤៦% ឬពី ៣ ០៨៦ ១៤៨ករណី ដល់ ៣ ៣៤៧ ៣៤៤ករណី និងក្រោមគម្រោង ប.ស.ស. ផ្នែកថែទាំសុខភាពបានកើនឡើង ៩៩,៧១% ឬពី ២ ៥៣០ ៩៨៣ករណី ទៅ ៥ ០៥៤ ៦៣៩ករណី។

៣១. ការចំណាយដោយមូលនិធិសមធម៌ក្នុងឆ្នាំ២០២៣ បានកើនឡើង ១១,៣៩% ធៀបនឹងការចំណាយក្នុងឆ្នាំ២០២២ និងការចំណាយដោយ ប.ស.ស. បានកើនឡើង ១២៧,២៩% ធៀបនឹងឆ្នាំ២០២២។ ជារួម កំណើននៃការចំណាយខាងលើនេះ គឺមានសង្គតិភាពជាមួយការកើនឡើងនៃការប្រើប្រាស់សេវាសុខាភិបាល និងការពង្រីកវិសាលភាពគ្របដណ្តប់ នៃប្រជាជនគោលដៅក្នុងកម្មវិធី/គម្រោងទាំងពីរ។

៣២. បន្ទុកហានិភ័យនៃការចំណាយលើសុខភាពបានបង្ហាញថា អាំងស៊ីដង់នៃចំណាយលើសពី ១០% នៃចំណូល ឬចំណាយសរុបរបស់គ្រួសារបានធ្លាក់ចុះពី ១៧,៨៥% នៅឆ្នាំ២០១៩ មកនៅ១២,៨៦% ឆ្នាំ ២០២១ និងអាំងស៊ីដង់នៃប្រជាពលរដ្ឋដែលធ្លាក់ខ្លួនក្រីក្រដោយសារការចំណាយលើសុខភាពក៏បានធ្លាក់ចុះពី ៣,៩៣% នៅឆ្នាំ២០១៩ ទៅ ៣,៥៤% នៅអំឡុងពេលដូចគ្នានេះ។ ទោះជាដូច្នេះក្តី ទិន្នន័យនេះហាក់នៅខ្ពស់បើធៀបនឹងប្រទេសក្នុងតំបន់ ហើយក៏សបញ្ជាក់ផងដែរថា ជារៀងរាល់ឆ្នាំប្រជាពលរដ្ឋកម្ពុជាជាច្រើននាក់ នៅតែប្រឈមនឹងហានិភ័យផ្នែកហិរញ្ញវត្ថុ និងការធ្លាក់ទៅក្នុងភាពក្រីក្រ ដោយសារការចំណាយពីហោប៉ៅផ្ទាល់លើសេវាថែទាំសុខភាព។

### ង. ភាពប្រសើរឡើងនៃស្ថានភាពសុខភាព

៣៣. កម្ពុជាសម្រេចបានសមិទ្ធផលធំធេងក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងសុខភាព នៅក្នុងបណ្ដាទសវត្សរ៍ចុងក្រោយនេះ។ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការគ្រប់គ្រងសារពើពន្ធប្រកបដោយការប្រុងប្រយ័ត្ន បានដើរតួចម្បងក្នុងការរក្សាកំណើនសេដ្ឋកិច្ចរឹងមាំ និងមានសង្គតិភាព ការធ្លាក់ចុះយ៉ាងលឿន នៃភាពក្រីក្រ ភាពរឹងមាំនៃប្រព័ន្ធសុខាភិបាល ការពង្រីកប្រព័ន្ធគាំពារសង្គម ភាពប្រសើរឡើងនៃកត្តាសង្គមដែលមានបច្ច័យលើសុខភាព។ល។ វឌ្ឍនភាពទាំងអស់នេះបានធ្វើឱ្យអត្រារស់រានមានជីវិតរបស់កុមារកើនឡើង។




ប្រភព៖ ជំរឿនទូទៅប្រជាជនកម្ពុជាឆ្នាំ២០០៨ និង២០១៩

### ច. សុខភាពបន្តពូជ

៣៤. ផែនការគ្រួសារ និងការពន្យារកំណើត៖ រវាងឆ្នាំ២០១៩-២០២៣ និន្នាការនៃអត្រាប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើបណាមួយ បានធ្លាក់ចុះជាលំដាប់។ ដោយឡែករវាងឆ្នាំ២០២២ និងឆ្នាំ២០២៣ អត្រានេះបានធ្លាក់ចុះ ៤,៤២ភាគពិន្ទុ។ ចំនួនស្ត្រីក្នុងវ័យបន្តពូជអាយុពី ១៥-៤៩ឆ្នាំ ដែលបានរៀបការហើយកំពុងប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើបណាមួយ បានធ្លាក់ចុះពី ៥៨៩ ៤៨៥នាក់ នៅឆ្នាំ២០២២ មកនៅ ៥៧៥ ៨៩៣នាក់ (ប្រើប្រាស់នៅសេវាសាធារណៈចំនួន ៥៦៦ ៦២៧នាក់ និងនៅសេវាឯកជនដែលបានរាយការណ៍ចំនួន ៩ ២៦៦នាក់) នៅឆ្នាំ២០២៣។ អត្រានេះប្រែប្រួលពីខេត្តដែលមានអត្រាទាបជាងគេ ១,២៣% ទៅខេត្តដែលអត្រាខ្ពស់ជាងគេ ២៦,៤៧%។ មធ្យោបាយពន្យារកំណើតទំនើបដែលស្ត្រីកំពុងប្រើប្រាស់នៅមូលដ្ឋានសុខាភិបាលសាធារណៈភាគច្រើនគឺ ថ្នាំគ្រាប់ ៥១% ថ្នាំចាក់ ២៩,៨% បន្ទាប់មកដាក់កងក្រោមស្បែក ៨,៨២% កងដាក់ក្នុងស្បូន ៧,៤៤% និងស្រោមអនាម័យត្រឹមតែ ២,៩% ប៉ុណ្ណោះ។ យោងតាមការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០២១/២០២២ បានបង្ហាញថា ៤៩,៩% នៃស្ត្រីក្នុងវ័យបន្តពូជអាយុពី ១៥-៤៩ឆ្នាំ ដែលបានរៀបការហើយកំពុងប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើបណាមួយ ប្រើប្រាស់សេវាសុខាភិបាលឯកជន ក្នុងនោះ ១៩% នៅគ្លីនិកឯកជន និង ១៤,២% នៅឱសថស្ថានដែលជាប្រភពចម្បងនៃការផ្ដល់មធ្យោបាយពន្យារកំណើតទំនើប

(ជាពិសេសថ្នាំគ្រាប់)។ នៅឆ្នាំ២០២៣ មានមូលដ្ឋានសុខាភិបាលសាធារណៈ ៩៥កន្លែង បានផ្តល់សេវាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទសម្រាប់យុវវ័យ តាមពិធីសារដែលបានធ្វើបច្ចុប្បន្នភាពរបស់ក្រសួងសុខាភិបាល។

៣៥. ការរំលូត/រលូត រវាងឆ្នាំ២០២០និងឆ្នាំ២០២២ ករណីរំលូតនិងរលូតមាននិន្នាការធ្លាក់ចុះ ប៉ុន្តែបានងើបឡើងវិញនៅក្នុងឆ្នាំ២០២៣ ជាមួយនឹងកំណើន ១៩,២០% ធៀបនឹងឆ្នាំ២០២២។ ករណីរំលូតនិងរលូតបានកើនឡើងពី ១២ ៧១៤ករណី ក្នុងឆ្នាំ២០២២ ទៅ ១៥ ៧៣៧ករណី ក្នុងឆ្នាំ២០២៣ (ក្នុងនោះ ករណីរំលូតមានចំនួន ៦ ០៦២ករណី និងរលូតមានចំនួន ៩ ៦៧៥ករណី ដែលបានរាយការណ៍ពីមូលដ្ឋានសុខាភិបាលសាធារណៈទូទាំងប្រទេស)។ គួរកត់សម្គាល់ថា ករណីរលូតបានកើនឡើង ២៧,៩១% បើធៀបនឹងឆ្នាំ២០២២ ចំណែកករណីរំលូតក៏បានកើនឡើង ១៧,៧១% ផងដែរ។ នៅឆ្នាំ២០២៣ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ដែលផ្តល់សេវារំលូត/រលូតប្រកបដោយសុវត្ថិភាព និងសេវាថែទាំក្រោយរំលូត/រលូតមានចំនួន ៨២០កន្លែង ដោយកើនឡើង ៨៨កន្លែង ធៀបនឹងឆ្នាំ២០២២ ដែលមាន ៧៣២កន្លែង។ ចំនួនករណីរំលូត និងរលូតមានកម្រិតផ្សេងៗគ្នាពីខេត្តមួយទៅខេត្តមួយទៀត។

### ឆ. សុខភាពមាតា និងទារក

៣៦. អត្រាមរណភាពមាតា មរណភាពទារក និងកុមារអាយុក្រោម ៥ឆ្នាំ បានបន្តធ្លាក់ចុះថែមទៀតរវាងឆ្នាំ២០១៤ និងឆ្នាំ២០២១/២២។ គួរកត់សម្គាល់ថា មរណភាពទារក និងកុមារអាយុក្រោម៥ឆ្នាំសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ មុនកាលកំណត់ ៨ឆ្នាំ។ ដោយឡែកការធ្លាក់ចុះនៃមរណភាពមាតាមានល្បឿនយឺតក្នុងអំឡុងពេលពីឆ្នាំ២០១៤ ដល់ឆ្នាំ២០២១ ធៀបនឹងល្បឿននៃការធ្លាក់ចុះក្នុងសម័យកាលគោលដៅអភិវឌ្ឍសហស្សវត្សរ៍ ឆ្នាំ២០០០-២០១៥។



៣៧. ការថែទាំគភ៌មុនសម្រាលៈ រវាងឆ្នាំ២០២២-២០២៣ អត្រាពិនិត្យថែទាំគភ៌មុនសម្រាលលើកទី២ បានកើនឡើង ១១,០៨ភាគរយពិន្ទុ ឬកើនឡើងពី ៨៨,២៦% នៅឆ្នាំ២០២២ ដល់ ៩៩,៣៤% នៃស្ត្រីមានគភ៌រំពឹងទុកចំនួនប្រមាណ ៣៣៣ ១៥៣នាក់ នៅឆ្នាំ២០២៣ និងអត្រានៃការពិនិត្យលើកទី៤ បានកើន ១៣,៤៣ភាគរយពិន្ទុ ឬពី ៦១,៤៧% ទៅ ៧៤,៩០%។ នៅឆ្នាំ២០២៣ ករណីពិនិត្យថែទាំគភ៌មុនសម្រាលលើកទី២ មានចំនួនសរុប ៣៣០ ៩៥៩ករណី ក្នុងនោះ ពិនិត្យនៅសេវាសាធារណៈមានចំនួន ៣០៥ ៥៩៦ករណី និងនៅសេវាឯកជនមានចំនួន ២៥ ៣៦៣ករណី។ រីឯករណីពិនិត្យថែទាំគភ៌មុនសម្រាលលើកទី៤ ទាំងនៅសេវាសាធារណៈ និងសេវាឯកជនមានចំនួនសរុប ២៤៩ ៥២៣ករណី។ អត្រាពិនិត្យមុនសម្រាលលើកទី២ និងលើកទី៤ មានកម្រិតប្រែប្រួលពីខេត្តមួយទៅខេត្តមួយក្នុងទូទាំងប្រទេស។ អត្រាពិនិត្យលើកទី២ ទាបបំផុត ៥១,៥៨% និងអត្រាខ្ពស់បំផុត ១១៩,៦៧%។ ខេត្តចំនួន ៥ ដែលមានអត្រាពិនិត្យលើកទី២ លើស ១០០% គឺខេត្តពោធិ៍សាត់ រតនៈគិរី កោះកុង កំពង់ចាម និងមណ្ឌលគិរី។ ការពិនិត្យថែទាំគភ៌មុនសម្រាលបានស្រាវជ្រាវរកឃើញស្ត្រីមានគភ៌បម្រុងមានគ្រោះថ្នាក់ ៤១ ១៩១នាក់ ក្នុងនោះមានបញ្ហាធ្លាក់ឈាម ៩៦៤នាក់ ស្លេកស្លាំង ២៣ ១៦២នាក់ និងបញ្ហាផ្សេងៗទៀត ១៧ ០៦៥នាក់។ ស្ត្រីទាំងនោះ បានទទួលការប្រឹក្សាយោបល់និងការណែនាំ ព្រមទាំងការពិនិត្យតាមដាន និងការថែទាំយ៉ាងយកចិត្តទុកដាក់នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ។

៣៨. និន្នាការនៃអត្រាពិនិត្យថែទាំម្ដាយក្រោយសម្រាលលើកទី១ លើកទី២ លើកទី៣ លើកទី៤ បានធ្លាក់យ៉ាងខ្លាំងក្នុងអំឡុងពេលមានការរាតត្បាតនៃជំងឺកូវីដ-១៩ ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២២ ប៉ុន្តែបានឡើងក្នុងសមាមាត្រតិចតួចក្នុងឆ្នាំ២០២៣។ នៅឆ្នាំ២០២៣ ការពិនិត្យថែទាំម្ដាយក្រោយសម្រាលលើកទី១ (ក្នុងសប្ដាហ៍ទី១ ក្រោយសម្រាល) លើកទី២ (ក្នុងសប្ដាហ៍ទី២ ក្រោយសម្រាល) លើកទី៣ (នៅពេលកូនមានអាយុ ១ខែកន្លះ) និងលើកទី៤ (នៅពេលកូនមានអាយុ ២ខែកន្លះ) នៅមូលដ្ឋានសុខាភិបាលសាធារណៈមានចំនួនសរុប ៤៣០ ២៨០នាក់ ក្នុងអត្រាពិនិត្យថែទាំក្រោយសម្រាលធៀបនឹងចំនួនស្ត្រីមានគភ៌រំពឹងទុកលើកទី១ ៥៧,០៨% (១៩០ ១៦៧នាក់) លើកទី២ ៤១,៧៣% (១៣៩ ០២៧នាក់) លើកទី៣ ២៣,២៩%(៧៧ ៥៧៨នាក់) និងលើកទី៤ ៧,០៦% (២៣ ៥០៨នាក់)។ ចំណែកទារកដែលទទួលបានការថែទាំក្រោយសម្រាលលើកទី១ ចំនួន ១៨៣ ៧២០នាក់ លើកទី២ ចំនួន ១៣៥ ១០៦នាក់ លើកទី៣ ចំនួន ៧៦ ៥៥៦នាក់ និងលើកទី៤ ចំនួន ២៣ ១៥០នាក់។

៣៩. មរណភាពមាតា និងទារកៈ យោងតាមរបាយការណ៍ប្រចាំឆ្នាំស្ដីពីការស្រាវជ្រាវមរណភាពមាតា និងការសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកទើបកើត ក្នុងឆ្នាំ២០២៣ ករណីសង្ស័យមរណភាពមាតាដែលបានរាយការណ៍ពីមូលដ្ឋានសុខាភិបាលសាធារណៈមានចំនួនសរុប ៩៥ករណី។ រីឯទារកកើតរស់មានចំនួន ២៨០ ៩៧២នាក់ និងទារកកើតស្លាប់ ២ ០៨៧នាក់ ក្នុងនោះទារកកើតស្លាប់មុន ២៤ម៉ោង ៤៩២នាក់ និងទារកស្លាប់កើត(ស្លាប់កើតភ្លាមៗ និងស្លាប់កើតយូរ) ២ ០២៥នាក់។ ក្រៅពីស្ថានភាពខាងលើ ទារកកើតទម្ងន់តិចជាង ២,៥គ.ក្រ ចំនួន ១១ ៤៧២នាក់ ទារកទម្ងន់លើសពី ២,៥គ.ក្រ ចំនួន ២៦៣ ៣៥៣នាក់ ទារកកើតមិនបានថ្លឹងទម្ងន់ចំនួន ១៤៧នាក់ និងម្ដាយផ្ដល់កំណើតកូនភ្លោះពីរ ឬភ្លោះបីចំនួន ១ ៧៦៩នាក់។

ស្ថានភាពទារកកើត ដែលបានរាយការណ៍ដោយមូលដ្ឋានសុខាភិបាលសាធារណៈ ឆ្នាំ២០១៩-២០២៣

| ស្ថានភាពទារកកើត | 2019 | 2020 | 2021 | 2022 | 2023 |
|---|---|---|---|---|---|
| ទារកកើតរស់ | 306 891 | 309 637 | 285 173 | 259 954 | 280 972 |
| ទារកកើតស្លាប់ | 2 122 | 2 416 | 2 540 | 2 042 | 2 087 |
| ទារកកើតស្លាប់មុន២៤ម៉ោង | 222 | 304 | 280 | 240 | 492 |
| ទារកស្លាប់កើត (កើតភ្លាមៗ/កើតយូរ) | 1 870 | 2 054 | 1 157 | 1 100 | 2 025 |
| ទារកកើតមានទម្ងន់តិចជាង២,៥គ.ក្រ | 20 366 | 19 654 | 17 942 | 17 902 | 17 472 |
| ទារកកើតមានទម្ងន់លើសពី២,៥គ.ក្រ | 285 917 | 289 506 | 266 949 | 241 747 | 263 353 |
| ទារកកើតមិនបានថ្លឹងទម្ងន់ | 607 | 477 | 282 | 8 234 | 147 |
| ចំនួនម្ដាយផ្ដល់កំណើតកូនភ្លោះពីរ/បី | 1 990/20 | 1 982/24 | 1 673/22 | 1 442/15 | 1 769/18 |

ប្រភព៖ ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាលរបស់ក្រសួងសុខាភិបាល

៤០. ការបង្ការការចម្លងមេរោគអេដស៍/មេរោគស្វាយពីម្ដាយទៅកូន៖ នៅឆ្នាំ២០២៣ សេវាបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូនមានចំនួន ១ ៣៨៧កន្លែង។ ស្ត្រីមានគភ៌ដែលបានធ្វើតេស្តមេរោគអេដស៍នៅពេលពិនិត្យផ្ទៃពោះមានចំនួន ៣០៥ ៣៣៨នាក់ ឬស្មើនឹង ៩១,៦៥% នៃស្ត្រីមានគភ៌រំពឹងទុក ក្នុងនោះ ១៩៦នាក់ ដែលវិជ្ជមានតេស្តបញ្ជាក់មេរោគអេដស៍បានទទួលឱសថព្យាបាលតាមលក្ខខណ្ឌបច្ចេកទេស (នៅពេលពិនិត្យផ្ទៃពោះ ពេលឈឺពោះសម្រាល និងក្រោយសម្រាល) និងទារកប្រឈមហានិភ័យ ៥៥៣នាក់ បានទទួលឱសថសម្រាប់ការបង្ការការចម្លងពីម្ដាយ។ រីឯស្ត្រីមានគភ៌ដែលស្ម័គ្រចិត្តធ្វើតេស្តរហ័សរកមេរោគស្វាយ និងបានទទួលយកលទ្ធផលតេស្តមានចំនួន ២៧៨ ៨០៨នាក់ ក្នុងនោះប្រតិកម្មដោយតេស្តរហ័សរកមេរោគស្វាយចំនួន ៤ ៨០៤នាក់ និងស្ត្រីទទួលបានការព្យាបាលជំងឺស្វាយចំនួន ១ ៧៤៧នាក់។

## ផ. សុខភាពកុមារ

| សូចនាករ | លទ្ធផល | | | | | គោលដៅចំណុច | កម្រិតប្រែប្រួល |
|---|---|---|---|---|---|---|---|
| | 2019 | 2020 | 2021 | 2022 | 2023 | 2023 | |
| ១.អត្រាគ្របដណ្ដប់នៃបង្ការជំងឺខាន់ស្លាក់ ក្អកមាន់ តេតាណូស រលាកថ្លើមប្រភេទបេ រលាកសួត រលាកស្រោមខួរ (DPT-Hept Bib) ៣ដូស(%) | 90.0 | 106.6 | 98.31 | 96.33 | **107.77** | 95 | **+12.77** |
| ២.អត្រាគ្របដណ្ដប់នៃវ៉ាក់សាំងបង្ការកញ្ជ្រិល ស្អូចនៅខែទី៩ (%) | 102.0 | 107.0 | 102.0 | 102.1 | **108.63** | 95 | **+13.63** |
| ៣.ចំនួនលើកនៃការពិគ្រោះជំងឺក្រៅករណីថ្មី លើកុមារអាយុក្រោម៥ឆ្នាំ ម្នាក់ក្នុងមួយឆ្នាំ | 1.62 | 1.29 | 1.26 | 1.28 | **1.64** | 1.65 | **-0.01** |

ប្រភព៖ ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាលរបស់ក្រសួងសុខាភិបាល

៤១. ការផ្តល់ថ្នាំបង្ការជំងឺ៖ បច្ចុប្បន្នកម្មវិធីជាតិផ្តល់ថ្នាំបង្ការបានផ្តល់វ៉ាក់សាំងបង្ការចំនួន ១២មុខ ក្នុងនោះវ៉ាក់សាំង ១១មុខ សម្រាប់កុមារអាយុក្រោម ១ឆ្នាំ រួមមាន៖ វ៉ាក់សាំងបង្ការជំងឺរបេង ខាន់ស្លាក់ ក្អកមាន់ តេតាណូស គ្រុនស្វិតដៃជើង កញ្ជ្រិល រលាកថ្លើមប្រភេទបេ (បញ្ចូលនៅឆ្នាំ២០០១) និងរលាកស្រោមខួរក្បាល JE (បញ្ចូលនៅឆ្នាំ២០១០) រលាកសួត-ស្អូច (បញ្ចូលនៅឆ្នាំ២០១០ និង២០១៣) និងវ៉ាក់សាំង ១មុខទៀតសម្រាប់បង្ការជំងឺមហារីកមាត់ស្បូនលើកុមារីអាយុ ៩ឆ្នាំ (បញ្ចូលនៅឆ្នាំ២០១៧)។ នៅក្នុងឆ្នាំ២០២៣ អត្រាគ្របដណ្តប់នៃការចាក់វ៉ាក់សាំងបង្ការជំងឺលើកុមារអាយុក្រោម ១ឆ្នាំ ១០៧,៧៧% កើនឡើង ១១,៤៤%ពិន្ទុ ធៀបនឹងឆ្នាំ២០២២។

៤២. ការពិនិត្យជំងឺក្រៅលើកុមារ៖ រវាងឆ្នាំ២០១៩-២០២៣ ចំនួនលើកនៃការពិនិត្យពិគ្រោះជំងឺក្រៅករណីថ្មីនៃកុមារអាយុក្រោម ៥ឆ្នាំម្នាក់ក្នុងមួយឆ្នាំ មាននិន្នាការថយចុះ ពី១,៦២ នៅឆ្នាំ២០១៩ មក ១,២៦ នៅឆ្នាំ២០២១ បន្ទាប់មកបានចាប់ផ្តើមងើបឡើងវិញពី ១,២៨ នៅឆ្នាំ២០២២ ដល់ ១,៦៤ នៅឆ្នាំ២០២៣។ នៅឆ្នាំ២០២៣ ការពិនិត្យជំងឺក្រៅករណីថ្មី លើកុមារអាយុក្រោម ៥ឆ្នាំ មានចំនួនសរុប ២ ៤៩៨ ៨៤៣ករណី ក្នុងនោះ នៅមូលដ្ឋានសុខាភិបាលសាធារណៈចំនួន ២ ៣០២ ០៦៣ករណី និងនៅសេវាឯកជនដែលបានរាយការណ៍ចំនួន ១៩៦ ៧៨០ករណី។ កម្រិតប្រើប្រាស់សេវាពិនិត្យជំងឺក្រៅករណីថ្មី និងចំនួនលើកមកពិនិត្យពិគ្រោះជំងឺករណីថ្មីនៅមូលដ្ឋានសុខាភិបាលសាធារណៈ ដោយកុមារអាយុក្រោម ៥ឆ្នាំម្នាក់ក្នុងមួយឆ្នាំ ប្រែប្រួលតាមរាជធានី ខេត្ត ពីអត្រាទាបបំផុត ០,៤៣លើក ទៅអត្រាខ្ពស់បំផុត ២,៣៣លើក។ ខេត្តដែលចំនួនលើកនៃការពិនិត្យជំងឺក្រៅករណីថ្មី នៃកុមារអាយុក្រោម៥ឆ្នាំម្នាក់ក្នុងមួយឆ្នាំ លើសពីមធ្យមភាគទូទាំងប្រទេស គឺរាជធានីភ្នំពេញ ខេត្តសៀមរាប ពោធិ៍សាត់ បន្ទាយមានជ័យ មណ្ឌលគិរី តាកែវ កំពង់ចាម បាត់ដំបង និងត្បូងឃ្មុំ។

៤៣. ជំងឺនាំមុខឬបញ្ហាសុខភាព ១០ ដែលជាមូលហេតុចម្បងនៃការពិនិត្យជំងឺក្រៅករណីថ្មី ៩៧១ ៣៥៨ គឺមាន៖ ជំងឺរលាកផ្លូវដង្ហើមលើស្រួចស្រាល់ ៦៦,៩៥% រាកគ្មានខ្សោះជាតិទឹក ៧,៣៣% រលាកសួត ៦,១៧% រលាកទងសួតស្រួចស្រាល់ ៣,៩៨% រលាកផ្លូវដង្ហើមផ្នែកខាងក្រោមផ្សេងៗទៀត ៣,៩០% រលាកបំពង់កស្រួចស្រាល់ ២,៩៧% រាកមូល ២,៩០% ភ្នែកក្រហម ២,២៥% រាកខ្សោះជាតិទឹកមធ្យម ១,៨៣% និងរមាស់ស្បែក ១,៧១%។ រីឯការពិនិត្យជំងឺក្រៅតាមពិធីសារសមាហរណកម្មគ្រប់គ្រងជំងឺកុមារលើកុមារអាយុក្រោម ៥ឆ្នាំ មានចំនួនសរុប ១ ១២៣ ៩៧៤ ករណី ក្នុងនោះករណីថ្មីចំនួន ១ ០៨៧ ០៩០ករណី។ គួរកត់សម្គាល់ថា ចំនួនពិនិត្យករណីថ្មីតាមបែបសមាហរណកម្មនៅឆ្នាំ២០២៣ បានកើនឡើង ៦៨ ៣៤៨ករណី ឬស្មើនឹងប្រមាណ ៦,៧% លើសឆ្នាំ២០២២។

៤៤. ការសម្រាកព្យាបាល៖ កុមារអាយុក្រោមប្រាំឆ្នាំសម្រាកព្យាបាលបានកើនពី ១៤៦ ១០៤នាក់ នៅឆ្នាំ ២០២២ ទៅ ២០៥ ៦៨២នាក់ (ស្រី ៨៩ ៤០៦នាក់) ឬកើនឡើង ៤០,៨% នៅឆ្នាំ២០២៣ ក្នុងនោះកុមារ ១ ៦៧៥នាក់បានស្លាប់។ ជំងឺនាំមុខ ឬបញ្ហាសុខភាពចម្បង ៥ ដែលជាមូលហេតុនៃការសម្រាកពេទ្យរបស់កុមារចំនួនសរុប ៧៦ ០៩៣ករណី គឺជំងឺរលាកទងសួតស្រួចស្រាល់ ២៥,២៨% រលាកបំពង់កស្រួចស្រាល់ ២៥,១៤% រលាកផ្លូវដង្ហើមលើស្រួចស្រាល់ ១៨,៧៩% រលាកសួត ១៧,១១% និងរាកគ្មានខ្សោះជាតិទឹក ១៣,៦៨%។

### ឈ. ការកែលម្អកង្វះអាហារូបត្ថម្ភ

៤៥. អន្តរាគមន៍ក្នុងការកែលម្អស្ថានភាពអាហារូបត្ថម្ភកុមារ រួមមាន៖ ផ្តល់ការអប់រំម្តាយពីអត្ថប្រយោជន៍នៃការបំបៅទារកដោយទឹកដោះម្តាយ ការផ្តល់អាហារបំប៉នស្របតាមដំណាក់កាលលូតលាស់របស់កុមារ និងការថែទាំ និងការបង្ការទារក/កុមារពីជំងឺផ្សេងៗ ការផ្តល់វ៉ាក់សាំងបង្ការជំងឺតាមកាលវិភាគ ការផ្តល់មីក្រូសារជាតិ និងថ្នាំទម្លាក់ព្រូនការតាមដានការលូតលាស់របស់កុមារ និងការពិនិត្យព្យាបាលថែទាំកុមារកង្វះអាហារូបត្ថម្ភ។

| សូចនាករ | លទ្ធផល | | | | | គោលដៅ | កម្រិតប្រែប្រួល |
|---|---|---|---|---|---|---|---|
| | 2019 | 2020 | 2021 | 2022 | 2023 | 2023 | |
| %នៃទារកបានទទួលការបំបៅដោយ ទឹកដោះម្តាយក្នុងអំឡុងមួយម៉ោងដំបូងនៃកំណើត | 65.36 | 71.14 | 72.22 | 71.95 | 71.02 | 60.0 | +11.02 |
| %នៃកុមារអាយុពី ៦-៥៩ខែ បានទទួលគ្រាប់ថ្នាំជីវជាតិ-អា ក្នុងអំឡុងពេល៦ខែចុងក្រោយនៃឆ្នាំ | 73.04 | 74.0 | 62.59 | 70.70 | 84.02 | 90 | -5.98 |
| %នៃកុមារអាយុពី១២ខែ ដល់៥៩ខែបាន ទទួលថ្នាំម៉េបង់ដាហ្សុលក្នុងអំឡុងពេល ៦ខែចុងក្រោយនៃឆ្នាំ | 75.15 | 76.0 | 61.86 | 64.42 | 73.73 | 90 | -16.27 |
| %ស្ត្រីមានគភ៌ទទួលគ្រាប់ថ្នាំជីវជាតិដែក/អាស៊ីតហ្វូលិក៩០គ្រាប់ | 91.05 | 89.47 | 76.16 | 79.84 | 87.29 | 90 | -2.71 |
| %ស្ត្រីក្រោយសម្រាលបានទទួលគ្រាប់ថ្នាំជីវជាតិដែក/អាស៊ីតហ្វូលិក ៤២គ្រាប់ | 78.69 | 80.96 | 77.16 | 72.25 | 76.22 | 90 | -13.78 |

៤៦. ការបំបៅទារកដោយទឹកដោះម្តាយ៖ អត្រាទារកកើតរស់បានទទួលការបំបៅដោយទឹកដោះម្តាយនៅក្នុងមួយម៉ោងដំបូងក្រោយកំណើតនៅឆ្នាំ២០២៣ មានអត្រាប្រហាក់ប្រហែលនឹងឆ្នាំ២០២២ ដែរ ៧១,០២%។ អត្រានេះបែប្រួលពីខេត្តមួយទៅខេត្តមួយទៀតពីអត្រាទាបបំផុត ៣៩,៣១% ទៅអត្រាខ្ពស់បំផុត ៩៨,១៩%។ ខេត្តចំនួនប្រាំមួយដែលមានអត្រាទាបជាងអត្រាមធ្យមទូទាំងប្រទេស គឺខេត្តកណ្តាល កំពង់ស្ពឺ ស្វាយរៀង ស្ទឹងត្រែង រាជធានីភ្នំពេញ និងកំពង់ចាម។ នៅឆ្នាំ២០២៣ ទារកកើតរស់ដែលបានទទួលការបំបៅដោយទឹកដោះម្តាយនៅក្នុងម៉ោងដំបូងក្រោយកំណើតមានចំនួន ១៩៩ ៥៤២នាក់ ឬស្មើនឹង ៧១,០២% នៃទារកកើតរស់ ២៨០ ៩៧២នាក់ ដែលបានកើតនៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ។ គួរបញ្ជាក់ថា នៅឆ្នាំ២០២២ ចំនួនទារកកើតរស់ដែលបានទទួលការបំបៅដោយទឹកដោះម្តាយ នៅក្នុងម៉ោងដំបូងក្រោយកំណើតមានចំនួនសរុប ១៨៧ ០៤៦នាក់ ។

៤៧. ការផ្តល់គ្រាប់ថ្នាំជីវជាតិ-អា៖ នៅឆ្នាំ២០២៣ អត្រាកុមារបានទទួលគ្រាប់រថ្នាំជីវជាតិ-អា ក្នុងជុំទីពីរបានកើនឡើង ២,៦% ធៀបនឹងឆ្នាំ២០២២។ តាមការប៉ាន់ស្មានដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ កុមារអាយុពី ៦-៥៩ខែ នៅឆ្នាំ២០២៣ មានចំនួន ១ ៣៧០ ១៩៨នាក់ ក្នុងនោះ កុមារបានទទួលគ្រាប់ថ្នាំជីវជាតិ-អា ក្នុងអំឡុងពេល៦ខែដើមឆ្នាំ (ជុំទីមួយ) មានចំនួន ១ ០៧៣ ៤៣៣នាក់ ស្មើនឹង ៧៨,៣៤% និងក្នុងអំឡុងពេល៦ខែចុងឆ្នាំ (ជុំទីពីរ) មានចំនួន ១ ១៥១ ២៥១នាក់ ឬស្មើនឹង ៨៤,០២%។ អត្រា

នេះមានការប្រែប្រួលពីខេត្តមួយទៅខេត្តមួយទៀត ពីកម្រិតទាបបំផុត ៣៣,៣៨% ទៅកម្រិតខ្ពស់បំផុត ១៣២,៨៤%។ ដោយឡែកការផ្តល់គ្រាប់ថ្នាំជីវជាតិ-អា ក្នុងការព្យាបាលកុមារមានជំងឺស្ងួតភ្នែក និងជំងឺខ្វាក់មាន់បានចំនួន ៥ ១៨៥នាក់ កុមារមានជំងឺកញ្ជ្រិល ១៣៨នាក់ និងកុមារកង្វះអាហាររូបត្ថម្ភ/រាគជាប់/រាគរ៉ាំរ៉ៃ ៦៤០នាក់។

៤៨. ការផ្តល់ថ្នាំទំលាក់ព្រូន៖ នៅ២០២៣ កុមារអាយុពី ១២-៥៩ខែ ដែលបានទទួលថ្នាំមេបង់ដាហ្សុល ជុំទី២ (៦ខែចុងឆ្នាំ) មានចំនួន ១ ០១០ ២២១នាក់ បានកើនឡើងប្រមាណ ១០% ធៀបនឹងឆ្នាំ២០២២។ ស្ត្រីក្នុងវ័យបន្តពូជអាយុពី១៥-៤៩ឆ្នាំ ចំនួន ១២៨ ២០៩នាក់ និងស្ត្រីបំបៅដោះកូនចំនួន ៨៥ ៦០១នាក់ បានទទួលថ្នាំមេបង់ដាហ្សុល ដោយមានការកើនឡើងលើសឆ្នាំ២០២២ ចំនួន ៤ ០៦០នាក់ និង ៣ ៦០១នាក់តាមលំដាប់រៀង។

៤៩. ការផ្តល់គ្រាប់ថ្នាំជាតិដែក/អាស៊ីតហ្វូលិក៖ នៅឆ្នាំ២០២៣ ស្ត្រីមានគភ៌បានទទួលគ្រាប់ថ្នាំជាតិដែក/អាស៊ីតហ្វូលិក៩០គ្រាប់ មានចំនួន ២៩០ ៧៩៦នាក់ ឬស្មើនឹង ៨៧,២៩% នៃស្ត្រីមានគភ៌រំពឹងទុក ដោយកើនឡើងប្រមាណ ៨,៥ភាគរយពិន្ទុ ធៀបនឹងឆ្នាំ២០២២ (៧៩,៨៤%)។ រីឯស្ត្រីក្រោយសម្រាលបានទទួលអាស៊ីតហ្វូលិក/គ្រាប់ថ្នាំជាតិដែក ៤២គ្រាប់ មានចំនួន ២៥៣ ៩៣៨ នាក់ ឬស្មើនឹង ៧៦,២២% ដោយកើនឡើងប្រមាណ ៤ ភាគរយពិន្ទុ ធៀបនឹងឆ្នាំ២០២២។

៥០. ការពិនិត្យពិគ្រោះ និងព្យាបាលជំងឺកង្វះអាហារូបត្ថមនៅឆ្នាំ២០២៣ កុមារអាយុក្រោម ៥ឆ្នាំ ដែលបានមកពិនិត្យពិគ្រោះជំងឺក្រៅ និងបានរកឃើញមានបញ្ហាកង្វះអាហាររូបត្ថម្ភមានចំនួនសរុប ៨ ៩៧៧ ករណី ដោយកើនឡើង ៧៤,៦៥% បើធៀបនឹងឆ្នាំ២០២២ (៥ ១៤០ករណី)។ គួរកត់សម្គាល់ថា របាយការណ៍សូចនាករកង្វះអាហាររូបត្ថម្ភ ទើបនឹងត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាល ដើម្បីប្រមូលទិន្នន័យចាប់ពីឆ្នាំ២០២២ កន្លងទៅនេះ។

## ២.២. កាកបាទក្រហមកម្ពុជា

៥១. ក្នុងនាមជាស្ថាប័នមនុស្សធម៌ និងសប្បុរសធម៌ កាកបាទក្រហមកម្ពុជា (ក.ក្រ.ក.) បានដើរតួនាទីយ៉ាងសំខាន់ក្នុងការឆ្លើយតប ការត្រៀមឆ្លើយតប និងការកាត់បន្ថយហានិភ័យចំពោះគ្រោះមហន្តរាយនានា ស្របតាមសេចក្តីណែនាំ គោលនយោបាយ និងបទដ្ឋានប្រតិបត្តិមួយចំនួន រួមមាន៖ ការពង្រឹងសមត្ថភាពគ្រប់គ្រង និងអនុវត្តនីតិវិធីភស្តុភារ ការរាយការណ៍ពីផលប៉ះពាល់ដោយគ្រោះមហន្តរាយនានា ការធ្វើលំហាត់សាកល្បងឆ្លើយតបសង្គ្រោះបន្ទាន់គ្រោះមហន្តរាយទឹកជំនន់ និងទម្រង់ប្រតិបត្តិការផ្គត់ផ្គង់ឆ្លើយតបចំមុខសញ្ញដែលត្រូវជួយ ជាពិសេសការពង្រឹងភាពធន់នៅក្នុងសហគមន៍។

៥២. ទន្ទឹមនឹងការគ្រប់គ្រងគ្រោះមហន្តរាយ វិបត្តិភ័យ និងបម្រែបម្រួលអាកាសធាតុ ក.ក្រ.ក. បាននិងកំពុងអនុវត្តសកម្មភាពដូចភ្លៀងរលឹម លើការងារជាវិស័យអាទិភាព "សុខភាព និងការថែទាំសុខភាព" ដែលឥស្សរជនឆ្នើមថ្នាក់ជាតិតែងយកចិត្តទុកដាក់យ៉ាងខ្លាំង គឺការលើកកម្ពស់សុខភាពមាតា ទារកនិងកុមារ។

៥៣. ក.ក្រ.ក. បានអប់រំផ្សព្វផ្សាយតាមសមាគម គ្រឹះស្ថានសិក្សា និងរាល់ពេលចែកអំណោយ នូវខ្លឹមសារអនាម័យ ទឹកស្អាត ហូបស្អាត រស់នៅស្អាត ការពារជំងឺឆ្លង និងជំងឺមិនឆ្លងនានា។ ជាពិសេស រៀងរាល់ឆ្នាំ

នៅថ្ងៃទិវាជាតិ ២១ កុម្ភៈ ស្ដីពី "សុខភាពមាតា ទារក និងកុមារ" ក.ក្រ.ក. បានសហការជាមួយផ្នែកពាក់ព័ន្ធរៀបចំវេទិកានានាចំនួន ១២លើកជាប្រចាំខែ ដោយមានការចូលរួមពីស្ត្រីចំនួន ៨ ៧៥៤នាក់។

៥៤. ក.ក្រ.ក. បានផ្ដល់ជំនួយឧបត្ថម្ភជូនស្ត្រីឆ្លងទន្លេមានជីវភាពខ្វះខាត ទាំងថវិកា ស្បៀងអាហារ សម្លៀកបំពាក់ និងជម្រកជាច្រើនទៀត។ ដោយឡែក ស្ត្រីជាកម្មការិនីមានផ្ទៃពោះ និងឆ្លងទន្លេរួចចំនួន ៧ ៣២២នាក់។

៥៥. ក.ក្រ.ក. បានជួយដល់ស្ត្រី និងកុមារមានផ្ទុកមេរោគអេដស៍តាមសហគមន៍សរុបមាន៖ ស្ត្រីមានផ្ទៃពោះចំនួន ២ ៩០៦នាក់ ស្ត្រីផ្ទុកមេរោគអេដស៍ ១ ៣៤៨គ្រួសារ និងអប់រំអំពីវិធីការពារចំនួន ២ ២៣០នាក់។

៥៦. ក.ក្រ.ក. បានផ្ដល់អំណោយជាប្រចាំឆ្នាំជួយដល់មជ្ឈមណ្ឌលថែទាំទារក កុមារជាតិ មណ្ឌលកុមាររងគ្រោះ កុមារពិការ ជាថវិកាសម្ភារៈស្បៀងអាហារ និងមធ្យោបាយធ្វើដំណើរជាប្រចាំឆ្នាំ។ ជាពិសេសជួយ ១លានដុល្លារអាមេរិកជាប្រចាំឆ្នាំដល់មន្ទីរពេទ្យគន្ធបុប្ផា និងមន្ទីរពេទ្យកុមារអង្គរ។

៥៧. ក.ក្រ.ក. បានផ្ដល់ប្រាក់កម្ចីខ្នាតតូចគ្មានការប្រាក់ដល់ស្ត្រី កុមាររស់នៅតាមព្រំដែនប្រឈមនឹងគ្រោះថ្នាក់ដោយសារសំណល់គ្រឿងផ្ទុះពីសម័យសង្គ្រាមចំនួន ៥៤៤គ្រួសារ។

៥៨. បានជួយជំនួយសម្ភារៈថវិកា ស្បៀងអាហារ ជូនស្ត្រី ទារក កុមាររស់នៅតាមម្ដាយឪពុកក្នុងពន្ធនាគារជារៀងរាល់ឆ្នាំសរុបថវិកាចំនួន ២០លានរៀលក្នុងឆ្នាំ២០២៣ និង ២០លានរៀលក្នុងឆ្នាំ២០២៤។

## ២.៣. ការចុះអត្រានុកូលដ្ឋាន

### ក. ការចុះបញ្ជីកំណើត

៥៩. នៅកម្ពុជា កុមារប្រមាណ ៩៤% នៃកុមារទាំងអស់ ដែលមានអាយុ ០-៤ឆ្នាំ មានសំបុត្រកំណើត។ ភាគរយនេះ គឺមានកម្រិតខ្ពស់បំផុតនៅរាជធានីភ្នំពេញ ប្រមាណជិត ៩៤% នៅទីប្រជុំជនផ្សេងៗ មានជិត ៩៧% និងនៅតំបន់ជនបទ មានជិត៩៣%។[9]

៦០. ក្នុងឆ្នាំ២០២៣ ចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទបានចំនួន ៦៣២ ៨៦១បញ្ជី មនុស្ស ៧៥៥ ៦៥៩នាក់ ស្រី ៣៣៥ ៩០២នាក់ ក្នុងនោះ ការចុះបញ្ជីកំណើត និងបញ្ជាក់កំណើតចំនួន ៤៤៩ ៦៩២បញ្ជី ការចុះបញ្ជីអាពាហ៍ពិពាហ៍ចំនួន ១២២ ៧៩៨បញ្ជី និងការចុះបញ្ជីមរណភាពចំនួន ៦០ ៣៧១បញ្ជី។ គិតចាប់ពីឆ្នាំ២០០២ ដល់ឆ្នាំ២០២៣ ការចុះបញ្ជីអត្រានុកូលដ្ឋានសម្រេចបាន ២០ ៥៧៨ ៣៦៣បញ្ជី មនុស្ស ២១ ៧២៣ ៦១៣នាក់ ស្រី ១០ ៣៨៥ ២៧៣នាក់។ ចេញសេចក្ដីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទបានចំនួន ២ ២៣៧ច្បាប់ ព្រមទាំងចេញសេចក្ដីសម្រេចលើសំណុំឯកសារស្ដីពីការសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរនិងជនបរទេសចំនួន ២ ១៨៧ច្បាប់ មាន ៤២សញ្ញាតិ (បូកយោងគ្រាដើមសរុបមានចំនួន ២៣ ៨៣១ច្បាប់)។

៦១. វាយបញ្ចូលទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានកំណើតបានចំនួន ២៧២ ៤៧៩បញ្ជី (បូកយោងពីដើមគ្រាសរុបចំនួន ៧ ២៩៤ ៦០០បញ្ជី)។ បើកផ្ដល់ជូនរដ្ឋបាលរាជធានី ខេត្តទាំង២៥ នូវសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទចំនួន ៤៥ ៤១៩ក្បាល និងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទចំនួន ៧ ៧២៣ ៥៩០សន្លឹក។

---

[9] របាយការណ៍អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០២១ ទំព័រ៣៣

ចេញសេចក្តីសម្រេចស្តីពីការកែតម្រូវ និងមោឃភាពទិន្នន័យអត្រានុកូលដ្ឋានបានចំនួន ១៩ ៥៤៣ច្បាប់ (បូកយោងពីដើមគ្រាសរុបមានចំនួន ៩០ ៥២៦ច្បាប់)។[10]

## ២.៤. បរិយាកាសគ្រួសារ[11]

### ក.ការថែទាំជំនួស

៦២. កន្លែងថែទាំកុមារមានចំនួន ២៧០ ដែលមានកុមារសរុបចំនួន ៩,០៥៣នាក់ ស្រី ៤,៦០១នាក់ ក្នុងនោះ កុមារអាយុពី ០-១៧ឆ្នាំ មានចំនួន ៧,០៧៩នាក់ ស្រី ៣,៥០៨នាក់ និងយុវជនមានអាយុចាប់ពី ១៨ឡើង មានចំនួន ១,៩៧៤នាក់ ស្រី ១,០៩៣នាក់។ កុមារដែលត្រូវបានធ្វើសមាហរណកម្ម ឬបង្រួបបង្រួមគ្រួសារ ឬកុមារចាកចេញពីមណ្ឌលថែទាំសរុបចំនួន ៩២៣នាក់។

តារាង ៖ ចំនួនកន្លែងថែទាំ និងចំនួនកុមារ និងយុវជន ទិន្នន័យឆ្នាំ២០២៣

| ប្រភេទកន្លែងថែទាំ | ចំនួន | ចំនួនកុមារអាយុ ០-១៧ឆ្នាំ | | ចំនួនយុវជន ១៨ឆ្នាំឡើង | |
|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី |
| មណ្ឌលថែទាំរបស់រដ្ឋ | ២១ | ៦៩៤ | ២៩០ | ៣១១ | ១៤៥ |
| មណ្ឌលថែទាំរបស់អង្គការដៃគូ | ១៦០ | ៤,៣៨៧ | ២,២៣៣ | ១,០៧៨ | ៦០១ |
| កន្លែងថែទាំបែបសហគមន៍ | ៨៩ | ១,៩៩៨ | ៩៨៥ | ៥៨៥ | ៣៤៧ |
| **សរុបរួម** | **២៧០** | **៧,០៧៩** | **៣,៥០៨** | **១,៩៧៤** | **១,០៩៣** |

ប្រភព៖ របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួង ស.អ.យ.

៦៣. ផ្អែកតាមទិន្នន័យអធិការកិច្ចកន្លែងថែទាំកុមារ ឆ្នាំ២០២៣ ក្រសួងបានផ្តល់វិញ្ញាបនបត្រទទួលស្គាល់មណ្ឌលថែទាំកុមារសរុបចំនួន ៧៩មណ្ឌល ស្មើនឹង ៤៣.៦% នៃមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាលទាំង ១៦០ ដែលក្នុងនោះមណ្ឌលថែទាំកុមារដែលគ្មានលិខិតអនុញ្ញាតមានចំនួន ៨១មណ្ឌល។

៦៤. ក្រសួង ស.អ.យ. បានបញ្ចប់ការកែសម្រួលឡើងវិញនូវគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ឆ្នាំ២០០៦ ដើម្បីឱ្យស្របតាមស្ថានភាពសេដ្ឋកិច្ច-សង្គម ច្បាប់ និងគោលនយោបាយរបស់កម្ពុជានាពេលបច្ចុប្បន្ន ព្រមទាំងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីការថែទាំជំនួសចំពោះកុមារ។ ក្រសួងក៏បានដាក់ឱ្យអនុវត្ត និងផ្សព្វផ្សាយផែនការសកម្មភាពស្តីពីការធ្វើឱ្យប្រសើរឡើងនូវការថែទាំជំនួសចំពោះកុមារ ឆ្នាំ២០២៣-២០២៧។

៦៥. ក្រសួង ស.អ.យ. បានអនុវត្តសាកល្បងការសមាហរណកម្មកុមារមានពិការភាពកម្រិតស្រាលចំនួន ៣ នាក់ (ស្រី ១នាក់) ចេញពីមណ្ឌលថែទាំទៅរស់នៅជាមួយគ្រួសារវិញ នៅខេត្តតាកែវ រាជធានីភ្នំពេញ និងខេត្តបាត់ដំបង ដោយបានចុះត្រួតពិនិត្យ និងវាយតម្លៃចំនួន ៣លើក។

[10] របាយការណ៍ស្តីពីលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងមហាផ្ទៃ

[11] របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួង ស.អ.យ.

**ខ.ការសុំកូន**

៦៦. ក្រសួង ស.អ.យ. បានរៀបចំ និងដាក់ឱ្យអនុវត្តសៀវភៅណែនាំស្តីពីការអនុវត្តសុំកូនក្នុងប្រទេស ដោយបានសម្របសម្រួល និងផ្តល់បច្ចេកទេសលើការសុំកូនក្នុងប្រទេសជាមួយមន្ទីរ ស.អ.យ. និងអង្គការដៃគូ។ ក្នុងឆ្នាំ២០២៣ តុលាការបានចេញដីការសម្រេចស្តីពីការបង្កើតសុំកូនចំនួន ៤ករណី និងបានបញ្ជូនឈ្មោះ និងសំណុំឯកសារកុមារកំព្រាចំនួន ៦នាក់ ជូនរដ្ឋបាលសុំកូនអន្តរប្រទេស ដើម្បីបន្តនីតិវិធីរៀបចំផែនការអចិន្ត្រៃយ៍តាមរយៈសុំកូនអន្តរប្រទេស។

៦៧. ចំពោះការសុំកូនអន្តរប្រទេស ក្រសួង ស.អ.យ. បានផ្តល់អាជ្ញាបណ្ណឱ្យទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលមានប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជាចំនួន ៣ រួមមាន ទីភ្នាក់ងារ CIAI ទីភ្នាក់ងារ CIFA និងទីភ្នាក់ងារ LOSO។ ទន្ទឹមនេះ រដ្ឋបាលសុំកូនអន្តរប្រទេសក៏ទទួលបាននូវរបាយការណ៍ស្តីពីស្ថានភាពកុមារ ដែលជាកូនសុំសរុបចំនួន ២៣២នាក់ ក្នុងនោះនៅប្រទេសអូទ្រីសចំនួន ២ករណី ប្រទេសអ៊ីតាលីចំនួន ១៩២ករណី ប្រទេសកាណាដាចំនួន ៣៧ករណី និងប្រទេសអេស្ប៉ាញចំនួន ១ករណី។

**គ.កូនតាមឪពុកម្តាយក្នុងពន្ធនាគារ**

៦៨. ក្នុងឆ្នាំ២០២៣ ផ្អែកលើទិន្នន័យការគ្រប់គ្រងករណី មានកុមារតាមម្តាយក្នុងពន្ធនាគារចំនួន ៥៤នាក់ ដែលក្នុងចំណោមនោះ ចំនួន ៦នាក់ ត្រូវបានធ្វើការបង្វែរពីពន្ធនាគារទៅរស់នៅជាមួយគ្រួសារនៅក្នុងសហគមន៍។

## ២.៤. បទដ្ឋាននៃការរស់នៅ

**ក. ទឹកស្អាត និងអនាម័យ**

៦៩. ទឹកស្អាត និងអនាម័យត្រូវបានចាត់ទុកថា មានចំណងទាក់ទងយ៉ាងរឹងមាំជាមួយអាហារូបត្ថម្ភ។ បញ្ហាកង្វះអាហារូបត្ថម្ភ និងភាពក្រិនក្រោះ បានបង្កឡើងដោយសារបញ្ហាអនាម័យនៅមានកម្រិតទាប និងការប្រើប្រាស់ទឹកមិនស្អាត។ នៅទូទាំងប្រទេសកម្ពុជា ក្នុងឆ្នាំ២០២១ មានគ្រួសារប្រមាណ ៨៧% (ទីប្រជុំជន ៩១,៦% ទីជនបទ៨២,៧%) មានលទ្ធភាពប្រើប្រាស់ប្រភពទឹកដែលបានកែលម្អ។[12] សេចក្តីប្រកាសថ្នាក់ជាតិស្តីពីស្តង់ដាគុណភាពទឹកទទួលទាន និងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត ត្រូវបានរៀបចំឡើងដាក់ឱ្យប្រើប្រាស់ ហើយស្ថានីយប្រព្រឹត្តិកម្មទឹកស្អាតមួយចំនួនត្រូវបានកែលម្អ និងបើកឱ្យដំណើរការដើម្បីលើកកម្ពស់គុណភាពទឹកស្អាត និងពង្រីកវិសាលភាពឱ្យបានកាន់តែទូលំទូលាយដល់អ្នកប្រើប្រាស់នៅទូទាំងប្រទេស។

**ខ. បង្គន់អនាម័យ**

៧០. ភាគរយនៃគ្រួសារក្នុងប្រទេសកម្ពុជា ដែលមានលទ្ធភាពប្រើប្រាស់បង្គន់អនាម័យកែលម្អពីឆ្នាំ២០០៤ ដល់ឆ្នាំ២០២១ បានកើនឡើងពី២៥% នៅឆ្នាំ២០០៤ ដល់៥៦% នៅឆ្នាំ២០១៤ ហើយ បន្តកើនឡើងដល់ ៨៨% នៅឆ្នាំ២០២១។[13]

---

[12] របាយការណ៍អង្កេតសេដ្ឋកិច្ចកម្ពុជា ២០២១ ទំព័រ៤៣

[13] របាយការណ៍អង្កេតសេដ្ឋកិច្ចកម្ពុជា ២០២១ ទំព័រ៤៧

### គ. វឌ្ឍនភាពការតភ្ជាប់បណ្ដាញអគ្គិសនីតាមភូមិ និងការតភ្ជាប់ចរន្តអគ្គិសនីតាមខ្នងផ្ទះ

៧១. ការអភិវឌ្ឍបណ្ដាញចែកចាយថាមពលអគ្គិសនីទាំងរដ្ឋ និងឯកជន នៅក្នុងប្រទេសកម្ពុជា តាមរយៈខ្សែបណ្ដាញជាតិបញ្ជូនអគ្គិសនីដល់រាជធានី-ខេត្ត ទាំង២៥ ភូមិដែលមានអគ្គិសនីប្រើប្រាស់ មានការកើនឡើង ពី ២៤,១៦% នៅឆ្នាំ២០០៩ ដល់ ៩៨,៨៧% នៅឆ្នាំ២០២៣។ ចំពោះការតភ្ជាប់ថាមពលអគ្គិសនីតាមខ្នងផ្ទះក៏មានការកើនឡើង ពី ១៨,៧៩% នៅឆ្នាំ២០០៩ ដល់ ៩៤,០២% នៅឆ្នាំ២០២៣ ។






## ៣. ការអភិវឌ្ឍកុមារ[14]

### ៣.១. ការអប់រំ[15]

#### ក. ធនធានមនុស្សផ្នែកអប់រំ

៧២. បុគ្គលិកអប់រំមាន ១២៤ ៥១៧នាក់ (ថយ ០,៨៥%) ស្រី ៥៩ ១៦៥នាក់ ធៀបទៅនឹងឆ្នាំ២០២២ ក្នុងនោះថ្នាក់ជាតិ ៤ ៩៧៨នាក់ (ថយ ១,៩៦%) ស្រី ១ ៦៥៨នាក់ និងថ្នាក់ក្រោមជាតិ ១១៩ ៥៣៩នាក់ (ថយ ០,៨១%) ស្រី ៥៧ ៥០៧នាក់។ បុគ្គលិកមិនបង្រៀន ៣៣ ៣៥៥នាក់ ស្រី ១០ ៦៥៣នាក់ និងបុគ្គលិកបង្រៀន ៨៦ ១៨៤នាក់ ស្រី ៤៦ ៨៥៤នាក់។

#### ខ. សាលាចំណេះទូទៅ និងមត្តេយ្យសិក្សា

៧៣. សាលារៀនគ្រប់កម្រិតសិក្សាបានកើនឡើងគួរឱ្យកត់សម្គាល់គ្រប់គោលដៅ ឆ្លើយតបនឹងគោលនយោបាយបង្កិតសាលារៀនឱ្យជិតលំនៅឋានរបស់ប្រជាជន។ ជាលទ្ធផលក្នុងរយៈពេល ១ឆ្នាំកន្លងមកនេះ វិស័យអប់រំសម្រេចបានសមិទ្ធផលធំៗ តាមរយៈអន្តរាគមន៍មួយចំនួន ដូចជា យុទ្ធនាការប្រមូលកុមារដល់វ័យសិក្សា ការសាងសង់អគារសិក្សា ការផ្ដល់គ្រូបង្រៀន ការផ្ដល់ថវិកាដំណើរការសាលារៀន ការផ្ដល់អាហារូបករណ៍ដល់សិស្សមកពីគ្រួសារក្រីក្រ ដែលបានបង្កឱកាសឱ្យសិស្សានុសិស្ស និងនិស្សិតមានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានការអប់រំនៅគ្រប់កម្រិត។ ឆ្នាំសិក្សា២០២៣-២០២៤ សាលារៀនចំណេះទូទៅ និងមត្តេយ្យសិក្សាមាន ១៩ ៣៨១ កើន ៥១១ ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣ ក្នុងនោះ សាលាមត្តេយ្យសិក្សាគ្រប់រូបភាព ៨ ៨៩១សាលា/កន្លែង (សាធារណៈ ៤ ៦៩៤ សហគមន៍ ៣ ២៩០ និងឯកជន ៩០៧) សាលាបឋមសិក្សា ៨ ២៥២ (ឯកជន ៨៥៤) អនុវិទ្យាល័យ ១ ៣៤១ (ឯកជន ៩៩) និងវិទ្យាល័យ ៨៩៧ (ឯកជន ៣១៦ វិទ្យាល័យធនធាន ៦៧ និងវិទ្យាល័យអប់រំពិសេស ៦)។




---

[14] កុមារត្រូវទទួលបាននូវការសិក្សារៀនសូត្រគ្រប់ប្រភេទ គឺការសិក្សានៅសាលារៀន និងនៅតាមផ្ទះ ឬសហគមន៍ ដូចជាទទួលការអប់រំ និងផ្ដល់ដំបូន្មានល្អៗស្ដីពីការរស់នៅ ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងការថែបំប៉នសុខភាព។ល។

[15] សន្និបាតបូកសរុបលទ្ធផលការងារ អប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០២២-២០២៣ និងទិសដៅឆ្នាំសិក្សា២០២៣-២០២៤

**ឥ. ការអប់រំកុមារតូច**

៧៤. ថ្នាក់មត្តេយ្យសិក្សាគ្រប់រូបភាពចំនួន ១៦ ១៥០ កើនចំនួន ១ ១៩៤ ក្នុងនោះថ្នាក់មត្តេយ្យសិក្សាសាធារណៈចំនួន ៨ ៨២៤ កើនចំនួន ៣៧២ និងថ្នាក់មត្តេយ្យសិក្សាសហគមន៍ចំនួន ៣ ៥៦៦ កើនចំនួន ១០៧ (មត្តេយ្យសិក្សាសហគមន៍មានលក្ខណៈស្តង់ដាចំនួន ១ ៤៣៨ថ្នាក់) ថ្នាក់មត្តេយ្យសិក្សាឯកជនចំនួន ៣ ៧៦០ កើនចំនួន ៧១៥។

ស្ថិតិសាលា ថ្នាក់មត្តេយ្យសិក្សាគ្រប់រូបតាពឆ្នាំសិក្សា២០២២-២០២៣ និងឆ្នាំសិក្សា២០២៣-២០២៤




៧៥. កុមារតូចទទួលបានសេវាអប់រំគ្រប់រូបភាពចំនួន ៤០០ ៩៥៩នាក់ (កើនចំនួន ១៣ ៦៨០នាក់ ស្មើនឹង ៣,៥៣%) ស្រីចំនួន ២០១ ២៩០នាក់ (កើនចំនួន ៧ ២១៨នាក់ ស្មើនឹង ៣,៧១%) ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣។ កុមារអាយុ៣ឆ្នាំមានចំនួន ៥៤ ៤២៣នាក់ (កើនចំនួន ៤ ២៧២នាក់) ស្រីចំនួន ២៨ ៣០១នាក់ (កើនចំនួន ២ ២៤៥នាក់)។ កុមារអាយុ៤ឆ្នាំមានចំនួន ១២៧ ៥៨៦នាក់ (កើនចំនួន ១០ ៧៨៣នាក់) ស្រីចំនួន ៦៤ ៧៥២នាក់ (កើនចំនួន ៥ ៣៧៥នាក់)។ កុមារអាយុ៥ឆ្នាំមានចំនួន ២១៨ ៩៥០នាក់ (កើនចំនួន ៥ ១១៦នាក់) ស្រីចំនួន ១០៨ ២៣៤នាក់ (កើនចំនួន ២ ៦៩៨នាក់)។

៧៦. កុមារអាយុ៣ទៅ៥ឆ្នាំ ដែលបានទទួលសេវាអប់រំនៅមត្តេយ្យសិក្សាសាធារណៈមានចំនួន ២៥៧ ៧២៥ នាក់ ស្មើ ២៤,៨% ធៀបទៅនឹងប្រជាជនមានអាយុ៣ទៅ៥ឆ្នាំ (កើន ១,២%) ស្រីចំនួន ១២៨ ៩៦៤នាក់ (កើន ៣ ០២៧នាក់)។ កុមារអាយុ៣ទៅ៥ឆ្នាំ ដែលបានទទួលសេវាអប់រំនៅមត្តេយ្យសិក្សាឯកជនមានចំនួន ៦១ ៤៦៧នាក់ ស្មើនឹង ៥,៩% ធៀបទៅនឹងប្រជាជនអាយុ៣ទៅ៥ឆ្នាំ (កើន ២១,២%) ស្រីចំនួន ២៩ ៩៧៤នាក់ កើនចំនួន ៦ ៤៨៦នាក់។ កុមារអាយុ៣ទៅ៥ឆ្នាំ ដែលបានទទួលសេវាអប់រំនៅមត្តេយ្យសិក្សាសហគមន៍មានចំនួន ៨១ ៧៦៧នាក់ ស្មើ ៧,៩% (កើន ៥,១%) ធៀបទៅនឹងប្រជាជនអាយុ៣ទៅ៥ឆ្នាំ ស្រីចំនួន ៤២ ២៤៩នាក់។

## ស្ថិតិកុមារមត្តេយ្យសិក្សាតាមកម្មវិធីឆ្នាំសិក្សា២០២៣-២០២៤




ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ២០២៣-២០២៤

៧៧. ក្រសួង អ.យ.ក. បានអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀនសម្រាប់អនុវិស័យការអប់រំកុមារតូចចំនួន ២១៣សាលា ក្នុងចំណោមសាលាមត្តេយ្យសិក្សាសាធារណៈចំនួន ៣៦០សាលា។ ប្រកាសដាក់ឱ្យអនុវត្តស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ។ រៀបចំកម្មវិធីអប់រំមាតាបិតាផ្សារភ្ជាប់នឹងមត្តេយ្យសិក្សាសាធារណៈ និងមត្តេយ្យសិក្សាសហគមន៍មានលក្ខណៈស្តង់ដា។ អនុវត្តកម្មវិធីការអប់រំពហុភាសាសម្រាប់កុមារជនជាតិដើមភាគតិច (ទំពួន គ្រឹង ព្នង កួយ ក្រោល កាវ៉ែត ព្រៅ ចារ៉ាយ និងកាចក់)។

៧៨. ក្រសួង អ.យ.ក. បានអនុវត្តកម្មវិធីការអប់រំបរិយាបន្នសម្រាប់សាលាមត្តេយ្យសិក្សាសាធារណៈចំនួន ៩២១ កុមារមានពិការភាពចំនួន ៧៥៨នាក់ (ស្រីចំនួន ២៦០នាក់) កើនចំនួន ១៩៥នាក់ (ស្រីចំនួន ៤៣នាក់) និងមត្តេយ្យសិក្សាសហគមន៍ចំនួន ៣៨១កន្លែង កុមារមានពិការភាពចំនួន ១៨៥នាក់ (ស្រីចំនួន ៧០នាក់) ថយចំនួន ៤៨នាក់ (ស្រីចំនួន ៣៦នាក់) នៅខេត្តសៀមរាប កំពង់ធំ រតនគិរី ក្រចេះ បាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ព្រៃវែង ព្រះសីហនុ ឧត្តរមានជ័យ និងរាជធានីភ្នំពេញ។ ក្រសួងក៏បានបំប៉នសមត្ថភាពគ្រូមត្តេយ្យសិក្សាស្តីពីការអប់រំបរិយាបន្ន និងផែនការជួយជាបុគ្គលសម្រាប់កុមារដែលមានតម្រូវការពិសេស ព្រមទាំងបានបំប៉នសមត្ថភាពប្រធានក្រុមបច្ចេកទេស ឬប្រធានកម្រងសាលាមត្តេយ្យសិក្សាគោលដៅស្តីពីគំរូល្បែងសិក្សាបរិយាបន្ន និងបានចុះពិនិត្យតាមដានការអនុវត្តគំរូល្បែងបរិយាបន្ន និងសិក្សាស្រាវជ្រាវពីប្រសិទ្ធភាពនៃការប្រើប្រាស់ល្បែងបរិយាបន្ន នៅតាមកម្រងសាលាមត្តេយ្យសិក្សាគោលដៅក្នុងខេត្តព្រៃវែង ក្រចេះ កំពង់ធំ និងកំពង់ចាម សហការជាមួយដៃគូអភិវឌ្ឍ។

៧៩. ក្រសួង អ.យ.ក. បានផ្តល់ប្រពន្ធផ្គត់ផ្គង់ទឹកស្អាត និងបង្គន់អនាម័យ ដល់សាលាមត្តេយ្យសិក្សាសហគមន៍ ផ្តល់ថ្នាំទម្លាក់ដង្កូវព្រូនដល់កុមារ រៀបចំកន្លែងលាងសម្អាតដៃដោយមានទឹក និងសាប៊ូជាប្រចាំសាលាមត្តេយ្យសិក្សាដាច់ដោយឡែក ព្រមទាំងរៀបចំបន្ទប់សុខភាពនៅសាលាមត្តេយ្យសិក្សា ២៩៥សាលា នៅខេត្តកំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ ព្រះសីហនុ ព្រះវិហារ ពោធិ៍សាត់ សៀមរាប និងរាជធានីភ្នំពេញ។

៨០. ការអនុវត្តកម្មវិធី និងសកម្មភាពនានាពាក់ព័ន្ធនឹងការអប់រំកុមារតូចទទួលបានការគាំទ្រ និងការចូលរួមយ៉ាងសកម្មពីអ្នកពាក់ព័ន្ធ។ ប្រការនេះបានបង្ហាញនូវវឌ្ឍនភាពនៃការវិនិយោគលើការអប់រំកុមារតូចបែបពហុវិស័យ ប្រកបដោយភាពប្រទាក់ក្រឡាគ្រប់ទិដ្ឋភាព។

### ឃ. ការអប់រំបឋមសិក្សា

៨១. ឆ្នាំសិក្សា២០២៣-២០២៤ សាលាបឋមសិក្សាសរុបចំនួន ៨ ២៥២ កើនចំនួន ១៩២។ ក្នុងនោះសាលាបឋមសិក្សាសាធារណៈមានចំនួន ៧ ៣៩៨ កើនចំនួន ៦០ ធៀបនឹងឆ្នាំសិក្សា២០២២-២០២៣។ សាលារៀនឯកជនមានចំនួន ៨៥៤ កើនចំនួន ១២៥ ធៀបនឹងឆ្នាំសិក្សា២០២២-២០២៣។ សាលាបឋមសិក្សាមិនគ្រប់កម្រិតចំនួន ៣១៥ កើនចំនួន ៧ ធៀបនឹងឆ្នាំសិក្សា២០២២-២០២៣។ ឆ្នាំសិក្សា២០២៣-២០២៤ សាលាបឋមសិក្សាសាធារណៈមានថ្នាក់រៀនចំនួន ៦៤ ២៨៩ កើនចំនួន ១ ០១៨ និងបន្ទប់រៀនចំនួន ៤៧ ៧៦៦ កើនចំនួន ៧៣៥ ធៀបនឹងឆ្នាំសិក្សា២០២២-២០២៣។

ស្ថិតិសាលាបឋមសិក្សាឆ្នាំសិក្សា ២០២៣-២០២៤




៨២. សិស្សបឋមសិក្សាមានចំនួន ២ ២៦៥ ៧៨៣នាក់ (កើន ៦៥ ៧៦២នាក់ ស្មើ ២,៩៨%) ស្រីចំនួន ១ ០៨៦ ៨៩២នាក់ (កើន ៣០ ៣០៣នាក់ ស្មើ ២,៨៦%) ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣។ សិស្សបឋមសិក្សាសាធារណៈចំនួន ២ ០៩២ ៣១៧នាក់ (កើន ៣៤ ៧០៥នាក់) ស្រីចំនួន ១ ០០២ ៧៦៧នាក់ (កើន ១៥ ៤៧១នាក់) ធៀបនឹងឆ្នាំសិក្សា២០២២-២០២៣។ សិស្សបឋមសិក្សាឯកជនចំនួន ១៧៣ ៤៦៦នាក់ (កើន ៣១ ០៥៧នាក់) ស្រីចំនួន ៨៤ ១២៥នាក់ (កើន ១៤ ៨៣២នាក់) ធៀបនឹងឆ្នាំសិក្សា២០២២-២០២៣។ ការចូលរៀននៅបឋមសិក្សាសម្រេចបានអត្រាពិតនៃការសិក្សា ៩៩,៦% កើន ៣,៩% ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣។

៨៣. ឆ្នាំសិក្សា២០២៣-២០២៤ ភាគរយសិស្សថ្មីថ្នាក់ទី១ ដែលបានឆ្លងកាត់មត្តេយ្យសិក្សាសាធារណៈ ៧៧,៨% កើន ៧,៩% ធៀបនឹងឆ្នាំសិក្សា២០២២-២០២៣។ មាតាបិតាចាប់ផ្ដើមយល់ដឹងអំពីអត្ថប្រយោជន៍ពីការបញ្ជូនកូនទៅសាលារៀនតាំងពីកម្រិតមត្តេយ្យសិក្សា។ ការបញ្ជូនកូនទៅរៀនមត្តេយ្យសិក្សា អាចជួយសម្រាលបន្ទុកមាតាបិតាដែលជាប់រវល់ក្នុងការបំពេញការងារ និងប្រកបរបរចិញ្ចឹមជីវិត។ ទន្ទឹមនឹងនេះ ក្រសួងផ្ដល់សេវាអប់រំកុមារតូច និងមត្តេយ្យសិក្សាកាន់តែប្រសើរ ធ្វើឱ្យអ្នកទទួលសេវាមានទំនុកចិត្ត និងបញ្ជូនកូនទៅរៀន។ លទ្ធផលដែលបានមកពីការអនុវត្តជាក់ស្ដែងរំពឹងថានឹងជួយលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស និងអាចរួមចំណែកកាត់បន្ថយអត្រាត្រួតថ្នាក់ ជាពិសេស នៅថ្នាក់ដំបូងនៃការអប់រំបឋមសិក្សា ដោយកុមារមានមូលដ្ឋានគ្រឹះលើការអាន ការសរសេរ ការគិតលេខ ទំនាក់ទំនង ការលេង

ល្បែងសិក្សា ការងារក្រុម ការបណ្តុះភាពក្លាហាន ការអភិវឌ្ឍរាងកាយ និងបញ្ញា។ល។ និន្នាការនេះស្រប នឹងកំណើន នៃការទទួលបានសេវាអប់រំកុមារតូចនៅមុនពេល និងនៅពេលចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំនេះ ប៉ុន្តែការចូលរៀននៅមត្តេយ្យសិក្សាមានកំណើននៅឆ្នាំសិក្សាជាបន្តបន្ទាប់។

៨៤. ឆ្នាំសិក្សា២០២៣-២០២៤ អត្រាពិតចូលរៀនថ្មីនៅបឋមសិក្សា ៩៤,១% (ប្រុស ៩៣,៧% ស្រី ៩៤,៦%) កើន ៤,៣% (ប្រុសកើន ៤,៦% និងស្រីកើន ៤,១%) ធៀបនឹងឆ្នាំសិក្សា២០២២-២០២៣។ សិស្សថ្នាក់ទី១ ចូលរៀនត្រូវតាមអាយុគួរឱ្យកត់សម្គាល់ ប្រការនេះបញ្ជាក់ថា ការអនុវត្តគោលនយោបាយជាតិគាំពារសង្គម និងការយល់ដឹងរបស់មាតាបិតា ឬអាណាព្យាបាលពីតម្លៃនៃការសិក្សា និងការពង្រាយសាលារៀនទៅគ្រប់ទីកន្លែង។

៨៥. ឆ្នាំសិក្សា២០២៣-២០២៤ អត្រាពិតនៃការសិក្សាបឋមសិក្សា ៩៩,៦% (កើន ៣,៨%) ប្រុស ៩៩,៧% (កើន ៤,២%) ស្រី ៩៩,៦% (កើន ៣,៧%) ធៀបនឹងឆ្នាំសិក្សា២០២២-២០២៣។ អត្រាពិតនៃការសិក្សានៅបឋមសិក្សារក្សាបានកម្រិតខ្ពស់ និងសមត្ថភាពរបស់សិស្សសមស្របតាមកម្រិតថ្នាក់ភាពត្រឹមត្រូវនៃទិន្នន័យដែលប្រមូលបានក្នុងអំឡុងពេលនេះ ចាំបាច់ត្រូវលើកឡើងនូវយុទ្ធសាស្ត្រជាក់លាក់ ដើម្បីផ្តល់សេវាអប់រំឱ្យដល់ក្រុមសិស្សទាំងនេះ។

៨៦. ការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន បានជួយសិស្សឱ្យចុះឈ្មោះចូលរៀន រៀនទៀងទាត់ និងបន្តរៀនរហូតចប់ភូមិសិក្សា ប្រកបដោយគុណភាព។ និន្នាការនេះ ក្រសួងអប់រំ យុវជន និងកីឡាបានផ្តល់ថវិកាលើការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន ដើម្បីលើកកម្ពស់សមធម៌នៃការអប់រំនៅបឋមសិក្សា និងអនុវត្តតាមយុទ្ធសាស្ត្ររួមស្តីពីការផ្ទេរ-ទទួលកម្មវិធីផ្តល់អាហារតាមសាលារៀន ពីកម្មវិធីស្បៀងអាហារពិភពលោក។ ប្រការនេះបញ្ជាក់ថា រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់អនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមផ្នែកជំនួយសង្គម។ ទន្ទឹមនេះ ក្រសួងក៏បានពង្រឹងបន្ថែមលើកម្មវិធីសាលាកុមារមេត្រី ដោយអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បរិស្ថានសិក្សាស្អាត និងមានសុវត្ថិភាព ដោយប្រែក្លាយសាលាកុមារមេត្រីកម្រិតអភិវឌ្ឍន៍ទៅជាសាលាបឋមសិក្សាគំរូ។ ការវិនិយោគយ៉ាងច្រើនត្រូវបានធ្វើឡើង ដើម្បីធានាឱ្យសាលាបឋមសិក្សាមានអគ្គិសនីប្រើប្រាស់ មានបង្គន់អនាម័យ កន្លែងលាងសម្អាតដៃ ការផ្តល់ទឹកស្អាតសម្រាប់ទទួលទាន និងប្រអប់សង្គ្រោះបឋម ដែលជាការរួមចំណែកធ្វើឱ្យសិស្សមានសុខភាពល្អ និងមករៀនទៀងទាត់។ ទន្ទឹមនឹងនេះ ការបង្កើតការិយាល័យសុខភាពសិក្សា នៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត បានរួមចំណែកលើកកម្ពស់សុខភាពសិក្សា នៅតាមសាលារៀនក្នុងពេលដែលសាលារៀនបើកដំណើរការផងដែរ។

៨៧. ក្នុងឆ្នាំសិក្សា២០២៣-២០២៤ តាមរយៈអត្រារំហូរសិស្សបានបង្ហាញថា អត្រាត្រួតថ្នាក់ ៥,៨% (ថយ ០,១%) ប្រុសចំនួន ៧,៣% (ថយ ០,២%) ស្រីចំនួន ៤,១% (ថយ ០,១%) ធៀបនឹងឆ្នាំសិក្សា២០២២-២០២៣។ ចំពោះអត្រាបោះបង់ការសិក្សានៅបឋមសិក្សាចំនួន ៥,៤% (ថយ ២,១%) ប្រុសចំនួន ៥,២% (ថយ ០,៣%) ស្រីចំនួន ៥,៧% (ថយ ៣,៨%) ធៀបនឹងឆ្នាំសិក្សា២០២២-២០២៣។ ជារៀងរាល់ឆ្នាំអត្រាបោះបង់ការសិក្សារបស់សិស្សប្រុសថយតិចជាងសិស្សស្រី។

៨៨. ផ្អែកលើសកលកម្មនៃការអប់រំបឋមសិក្សា ក្រសួង អ.យ.ក. បានវាស់វែងការប្រែប្រួលគុណភាពនៃសេវាអប់រំតាមរយៈអត្រាបញ្ចប់ការសិក្សា អត្រាគង់វង្ស និងអត្រាឆ្លងភូមិសិក្សាទៅមធ្យមសិក្សាបឋមភូមិ។ ឆ្នាំ

សិក្សា២០២៣-២០២៤ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា ៨៩,២% (កើន ២,៤%) ប្រុសចំនួន ៨៦,៣% (កើន ១%) ស្រីចំនួន ៩២,៣% (កើន ២,៩%) ធៀបនឹងឆ្នាំសិក្សា២០២២-២០២៣។ បើទោះបីយ៉ាងណា អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាមានទំនោរកើនឡើងជាបន្តបន្ទាប់។ អត្រាគង់វង្សនៅបឋមសិក្សា សម្រាប់វាស់ភាគរយនៃក្រុមសិស្សដែលបានចុះឈ្មោះចូលរៀននៅថ្នាក់ទី១ នៃបឋមសិក្សាដែលរំពឹងថាពួកគេនឹងរៀនដល់ថ្នាក់ចុងក្រោយ ដោយមិនគិតពីការត្រួតថ្នាក់នៅឆ្នាំសិក្សាណាមួយ។ ឆ្នាំសិក្សា២០២៣-២០២៤ អត្រាគង់វង្សនៅបឋមសិក្សា ៧៧,៥% (កើន ៨%) ប្រុសចំនួន ៧៨,៧% (ថយ ១,៦%) ស្រីចំនួន ៧៦,៣% (កើន ១៥,៩%) ធៀបនឹងឆ្នាំសិក្សា២០២២-២០២៣។ ឆ្នាំសិក្សា២០២៣-២០២៤ អត្រាឆ្លងភូមិសិក្សានៅបឋមសិក្សា ៨៦,៦% (កើន ២,៩%) ប្រុសចំនួន ៨១,៤% (ថេរ) ស្រីចំនួន ៨៩% (កើន ៣,១%) ធៀបនឹងឆ្នាំសិក្សា២០២២-២០២៣។ វិធានការអនុវត្តក្នុងការទប់ស្កាត់ការបោះបង់ការសិក្សា និងការត្រួតថ្នាក់នៅថ្នាក់ដំបូង ឬការចូលរៀនយឺត អាចមានផលប៉ះពាល់លើលទ្ធផលទាំងនេះ ដើម្បីបង្កើនអត្រាបញ្ចប់ការសិក្សា និងពង្រឹងអត្រាគង់វង្សតម្រូវឱ្យកំណត់យុទ្ធសាស្ត្រសមស្របសម្រាប់អនុវត្តឱ្យឆ្លើយតបនឹងការអប់រំជាសកលនៅកម្រិតបឋមសិក្សា។

៨៩. ការពង្រឹងគុណវុឌ្ឍិស្របតាមស្តង់ដាជាតិ (១២+២) ឆ្នាំសិក្សា២០២៣-២០២៤ ភាគរយគ្រូបឋមសិក្សាដែលមានគុណវុឌ្ឍិស្របតាមស្តង់ដាជាតិ (១២+២) ៧៨,១% កើន ០,៣% ធៀបនឹងឆ្នាំសិក្សា២០២២-២០២៣។ សាលាបឋមសិក្សាមានបណ្ណាល័យតាមស្តង់ដា ១ ៧២៥ កើន ១៣៦ ធៀបនឹងឆ្នាំសិក្សា២០២២-២០២៣។ ការអនុវត្តសកម្មភាពនេះ មានភាពប្រសើរឡើង សមត្ថភាពនៃការគ្រប់គ្រងបណ្ណាល័យ ការបណ្តុះបណ្តាលលើការគ្រប់គ្រងបណ្ណាល័យ ដែលមានស្តង់ដាបណ្ណាល័យច្បាស់លាស់។ ម្យ៉ាងវិញទៀតវឌ្ឍនភាពនេះ ត្រូវបានវាស់វែងតាមរយៈការចូលទៅប្រើប្រាស់សម្ភារសិក្សានៅក្នុងបណ្ណាល័យ។

៩០. រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បានយកចិត្តទុកដាក់ក្នុងការវិនិយោគផ្នែកហេដ្ឋារចនាសម្ព័ន្ធសាលារៀន ដើម្បីបង្កើនការចូលរៀន និងការលើកកម្ពស់អាហារូបត្ថម្ភឈានទៅលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។ ទន្ទឹមនេះ ក្រសួង អ.យ.ក. ក៏បានបង្កើនចំនួនសាលារៀនជំនាន់ថ្មី តាមរយៈការផ្តល់នូវវិញ្ញាបនបត្រសាលារៀនជំនាន់ថ្មី ដើម្បីជាសក្ខីភាពបញ្ជាក់ពីឧត្តមភាពនៃការអនុវត្តកន្លងមក។ ក្នុងនោះក្រសួងក៏បានបង្កើនម៉ោងសិក្សា មុខវិជ្ជាសិក្សា និងជួយលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សឱ្យប្រកបដោយគុណភាព ដោយប្រើប្រាស់មូលនិធិសមធម៌។ ពង្រឹងការចូលរួមរបស់សហគមន៍ លើកកម្ពស់សមត្ថភាព គណនេយ្យភាព ស្វ័យភាព តម្លាភាព និងភាពជាម្ចាស់ ពោលគឺបណ្តុះវប្បធម៌ថ្មីនៅតាមសាលារៀន ឈានទៅសម្រេចស្តង់ដាសាលាបឋមសិក្សាគំរូ។ ពង្រឹងវិធីសាស្ត្របង្រៀននិងរៀន និងសម្ភារឧបទេសតាមរយៈការសិក្សាភាសាខ្មែរ(អាន-សរសេរ) និងគណិតវិទ្យាថ្នាក់ដំបូង ដែលមានវិធីសាស្ត្រថ្មីៗ ទំនើបទាន់សម័យ ធ្វើឱ្យកុមារសប្បាយនឹងសកម្មភាពក្នុងការរៀនសូត្រ ក្រោមការជួយគាំទ្រពីសំណាក់ទីប្រឹក្សាគរុកោសល្យ។

៩១. ក្រសួង អ.យ.ក. បានពង្រឹងកម្មវិធីអប់រំបរិយាបន្ន សម្រាប់កុមារជនជាតិដើមភាគតិច និងកុមារមានពិការភាព តាមរយៈកម្មវិធីអប់រំពហុភាសា កម្មវិធីអប់រំកុមារមានពិការភាព និងការពន្លឿនការសិក្សា ដែលបានផ្តល់ឱកាសកាន់តែប្រសើរពីមួយឆ្នាំទៅមួយឆ្នាំ ដល់កុមារជនជាតិដើមភាគតិច កុមារមានពិការភាព និងកុមារលើសអាយុឱ្យទទួលបានការអប់រំប្រកបដោយគុណភាព និងបរិយាបន្ន។

៩២. កម្មវិធីអាហារូបករណ៍ និងអាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍បានជួយលើកកម្ពស់អាហារូបត្ថម្ភ ជួយសិស្សជួបការលំបាកឱ្យរៀនចប់ភូមិសិក្សា និងមានលទ្ធភាពឆ្លងភូមិសិក្សា។

ក្រសួងក៏បានការពង្រឹង និងពង្រីកកម្មវិធីលើកកម្ពស់សុខភាពសិក្សាដែលបង្ហាញពីការយកចិត្តទុកដាក់ក្នុងការលើកកម្ពស់សុខភាពអ្នកសិក្សា និងបុគ្គលិកអប់រំគ្រប់ជ្រុងជ្រោយ ដើម្បីបណ្តុះទម្លាប់ហូបស្អាត ផឹកស្អាត រស់នៅស្អាត។

៩៣. បន្តការបណ្តុះបណ្តាល និងរិត្រឹតការគ្រូបង្រៀន ដើម្បីជួយអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនជាប្រចាំឆ្លើយតបទៅនឹងបរិបទបរិវត្តកម្មអប់រំ។ អភិវឌ្ឍកម្មវិធីសិក្សា និងការសិក្សាស្រាវជ្រាវឆ្លើយតបទៅនឹងសង្គមឌីជីថល។ បណ្តុះទម្លាប់អាន ដជយផ្សារភ្ជាប់ការរៀន និងបង្រៀនទៅនឹងបណ្ណាល័យ ការសិក្សាស្រាវជ្រាវ និងការតែងនិពន្ធ។ បន្តយកចិត្តទុកដាក់ចំពោះការរៀន និងបង្រៀនពីចម្ងាយ ដើម្បីលើកកម្ពស់ការសិក្សា និងស្វ័យសិក្សារបស់សិស្ស បង្កើនសមត្ថភាពគ្រូបង្រៀន តាមគ្រប់មធ្យោបាយ គ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ ពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីកែលម្អបញ្ហាដែលកើតមានតាមគ្រឹះស្ថានសិក្សាទាន់ពេលវេលា និងឆ្លុះបញ្ចាំងលទ្ធផលសិក្សារបស់សិស្សសម្រាប់ជាមូលដ្ឋានក្នុងការអភិវឌ្ឍគោលនយោបាយអប់រំ។

៩៤. ក្រសួងបានចេញប្រកាសបើកគ្រឹះស្ថានបឋមសិក្សាសាធារណៈ ២០សាលា ប្តូរឈ្មោះ ៦សាលា និងសាលាបឋមសិក្សាឯកជនអនុវត្តកម្មវិធីជាតិ ៣៧សាលា និងកម្មវិធីអន្តរជាតិ ៤សាលា។ បន្តអភិវឌ្ឍសមត្ថភាព លើកទឹកចិត្ត និងការតែងតាំងបុគ្គលិកអប់រំ ព្រមទាំងបានពង្រាយគ្រូបង្រៀនបឋមសិក្សាពីសាលាលើសទៅសាលាខ្វះគ្រូ។ ពង្រាយគ្រូបង្រៀនបឋមសិក្សាចេញថ្មីបានបណ្តុះបណ្តាលតាមរូបមន្ត (១២+៤) ចំនួន ២៩៤នាក់ ស្រីចំនួន ២១២នាក់ និងបណ្តុះបណ្តាលតាមរូបមន្ត (១២+២) ចំនួន ១ ២១០នាក់ ស្រីចំនួន ៨៧៥នាក់ ទៅសាលារៀនដែលមានតម្រូវការគ្រូ។ ក្រសួងបានលើកទឹកចិត្ត និងជួយជំរុញបុគ្គលិកអប់រំឱ្យបំពេញការងារប្រកបដោយមនសិការវិជ្ជាជីវៈ។

### ង. ការអប់រំមធ្យមសិក្សា

៩៥. សិស្សមធ្យមសិក្សាបឋមភូមិមាន ៧១១ ១១៣នាក់ (កើន ១៦ ៩៥២នាក់ ស្មើ ២.៤៤%) ស្រី ៣៧៨ ២៤៧នាក់ (កើន ១៥ ៥៩២នាក់ ស្មើ ៤,៤៩%) ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣។ ការចូលរៀននៅមធ្យមសិក្សាបឋមភូមិសម្រេចបានអត្រារួមនៃការសិក្សា ៦៥,៥% (កើន ០,៧%) ស្រី ៦៩,៩% (កើន ០,៥%) ធៀបទៅនឹងឆ្នាំសិក្សា ២០២២-២០២៣។

៩៦. សិស្សមធ្យមសិក្សាទុតិយភូមិមាន ៤៣០ ៧៩២នាក់ (កើន ២៩ ១៨៧នាក់ ស្មើ ៧,២៦%) ស្រី ២៣៧ ២៩៨នាក់ (កើន ១៨ ៧៨២នាក់ ស្មើ ៨,៥៦%) ធៀបទៅនឹងឆ្នាំសិក្សា ២០២២-២០២៣។ ការចូលរៀននៅមធ្យមសិក្សាទុតិយភូមិសម្រេចបានអត្រារួមនៃការសិក្សា ៤៦,៧% (កើន ២,៥%) ស្រី ៥២,៨% (កើន ៣,៦%) ធៀបទៅនឹងឆ្នាំសិក្សា ២០២២-២០២៣។

៩៧. សិស្សមធ្យមសិក្សាចំណេះទូទៅនិងបច្ចេកទេសមាន ៣ ៥១២នាក់ (កើន ២៥៣នាក់ ស្មើ ៧,៧៦%) ស្រី ១ ២៤៦នាក់ (កើន ៨៦នាក់ ស្មើ ៧,៤១%) ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣។ ជំនាញបណ្តុះបណ្តាល មានជំនាញអគ្គិសនី ១ ២៧២នាក់ ស្រី ១៤៦នាក់ ជំនាញអេឡិចត្រូនិក ៤៧៤នាក់ ស្រី ១០៥នាក់ ជំនាញបសុវប្បកម្ម ៣២៧នាក់ ស្រី ១៨២នាក់ ជំនាញក្សេត្រសាស្ត្រ ៥២៥នាក់ ស្រី ២៧៣នាក់ ជំនាញមេកានិក ១៦១នាក់ ស្រី ២០នាក់ ជំនាញការិយាល័យជួរមុខ ៦៩នាក់ ស្រី ៤៥នាក់ ជំនាញកុំព្យូទ័រ ២៨៨នាក់ ស្រី ១៧៦នាក់ ជំនាញគណនេយ្យ ១៥៥នាក់ ស្រី ១២១នាក់ ជំនាញកែច្នៃអាហារ ១៥២នាក់ ស្រី ១៣៧នាក់ ជំនាញឌីជីថលមេខៀឌីហ្សាញ ៦៧នាក់ ស្រី ២៧នាក់។

៩៨. ឆ្នាំសិក្សា ២០២៣-២០២៤ គ្រឹះស្ថានមធ្យមសិក្សាសាធារណៈមាន ១ ៨២៣ កើន៤ ក្នុងនោះអនុវិទ្យាល័យ ១ ២៤២ ថយ ៦ និងវិទ្យាល័យ ៥៨១ កើន ១០ (វិទ្យាល័យធនធាន៦៧ និងវិទ្យាល័យអប់រំពិសេស ៦) វិទ្យាល័យដែលមានកម្រិតថ្នាក់ទី៧ ដល់ថ្នាក់ទី១២ មាន ៥៤៦ កើន ១០ និងកម្រិតថ្នាក់ទី១០ ដល់ថ្នាក់ទី១២ មាន ៣៥ ថេរ។

៩៩. គ្រឹះស្ថានមធ្យមសិក្សាឯកជនមាន ៤១៥ កើន ៧៨ ក្នុងនោះអនុវិទ្យាល័យ ៩៩ កើន ៧ និងវិទ្យាល័យ ៣១៦ កើន៧១។ វិទ្យាល័យដែលមានកម្រិតថ្នាក់ទី៧ ដល់ថ្នាក់ទី១២ មាន ៣១១ កើន ៧២ និងកម្រិតថ្នាក់ទី១០ ដល់ថ្នាក់ទី១២ មាន៥ ថយ ១។

១០០. អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ ៦៥,៥% (កើន ០,៧%) ស្រី ៦៩,៩% (កើន ០,៥%) ក្នុងនោះគ្រឹះស្ថានសិក្សាសាធារណៈ ៦១% ស្រី ៦៥,២% និងឯកជន ៤,៥% ស្រី ៤,៧%។ អត្រាឆ្លងភូមិសិក្សានៅមធ្យមសិក្សាបឋមភូមិ ៨៦,៦% (កើន ២,៩%) ស្រី ៨៩,០% (កើន ៣,១%)។ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ៦០,៩៧% (កើន ១,២៧%) ស្រី ៦៦,៣៧% (កើន ១,៨៧%) និងប្រុស ៥៥,៦៩% (កើន ០,៧៩%)។ អត្រាគង់វង្សនៅមធ្យមសិក្សាបឋមភូមិ ៥៣,៥៥% (កើន ៩,២៥%) ស្រី ៥៥,១០% (កើន ១៥,៥%) និងប្រុស ៥១,៧៦% (កើន ២,១៨%)។

### ស្ថិតិមធ្យមសិក្សាចំណេះទូទៅសាធារណៈ ឆ្នាំសិក្សា ២០២២-២០២៣ និង២០២៣-២០២៤

| បរិយាយ | ឆ្នាំសិក្សា | | កើន/ថយ (+/-) |
|---|---|---|---|
| | ២០២២-២០២៣ | ២០២៣-២០២៤ | |
| សាលារៀន | ១,៨១៩ | ១,៨២៣ | +៤ |
| បន្ទប់រៀន | ២១,៣២៥ | ២១,៥៦៤ | +២៣៩ |
| ថ្នាក់រៀន | ២២,៦៦០ | ២៣,៨៤២ | +១,១៨២ |
| បុគ្គលិកសរុប | ៥២,១០៧ | ៥២,៩១៤ | +៨០៧ |
| បុគ្គលិកស្រី | ២១,០០៨ | ២១,៥៥៩ | +៥៥១ |
| បុគ្គលិកមិនបង្រៀនសរុប | ៧,៨៦៩ | ៨,០០៧ | +១៣៨ |
| បុគ្គលិកមិនបង្រៀនស្រី | ២,១៧១ | ២,២៣៧ | +៦៦ |
| បុគ្គលិកបង្រៀនសរុប | ៤៤,២៣៨ | ៤៤,៩០៧ | +៦៦៩ |
| បុគ្គលិកបង្រៀនស្រី | ១៨,៨៣៧ | ១៩,៣២២ | +៤៨៥ |
| សិស្សសរុប | ១,០២៩,៩៩៣ | ១,០៥៨,១១២ | +២៨,១១៩ |
| សិស្សស្រី | ៥៤៧,៥២៥ | ៥៦៤,៤៤២ | +១៦,៩១៧ |

ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

១០១. អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ៤៦,៧% (កើន ២,៥%) ស្រី ៥២,៨% (កើន ៣,៦%) ក្នុងនោះគ្រឹះស្ថានសិក្សាសាធារណៈ ៤២,៩% ស្រី ៤៨,៧% និងឯកជន ៣,៨% ស្រី ៤,១%។ អត្រាគង់វង្សនៅមធ្យមសិក្សាទុតិយភូមិ ៣៤,១២% (កើន ៩,០២%) ស្រី ៣៧,០៧% (កើន ១៣,៧៧%) និងប្រុស ៣០,៨៧% (កើន ៣,៩៧%)។

១០២. មធ្យមសិក្សាបឋមភូមិ៖ អត្រាឡើងថ្នាក់កើន ២,៣% ស្រីកើន ៣% អត្រាត្រួតថ្នាក់កើន ០,៥% ស្រីកើន ០,៣% និងអត្រាបោះបង់ការសិក្សាថយ ២,៨% ស្រីថយ ៣,៤% និងអត្រាឆ្លងភូមិសិក្សាបឋមភូមិកើន ២,៩% ស្រីកើន ៣,១%។

១០៣. មធ្យមសិក្សាទុតិយភូមិ៖ អត្រាឡើងថ្នាក់កើន ១,២% ស្រីកើន ២,១% អត្រាត្រួតថ្នាក់កើន ០,៤% ស្រីកើន ០,៣% និងអត្រាបោះបង់ការសិក្សាថយ ១,៦% ស្រីថយ ២,៤% និងអត្រាឆ្លងភូមិសិក្សាមធ្យមសិក្សាទុតិយភូមិ កើន ២,៧% ស្រីកើន ៣,១% (តារាងទី៥)។

### អត្រាលំហូរសិស្សនៅមធ្យមសិក្សារវាងឆ្នាំសិក្សា ២០២១-២០២២ និង ២០២២-២០២៣

| បរិយាយ | ឆ្នាំសិក្សា | | កើន-ថយ | ឆ្នាំសិក្សា | | កើន-ថយ |
|---|---|---|---|---|---|---|
| | ២០២១-២២ | ២០២២-២៣ | (+/-) | ២០២១-២២ | ២០២២-២៣ | (+/-) |
| | មធ្យមសិក្សាបឋមភូមិ | | | | | |
| | សរុប | | | ស្រី | | |
| អត្រាឡើងថ្នាក់ | ៧៩.៨ | ៨២.១ | +២.៣ | ៨១.៦ | ៨៤.៦ | +៣.០ |
| អត្រាត្រួតថ្នាក់ | ២.០ | ២.៥ | +០.៥ | ១.២ | ១.៥ | +០.៣ |
| អត្រាបោះបង់ការសិក្សា | ១៨.២ | ១៥.៤ | -២.៨ | ១៧.២ | ១៣.៨ | -៣.៤ |
| អត្រាឆ្លងភូមិសិក្សា | ៨៣.៧ | ៨៦.៦ | +២.៩ | ៨៥.៩ | ៨៩.០ | +៣.១ |
| | មធ្យមសិក្សាទុតិយភូមិ | | | | | |
| | សរុប | | | ស្រី | | |
| អត្រាឡើងថ្នាក់ | ៨៣.៤ | ៨៤.៦ | +១.២ | ៨៥.១ | ៨៧.២ | +២.១ |
| អត្រាត្រួតថ្នាក់ | ១.៣ | ១.៧ | +០.៤ | ០.៩ | ១.២ | +០.៣ |
| អត្រាបោះបង់ការសិក្សា | ១៥.៣ | ១៣.៧ | -១.៦ | ១៣.៩ | ១១.៥ | -២.៤ |
| អត្រាឆ្លងភូមិសិក្សា | ៧៧.៦ | ៨០.៣ | +២.៧ | ៨០.៦ | ៨៣.៧ | +៣.១ |

ប្រភព៖ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

១០៤. លទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ក្នុងឆ្នាំសិក្សា ២០២២-២០២៣ នេះបេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ១៦៥ ១៣៨នាក់ ស្មើ ៩៤,៥៤% ស្រី ៩១ ២២៧នាក់ ស្មើ ៩៦,៩០% ដោយមានកំណត់និទ្ទេសល្អ ល្អបង្គួរ និងមធ្យម។ បើធៀបទៅនឹងឆ្នាំ២០២២ បេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ១៥៣ ៦៤៩នាក់ ស្រី ៨៤ ២៨១នាក់ ស្មើ ៩៤,៧៥% ស្រី ៩៧,០៥%។

១០៥. លទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ក្នុងឆ្នាំសិក្សា ២០២២-២០២៣ នេះ បេក្ខជនមកប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ១៣៥ ០៧២នាក់ ស្រី ៧២ ៣៤៦នាក់ បេក្ខជនប្រឡងជាប់ ៩៨ ៤៦០នាក់ ស្មើ ៧២,៨៩% ស្រី ៥៦ ៤៩២នាក់ ស្មើ ៧៨,០៩% ក្នុងនោះបេក្ខជននិទ្ទេស A ១ ៦៧៣នាក់ស្រី ៩៤៧នាក់ និទ្ទេសB ៦ ៩៦៤នាក់ ស្រី ៤ ១៦៦នាក់ និទ្ទេស C ១៨ ៣០៨នាក់ ស្រី ១១ ៥១៩នាក់ និទ្ទេស D ៣៤ ២៤៦នាក់ ស្រី ២០ ៣២១នាក់ និងនិទ្ទេស E ៣៧ ២៦៩នាក់ ស្រី ១៩ ៥៣៩នាក់ (តារាងទី៧)។

### ការប្រៀបធៀបលទ្ធផលប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និង
### សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំណេះទូទៅនិងបំពេញវិជ្ជា រវាងឆ្នាំសិក្សា២០២១-២០២២ និង២០២២-២០២៣

| ភូមិសិក្សា | ឆ្នាំសិក្សា | | ឆ្នាំសិក្សា | | កើន-ថយ,(+/-) | | | |
|---|---|---|---|---|---|---|---|---|
| | ២០២១-២២ | | ២០២២-២៣ | | | | | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ភាគរយ | ស្រី | ភាគរយ |
| ម.បឋមភូមិ | ១៥៣,៦៤៩ | ៨៤,២៨១ | ១៦៥,១៣៨ | ៩១,២២៧ | +១១,៤៨៩ | +៧,៤៧ | +៦,៩៤៦ | +៨,២៤ |
| ម.ទុតិយភូមិ | ៩០,៩៥០ | ៥២,៥១២ | ៩៨,៤៦០ | ៥៦,៤៩២ | +៧,៥១០ | +៨,២៥ | +៣,៩៨០ | +៧,៥៧ |

១០៦. លទ្ធផលសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ២០២២-២០២៣ ធៀបនឹងឆ្នាំសិក្សា២០២១-២០២២ ថយ ០,២១% ស្រីថយ ០,១៥% រីឯលទ្ធផលសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ២០២២-២០២៣ ធៀបនឹងឆ្នាំ២០២១-២០២២ កើន ០,៥៦% ស្រី កើន ០,៥៧%។

### ភាគរយលទ្ធផលសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ
### ឆ្នាំសិក្សា ២០២១-២០២២ និង២០២២-២០២៣




ប្រភព៖ នាយកដ្ឋានកិច្ចការប្រឡង

១០៧. លទ្ធផលសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ២០២២-២០២៣ ធៀបនឹងឆ្នាំ២០២១-២០២២ កើន ០,៥៦% ស្រីកើន ០,៥៧% ក្នុងនោះថ្នាក់វិទ្យាសាស្រ្តថយ ២,១១% ស្រីថយ ២,៨២% និងថ្នាក់វិទ្យាសាស្រ្តសង្គមកើន ១,៥១% ស្រីកើន ១,៨៤%។




## ច. ការអប់រំក្រៅប្រព័ន្ធ

១០៨. តាមការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០២១ បង្ហាញថា អត្រាអក្ខរកម្មជនពេញវ័យអាយុ ១៥ឆ្នាំឡើងមាន ៨៤,៧% សម្រាប់ជនពេញវ័យទាំងពីរភេទ ក្នុងនោះអត្រាអក្ខរកម្មសម្រាប់ស្ត្រីមាន ៨០,៣% និងបុរស ៨៩,៥% នៅឆ្នាំ២០១៩/២០ សម្រាប់ជនពេញវ័យទាំងពីរភេទមាន ៨១,៩% ស្រី ៧៧,១%។ អត្រាអក្ខរជនជាស្ត្រីមានការកើនឡើង ដោយសារការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលលើការលើកកម្ពស់សិទ្ធិនារីក្នុងវិស័យអប់រំ។

អត្រាអក្ខរកម្មជនពេញវ័យអាយុ ១៥ឆ្នាំឡើង




ប្រភព៖ របាយការណ៍អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០២១ (វិទ្យាស្ថានជាតិស្ថិតិ ធ្នូ ២០២២)

១០៩. អ្នកសិក្សាបានទទួលការអប់រំគ្រប់កម្មវិធី ៤០ ៨៤៤នាក់ (ថយ ៩ ៤១១នាក់ ស្មើ ១៨,៧២%) ស្រី ២២ ៣៨២នាក់ (ថយ ៤ ២៩៥នាក់ ស្មើ ១៦,១០%) ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣។ អ្នកចូលរៀនកម្មវិធីអក្ខរកម្មអប់រំក្រៅប្រព័ន្ធ ១៦ ៥៨៧នាក់ ស្រី ១០ ៣០៦នាក់ អ្នកសិក្សាជំនាញមុខរបរងាយៗ ១១ ២០៣នាក់ ស្រី ៧ ២២៥នាក់ អ្នកសិក្សាកម្មវិធីសមមូលបឋមសិក្សានិងមធ្យមសិក្សា ៨ ៣១០នាក់ ស្រី ៣ ៣៣១នាក់ និងអ្នកសិក្សាបំពេញវិជ្ជាបឋមភូមិ និងទុតិយភូមិ ៤ ៧៤៤នាក់ ស្រី ១ ៥២០នាក់។

## ៣.២. ការបណ្តុះបណ្តាលវិជ្ជាជីវៈ

១១០. យោងតាមការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជារបស់ក្រសួងផែនការ (ឆ្នាំ២០១២-២០២១) បានបង្ហាញថា ភាគរយកុមារដែលបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច បានថយចុះគួរឱ្យកត់សម្គាល់ពីចំនួន២៤% ក្នុងឆ្នាំ២០១២ មកត្រឹម១៧% ក្នុងឆ្នាំ២០២១។ ក្នុងឆ្នាំ២០២៣ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានពង្រីករបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព តាមរបបភាគទានដោយស្ម័គ្រចិត្តជូនអ្នកនៅក្នុងបន្ទុកសមាជិក ប.ស.ស. ក្នុងនោះបានចុះបញ្ជិកាជូនកុមារ ដែលជាកូនស្ថិតក្នុងបន្ទុកសមាជិក ប.ស.ស. បានចំនួនសរុប ៧៤៨នាក់ (ស្រី ៣៥៧នាក់) ក្នុងនោះរួមមាន៖

- បុគ្គលស្វ័យនិយោជន៍មានចំនួន ៥០នាក់ (ស្រី ២៦នាក់)
- កម្មករនិយោជិតមានចំនួន ៦១នាក់ (ស្រី ២៣នាក់)
- មន្ត្រីសាធារណៈមានចំនួន ៦៣៧នាក់ (ស្រី ៣០៨នាក់)។

១១១. ក្រសួង ក.ប. បានដាក់ឱ្យអនុវត្តកម្មវិធីបណ្តុះបណ្តាល និងជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ដល់យុវជនចំនួន ១,៥លាននាក់ ក្នុងនោះយុវជនមកពីគ្រួសារក្រីក្រ និងងាយរងហានិភ័យអាចចូលរៀនដោយមិនបង់ថ្លៃ និងទទួលបានប្រាក់ឧបត្ថម្ភចំនួន ២៨ម៉ឺនរៀលក្នុងមួយខែ។ ដោយឡែក យុវជននានារួមទាំងបុគ្គល នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ អាចចូលរៀនកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមិនបង់ថ្លៃនេះផងដែរ ដើម្បីចាប់យកជំនាញមួយពិតប្រាកដមុនចូលទីផ្សារការងារ ឬផ្លាស់ប្តូរជំនាញ ឬបង្កើនជំនាញរបស់ខ្លួន។ គិតត្រឹមខែមីនា ឆ្នាំ២០២៤ មានយុវជន (ក្រោម១៨ឆ្នាំ) ចំនួន ៣៤ ២៦៧នាក់ (ស្រី៩ ៦០៦នាក់) កំពុងទទួលបានការបណ្តុះបណ្តាល ក្នុងនោះចំនួន ១៦ ២៦៧នាក់ (ស្រី៥ ២២៣នាក់) កំពុងទទួលបានការបណ្តុះបណ្តាលសញ្ញាបត្របច្ចេកទេសវិជ្ជាជីវៈកម្រិត១ (C1)។

## ៤. ការការពារកុមារ[16]

### ៤.១.ការបង្ការ ទប់ស្កាត់

#### ក. ការលើកកម្ពស់កិច្ចការពារ

១១២. ក្រសួងព័ត៌មានបានផលិត និងផ្សព្វផ្សាយមាតិកាវិទ្យុ ទូរទស្សន៍ ទស្សនាវដ្ដី និងព័ត៌មានបោះពុម្ពពាក់ព័ន្ធទៅនឹងការបង្ការ និងការទប់ស្កាត់ រួមមាន៖ មាតិកាទម្រង់ជាព័ត៌មានរួមមាន ១១៥អត្ថបទព័ត៌មាន មាតិកាជាភាសាបារាំងមានចំនួន ១១មាតិកា និងមាតិកាជាភាសាអង់គ្លេសមានចំនួន ២៧មាតិកា។ មាតិកាទម្រង់ជាបទយកការណ៍ និងបទអត្ថាធិប្បាយមានចំនួន ១១មាតិកា។ មាតិកាគ្រប់ទម្រង់ត្រូវបានផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយជាតិរួមមានទូរទស្សន៍វិទ្យុAMវិទ្យុFM ទីភ្នាក់ងារសារព័ត៌មានកម្ពុជា ទូរទស្សន៍ថ្នាលឌីជីថល MoInfoTV និងបណ្ដាញសង្គមថ្នាក់ជាតិ និងរាជធានី ខេត្ត រួមមាន Facebook, Telegram គេហទំព័រ និងTik Tok Instagram ព្រមទាំងមធ្យោបាយផ្សព្វផ្សាយបោះពុម្ព រួមមាន៖ ព្រឹត្តិប័ត្រប្រចាំថ្ងៃ ទស្សនាវដ្ដីកម្ពុជាប្រចាំខែ និងកាសែតអេឡិចត្រូនិចប្រចាំថ្ងៃ។

១១៣. ក្រុមការងារបច្ចេកទេសគាំពារ និងអភិវឌ្ឍន៍កុមារតូចក្នុងវិស័យព័ត៌មានបានបើកសិក្ខាសាលាប្រមូលផ្ដុំចំនួន១វគ្គនៅខេត្តប៉ៃលិន ក្រោមប្រធានបទ "ការផលិតកម្មវិធីផ្សាយពាក់ព័ន្ធនឹងការគាំពារ និងអភិវឌ្ឍន៍កុមារតូច"។ សិក្ខាកាមជាអ្នកសារព័ត៌មានថ្នាក់ក្រោមជាតិនៅខេត្តប៉ៃលិន និងកំពង់ឆ្នាំងដែលចូលរួមសរុប ៦០រូប ក្នុងនោះស្ត្រីចំនួន២១រូប។

១១៤. ក្រសួងកិច្ចការនារី បានចុះគាំទ្រការផ្សព្វផ្សាយនៅសហគមន៍លើឧបករណ៍សកល (កម្រិតទី១) ស្ដីពី "ការចិញ្ចឹមកូនបែបវិជ្ជមាន" នៅខេត្តកណ្ដាល រតនគិរី កំពត បាត់ដំបង ព្រះសីហនុ សៀមរាប ព្រៃវែង ក្រចេះ និងរាជធានីភ្នំពេញ ដើម្បីគាំទ្រអ្នកស្ម័គ្រចិត្តភូមិក្នុងការអប់រំផ្សព្វផ្សាយ ពិនិត្យលើដំណើរការសម្របសម្រួល និងបំពេញបន្ថែមនូវចំណុចខ្វះខាត ដែលមានការចូលរួមពីក្រុមការងារបច្ចេកទេសក្រសួង តំណាងអង្គការយូនីសេហ្វ (UNICEF) មន្ត្រីការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមស្រុក អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ សរុបចំនួន ៣៩២០នាក់ (ស្រី ២៧៥៩នាក់)។

១១៥. បើកវគ្គបណ្ដុះបណ្ដាលស្ដីពីសុខុមាលភាពសង្គម ដល់មន្ត្រីក្រសួង និងមន្ទីរកិច្ចការនារីទាំង ២៥រាជធានីខេត្ត ដែលមានអ្នកចូលរួមចំនួន ១៦៧នាក់ (ស្រី ១៤១នាក់) នៅខេត្តតាកែវ បាត់ដំបង និងមណ្ឌលគិរី ក្នុងគោលបំណងពង្រឹងចំណេះដឹងដល់អ្នកចូលរួម អំពីសិទ្ធិទទួលបានការគ្រប់គ្រងលើអចលនទ្រព្យ ការចុះបញ្ជីអត្រានុកូលដ្ឋាន និងសិល្បៈក្នុងការរស់នៅប្រកបដោយសមធម៌យេនឌ័រ។

១១៥. បើកវគ្គបណ្ដុះបណ្ដាលស្ដីពី "សុវត្ថិភាពកុមារលើប្រព័ន្ធអនឡាញ" និងឧបករណ៍ផ្សព្វផ្សាយ (កម្រិតទី១) ស្ដីពី "ការចិញ្ចឹមកូនបែបវិជ្ជមាន" ដល់មន្ត្រីក្រសួង និងមន្ទីរកិច្ចការនារី ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម មេឃុំ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក.) មេ

[16] ឪពុកម្ដាយត្រូវមើលថែ និងប្រៀនប្រដៅកុមារ ហើយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវចាត់វិធានការជួយកុមារឱ្យរួចផុតពីគ្រោះមហន្តរាយនានា ដូចជា គ្រឿងញៀន ល្បែងអបាយមុខ អំពើអនាចារ ការរើសអើង ការសេពកាមគុណលើកុមារ ការធ្វើអាជីវកម្មលើកុមារ ការលក់កុមារ និងអំពើផ្សេងៗទៀត ដែលប៉ះពាល់ដល់ឧត្ដមប្រយោជន៍កុមារ។ ឪពុកម្ដាយ ត្រូវការពារកូនរបស់ខ្លួន និងចូលរួមចំណែកការពារកុមារផ្សេងៗទៀត ពីការរំលោភបំពានទាំងឡាយដែលបង្កឡើងដោយជនខិលខូច។ អាជ្ញាធរមានសមត្ថកិច្ច ក៏មានភារកិច្ចការពារកុមារពីការរំលោភបំពាននានា ដែលប្រព្រឹត្តដោយឪពុកម្ដាយ អាណាព្យាបាល ឬអ្នកមានអំណាចផ្សេងៗទៀតមកលើកុមារ

ភូមិ សមាជិកភូមិ និងអ្នកស្ម័គ្រចិត្តភូមិក្នុងខេត្ត រតនគិរី ព្រៃវែង ក្រចេះ សៀមរាប បាត់ដំបង កំពត ព្រះសីហនុ និងខេត្តកណ្តាលសរុបចំនួន ២៤៩នាក់ (ស្រី ២០០ នាក់) នៅរាជធានីភ្នំពេញ បន្ទាយមានជ័យ និងរតនគិរី ដើម្បីបង្កើនការយល់ដឹងដល់មន្ត្រីបង្គោលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្សព្វផ្សាយបន្តនៅតាមឃុំគោលដៅ និងចំណេះដឹងទាក់ទងនឹងការចិញ្ចឹមកូនបែបវិជ្ជមាន និងសុវត្ថិភាពកុមារលើប្រព័ន្ធអនឡាញ មានលទ្ធភាពពេញលេញ សម្រាប់គាំទ្រដល់ដំណើរការអនុវត្តគម្រោងស្តីពីការចិញ្ចឹមកូនបែបវិជ្ជមានដោយមានសមាសភាពចូលរួម។

១១៧. មន្ទីរកិច្ចការនារីទាំង ២៥រាជធានី ខេត្ត បានចុះបើកវេទិកាផ្សព្វផ្សាយស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន ការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ និងសុវត្ថិភាពកុមារនៅលើប្រព័ន្ធអនឡាញដល់ប្រជាពលរដ្ឋនៅតាមសហគមន៍សរុបចំនួន ១៩ ២៧៧នាក់ (ស្រី ១២ ៥៦៤នាក់) ដើម្បីផ្តល់ចំណេះដឹងបន្ថែមអំពីកាតព្វកិច្ច និងការផ្លាស់ប្តូរឥរិយាបថរបស់ឪពុកម្តាយ ឬអាណាព្យាបាលក្នុងការចិញ្ចឹមកូន និងការអប់រំសីលធម៌ ដើម្បីការរស់នៅមានភាពថ្លៃថ្នូរក្នុងសង្គម។

១១៨. មន្ទីរទាំង ២៥ រាជធានី ខេត្ត ចុះផ្សព្វផ្សាយសហគមន៍ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ការទប់ស្កាត់អំពើជួញដូរមនុស្សការទប់ស្កាត់ការរំលោភបំពាន់ផ្លូវភេទលើស្ត្រី និងក្មេងស្រី ផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន ច្បាប់ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) ការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍វ័យកុមារភាព និងការមានផ្ទៃពោះវ័យជំទង់ ជូនដល់ក្រុមប្រឹក្សាឃុំ មេភូមិ ប្រជាការពារភូមិ ប្រជាពលរដ្ឋ និងសិស្សានុសិស្ស សរុបចំនួន ៩ ៥៨៤នាក់ (ស្រី ៦៥៩នាក់)។

១១៩. រៀបចំវេទិកាអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋចំនួន ០៨លើក ស្តីពី "ការបង្ការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើស្ត្រី និងក្មេងស្រី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការលើកកម្ពស់ការចូលរួមរបស់អ្នកម្តាយដើម្បីទប់ស្កាត់ការប្រើប្រាស់ និងចែកចាយគ្រឿងញៀន ការទប់ស្កាត់អំពើជួញដូរស្ត្រីនិងកុមារ និងរាល់ទម្រង់នៃការកេងប្រវ័ញ្ច និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន នៅខេត្តមណ្ឌលគិរី ប៉ៃលិន បាត់ដំបង ព្រះសីហនុ កំពង់ធំ និងខេត្តព្រះវិហារ ក្នុងគោលបំណងឱ្យប្រជាពលរដ្ឋបានយល់ដឹងពីវិធីទប់កំហឹង ផលប្រយោជន៍នៃដំណោះស្រាយដោយអហិង្សា វិធីការពារខ្លួន និងស្វែងរកជំនួយនៅពេលមានករណីរំលោភបំពានផ្លូវភេទកើតឡើង និងតួនាទីសំខាន់របស់ស្ត្រីជាម្តាយក្នុងការចូលរួមទប់ស្កាត់ការប្រើប្រាស់ និងចែកចាយគ្រឿងញៀននៅក្នុងគ្រួសារ ក៏ដូចជាសហគមន៍ ដែលមានប្រជាពលរដ្ឋចូលរួមចំនួន ៨៨៦នាក់ (ស្រី ៥៧០នាក់)។

១២០. ក្រសួង ក.ប. បានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការកាត់បន្ថយពលកម្មកុមារ និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ និងការងារដោយបង្ខំ ដោយបានចុះផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិ-ឧស្សាហកម្ម ក្នុងខេត្តគោលដៅចំនួន ៥ គឺខេត្តត្បូងឃ្មុំ សៀមរាប បាត់ដំបង កំពង់ចាម និងខេត្តកណ្តាល ចំនួន ៤២លើក មានអ្នកចូលរួមចំនួន ២ ៦៦៨នាក់ (ស្រី ១ ២២៦នាក់)។ បន្ថែមពីនេះ ក្រសួងបានចុះធ្វើអធិការកិច្ចការងារចំនួន ៨ ២៨៩លើក ,ដាក់កំហិតចំនួន ១២២សហគ្រាស ,ផាកពិន័យចំនួន ១២០សហគ្រាស ដែលអនុវត្តមិនបានត្រឹមត្រូវតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យការងារ ដោយក្នុងនោះផាកពិន័យ ១សហគ្រាស ពាក់ព័ន្ធនឹងការប្រើប្រាស់កម្មករក្រោមអាយុអប្បបរមា។ ក្រសួងបានរៀបចំសេចក្តីព្រាងអំពីយន្តការទ្រទ្រង់

និងការកំណត់ស្តង់ដារ ក្នុងការបង្កើតទារកដ្ឋាន និងមត្តេយ្យសហគមន៍នៅក្នុងតំបន់ដែលមានរោងចក្រ សហគ្រាស។ ក្រសួងបាន និងកំពុងរៀបចំលិខិតស្នើសុំកិច្ចសហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីជួបប្រជុំជាមួយ ដៃគូពាក់ព័ន្ធ ជាពិសេស ម្ចាស់តំបន់សេដ្ឋកិច្ចពិសេសនានា ដើម្បីពិភាក្សាអំពីយន្តការលើកទឹកចិត្ត និងជំរុញការសាងសង់ទារកដ្ឋាន និងមត្តេយ្យសហគមន៍នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។

### ៩. ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ

១២១. ដើម្បីអនុវត្តផែនការសកម្មភាព ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវតាមកុមារប្រព័ន្ធអនឡាញនៅកម្ពុជា ឆ្នាំ២០២១-២០២៥ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.) បានសហការជាផ្លូវការជាមួយអង្គការឆាលហ្វានកម្ពុជា (ChildFund Cambodia) ដើម្បីអនុវត្តសកម្មភាពគម្រោង Swipe Safe ដោយផ្តោត លើការអភិវឌ្ឍសម្ភារៈឧបទ្ទេសសម្រាប់ការបណ្តុះបណ្តាល និងផ្សព្វផ្សាយអំពី "សុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ" ទៅដល់កុមារ ឪពុកម្តាយ អ្នកថែទាំ និងកម្លាំងសេវាសង្គម។

១២២. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងអង្គការឆាលហ្វានបានសហការរៀបចំសៀវភៅស្តីពី "សុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ" សម្រាប់គ្រូបង្គោល និងអ្នកសម្របសម្រួល ដែលមានចំនួន ៤ឯកសារផ្សេងៗគ្នា ដោយផ្តោតលើក្រុមគោលដៅ ដូចជា កុមារ ឪពុកម្តាយ អ្នកថែទាំ និងកម្លាំងសេវាសង្គម។ គម្រោង Swipe Safe បានអនុវត្តសាកល្បងលើការប្រើប្រាស់សម្ភារៈឧបទ្ទេសបណ្តុះបណ្តាលនៅខេត្តចំនួន ៣ គឺ ខេត្តបាត់ដំបង ខេត្តក្រចេះ និងខេត្តព្រៃវែង ក្នុងស្រុកសង្កែ ស្រុកឆ្លូង និងស្រុកកំពង់ត្របែក។ ដោយសហការជាមួយអង្គការ WOMEN និងអង្គការ OEC ក្រោមការឧបត្ថម្ភគាំទ្រដោយអង្គការឆាលហ្វាន។

១២៣. អគ្គលេខាធិការដ្ឋាន ក.ជ.ក. និងអង្គការឆាលហ្វាន់កម្ពុជា បានសហការបណ្តុះបណ្តាលលើការប្រើប្រាស់ឯកសារសម្ភារឧបទ្ទេសស្តីពី "សុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ" ទៅដល់អ្នកស្ម័គ្រចិត្តសហគមន៍ចំនួន ១២នាក់ (ស្រី ១១នាក់) និងអ្នកសម្របសម្រួលយុវជនចំនួន ៣០នាក់ (ស្រី ២១នាក់) ដើម្បីពួកគេបណ្តុះបណ្តាលបន្តដល់ក្រុមគោលដៅជា ឪពុកម្តាយ អាណាព្យាបាល អ្នកថែទាំ យុវជន និងកុមារ។

១២៤. ក្រុមការងារបច្ចេកទេសអគ្គលេខាធិការដ្ឋាន ក.ជ.ក. បានចុះពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តសាកល្បងបណ្តុះបណ្តាលឯកសារសម្ភារឧបទ្ទេសស្តីពី "សុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ" របស់អ្នកស្ម័គ្រចិត្តសហគមន៍ និងអ្នកសម្របសម្រួលយុវជន ទៅដល់ឪពុកម្តាយ អាណាព្យាបាល អ្នកថែទាំ យុវជន និងកុមារ នៅខេត្តបាត់ដំបង ខេត្តក្រចេះ និងខេត្តព្រៃវែង ក្នុងស្រុកសង្កែ ស្រុកឆ្លូង និងស្រុកកំពង់ត្របែក ចំនួន ៥៧ក្រុម (ក្រុមឪពុកម្តាយ ១២ក្រុម) ដែលមានអ្នកចូលរួមសរុប ១ ០៧២នាក់ (ស្រី ៦៦៥នាក់)។ ទន្ទឹមនេះ ក្រុមការងារបច្ចេកទេសអគ្គលេខាធិការដ្ឋាន ក.ជ.ក. ក៏បានបណ្តុះបណ្តាលអំពី "សុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ" ដល់កម្លាំងសេវាសង្គមចំនួន ១៦៦នាក់ (ស្រី ៦៨នាក់) នៅខេត្តបាត់ដំបង ក្រចេះ និងព្រៃវែង។

### ត. អំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ

១២៥. គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សហការជាមួយអង្គការដៃគូបានផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ តាមរយៈវេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ទិវា

ជាតិអន្តរសាសនា យុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត និងតាមកម្មវិធីផ្សេងៗ សរុបចំនួន ១៦២ ២០៧លើក មានអ្នកចូលរួមសរុបចំនួន ៨ ៩៧៨ ២៨៩នាក់(ស្រីចំនួន ៤ ៥៤៥ ៧៣១ នាក់) ធៀបនឹងឆ្នាំ២០២២ មានចំនួន ៦ ៤៤១ ៨៧៣នាក់ គឺមានការកើនឡើងចំនួន ២ ៥៣៦ ៤១៦ នាក់ ស្មើនឹង ២៨,២៥%។

**ឃ. ការប្រយុទ្ធប្រឆាំងគ្រឿងញៀន**

១២៦. អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានខិតខំអនុវត្តការងារ ដោយជំរុញបង្កើនប្រសិទ្ធភាពការផ្សព្វផ្សាយ អប់រំជាសាធារណៈពីគ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈសារព័ត៌មានជាភាសាខ្មែរ និងបរទេស ការផលិតវីដេអូខ្លី ការផលិតពាក្យស្លោកអប់រំ ព្រឹត្តិប័ត្រព័ត៌មាន ផ្សព្វផ្សាយវិទ្យុ ទូរទស្សន៍រដ្ឋ និងឯកជន គេហទំព័រ បណ្តាញផ្សព្វផ្សាយសង្គម ស្លាកផលិតផល។ ទន្ទឹមនេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានបង្កើតកម្មវិធី App NoDrug ដើម្បីធ្វើការផ្សព្វផ្សាយអប់រំនៅក្នុងសហគមន៍ តាមរយៈក្រសួងសមាជិក អ.ជ.ប.គ.ញ. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។ សរុបនៃអ្នកដែលបានទទួលសារអប់រំមានចំនួនប្រមាណ ១៥ ៧៩៧ ៩១៤ អង្គ/នាក់ មានចំនួនប្រហាក់ប្រហែលគ្នា បើធៀបនឹងឆ្នាំ២០២២ (១៥ ៣១៤ ៥៨១អង្គ/នាក់)។

**ង. ការទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនិងការងារដោយបង្ខំ**

១២៧. ក្នុងឆ្នាំ២០២៣ វិទ្យាស្ថានជាតិការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានសហការជាមួយគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (ILO-BFC) រៀបចំវគ្គបណ្តុះបណ្តាលស្តីពីលក្ខខណ្ឌទូទៅនៃការងារ លក្ខខណ្ឌសុវត្ថិភាពនិងសុខភាពការងារ និងលក្ខខណ្ឌទំនាក់ទំនងវិជ្ជាជីវៈ ចំនួន ១៤ លើក ជូនដល់មន្ត្រីអធិការកិច្ចការងារចំនួន ៣៤៣នាក់ (ស្រី ៥៣នាក់) ដើម្បីបង្កើនសមត្ថភាពក្នុងការចុះអធិការកិច្ចការងារ ជាពិសេស ការចុះអធិការកិច្ចការងារលើពលកម្មកុមារនៅក្នុងវិស័យអាទិភាព។

គិតចាប់ពីឆមាសទី២ ឆ្នាំ២០២៣ ដល់ខែមីនា ឆ្នាំ២០២៤ ក.ប. បានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការងារដោយបង្ខំ ដោយបានធ្វើអធិការកិច្ចការងារកុមារចំនួន ១៤៥លើក, បានចុះត្រួតពិនិត្យ វាយតម្លៃ លក្ខខណ្ឌការងារ និង ប្រភេទការងារសម្រាប់ កម្មករនិយោជិតវ័យក្មេងចំនួន ៤លើក ព្រមទាំងបានអនុវត្តកិច្ចអន្តរាគមន៍ស្នូលដកហូតទប់ស្កាត់ពលកម្មកុមារក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិ-ឧស្សាហកម្មចំនួន ៨០នាក់ (ស្រី ៣៤ នាក់), បានចុះផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារចំនួន ១១លើក ដោយមានអ្នកចូលរួមចំនួន ៨៩០នាក់ ស្រី ៣៧០នាក់។

នៅឆ្នាំ២០២៣ មន្ត្រីអធិការកិច្ចការងារ បានចុះធ្វើកិច្ចសន្យារវាងនិយោជក និងអធិការកិច្ចការងារ កិច្ចសន្យារវាងនិយោជក និយោជិត និងអាណាព្យាបាលស្តីពីការយល់ព្រមទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ ចំនួន ១ ២៦២កិច្ចសន្យា នៅទូទាំងប្រទេស។

ការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារដែលចូលរួមសកម្មភាពសេដ្ឋកិច្ច

| ល.រ | បរិយាយ | ឯកតា | ២០២២ | ២០២៣ | បម្រែបម្រួល (%) |
| --- | --- | --- | --- | --- | --- |
| ១ | ចំនួនកុមារដកហូត និងទប់ស្កាត់ | សរុប | ៤០០ | ៤០០ | 0.00% |
| | | ស្រី | ១៩១ | ២០៤ | ៦.៨១% |
| ២ | ការផ្សព្វផ្សាយ | លើក | ១៥៧ | ៤២ | -៧៣.២៥% |
| | | សរុប | ៥,១០៥ | ២,៦៦៨ | -៤៧.៧៤% |
| | | ស្រី | ១,៩៧៤ | ១,២២៦ | -៣៧.៨៩% |
| ៣ | បណ្តុះបណ្តាលគ្រូបង្គោល | វគ្គ | ៥ | ១ | -៨០.០០% |
| | | សរុប | ២៥៨ | ៦៤ | -៧៥.១៩% |
| | | ស្រី | ១៤០ | ៤០ | -៧១.៤៣% |

ប្រភព៖ នាយកដ្ឋានការងារកុមារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ៤.២.ការអន្តរាគម និងឆ្លើយតប

### ក. អំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ

១២៨. កម្លាំងជំនាញនៃស្នងការដ្ឋានគរបាលចំនួន ០៦ខេត្ត (បន្ទាយមានជ័យ កោះកុង បាត់ដំបង ព្រះវិហារ ត្បូងឃ្មុំ កែប) បានធ្វើការទប់ស្កាត់ពលករចំណាកស្រុកខុសច្បាប់ នៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ និង វៀតណាមចំនួន ២៦លើក មនុស្សចំនួន ៦៦៤នាក់ (ស្រី ២៥៨នាក់) អនីតិជន ២៧នាក់ បានធ្វើកិច្ចសន្យាការអប់រំណែនាំកុំឱ្យចំណាកស្រុកខុសច្បាប់ទៅក្រៅប្រទេសទៀត។

១២៩. នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ១៦៤ករណី (ធៀបនឹងឆ្នាំ២០២២ មានចំនួន ១៦៦ករណី ថយចុះចំនួន ០២ករណី) ស្មើនឹង ១,២០%។ ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ១៩៤នាក់ (ស្រី ៣៥នាក់) អនីតិជន ២៧នាក់ (ស្រី ០២នាក់)។ ក្នុងនោះជនសង្ស័យបរទេសចំនួន ១១នាក់ មានជនជាតិ (ចិន ០៣នាក់ ហ្វីលីពីន ០១នាក់ អាមេរិក០១នាក់ ជនជាតិវៀតណាម ០៤នាក់ ស្វីស ០១នាក់ និងប៉ាគីស្ថាន ០១នាក់)។ សង្គ្រោះជនរងគ្រោះ ចំនួន ៤៧៦នាក់ (ស្រី ៣៤៦នាក់) ក្នុងនោះ អាយុក្រោម១៥ឆ្នាំ ១៣៥នាក់ (ស្រី) អាយុ១៥-១៧ឆ្នាំ ៤៧នាក់ (ស្រី ៤៤នាក់) និងអាយុពី១៨ឆ្នាំឡើង ២៩៤នាក់ (ស្រី ១៦៧នាក់) (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ១៦២នាក់ និងប្រគល់ឱ្យគ្រួសារ ៣១៤នាក់)។ ក្នុងនោះចែកជា អំពើជួញដូរមនុស្សចំនួន ២៤ករណី និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន ១៤០ករណី។

### ខ. ការប្រយុទ្ធប្រឆាំងគ្រឿងញៀន

១៣០. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន៖ បានបង្ក្រាបបទល្មើសគ្រឿងញៀនសរុបចំនួន ៨ ០៦៣ករណី បើធៀបនឹងឆ្នាំ២០២២ មានចំនួនកើនឡើងជាង ១ ៦៧៣ករណី ស្មើនឹង២៦,១៨%។ ឃាត់ខ្លួនជនសង្ស័យសរុបចំនួន ២០ ០០២នាក់ (ស្រី ១ ០០០នាក់) បើធៀបនឹងឆ្នាំ២០២២ មានចំនួនកើនឡើង ៥

០០០នាក់ ស្មើនឹង ៣៣,៣៣%។ ជនសង្ស័យរួមមាន៖ ជនជាតិខ្មែរចំនួន ១៩ ៤១៦នាក់ (ស្រី៩១៤នាក់) និងជនបរទេសចំនួន ៥៨៦នាក់ (ស្រី៨៦នាក់) ដែលមាន ១៦ជនជាតិ៖ វៀតណាម២៨៦នាក់ (ស្រី៦៥នាក់) ចិន១៨៤នាក់(ស្រី១២នាក់) ថៃ៤៤នាក់(ស្រី៨នាក់) ចិនតៃវ៉ាន់២៦នាក់(ស្រី១នាក់) ឥណ្ឌូនេស៊ី១៨នាក់ អាមេរិក៧នាក់ ឡាវ៦នាក់ ម៉ាឡេស៊ី៥នាក់ កូរ៉េ២នាក់ សឹង្ហបុរី២នាក់ ជប៉ុន១នាក់ អង់គ្លេស១នាក់ អូស្ត្រាលី១នាក់ ភូមា១នាក់ Tridadian១នាក់ និង Bolovian ១នាក់។

១៣១. គ្រឿងញៀនសរុបចាប់យកបានចំនួន ២តោន ៩៨៨គ.ក្រ ៩០២,៨៣ក្រាម បើប្រៀបធៀបនឹងឆ្នាំ ២០២២ (ចំនួន ១៤តោន ៩១៩គ.ក្រ ៤៦៧,០៧ក្រាម) មានចំនួនតិចជាង ១១តោន ៩៣០គ.ក្រ ៥៦៤,២៤ ក្រាម មានន័យថា ចាប់យកបានប្រមាណតែ ១ភាគ៥ ប៉ុណ្ណោះបើធៀបនឹងឆ្នាំកន្លងទៅ។

១៣២. ជាមួយគ្នានេះ ក្នុងឱកាសប្រារព្ធពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ បានបំផ្លាញតាមលក្ខណៈបច្ចេកទេស និងសុវត្ថិភាព (តាមវិធីដុតកម្ទេច និងបន្សាប) នូវគ្រឿងញៀន និងសារធាតុពាក់ព័ន្ធ សរុបចំនួណ ៣៤៧តោន ៣៣៨គីឡូក្រាម ៩៤០,០៧ក្រាម និង ១ ២០៧គ្រាប់។

### ត. បណ្ដាញទូរសព្ទទាន់ហេតុការណ៍ និងការរាយការណ៍តាមអនឡាញ

១៣៣. បច្ចុប្បន្ននេះ កម្ពុជាមានបណ្ដាញទូរស័ព្ទចំនួន ២ខ្សែសំខាន់ៗ ដែលផ្តល់សេវាជួយកុមារ ក្នុងនោះរួមមាន បណ្ដាញទាន់ហេតុការណ៍ ១២៨៨ របស់នគរបាលជាតិ និងបណ្ដាញទូរជំនួយកុមារ ១២៨០ របស់អង្គការបណ្ដាញទូរស័ព្ទជំនួយកុមារកម្ពុជា។ ក្រៅពីបណ្ដាញទូរស័ព្ទទាន់ហេតុការណ៍ទាំងពីរនេះ ក៏មានបណ្ដាញទូរស័ព្ទទាន់ហេតុការណ៍មួយចំនួនផ្សេងទៀត ដែលផ្តល់ដោយអង្គការដៃគូដែលធ្វើការពាក់ព័ន្ធនឹងកុមារផងដែរ។

១៣៤. អង្គការបណ្ដាញទូរស័ព្ទជំនួយកុមារកម្ពុជា(១២៨០)[17] ផ្តល់សេវាពិគ្រោះយោបល់តាមទូរស័ព្ទដោយឥតគិតថ្លៃ ២៤/៧៖ ក្រុមអ្នកពិគ្រោះយោបល់របស់ CHC បានឆ្លើយការហៅចូលទូរស័ព្ទចំនួន ១៩ ៦១៨ ដង ក្នុងនោះអតិថិជនចំនួន ២ ៥០៨នាក់ បានទទួលការពិគ្រោះយោបល់តាមទូរស័ព្ទ អតិថិជនចំនួន ១២៧ នាក់ បានរាយការណ៍អំពីបញ្ហាទាក់ទងនឹងការការពារកុមារ និងអតិថិជនចំនួន ៥ ៦២៨នាក់ បានទទួលសេវាកម្មអប់រំ និងព័ត៌មានផ្អែកលើបញ្ហា។ ក្នុងចំណោមអតិថិជន ១៩ ៦១៨នាក់ មានស្រី ៦ ៦៦៤នាក់ ប្រុស ៣ ៤៩២នាក់ LGBTIQ ៦០នាក់ មិនអាចកំណត់បាន ៩ ៤០២នាក់ (ក្នុងនោះមានកុមារ ១ ២០៧នាក់ យុវជន ១ ២១២នាក់ មនុស្សពេញវ័យ ៤ ១៩៣នាក់ មិនអាចកំណត់អាយុបាន ១៣ ០០៦នាក់)។

១៣៥. ប្រតិបត្តិការទូរស័ព្ទ និងអ៊ីនធឺណិត Hotline ៖ ដំណើរការប្រព័ន្ធទូរស័ព្ទរាយការណ៍បន្ទាន់ ០៩២ ៣១១ ៥១១ និងបណ្ដាញរាយការណ៍តាមប្រព័ន្ធអ៊ីនធឺណិត បានទទួលការរាយការណ៍ករណីសង្ស័យពាក់ព័ន្ធនឹងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារសរុបចំនួន ២៧១ករណី ក្នុងនោះមាន ២០៨ករណីសង្ស័យពាក់ព័ន្ធនឹងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ។ បានផ្តល់ព័ត៌មានពាក់ព័ន្ធករណីសង្ស័យនៃការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ ទៅកាន់តំណាងនាយក

[17] របាយការណ៍សមិទ្ធផលការងារ ឆ្នាំ២០២២ និងទិសដៅឆ្នាំ២០២៣ របស់អង្គការបណ្ដាញទូរស័ព្ទជំនួយកុមារកម្ពុជា (CHC)

ដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា និងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីចាត់វិធានការបង្ការ ទប់ស្កាត់ និងស៊ើបអង្កេតតាមនីតិវិធីច្បាប់ ចំនួន ៧១ករណី។

១៣៦. បច្ចុប្បន្ននេះ ក្រសួង ក.ប. បានដាក់ដំណើរការប្រព័ន្ធទូរស័ព្ទរាយការណ៍បន្ទាន់លេខ ១២៩៧ និងបណ្តាញរាយការណ៍តាមប្រព័ន្ធអ៊ីនធើណេត ចំនួន២ ដើម្បីជាយន្តការទទួលពាក្យបណ្តឹងនៃករណីប្រើប្រាស់ពលកម្មកុមារ និងការអន្តរាគមន៍ក្នុងរយៈពេល២៤ម៉ោង។

**ឃ. កិច្ចអន្តរាគមន៍ក្នុងការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ**

១៣៧. តាមរយៈការអនុវត្តគម្រោងកិច្ចអន្តរាគមន៍ស្នូលក្នុងការដកហូត ទប់ស្កាត់ និងគាំពារកុមារ ក្នុងឆ្នាំ២០២៣ កុមារគោលដៅចំនួន ៣៦០នាក់ (ស្រី ១៧៧នាក់) បានទទួលកញ្ចប់សង្គ្រោះសង្គម សម្រាប់ការអប់រំមូលដ្ឋាន និងកុមារចំនួន៤០នាក់ (ស្រី២៧នាក់) បានទទួលការបណ្តុះបណ្តាលជំនាញ និងក្រុមគ្រួសារចំនួន ៣៦០គ្រួសារ បានទទួលកញ្ចប់ថវិកាសម្រាប់បង្កើតមុខរបរ។

## ៤.៣. កិច្ចការយុត្តិធម៌

**ក. អំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ**

១៣៨. ទិន្នន័យទទួលបានពីក្រុមការងារជំនាញកិច្ចការយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ជាលទ្ធផលតាមដំណាក់កាលទាំង៣ នៃនីតិវិធីតុលាការ មានដូចខាងក្រោម៖

- ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត សំណុំរឿងសរុបមានចំនួន ៣៧១ (ក្នុងនោះសំណុំរឿងចាស់មានចំនួន ១៧)។ ជនរងគ្រោះសរុបមានចំនួន ៣២១នាក់ (ស្រី ១២៤នាក់) ក្នុងនោះអនីតិជន ១៩០នាក់ (ស្រី ៩០នាក់) និងជនបរទេស ២៤នាក់ (ស្រី ០៣នាក់)។ ជនល្មើសសរុបមានចំនួន ៦០០នាក់ (ស្រី ២៦នាក់) ក្នុងនោះអនីតិជន ៤៤នាក់ (ស្រីគ្មាន) និងជនបរទេស ១៧៨នាក់ (ស្រី ០៧នាក់)។ សំណុំរឿងចាត់ការរួច ២៧៥សំណុំរឿង មានដូចជា៖ បញ្ជូនទៅស៊ើបសួរ ២៣៦សំណុំរឿង បញ្ជូនរឿងទៅជម្រះ ២សំណុំរឿង នីតិវិធីបង្ហាញខ្លួនភ្លាម ២សំណុំរឿង តម្កល់រឿងទុកឥតចាត់ការ ៣២សំណុំរឿង បញ្ចូលសំណុំរឿង (០៣) ផ្ទេរសមត្ថកិច្ច(គ្មាន) និងកំពុងចាត់ការ ៩៦សំណុំរឿង។
- ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត សរុបមានចំនួន ៣៥៧សំណុំរឿង (ក្នុងនោះសំណុំរឿងចាស់មានចំនួន ៨៨) ជនរងគ្រោះសរុបមានចំនួន ៣២២នាក់ (ស្រី ១០៦នាក់) ក្នុងនោះអនីតិជន ១១០នាក់ (ស្រី ៤៩នាក់) និងជនបរទេស ៩១នាក់ (ស្រី ២០នាក់) ជនត្រូវចោទសរុបមានចំនួន ៤៩៨នាក់ (ស្រី ៥៨នាក់) ក្នុងនោះអនីតិជន ៣៨នាក់ (ស្រី ០១នាក់) និងជនបរទេស ១៣២នាក់ (ស្រី ២៦នាក់)។ ប្រភេទចំណាត់ការរួច ១៤៣ សំណុំរឿង មានដូចជា បានបញ្ជូនរឿងទៅជម្រះចំនួន១៣៧សំណុំរឿង លើកលែងចោទ(០៦) ផ្ទេរសមត្ថកិច្ច(គ្មាន) បណ្តឹងឧទ្ធរណ៍(គ្មាន) និងកំពុងចាត់ការចំនួន ២១៤ សំណុំរឿង។

- ដំណាក់កាលថៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្ត សរុបមានចំនួន ៣០៧សំណុំរឿង (ក្នុងនោះសំណុំរឿងចាស់មានចំនួន ១០០) ជនរងគ្រោះសរុបមានចំនួន ៣៨៨នាក់ (ស្រី ១៥២នាក់) ក្នុងនោះអនីតិជន ១២៥នាក់ (ស្រី ៩៦នាក់) និងជនបរទេស ២៣នាក់ (ស្រី ០១នាក់) ជនជាប់ចោទសរុបមានចំនួន ៥១៨នាក់ (ស្រី ៥២នាក់) ក្នុងនោះអនីតិជន ៣៨នាក់ (ស្រីគ្មាន) និងជនបរទេស ៧០នាក់ (ស្រី ០១នាក់) និងអញ្ញាតជន ០១នាក់។ សំណុំរឿងចាត់ការរួច ១៤៦ សំណុំរឿង មានដូចជា៖ **១.ប្រកាសសាលក្រម** ឱ្យរួចផុតពីបទចោទ ១១សំណុំរឿងមនុស្សចំនួន ០៨នាក់ (ស្រី ០១នាក់)។ **២.ផ្តន្ទាទោស** ពិន័យជាប្រាក់ ០១សំណុំរឿង ដាក់ពន្ធនាគារ ៩៩សំណុំរឿង មនុស្សចំនួន ៩៥នាក់ (ស្រី ០៩នាក់)។ **៣.ព្យួរទោស** ព្យួរទោសសាកល្បង ០១សំណុំរឿង ព្យួរទោសធម្មតា ០៩សំណុំរឿង មានមនុស្សចំនួន ១០នាក់ (ស្រី ០២នាក់)។ **៤.បណ្តឹងឧបាស្រ័យ** បណ្តឹងជំទាស់(គ្មាន) បណ្តឹងឧទ្ធរណ៍(គ្មាន) និងកំពុងចាត់ការ ១៦១សំណុំរឿង។

### ៩. ការប្រយុទ្ធប្រឆាំងគ្រឿងញៀន

១៣៩. ចំណាត់ការរឿងក្តីពាក់ព័ន្ធបទល្មើសគ្រឿងញៀនរបស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីខេត្ត៖

- ដំណាក់កាលអយ្យការ មានសំណុំរឿងសរុប ៧ ១៩៧រឿង (ក្នុងនោះសំណុំរឿងថ្មីចំនួន ៧ ០៩៥រឿង) និងមានជនល្មើសចំនួន ១៤ ៨៥២នាក់ (ជានីតិជន ១៤ ១៦៨នាក់/ស្រី ៨៦២នាក់ ជាអនីតិជន ៦៨៤នាក់/ស្រី ៤៥នាក់)។ ប៉ុន្តែជាក់ស្តែង ក្នុងដំណាក់កាលអយ្យការនេះ ចំនួនជនត្រូវចោទបញ្ជូនទៅថៅក្រមស៊ើបសួរមានតែ ១០ ២៣៤នាក់ និងចំនួនជនរងគ្រោះដោយសារគ្រឿងញៀន ដែលបានបញ្ជូនទៅមណ្ឌលបណ្តោះអាសន្នមានតែ ២ ៤៣១នាក់ ប៉ុណ្ណោះ។
- ដំណាក់កាលស៊ើបសួរ មានសំណុំរឿងចំនួន ៨ ១៨៧រឿង (ក្នុងនោះសំណុំរឿងថ្មីមានចំនួន ៧ ៣៧១រឿង) និងមានជនត្រូវចោទចំនួន ១៦ ៧៣៥នាក់ (ជានីតិជន ១៦ ១០៩នាក់/ស្រី ១ ០៦៣នាក់ ជាអនីតិជន ៦២៦នាក់/ស្រី ៣២នាក់) ក្នុងនោះជនត្រូវចោទជាប់ឃុំចំនួន ១២ ៨៩៧នាក់ និងជនត្រូវចោទនៅក្រៅឃុំចំនួន ៣ ៨៣៨នាក់។
- ដំណាក់កាលជំនុំជម្រះ មានសំណុំរឿងសរុបចំនួន ៧ ៤៨៤រឿង (ក្នុងនោះសំណុំរឿងថ្មីមានចំនួន ៧ ០៥៦រឿង) និងមានជនជាប់ចោទចំនួន ១៥ ៤៦៦នាក់ ក្នុងនោះជនជាប់ចោទជានីតិជនចំនួន ១៤ ៩៤៥នាក់ (ស្រី ៩០២នាក់) និងអនីតិជនចំនួន ៥២១នាក់ (ស្រី ៣៧នាក់) ជនជាប់ចោទសរុបមានចំនួន ៥១៨នាក់ (ស្រី ៥២នាក់) ក្នុងនោះជនជាប់ចោទជាប់ឃុំចំនួន ១១ ៩៣០នាក់ និងជនជាប់ចោទនៅក្រៅឃុំចំនួន ៣ ៥៣៦នាក់។

## ៤.៤. ការផ្តល់ជំនួយ និងសេវាគាំទ្រ

### ក. ការងារសង្គមកិច្ច

១៤០. ការងារសង្គ្រោះបន្ទាន់ដល់ក្រុមជនរងគ្រោះ និងងាយរងគ្រោះ៖ បានផ្តល់ជំនួយសង្គ្រោះបន្ទាន់ដល់គ្រួសាររងគ្រោះដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយ ដោយយថាហេតុនៅតាម

សហគមន៍សរុបចំនួន ៣៨ ៤១០គ្រួសារ រួមមាន ខេត្តកំពង់ចាម ២ ២៧២គ្រួសារ កណ្តាល ៥៣០ គ្រួសារ កែប ៣១០គ្រួសារ ក្រចេះ ៩៦៨គ្រួសារ កំពង់ឆ្នាំង ៥៥០គ្រួសារ សៀមរាប ១ ៧២០គ្រួសារ តាកែវ ៤៣០គ្រួសារ បន្ទាយមានជ័យ ១៦ ១៨៦គ្រួសារ ពោធិ៍សាត់ ២០០គ្រួសារ ព្រៃវែង ១ ២២៨ គ្រួសារ ស្ទឹងត្រែង ១ ២២០គ្រួសារ ស្វាយរៀង ៧៤៦គ្រួសារ កំពត ៥៦០គ្រួសារ កំពង់ធំ ១ ៦០០ គ្រួសារ បាត់ដំបង ១ ១១៩គ្រួសារ កំពង់ស្ពឺ ១ ៥៨៩គ្រួសារ មណ្ឌលគីរី ១ ១២៦គ្រួសារ រតនៈគីរី ១ ១១១គ្រួសារ ឧត្តរមានជ័យ ៧២៨គ្រួសារ ព្រះវិហារ ១ ៣១៦គ្រួសារ ត្បូងឃ្មុំ ៩០០គ្រួសារ កោះកុង ៣៥០គ្រួសារ ព្រះសីហនុ ៤០១គ្រួសារ ប៉ៃលិន ៣៩០គ្រួសារ រាជធានីភ្នំពេញ ៤៥០គ្រួសារ និងតាមរយៈ ក្រសួង ស.អ.យ. ៤១០គ្រួសារ។

១៤១. ការងារជនអនាថា និងជនផ្ទុកមេរោគអេដស៍៖ បានផ្តល់សេវាពិគ្រោះយោបល់ ដោះស្រាយ ទប់ស្កាត់ និងការពារដល់ជនអនាថាសរុបចំនួន ១ ០៨៨នាក់ ស្រី ៥៧៨នាក់ និងបានធ្វើសមាហរណកម្មទៅ គ្រួសារ និងសហគមន៍វិញ ៨០៣នាក់ ស្រី ៣២៤នាក់។ បានប្រឹក្សាយោបល់ ថែទាំ គាំទ្រជនរងគ្រោះ ដែលរងផលប៉ះពាល់ដោយសារផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗនៅតាម សហគមន៍ចំនួន ២១៥នាក់។

១៤២. មជ្ឈមណ្ឌលជនវិបល្លាសស្មារតីបានទទួលជនវិបល្លាសស្មារតីឱ្យស្នាក់នៅសរុបចំនួន ១២៥នាក់ បើគិត ពីឆ្នាំ២០២១មក មានជនវិបល្លាសស្មារតីសរុបចំនួន ២៤០នាក់ ស្រី ៩៣នាក់ កំពុងស្នាក់នៅ ព្យាបាល និងបានសមាហរណកម្មទៅគ្រួសារ និងសហគមន៍វិញចំនួន ២៣នាក់ ស្រី ០៧នាក់។

១៤៣. លើកកម្ពស់សេវាស្តារនីតិសម្បទាអនីតិជន ដោយបានធ្វើបច្ចុប្បន្នភាពទិន្នន័យអនីតិជនទំនាស់នឹងច្បាប់ នៅតាមពន្ធនាគារ មណ្ឌលអប់រំកែប្រែរាជធានី ខេត្ត និងមណ្ឌលយុវនីតិសម្បទា មានអនីតិជនសរុប ចំនួន ២ ៦៤៨នាក់ ស្រី ៦៨នាក់ (ទណ្ឌិត ៤១០នាក់ ស្រី ១៤នាក់ ពិរុទ្ធជន ២ ២៣៨នាក់ ស្រី ៥៤ នាក់)។ បានរៀបចំប្រកាសស្តីពីការបង្កើតគណៈកម្មការវាយតម្លៃកម្រិតកែប្រែរបស់ទណ្ឌិតនៅមណ្ឌល យុវនីតិសម្បទា និងប្រកាសស្តីពីការសិក្សាអប់រំក្រៅប្រព័ន្ធ និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់អនីតិជនក្នុង មណ្ឌលយុវនីតិសម្បទា។ ទន្ទឹមនេះ ក៏បានអនុវត្តកម្មវិធីបង្វែរអនីតិជនទំនាស់នឹងច្បាប់ ដោយក្នុងនោះ រួមមាន៖ (១.) ដំណាក់កាលរៀបចំរបាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាព សង្គមរបស់អនីតិជនទំនាស់នឹងច្បាប់ចំនួន ២៨៤ករណី។ (២.) ដំណាក់កាលចូលរួមស្តាប់ចម្លើយក្នុង សវនាការចំនួន ៣៧៧ករណី។ (៣.) ដំណាក់កាលបង្វែរចំនួន ៧៤ករណី និងវិធានការផ្សេងទៀតក្រៅ ពីឃុំខ្លួនអនីតិជនទំនាស់នឹងច្បាប់ចំនួន ៧៦ករណី។ (៤.) សមាហរណកម្មអនីតិជនចំនួន ៣៩ករណី។ (៥.) បិទករណីអនីតិជនចំនួន ៦៨ករណី។ (៦.) អនីតិជនបរាជ័យក្នុងការអនុវត្តផែនការបង្វែរចំនួន ០១ ករណី និងប្រព្រឹត្តិបទល្មើសសាឡើងវិញចំនួន ០៣ករណី។

១៤៤. កិច្ចការពារ និងលើកកម្ពស់សុខុមាលភាពជនពិការ៖ អត្រាជនមានពិការភាពបានកើនឡើងពីមួយឆ្នាំទៅ មួយឆ្នាំ ដោយសារ កំណើនជនចាស់ជរា ដំណពូជ គ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់ការងារ គ្រោះថ្នាក់ ដោយសារមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ អំពើហិង្សា គ្រោះមហន្តរាយ ជំងឺខ្វះអាហារូបត្ថម្ភ និងមូលហេតុ ផ្សេងៗទៀតដែលប្រែប្រួលតាមសម័យកាល។ យោងតាមការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ឆ្នាំ២០២១ របស់វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការបានបញ្ជាក់ថា អត្រាជនមានពិការភាពមានប្រមាណ៥,៣% ស្មើនឹង ៨៧២ ៥២៧នាក់ នៃចំនួនប្រជាជនសរុប។ អត្រានេះមានការកើនឡើង បើប្រៀបធៀបនឹងការ

អង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ឆ្នាំ២០១៩ ដែលមានអត្រាជនមានពិការភាពត្រឹមតែចំនួន ៦៨៩ ៤៥៧ នាក់ ស្មើ៤,៩%ប៉ុណ្ណោះ។

១៤៥. ក្រសួង ស.អ.យ. បានផលិត និងបោះពុម្ពប័ណ្ណសមធម៌សម្រាប់ជនមានពិការភាពចំនួន ២៣៣ ០៧៩ ប័ណ្ណ។ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ២០២អនក្រ.បក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ ស្ដីពីអត្តសញ្ញាណកម្មពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន។ជនមានពិការភាពចំនួន ៥០ ១១៦ នាក់ ត្រូវបានកំណត់អត្តសញ្ញាណកម្មពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន តាមការស្នើសុំដើម្បីទទួលបានបណ្ណសម្គាល់ពិការភាព។

១៤៦. គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា បានធ្វើការសម្របសម្រួលយកកូនតាមម្ដាយ ដែលមានអាយុលើសពី៣ឆ្នាំឡើង ទៅរស់នៅក្នុងអង្គការការអភិវឌ្ឍន៍កុមារកម្ពុជា ដោយទទួលបានការចិញ្ចឹមបីបាច់ថែរក្សា និងបណ្ដុះបណ្ដាលរៀនសូត្របានចំនួន៦នាក់ (កុមារី៣នាក់) បច្ចុប្បន្នកុមារទាំងនោះរស់នៅក្នុងអង្គការការអភិវឌ្ឍន៍កុមារកម្ពុជាចំនួន ៣នាក់(កុមារី១នាក់) និងបានធ្វើសមាហរណកម្មទៅជួបជុំជាមួយគ្រួសារវិញចំនួន ៣នាក់ (កុមារី ២នាក់)។ បានជួយការពារក្ដីដល់អនីតិជន ២រូប នៅពន្ធនាគារខេត្តត្បូងឃ្មុំ ដោយសារគាត់ជាកុមារាម្នាក់កំព្រាគ្មានទីពឹង គ.ស.ម.ក. ក៏បានជួយសម្រួលគាត់ទៅរស់នៅសមាគមស្នាមញញឹមថ្មីនៃក្ដីសង្ឃឹមរបស់កុមារ។ គ.ស.ម.ក. តែងតែយកចិត្តទុកដាក់ចំពោះកុមារទាំងអស់ដែលជួបបញ្ហាការលំបាកទាំងនៅក្រៅ និងក្នុងពន្ធនាគារ និងបាននាំយកនូវថវិកា សម្ភារៈសិក្សា សម្ភារៈក្មេងលេង សម្លៀកបំពាក់ ឱសថសម្រាប់ព្យាបាល និងគ្រឿងឧបភោគបរិភោគ ជូនដល់អង្គការបានចំនួន ២០លើក និងឧបត្ថម្ភអង្ករចំនួន ១៥០គីឡូក្រាម ជារៀងរាល់ខែដល់អង្គការស្នាមញញឹមថ្មីនៃក្ដីសង្ឃឹមរបស់កុមារ។ បន្ថែមពីនេះ ក៏បាននាំយកក្រុមគ្រូពេទ្យស្ម័គ្រចិត្តដែលមានជំនាញផ្នែកធ្មេញ បំពង់ក ច្រមុះ និងត្រចៀក ព្យាបាលកុមារទាំងអស់ក្នុងអង្គការសរុបបានចំនួន ៥លើក។ គ.ស.ម.ក. ក៏បានជួយសម្របសម្រួលយកកុមារី ដែលរងការរំលោភរហូតមានផ្ទៃពោះទៅពិនិត្យផ្ទៃពោះប្រចាំខែ និងទទួលបានការសម្រាលបុត្រដោយឥតគិតថ្លៃផងដែរ។

១៤៧. គ.ស.ម.ក. តែងតែយកចិត្តទុក្ខដាក់សម្របសម្រួលយកកូន ទៅជួបម្ដាយនៅរាល់ពេលមានបុណ្យជាតិធំៗ ដូចជា ចូលឆ្នាំសកល បុណ្យភ្ជុំបិណ្ឌ ចូលឆ្នាំខ្មែរ និងបុណ្យប្រពៃណីជាតិធំៗ ផងដែរ។

១៤៨. ដើម្បីបង្ការនិងទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចពលកម្ម និងអាជីវកម្មផ្លូវភេទ ក្រសួង ក.ប. បានផ្សព្វផ្សាយពីគោលការណ៍ណែនាំ នៃការធ្វើទេសន្តប្រវេសន៍ ប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាព ដល់ពលករ ដែលមានបំណងធ្វើការចំណាកស្រុកដូចតទៅ៖ (១)បានបណ្ដុះបណ្ដាលគ្រូបង្គោលតាមឃុំ/សង្កាត់ នៅតាមខេត្តជាប់ព្រំដែនកម្ពុជា-ថៃ (២)បានសហការជាមួយអនុពន្ធ័ការងារនៅតាមប្រទេសទទួលទទួលពលករដោយមានការចូលរួមសមាគមទីភ្នាក់ងារឯកជនបញ្ជូនពលករ និងទីភ្នាក់ងារឯកជនបញ្ជូនពលករផងដែរ (៣)បានផ្សព្វផ្សាយពីបញ្ជីឈ្មោះទីភ្នាក់ងារបញ្ជូនពលករស្របច្បាប់ នៅកម្ពុជា។ ដើម្បីឱ្យកុមារអាយុក្រោម ១៨ឆ្នាំ ទទួលបានវគ្គអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ហើយផ្ដល់នូវជំនាញមួយយ៉ាងតិចប្រចាំជីវិត ដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ និងយុវជននៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ ដើម្បីទទួលបានឱកាសការងារ និង/ឬបង្កើតការងារដោយខ្លួនឯងប្រកបដោយភាពម្ចាស់ការ មានគុណភាព និងផលិតភាពខ្ពស់សម្រាប់ផ្គត់ផ្គង់ និងឆ្លើយតបបានតាមតម្រូវការទីផ្សារប្រកបដោយចីរភាព ភាពធន់ និងបរិយាបន្ន។

## ៥. អំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ

១៤៩. ការទទួល និងសម្ភាសន៍ពលរដ្ឋខ្មែរបញ្ជូនត្រឡប់តាមផ្លូវគោក និងផ្លូវអាកាស៖ ក្រសួង ស.អ.យ. បានសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងមន្ទីរសង្គមកិច្ចរាជធានី ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងជនងាយរងគ្រោះ ដោយអំពើជួញដូរមនុស្សដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា សរុបចំនួន ២៣ ៦០១នាក់(ស្រី ១១ ១១៤នាក់) ក្នុងនោះកុមារចំនួន ២ ៣៦២នាក់ (កុមារី ១ ១០០នាក់)។

១៥០. ដោយឡែកជនរងគ្រោះ និងជនងាយរងគ្រោះ ដោយអំពើជួញដូរមនុស្ស បានទទួលពីកម្លាំងនគរបាលនៅក្នុងស្រុក និងបានសហការជាមួយអង្គការដៃគូសរុបចំនួន ១៣៧នាក់ (ស្រី ៤៥នាក់ កុមារា ០២នាក់) ក្នុងនោះជនជាតិខ្មែរចំនួន ៣៩នាក់ (ស្រី ១៥នាក់ កុមារា ០២នាក់) (ជាករណីអំពើជួញដូរមនុស្សបម្រុងឆ្លងដែនទៅធ្វើការនៅប្រទេសគោលដៅ) និងជនបរទេសចំនួន ៩៨នាក់ ស្រី ០៣នាក់ មានជនជាតិថៃ ០៥នាក់ វៀតណាម ៣៥នាក់(ស្រី ១០នាក់) ឥណ្ឌា ០៣នាក់ (ស្រី ០១នាក់) ឥណ្ឌូនេស៊ី ២៨នាក់ (ស្រី ០៥នាក់) និងជនជាតិហ្វីលីពិន ២៧នាក់ (ស្រី ១២នាក់) (ករណីជួញដូរកម្លាំងពលកម្ម)។

១៥១. ក្រសួង ស.អ.យ. និងមន្ទីរសង្គមកិច្ចរាជធានី ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សទៅស្តារនីតិសម្បទានៅមណ្ឌលរបស់អង្គការដៃគូសរុប ៤៣៦នាក់ (ប្រុស ៧១នាក់ ស្រី ៣៥៦នាក់ កុមារា ០១នាក់ កុមារី ០៨នាក់) ក្នុងនោះមានករណី (អាពាហ៍ពិពាហ៍ផ្ទុយនឹងឆន្ទៈ/បង្ខំ ២៨៤នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម ៨៦នាក់ និងងាយរងគ្រោះ ៦៦នាក់)។ ក្នុងនោះបញ្ជូនទៅអង្គការដៃគូចំនួន ៤៨៦នាក់ មានអង្គការ ការីតាសកម្ពុជា សមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍនៅកម្ពុជា (អាដហុក) អង្គការរតនៈអ៊ិនធើណេសសេនណល អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) អង្គការមូលនិធិហាការអន្តរជាតិ អង្គការសម្ព័ន្ធចាប់ដៃ អង្គការមូលនិធិ A21 អង្គការកម្ពុជាដើម្បីស្ត្រីមានវិបត្តិ CWCC អង្គការសង់ត្រាល់ និងអង្គការសួននៃក្តីសង្ឃឹម។

១៥២. ការធ្វើសមាហរណកម្ម ក្រសួង ស.អ.យ. និងមន្ទីរសង្គមកិច្ចរាជធានី ខេត្តបានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ សមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងរំលោភបំពានផ្លូវភេទ ត្រឡប់ទៅសហគមន៍វិញសរុប ២៨៣នាក់ (ប្រុស ៣៧នាក់ ស្រី ២៤៦នាក់) ក្នុងនោះករណីអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ/បង្ខំ ១៣២នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម ២៧នាក់ ជួញដូរ និងរំលោភបំពានផ្លូវភេទ ១១០នាក់ និងងាយរងគ្រោះ ១៤នាក់ ដោយមានការចូលរួមសហការគាំទ្រពីអង្គការដៃគូ។ បានធ្វើមាតុភូមិនិវត្តន៍ទៅប្រទេសដើមវិញចំនួន ៩០នាក់ (ស្រីចំនួន ៣៧នាក់) ជាករណីជួញដូរកម្លាំងពលកម្ម ជនរងគ្រោះជនជាតិឥណ្ឌូនេស៊ីចំនួន ២៨នាក់ (ស្រី ០៥នាក់) វៀតណាមចំនួន ៣៥នាក់ (ស្រី ១០នាក់) និងជនជាតិហ្វីលីពីន ២៧នាក់ (ស្រី ១២នាក់)។ ជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ៣០០នាក់ (ប្រុស ៤១នាក់ ស្ត្រី ២៥៩នាក់) កេងប្រវ័ញ្ចកម្លាំងពលកម្ម ១០៤នាក់ អាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ/បង្ខំ ២១នាក់ ជួញដូរ និងរំលោភបំពានផ្លូវភេទ

១៧១នាក់ និងងាយរងគ្រោះ ០៤នាក់ ត្រូវបានបន្តតាមដានក្រោយពីធ្វើសមាហរណកម្មរួច ដោយមានកិច្ចសហការជាមួយអង្គការដៃគូ។

១៥៣. ការបិទករណីក្រសួង ស.អ.យ. សហការជាមួយអង្គការដៃគូ បានបិទករណី នៃការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ១៥៣នាក់ (ស្ត្រី ១៣៤នាក់) ក្នុងនោះមាន ៖ (ករណីអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ/បង្ខំ ១២នាក់ ជួញដូរ និងរំលោភបំពានផ្លូវភេទ ៥៥នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម ៤៤នាក់ និងងាយរងគ្រោះ ៤២នាក់។

## គ. ការប្រយុទ្ធប្រឆាំងគ្រឿងញៀន

១៥៤. អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (អ.ជ.ប.គ.ញ.) ក្រសួងសមាជិកពាក់ព័ន្ធ គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន រួមនឹងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត បានខិតខំប្រឹងប្រែងអនុវត្តតាមគោលការណ៍ដឹកនាំ ដើម្បីពង្រឹងគុណភាពសេវាព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ មជ្ឈមណ្ឌលជាតិ មណ្ឌលបណ្តោះអាសន្នរដ្ឋ និងឯកជន ដែលមានសកម្មភាពសំខាន់ៗមួយចំនួនដូចជា ការកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន និងការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។

១៥៥. ការកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន៖ អ.ជ.ប.គ.ញ. ក្រសួងសមាជិកពាក់ព័ន្ធ រួមនិងអង្គការដៃគូបានសម្របសម្រួលអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន តាមរយៈការផ្តល់សេវាព្យាបាលដោយឱសថជំនួសមេតាដូន ដល់អ្នកញៀនគ្រឿងញៀនពួកអាភៀន នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និងមន្ទីរពេទ្យបង្អែកច្បារអំពៅរាជធានីភ្នំពេញ និងការអនុវត្តកម្មវិធីម្ជុល/ស៊ីរាំងចំពោះអ្នកប្រើប្រាស់គ្រឿងញៀន ដោយចាក់របស់អង្គការដៃគូទៅតាមគោលការណ៍ណែនាំរបស់ក្រសួងមានសមត្ថកិច្ច។

១៥៦. ការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន៖ ក្នុងឆ្នាំ២០២៣ ស្ថានភាពអ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀន មានដូចខាងក្រោម៖

- តាមរបាយការណ៍របស់ក្រសួង ស.អ.យ. អ្នកដែលបានធ្វើសមាហរណកម្មចេញពីមណ្ឌលចំនួន ១២ ៣១១នាក់ និងអ្នកបន្តធ្វើការបន្សាបព្យាបាលនៅក្នុងមណ្ឌលចំនួន ៥ ៥០៤៧នាក់។
- តាមរបាយការណ៍ក្រសួងសុខាភិបាល ការមកទទួលសេវាពិនិត្យព្យាបានៅតាមមូលដ្ឋានសុខាភិបាលសាធារណៈមានចំនួន ៣ ៨១១នាក់ (ស្រី ១ ៣២១នាក់)។
- តាមរបាយការណ៍របស់លេខាធិការដ្ឋាន នៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៨ ក្នុងចំណោមជនសង្ស័យប្រើប្រាស់គ្រឿងញៀនបានឃាត់ខ្លួនមានចំនួន ១ ៣៧៧ នាក់ បញ្ជូនទៅតុលាការ។

១៥៧. សរុបចំនួនអ្នកញៀន និងអ្នកប្រើប្រាស់គ្រឿងញៀន ដែលបានគ្រប់គ្រងចំនួន ២៣ ០៤៦នាក់ បើប្រៀបធៀបឆ្នាំ២០២២ (២២ ២១៣នាក់) មានការកើនឡើងចំនួន ៨៣៣នាក់។ អ.ជ.ប.គ.ញ. បានជំរុញឱ្យគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ខិតខំពង្រឹង និងបង្កើតគណៈកម្មការសម្រប

សម្រួលសម្រាប់ព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍នៅតាមឃុំ សង្កាត់ ដើម្បីគាំទ្រឱ្យអ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀន មានភាពងាយស្រួលទៅទទួលយកសេវាព្យាបាលនៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងលើកកម្ពស់ការថែទាំបន្តនៅតាមសហគមន៍។

១៥៨. ក្រសួងសុខាភិបាល បានបន្តដំណើរការសេវាពិនិត្យព្យាបាលជំងឺផ្លូវចិត្ត និងភាពញៀនគ្រឿងញៀនមានចំនួន ៤៥៤កន្លែងនៅទូទាំងប្រទេស ក្នុងនោះ៖ មន្ទីរពេទ្យថ្នាក់ជាតិ ២កន្លែង មន្ទីរពេទ្យខេត្ត ២៥កន្លែង មន្ទីរពេទ្យបង្អែក ៧២កន្លែង និងមណ្ឌលសុខភាព ៣៥៥កន្លែង។ បានដំឡើងស្លាកសញ្ញាសម្គាល់ទីតាំងផ្តល់សេវាពិនិត្យព្យាបាលជំងឺផ្លូវចិត្ត និងភាពញៀនគ្រឿងញៀនបានចំនួន ៣៤៥ទីតាំងស្មើនឹង៨២% លើចំនួនទីតាំងផ្តល់សេវាសរុប។ ក្នុងចំនួនមូលដ្ឋានដែលបានដំណើរការសេវាពិនិត្យព្យាបាលជំងឺផ្លូវចិត្ត និងភាពញៀនគ្រឿងញៀនទាំង ៤៥៤កន្លែង យើងមានគ្រូពេទ្យដែលបានទទួលការបណ្តុះបណ្តាលសម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀន ៨៨៣នាក់/ស្រី២៣០នាក់ (នៅមន្ទីរពេទ្យជាតិ ២កន្លែង មានគ្រូពេទ្យ ៣៨នាក់/ស្រី៩នាក់ មន្ទីរពេទ្យបង្អែក ៩៧កន្លែង មានគ្រូពេទ្យ ៣២៤នាក់/ស្រី៨២នាក់ និងនៅមណ្ឌលសុខភាព ៣៥៥កន្លែង មានគ្រូពេទ្យ ៥២១នាក់/ស្រី១៣៩នាក់)។

១៥៩. ចំពោះការសេវាស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន មានមជ្ឈមណ្ឌលរដ្ឋ មណ្ឌលឯកជន និងអង្គការចំនួន ១៥កន្លែង បានទទួលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនចំនួន ១២ ៨៣៦នាក់ ស្រី ៧៣៤នាក់ ឱ្យស្នាក់នៅបន្សាប ព្យាបាល និងស្តារនីតិសម្បទា និងបញ្ចេញជន រងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន ១២ ២៨៧នាក់ ស្រី ៨៩០នាក់ ដូចនេះ នៅសល់ជាក់ស្តែងចំនួន ៥ ៦៤៩ នាក់ ស្រី ២៧១នាក់។

១៦០. បានចេញលិខិតអនុញ្ញាត និងទទួលស្គាល់លើផ្នែកស្តារនីតិសម្បទាដល់មណ្ឌលចំនួន ០៣ រួមមានមណ្ឌលបន្សាបព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន កែ ស៊ុនួន ខេត្តបាត់ដំបង មណ្ឌលធីនឆាឡេន នៃកម្ពុជា ខេត្តតាកែវ និងមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន (DTA) រាជធានីភ្នំពេញ។

### ឃ. កម្មវិធីជំនួយសង្គម

១៦១. ចំពោះការអនុវត្តកម្មវិធីជំនួយសង្គម រដ្ឋាភិបាលបានផ្តល់ប្រាក់ឧបត្ថម្ភជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ០២ឆ្នាំថ្មីសរុបចំនួន ៥៣ ៧៩៧នាក់(ស្ត្រីមានផ្ទៃពោះ ៤៣ ៦៨៨នាក់) ហើយស្ត្រី និងកុមារមកអនុវត្តលក្ខខណ្ឌបានចំនួន ៤៦១ ៣១៥ករណី ដែលបានចំណាយថវិកាសរុប ៣៦ ៩៣៧ ៤៤០ ០០០រ។

១៦២. រាជរដ្ឋាភិបាលបានឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ចាប់ផ្តើមពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ដល់ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៣ ចំនួន ៧០៥ ៧១៦គ្រួសារ ដែលបានចំណាយទឹកប្រាក់សរុបចំនួន ៥ ០៩៩ ៨០៤ ២២៥ ០០០រ។

១៦៣. កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណាសម្រាប់ ២៥ រាជធានី ខេត្ត ដែលមានគ្រួសារទទួលផលសរុបចំនួន ៤៩៥ ៣០៧គ្រួសារ ដែលចំណាយថវិកាចំនួន ១៧៥ ៩៥២ ៨៣៦ ០០០រ។

១៦៤. កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ជូនគ្រួសាររងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីទឹកជំនន់សម្រាប់ ១៦ រាជធានី ខេត្ត មានគ្រួសារទទួលផលសរុបចំនួន ៩៩ ១៦៩គ្រួសារ ដែលចំណាយថវិកាចំនួន ៤៦ ៧៩៩ ០៤៨ ០០០រ។

១៦៥. នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៣ រាជរដ្ឋាភិបាលបានប្រកាសជាផ្លូវការដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំស្តីពីក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ និងគោលការណ៍ណែនាំស្តីពីក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន។ កម្មវិធីជំនួយសង្គមក្នុងកញ្ចប់គ្រួសារ គឺជាបណ្តុំកម្មវិធីជាតិជំនួយសង្គមចំនួន ៥ រួមមាន៖ (១.) កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ០២ឆ្នាំ (២.)កម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្រនៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ (៣.) កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព (៤.) កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរា (អាយុ ៦០ឡើង) និង(៥.) ការឧបត្ថម្ភសម្រាប់គ្រួសារដែលមានបណ្ណសមធម៌ទាំងអស់ និងគិតគូរដល់សមាជិកគ្រួសារដែលរស់នៅជាមួយមេរោគអេដស៍/ជំងឺអេដស៍។ ចំពោះកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ នឹងត្រូវចាប់ផ្តើមចាប់ពីខែមេសា ឆ្នាំ២០២៤ តទៅ។

១៦៦. ប.ស.ស. បានបន្តនិរន្តរភាព និងបង្កើនប្រសិទ្ធភាពការបើកផ្តល់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់ស្ត្រីមានផ្ទៃពោះមុនពេលសម្រាលកូនចំនួន ៤លើក និងក្រោយពេលសម្រាលកូនរហូតដល់កូនអាយុ ២ឆ្នាំចំនួន ១០លើក ដោយ១លើកទទួលបានថវិកា ៤ម៉ឺនរៀល ក្នុង ១នាក់ និងប្រាក់ឧបត្ថម្ភពេលសម្រាលកូនចំនួន ៨០ម៉ឺនរៀល ក្នុងកូន ១នាក់ ដើម្បីលើកកម្ពស់សុខុមាលភាពមាតា និងទារក រួមចំណែកដោះស្រាយបញ្ហាកង្វះអាហាររូបត្ថម្ភ ព្រមទាំងជំរុញការលូតលាស់ទាំងកាយសម្បទា និងបញ្ញាស្មារតីរបស់កូនចៅ ដែលជាសមាជិក ប.ស.ស.។ ក្នុងឆ្នាំ២០២៣ ការបើកផ្តល់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះមុនពេលសម្រាល ពេលសម្រាល និងក្រោយពេលសម្រាលកូន រហូតដល់កូនអាយុ២ឆ្នាំ មានស្ត្រីជាម្តាយចំនួន ១០១ ៩៦៤នាក់ និងកូនចំនួន ៨៩ ០៣៨នាក់ ដោយបានចំណាយថវិកាអស់ប្រមាណ ៤៤ ៨០៧ ៦៨០ ០០០រៀល។

១៦៧. ក្រសួង ក.ប. បានបន្តនិរន្តរភាពកុមារក្នុងគម្រោងដកហូតទប់ស្កាត់ពលកម្មកុមារចំនួន ២០០នាក់ (ស្រី ១០០នាក់) ក្នុងខេត្តសៀមរាប ត្បូងឃ្មុំ កំពង់ចាម និងបាត់ដំបង។ កុមារដែលបន្តនិរន្តរភាព គឺបានជ្រើសរើសកុមារដែលមានកង្វះអាហាររូបត្ថម្ភ លទ្ធផលនៃការសិក្សានៅមានកម្រិតទាប និងស្ថានភាពក្រីក្រនៃគ្រួសារមិនអាចធានារ៉ាប់រងការសិក្សាគង់វង្សរបស់កុមាររយៈពេលវែងបាន។

# ៥. ការចូលរួមរបស់កុមារ[18]

## ៥.១. ក្រុមប្រឹក្សាកុមារកម្ពុជា ក្រុមប្រឹក្សាយុវជនកម្ពុជា និងកាយរឹទ្ធិជាតិកម្ពុជា[19]

១៦៨. ក្រុមប្រឹក្សាកុមារកម្ពុជានៅតាមគ្រឹះស្ថានសិក្សាចំនួន ៨ ៩៨០ មានសមាជិក ១ ៥៦៣ ២៩៤នាក់ (ថយ ០,៨៤%) ស្រី ៧៨៦ ៩៨៣នាក់ (ថយ ៣,០៣%) និងក្រុមប្រឹក្សាយុវជនកម្ពុជានៅតាមគ្រឹះស្ថានសិក្សា ៦០៦ មានសមាជិក ៣៧៤ ៦៨៤នាក់ (កើន ៣,៩០%) ស្រី ២០៤ ៥៩៤នាក់ (កើន ៤,១៣%) ធៀបទៅនឹងឆ្នាំសិក្សា២០២២-២០២៣។

១៦៩. សមាជិកកាយរឹទ្ធិជាតិកម្ពុជា ១៨០ ០០០នាក់ (កើន ២,៨៥%) ស្រី ៤៩% ក្នុងនោះកាយរឹទ្ធិប្អូន ១៨ ១១៦នាក់ ស្រី ៨ ៨៧៧នាក់ កាយរឹទ្ធិជំទង់ ១២៣ ៥៩៥នាក់ ស្រី ៦០ ៥៦១នាក់ កាយរឹទ្ធិ រៀមច្បង ២២ ១១៧នាក់ ស្រី ១០ ៨៣៧នាក់ មេដឹកនាំកាយរឹទ្ធិ ១៣ ៥៦៧នាក់ ស្រី ៦ ៦៤៨នាក់ និងសមាជិកកិត្តិយស ២ ៥០៥នាក់ ស្រី ១ ២២៧នាក់ នៅតាមគ្រឹះស្ថានសិក្សា និងសហគមន៍។

១៧០. ក្រសួង អ.យ.ក. បានផ្តល់ឱកាសដល់យុវជន និងកុមារក្នុងការអនុវត្តគម្រោងស្ម័គ្រចិត្ត និងធ្វើការប្រកួតប្រជែង បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលស្តីពីការងារស្ម័គ្រចិត្ត ដែលបង្ហាញពីការចូលរួមរបស់យុវជន និងកុមារ ដើម្បីបង្ហាញពីសមត្ថភាព ការរួមចំណែក និងទស្សនៈរបស់ពួកគេ។ កម្មវិធីនេះ ឆ្លើយតបនឹងអាទិភាពទី៥ នៃផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា។ ក្រសួងបានរៀបចំទិវាអន្តរជាតិអ្នកស្ម័គ្រចិត្ត អបអរសាទរ និងលើកទឹកចិត្តដល់យុវជនស្ម័គ្រចិត្ត ដើម្បីបង្ហាញអំពីស្នាដៃការងារស្ម័គ្រចិត្តរបស់ខ្លួន។ កម្មវិធីយុវជន និងកុមារ បានជះឥទ្ធិពលដល់ការអភិវឌ្ឍយុវជន និងកុមារគួរឱ្យកត់សម្គាល់ដោយផ្ទាល់ និងប្រយោល។ យុវជន និងកុមារដែលបានចូលរួមផ្ទាល់ក្នុងកម្មវិធីនេះ ទទួលបានការបំប៉នចំណេះដឹង និងសមត្ថភាពបន្ថែមពីលើការសិក្សាក្នុងថ្នាក់រៀន តាមរយៈការអនុវត្តជាក់ស្តែងស្របតាមបរិបទសតវត្សរ៍ទី២១។

## ៥.២. បណ្តាញយុវជន បណ្តាញកុមារ និងក្លឹបកុមារ

១៧១. ក្រៅពីក្រុមប្រឹក្សាកុមារកម្ពុជា ក្រុមប្រឹក្សាយុវជនកម្ពុជា កាយរឹទ្ធិជាតិកម្ពុជា និងយុវជនកាកបាទក្រហម ក៏មានអង្គការសង្គមស៊ីវិលជាច្រើនបានបង្កើតនូវបណ្តាញយុវជន បណ្តាញកុមារ និងក្លឹបកុមារ ដែលមានគោលដៅលើកកម្ពស់ការចូលរួម សាមគ្គីភាព ការចែករំលែកបទពិសោធន៍ និងទស្សនៈ ជាពិសេសសំឡេងរបស់ពួកគេទាក់ទងនឹងបញ្ហាកុមារនៅកម្ពុជា ដែលក្នុងនោះមានដូចជា អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា និងសមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ។ល។

---

18 កុមារមានសិទ្ធិចូលរួមក្នុងការបញ្ចេញមតិយោបល់លើបញ្ហា ឬសកម្មភាពដែលមានឥទ្ធិពលដល់ដំណើរជីវិតរបស់ពួកគេ ចូលរួមសកម្មភាពក្នុងសហគមន៍ ការប្រជុំនានា ចូលរួមការទទួលនិងផ្សព្វផ្សាយព័ត៌មាន ការអានសៀវភៅ កាសែត ទស្សនាវដ្តី មើលទូរទស្សន៍ ដើម្បីពង្រីកការយល់ដឹង និងចេះប្រើវិចារណញ្ញាណ រិះគិតចំពោះព្រឹត្តិការណ៍ផ្សេងៗ។

19 សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០២២-២០២៣ និងទិសដៅឆ្នាំសិក្សា២០២៣-២០២៤.

## ៦. កិច្ចសហប្រតិបត្តិការលើវិស័យកុមារ

### ៦.១.កិច្ចប្រតិបត្តិការរបស់អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ

១៧២. ទន្ទឹមនឹងកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ជាពិសេសក្រសួង ស្ថាប័ន ដែលបំពេញការងារផ្តោតលើកុមារ បានប្រឹងប្រែងក្នុងការលើកកម្ពស់សិទ្ធិកុមារពីថ្នាក់ក្រោមជាតិ និងថ្នាក់ក្រោមជាតិ យើងក៏មានអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ សង្គមស៊ីវិល ជាច្រើនបានចូលរួមសហការយ៉ាងសកម្មលើការការពារ និងលើកកម្ពស់ឧត្តមប្រយោជន៍កុមារ និងបានសហការយ៉ាងជិតស្និទជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដែលក្នុងនោះមានដូចជា អង្គការយូនីសេហ្វ អង្គការប្លែនអន្តរជាតិកម្ពុជា អង្គការឆាលហ្វានកម្ពុជា អង្គការដែនដីមនុស្ស-ហូឡង់ដ៍ អង្គការសង្គ្រោះកុមារ អង្គការទស្សនៈពិភពលោកអន្តរជាតិកម្ពុជា អង្គការភូមិកុមារ SOS អង្គភាពការពារកុមារ (CPU) អង្គការ Eriks អង្គការមូលនិធិហាការអន្តរជាតិ អង្គការសម្ព័ន្ធចាប់ដៃ អង្គការសម្ពន្ធដើម្បីសិទ្ធិកុមារកម្ពុជា អង្គការបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា អង្គការសកម្មភាពដើម្បីកុមារ អង្គការជីវិតថ្លៃថ្នូរ និងសមាគមចលនាកុមារនិងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ អង្គការម្លប់ឫស្សី អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ។ល។ ខាងក្រោមនេះ គឺជាលទ្ធផលការងាររបស់អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ព្រមទាំងសង្គមស៊ីវិលមួយចំនួនអនុវត្តការងារពាក់ព័ន្ធនឹងវិស័យកុមារ ដែលបានផ្តល់ជូនមក ក.ជ.ក.។

**ក. អង្គការប្លែន**

១៧៣. អង្គការប្លែនអន្តរជាតិកម្ពុជា បាននិងកំពុងអនុវត្តកម្មវិធីប្រចាំប្រទេសចំនួន០៤ រួមមាន៖

- ការចាប់ផ្តើមជាមួយសុខភាព
- កិច្ចការពារជំនាន់ថ្មី
- ការរៀនពេញមួយជីវិត
- ភាពអ្នកដឹកនាំរបស់ក្មេងស្រី

១៧៤. កម្មវិធីការចាប់ផ្តើមជាមួយសុខភាព៖ កម្មវិធីផ្តោតលើការគាំពារនិងអភិវឌ្ឍកុមារតូច អាហារូបត្ថម្ភ និងអនាម័យ (WASH) បានគាំទ្រកុមារា និងកុមារីចំនួនប្រមាណ ៣៥ ០០០នាក់ ឱ្យមានសុខភាពល្អ អាហារូបត្ថម្ភគ្រប់គ្រាន់ ទទួលបានក្នុងការសិក្សាដំបូងល្អបំផុត ការអភិវឌ្ឍតាមរយៈការឆ្លើយតបយេនឌ័រ ការផ្លាស់ប្តូរអាកប្បកិរិយា និងសង្គម ភាពងាយស្រួល និងសេវាប្រកបដោយគុណភាព។

១៧៥. កម្មវិធីកិច្ចការពារជំនាន់ថ្មី (Protection Plus) បានគាំទ្រដល់កុមារ និងយុវជនច្រើនជាង ៧ ៧០០នាក់ ដើម្បីរស់នៅដោយគ្មានអំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច និងការមិនអើពើរ ដោយផ្តល់នូវការសម្របសម្រួល ការឆ្លើយតបផ្សេងៗប្រកបដោយគុណភាពផ្អែកលើយេនឌ័រ និងអាយុ តាមរយៈការគាំទ្ររបស់អង្គការប្លែនអន្តរជាតិកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងសហគមន៍ និងក្រុមគ្រួសារផងដែរ។

១៧៦. កម្មវិធីសិក្សាពេញមួយជីវិត បានគាំទ្រដោយផ្ទាល់ដល់កុមារ និងយុវជនច្រើនជាង ១១៩ ០០០នាក់ ដើម្បីទទួលបាននូវការអប់រំប្រកបដោយគុណភាពគ្រប់គ្រាន់ និងការអភិវឌ្ឍជំនាញ ដែលអាចជួយ និងគាំទ្រដល់ការសិក្សាពេញមួយជីវិត និងការងារសមរម្យ។

១៧៧. កម្មវិធីភាពដឹកនាំរបស់ក្មេងស្រី បានបំពាក់បំប៉នទៅដល់កុមារីវ័យជំទង់ យុវនារី កុមារាវ័យជំទង់ និងយុវជនប្រមាណជាង ២ ១០០នាក់ ឱ្យក្លាយជាពលរដ្ឋសកម្ម និងជាពលរដ្ឋចូលរួម តាមរយៈការបណ្តុះបណ្តាលលើការផ្តល់អំណាច និងភាពជាអ្នកដឹកនាំ។

១៧៨. បានសហការរៀបចំជាមួយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ រៀបចំគោលការណ៍ណែនាំជាតិដើម្បីអន្តរាគមន៍ WASH សន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងបានចាប់ផ្តើមអនុវត្តនៅទូទាំងប្រទេសជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍។

១៧៩. បានសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រៀបចំ និងដាក់ឱ្យដំណើរការជាផ្លូវការនូវថ្នាលកម្មវិធីជាតិអេឡិចត្រូនិចវាយតម្លៃការសិក្សាពីមុន (E-Recognition for Prior Learning/E-RPL) សម្រាប់វាយតម្លៃលើសមត្ថភាពមូលដ្ឋាន និងការបញ្ជាក់។ ដែលជាផ្នែកសំខាន់ នៃគំនិតផ្តួចផ្តើមការរៀនតាមអេឡិចត្រូនិករបស់ TVET។ កម្មវិធីនេះ មានគោលបំណងលើកកម្ពស់បរិយាបន្ន និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលជំនាញសេវាកម្ម ដោយផ្តល់សេវាវាយតម្លៃការសិក្សាពីមុនដល់កម្មករ និងកម្មការិនីទូទាំងប្រទេស មុននឹងចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាល TVET ដោយមិនចាំបាច់បង្ហាញខ្លួនដោយផ្ទាល់នៅមជ្ឈមណ្ឌលវាយតម្លៃឡើយ។

១៨០. ជាមួយនឹងវិធីសាស្ត្រចូលរួមរបស់យុវជនរបស់អង្គការភ្លែន កុមារនិងយុវជនចេះរៀបចំផែនការ ធ្វើការអភិវឌ្ឍ និងដឹកនាំសកម្មភាព ក្នុងនោះរួមមាន៖ ការដើរតួជាអ្នកដឹកនាំរបស់កុមារី ទិវាអន្តរជាតិកុមារី កិច្ចសន្ទនាជាតិដឹកនាំដោយយុវជន មូលនិធិចូលរួមរបស់យុវជន(មានក្រុមយុវជនចំនួន ២០) និងការបញ្ចេញសម្លេងរបស់កុមារី បិទក្រុមអនឡាញ បង្កើតលំហរសុវត្ថិភាពសម្រាប់ការចែករំលែក និងរៀនសូត្រ។ ការលើកឡើងពីបញ្ហានៃការឈប់រៀន ការរៀបការវ័យក្មេង និងដោយបង្ខំ អំពើហិង្សាប្រឆាំងនឹងកុមារ និងភាពជាអ្នកដឹកនាំរបស់ក្មេងស្រី។ បន្ថែមទៀតនេះ យុទ្ធនាការទូតកុមារីទទួលបានសមភាពរបស់យើងបានប្រើនូវចំណេះដឹងរបស់គេលើការរៀបចំយុទ្ធនាការ ការនិយាយជាសាធារណៈ ការសម្របសម្រួល និងដឹកនាំក្នុងកម្រិតជាតិ និងសហគមន៍។

១៨១. ក្រៅពីការអនុវត្តគម្រោងខាងលើ អង្គការភ្លែនអន្តរជាតិកម្ពុជា បានជួយជាបច្ចេកទេស និងហិរញ្ញវត្ថុដល់អគ្គលេខាធិការដ្ឋាន ក.ជ.ក. ដើម្បីរៀបចំគោលការណ៍ថ្នាក់ជាតិស្តីពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ និងរៀបចំយន្តការពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តសិទ្ធិកុមារនៅកម្ពុជា។

### ៩. អង្គការឆាលហ្វានកម្ពុជា

១៨២. អង្គការឆាលហ្វានកម្ពុជា គឺជាការិយាល័យតំណាងរបស់អង្គការឆាលហ្វានអូស្ត្រាលី ដែលជាអង្គការអភិវឌ្ឍន៍អន្តរជាតិឯករាជ្យ បំពេញការងារដើម្បីកាត់បន្ថយភាពក្រីក្រសម្រាប់កុមារនៅក្នុងសហគមន៍កំពុងអភិវឌ្ឍ។ អង្គការឆាលហ្វានអូស្ត្រាលី គឺជាសមាជិកសម្ព័ន្ធអង្គការឆាលហ្វាដែលជាបណ្តាញសកល នៃអង្គការចំនួន ១២ ជួយដល់កុមារនិងគ្រួសាររបស់ពួកគេជិត ២៣លាននាក់ នៅក្នុងប្រទេសចំនួន៧០។

១៨៣. អង្គការឆាលហ្វាន បានចាប់ផ្តើមការងារនៅកម្ពុជា ក្នុងឆ្នាំ២០០៧ និងបានធ្វើការក្នុងភាពជាដៃគូ ដើម្បីបង្កើតឱ្យបាននូវសហគមន៍ ឬប្រព័ន្ធដែលជួយដល់កុមារងាយរងគ្រោះ និងយុវជនទាំងអស់បានយល់ និងជឿជាក់លើសិទ្ធិរបស់ពួកគេ។ គម្រោងជាច្រើនត្រូវបានអនុវត្តនៅតាមតំបន់ជនបទ នៃខេត្តស្វាយរៀង

ក្រចេះ ព្រៃវែង និងបាត់ដំបង ដោយផ្តោតលើការធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរស់នៅរបស់សហគមន៍ក្រីក្រ និងងាយរងគ្រោះ។

១៨៤. អង្គការឆាលហ្វាន បានគាំទ្រកុមារ និងក្រុមគ្រួសាររបស់គេ ក្នុងប្រទេសកម្ពុជាតាមរយៈកម្មវិធីអភិវឌ្ឍដែលមានរយៈពេលវែង ហើយផ្តោតសំខាន់លើវិស័យសំខាន់ ដូចជា៖ កិច្ចការពារកុមារ, ការអប់រំ និងការសិក្សារៀនសូត្រពីសង្គម និងផ្លូវចិត្ត។ វិស័យកិច្ចការពារកុមារនៃអង្គការឆាលហ្វានកម្ពុជា មានគោលបំណងពង្រឹងបរិយាកាសប្រកប ដោយសុវត្ថិភាពសម្រាប់កុមារា-កុមារី រួមទាំងកុមារដែលមានពិការភាពតាមរយៈយន្តការផ្លូវការ និងនៅសហគមន៍។ យុទ្ធសាស្ត្រនៃវិស័យកិច្ចការពារកុមារមាន៖

- **ប្រព័ន្ធផ្លូវការ** : ប្រព័ន្ធការពារកុមារដែលមានស្រាប់ មានដំណើរការ ក្នុងនោះអ្នកពាក់ព័ន្ធនិងអ្នកផ្តល់សេវាមានចំណេះដឹង ជំនាញ និងធនធានដើម្បីការពារ និងឆ្លើយតបទៅនឹងហានិភ័យនៃការការពារកុមារ។
- **គាំទ្រគ្រួសារ និងសហគមន៍** : ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំមានចំណេះដឹង និងជំនាញក្នុងការផ្តល់នូវសុវត្ថិភាពដល់កុមារដើម្បីអភិវឌ្ឍខ្លួនប្រកបដោយសក្តានុពល។
- **ចំណេះដឹង និងជំនាញការពារខ្លួនសម្រាប់កុមារ** : កុមារអាចកំណត់អត្តសញ្ញាណ ការពារ និងឆ្លើយតបទៅនឹងហានិភ័យនៅក្នុងកម្រិត និងវិសាលភាពនៃការគ្រប់គ្រងរបស់ពួកគេ និងអាចស្វែងរកជំនួយសមស្របនៅពេលដែលពួកគេត្រូវការ។

១៨៥. អង្គការឆាលហ្វាន់កម្ពុជា បាននិងកំពុងសហការ និងគាំទ្រដល់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រៀបចំឯកសារសម្រាប់ការបណ្តុះបណ្តាល ស្តីពីសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ។ ឯកសារសម្រាប់បណ្តុះបណ្តាលមាន ៤ ឯកសារផ្សេងៗគ្នាគឺ៖ ១. ឯកសារសម្រាប់បណ្តុះបណ្តាលគ្រូបង្គោល ២. ឯកសារសម្រាប់បណ្តុះបណ្តាលកម្លាំងសេវាសង្គម ៣. ឯកសារសម្រាប់បណ្តុះបណ្តាលឪពុកម្តាយ និងអ្នកថែទាំ និង ៤. ឯកសារសម្រាប់បណ្តុះបណ្តាលកុមារ និងយុវជន។ ឯកសារទាំងនេះ ត្រូវបានពិនិត្យ និងប្រមូលធាតុចូលពីក្រសួងស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូ ចំនួន ៣លើក ក្នុងឆ្នាំ២០២៣ និងបានដាក់ឱ្យប្រើប្រាស់សាកល្បងក្នុងស្រុកគោលដៅនៃខេត្តចំនួន ៣ គឺស្រុកសង្កែ ខេត្តបាត់ដំបង ស្រុកសំបូរ ខេត្តក្រចេះ និងស្រុកកំពង់ត្របែក ខេត្តព្រៃវែង។

១៨៦. អង្គការឆាលហ្វាន់កម្ពុជា និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដោយមានការគាំទ្រពីអង្គការឆាលហ្វាន់អូស្ត្រាលី និងអង្គការឆាលហ្វាន់វៀតណាម បានសហការបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ជាតិបានចំនួន ២០នាក់ (ស្រី ៦នាក់) លើការប្រើប្រាស់ឯកសារបណ្តុះបណ្តាល ស្តីពីសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ។ គ្រូបង្គោលថ្នាក់ជាតិបានបន្តបណ្តុះបណ្តាលទៅដល់អ្នកស្ម័គ្រចិត្តសហគមន៍ចំនួន ១២នាក់ (ស្រី ១១នាក់) និងអ្នកសម្របសម្រួលយុវជនចំនួន ៣០នាក់ (ស្រី ២១នាក់) ដើម្បីពួកគេបណ្តុះបណ្តាលបន្តដល់ក្រុមគោលដៅជាឪពុកម្តាយ អាណាព្យាបាល អ្នកថែទាំ យុវជន និងកុមារ។

១៨៧. អង្គការឆាលហ្វាន់កម្ពុជា និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានអនុវត្តសាកល្បងលើការប្រើប្រាស់ឯកសារសម្រាប់ការបណ្តុះបណ្តាល ស្តីពីសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ ដោយបានបណ្តុះបណ្តាលដល់កម្លាំងសេវាសង្គមនៅខេត្តបាត់ដំបង ក្រចេះ និងព្រៃវែង ចំនួន ១៦៦នាក់ (ស្រី ៦៨នាក់) ។ អ្នកស្ម័គ្រចិត្តសហគមន៍បានបណ្តុះបណ្តាលអំពីសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ

ដល់ក្រុមឪពុកម្ដាយ អាណាព្យាបាល និងអ្នកថែទា នៅស្រុកសង្កែ ខេត្តបាត់ដំបង ចំនួន ៥៣២នាក់ (ស្រី ៤២៣នាក់) ស្រុកសំបូរ ខេត្តក្រចេះ ចំនួន ៥៨៧នាក់ (ស្រី ៥៣៥នាក់) ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ចំនួន ៤៩២នាក់ (ស្រី ៤៤០នាក់)។ អ្នកសម្របសម្រួលយុវជនបានបណ្ដុះបណ្ដាលអំពីសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ ដល់កុមារ និងកុមារវ័យជំទង់ នៅស្រុកសង្កែ ខេត្តបាត់ដំបង ចំនួន ១ ០២១ នាក់ (ស្រី ៥៧២នាក់) ស្រុកសំបូរ ខេត្តក្រចេះ ចំនួន ១ ១០១នាក់ (ស្រី ៦២៨នាក់) ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ចំនួន ៩១១នាក់ (ស្រី ៥២៨នាក់)។

**ត. អង្គការដែនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជា**

១៨៨. នៅឆ្នាំ២០២៣ អង្គការដែនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជា (TdH NL) បានអនុវត្តគម្រោងចំនួន ០១ ឈ្មោះថា "សុវត្ថិភាពនិងសិទ្ធិកុមារតាមប្រព័ន្ធអនឡាញ" ហៅកាត់ថា "ស្រួល" ដែលមានដៃគូអនុវត្តគម្រោងចំនួន ០២ គឺ អង្គកាសកម្មភាពដើម្បីកុមារ និងអង្គការសេរីភាពកម្ពុជា-អូស្ត្រាលី និងមានកិច្ចសហការអនុវត្តគម្រោងជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងនាកយដ្ឋានគោលនយោបាយ ICT នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

១៨៩. អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សហការជាមួយអង្គការដែនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជា (TdH NL) បានរៀបចំសិក្ខាសាលា "ស្ដាប់សម្លេងរបស់កុមារ" សម្រាប់ជាការចាប់ផ្ដើមវាយតម្លៃពាក់កណ្ដាលផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ២០២១-២០២៥ ដែលមានចូលរួមសរុបចំនួន ៥៧នាក់ (ស្ត្រី ៣០នាក់) ក្នុងនោះកុមារចំនួន ២២នាក់។

១៩០. អង្គការដែនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជា សហការគាំទ្រនាយកដ្ឋានគោលនយោបាយ ICT នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានរៀបចំ សិក្ខាសាលាផ្សព្វផ្សាយអំពីសុវត្ថិភាពតាមប្រព័ន្ធអនឡាញ និង "គោលការណ៍ណែនាំស្ដីពីកិច្ចការពារកុមារលើប្រព័ន្ធអនឡាញសម្រាប់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលនៅកម្ពុជា"សម្រាប់មន្ត្រីថ្នាក់ក្រោមជាតិចំនួន ៤៧នាក់ (ស្ត្រី ១៤នាក់) ដែលមកពីមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ មកពីតាមបណ្ដាខេត្តចំនួន១២។

១៩១. អង្គការដែនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជា បានគាំទ្រអង្គការសេរីភាពកម្ពុជាអូស្ត្រាលីបង្កើត Chatbot Game ឈ្មោះ សុវត្ថិភាពរបស់ខ្ញុំតាមប្រព័ន្ធអនឡាញ ដើម្បីលើកកម្ពស់ការយល់ដឹងពីសុវត្ថិពតាមប្រព័ន្ធអនឡាញ ការស្វែងរកការគាំទ្រពីមិត្តភ័ក្តិ និងអាណាព្យាបាល និងការរាយការណ៍។ លីងទៅកាន់ Game https://www.facebook.com/MySafetyOnline?mibextid=AEUHqQ ។

១៩២. ដោយមានការគាំទ្រពីអង្គការដែនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជា អង្គការសេរីភាពកម្ពុជាអូស្ត្រាលីផ្ដល់វគ្គបណ្ដុះបណ្ដាលដល់កុមារ និងអាណាព្យាបាល ចំនួន ៦៧៩ នាក់ ដែលមានកុមារចំនួន ៥៧៩នាក់ (ស្រី ៤៦៩នាក់) អាណាព្យាបាលចំនួន ១៥០នាក់ ឱ្យយល់ដឹងពីសុវត្ថិភាពតាមប្រព័ន្ធអនឡាញ ការរាយការណ៍ និងការបញ្ជូនករណី មិត្តអប់រំមិត្ត និងការទំនាក់ទំនងដែលមានសុវត្ថិភាព។

១៩៣. ដោយមានការគាំទ្រពីអង្គការដែនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជា ក្រុមកុមារី និងអង្គការសេរីភាពកម្ពុជាអូស្ត្រាលីបានធ្វើការការផ្សព្វផ្សាយផ្ទាល់ពីសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ ទៅដល់កុមារនៅតាម

សាលារៀនចំនួន ៩៤១នាក់ និងការផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញដែលទៅដល់កុមារចំនួន ១៣១ ៣៥៦នាក់ (ក្មេងស្រី ៦០%) តាមរយៈការផុសជារូបភាព វីដេអូ ស្តីពីការការពារ ការរាយការណ៍ និងការឆ្លើយតប ចំពោះការរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញ។

១៩៤. អង្គការដែនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជា បានគាំទ្រអង្គកាសកម្មភាពដើម្បីកុមារ (APLE) បង្កើតជាកញ្ចប់មេរៀន ៣សំខាន់ៗ៖ (១.) មេរៀនសំរាប់អ្នកអនុវត្តច្បាប់ (២.) មេរៀនសំរាប់គ្រួសារជនរងគ្រោះ និង (៣.) មេរៀនអនុវត្តល្អៗ ក្នុងការឆ្លើយតប និងការផ្តល់សំណងដលជនរងគ្រោះ ។

១៩៥. អង្គការដែនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជា បានគាំទ្រអង្គកាសកម្មភាពដើម្បីកុមារផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការឈ្វេងយល់ និងការឆ្លើយតបបែបកុមារមេត្រីចំពោះបទល្មើសការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញចំនួន ៥វគ្គ ទៅដល់មន្ត្រីថ្នាក់ជាតិ និងក្រោមជាតិចំនួន ២០៣នាក់ (ស្រី ១០៤នាក់) តាមរយៈកិច្ចសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ។

### ឃ. អង្គការសកម្មភាពដើម្បីកុមារ (APLE)

១៩៦. អង្គការសកម្មភាពដើម្បីកុមារ (APLE) បានអនុវត្តនូវគម្រោងមួយឈ្មោះថា ពង្រឹងយន្តការសង្គម និងច្បាប់ដើម្បីការពារកុមារងាយរងគ្រោះ ឬរងការប៉ះពាល់ដោយអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ។ គម្រោងផ្តោតលើកម្មវិធីផ្តល់ជំនួយសម្រាប់កុមាររងគ្រោះ កម្មវិធីអភិវឌ្ឍផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ។

១៩៧. កម្មវិធីផ្តល់ជំនួយសម្រាប់កុមាររងគ្រោះ រួមមាន ជំនួយផ្នែកសង្គមកិច្ច និងជំនួយផ្នែកច្បាប់។ ជំនួយផ្នែកសង្គមកិច្ច រួមមាន ការគាំទ្រផ្នែកសម្ភារៈ និងការប្រឹក្សាយោបល់ក្នុងដំណាក់កាលអន្តរាគមន៍វិបត្តិដល់កុមាររងគ្រោះ និងគ្រួសារ ដែលមានទិន្នន័យសង្ខេប នៃលទ្ធផលសម្រេចបាន ដូចខាងក្រោម៖

| ក្រុមគោលដៅ | សម្រាប់ប្រចាំឆ្នាំ(មករា ដល់ធ្នូ ឆ្នាំ២០២៣) | | | |
|---|---|---|---|---|
| | ស្រី | ប្រុស | LGBTIQ+ | សរុប |
| កុមាររងគ្រោះ | ៤៩ | ០៩ | ០២ | ៦០ |
| កុមារងាយរងគ្រោះ | ០ | ១០ | ០ | ១០ |
| សាក្សី | ០១ | ០ | ០ | ០១ |
| គ្រួសារ | ១៣២ | ៨៣ | ០ | ២១៥ |
| មន្ត្រីសង្គមកិច្ចនិងបុគ្គលិកអង្គការដែលពាក់ព័ន្ធចូលរួមប្រជុំ | ៨២ | ៩៦ | ០ | ១៧៨ |
| សរុប | ២៦៥ | ២០៨ | ០២ | ៤៧៥ |

១៩៨. ជំនួយផ្នែកច្បាប់ពាក់ព័ន្ធនឹងកិច្ចការពារផ្លូវច្បាប់ដល់កុមាររងគ្រោះ ដែលមានទិន្នន័យសង្ខេប នៃលទ្ធផលសម្រេចបាន ដូចខាងក្រោម៖

| ក្រុមគោលដៅ | សម្រាប់ប្រចាំឆ្នាំ(មករា ដល់ធ្នូ ឆ្នាំ២០២៣) | | | |
|---|---|---|---|---|
| | ស្រី | ប្រុស | LGBTIQ+ | សរុប |
| កុមាររងគ្រោះ | ៤៦ | ០៩ | ០២ | ៥៧ |
| កុមារងាយរងគ្រោះ | ០ | ១០ | ០ | ១០ |
| សាក្សី | ០១ | ០ | ០ | ០១ |
| គ្រួសារ | ៥១ | ០៨ | ០ | ៥៩ |
| មន្ត្រីសង្គមកិច្ចនិងបុគ្គលិកអង្គការដែលពាក់ព័ន្ធចូលរួមប្រជុំ | ១២ | ០៨ | ០ | ២០ |
| សរុប | ១១០ | ៣៥ | ០២ | ១៤៧ |

១៩៩. កម្មវិធីអភិវឌ្ឍផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ៖ មានគោលបំណងសំដៅពង្រឹងសមត្ថភាពដល់មន្ត្រីអនុវត្តច្បាប់ស្តីពីការអនុវត្តបទដ្ឋានកុមារមេត្រី សម្របសម្រួលកិច្ចសហការជាមួយស្ថាប័នអនុវត្តច្បាប់ជាតិ និងអន្តរជាតិ លើការកំណត់អត្តសញ្ញាណ និងសង្គ្រោះកុមាររងគ្រោះ ការស៊ើបអង្កេតបទល្មើសផ្លូវភេទកុមារ និងចូលរួមជាមួយយន្តការថ្នាក់ជាតិសំដៅពង្រឹងយន្តការការពារកុមារនៅថ្នាក់ក្រោមជាតិ។ ក្រោមកិច្ចសហការពីក្រសួងជំនាញពាក់ព័ន្ធ អគ្គស្នងការស្នងការនគរបាលជាតិ ស្នងការដ្ឋានរាជធានីខេត្ត កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងអង្គការសកម្មភាពដើម្បីកុមារក្នុងឆ្នាំ២០២៣នេះ សម្រេចបាននូវលទ្ធផលដូចខាងក្រោម៖ កម្មវិធីបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ ៦វគ្គ ដែលមានអ្នកចូលរួមចំនួ ២៨៧នាក់ (ស្រី ១១៧នាក់)។ សិក្ខាសាលាពិគ្រោះយោបល់ និងឆ្លុះបញ្ចាំងការអនុវត្ត ចំនួន ៣វគ្គ ដែលមានអ្នកចូលរួម ១៦២នាក់។

២០០. ប្រតិបត្តិការទូរស័ព្ទ និងអ៊ីនធឺណិត Hotline ៖ ដំណើរការប្រព័ន្ធទូរស័ព្ទរាយការណ៍បន្ទាន់ ០៩២ ៣១១ ៥១១ និងបណ្តាញរាយការណ៍តាមប្រព័ន្ធអ៊ីនធឺណិត បានទទួលការរាយការណ៍ករណីសង្ស័យពាក់ព័ន្ធនឹងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារសរុបចំនួន ២៧១ករណី ក្នុងនោះមាន ២០៨ករណីសង្ស័យពាក់ព័ន្ធនឹងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ។ បានផ្តល់ព័ត៌មានពាក់ព័ន្ធករណីសង្ស័យនៃការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ ទៅកាន់តំណាងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា និងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីចាត់វិធានការបង្ការ ទប់ស្កាត់ និងស៊ើបអង្កេតតាមនីតិវិធីច្បាប់ ចំនួន ៧១ករណី។

២០១. ការត្រួតពិនិត្យការប្រើប្រាស់បន្ទប់សម្ភាសន៍កុមារមេត្រី៖ នគរបាលជំនាញប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានប្រើប្រាស់បន្ទប់សម្ភាសន៍កុមារមេត្រី ដែលបានរៀបចំឡើងដោយអង្គការសកម្មភាពដើម្បីកុមារ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បាត់ដំបង កណ្តាល និងកំពតដើម្បីសម្ភាសកុមារសង្ស័យរងគ្រោះពីការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ មានចំនួន២១៧នាក់ (ស្រី១៩៧)។

២០២. នៅខែមករា ឆ្នាំ២០២៣ អង្គការសកម្មភាពដើម្បីកុមារ បានប្រកាសដាក់ឲ្យដំណើរការនូវប្រព័ន្ធជំនួយការឌីជីថល "ពិសី" (Chatbot) ស្តីពីសុវត្ថិភាពកុមារនៅលើប្រព័ន្ធអនឡាញនៅលើហ្វេស ប៊ុកផេករបស់អង្គការសកម្មភាពដើម្បីកុមារ ដើម្បីផ្តល់ភាពងាយស្រួលដល់សាធារណៈជន កុមារ យុវជន និងកំលាំង

សេវាសង្គមងាយស្រួលក្នុងការរាយការណ៍ ស្វែងរកជំនួយគាំទ្រ និងស្វែងយល់បន្ថែមស្តីការប្រយុទ្ធប្រឆាំងបទល្មើសការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ។ បានសហការផលិតសៀវភៅគោលការណ៍ណែនាំសម្រាប់ធ្វើការបណ្តុះបណ្តាល ស្តីពីការឆ្លើយតបនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញសម្រាប់មន្ត្រីអនុវត្តច្បាប់។ បានផលិតឯកសារគោល នៃការអនុវត្តល្អៗលើការឆ្លើយបតទៅនឹងបទល្មើសកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ ជាមួយកុមារ និងគ្រួសារដែលរងផលប៉ះពាល់។ ចូលរួមកិច្ចប្រជុំជាទៀងទាត់ជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងអង្គការមិនមែនរដ្ឋាភិបាលជាតិអន្តរជាតិ ដើម្បីពង្រឹងកិច្ចសហការឱ្យបានកាន់តែល្អប្រសើរសម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារពីការកេងប្រវ័ញ្ច និងរំលោភបំពានគ្រប់ទម្រង់។ បានផ្សព្វផ្សាយសៀវភៅគោលការណ៍ប្រតិបត្តិបែបកុមារមេត្រីដល់មន្ត្រីអនុវត្តច្បាប់ មន្ត្រីក្រសួងស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ដើម្បីចូលរួមក្នុងការលើកកម្ពស់ការឆ្លើយតបបែបកុមារមេត្រីទៅនឹងបទល្មើសកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើកុមារ។

២០៣. កម្មវិធីបញ្ចូលរួមសហគមន៍ ឧស្សាហកម្ម និងប្រព័ន្ធផ្សព្វផ្សាយ ជាកម្មវិធីសំខាន់មួយក្នុងចំណោមកម្មវិធីទាំង០៤ របស់អង្គការសកម្មភាពដើម្បីកុមារ។ កម្មវិធីនេះត្រូវបានអនុវត្តក្នុងគោលបំណងបង្កើនចំណេះដឹងសមត្ថភាព និងជំនាញអំពីការបង្ការទប់ស្កាត់ និងការឆ្លើយតបចំពោះការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទកុមារ រួមទាំងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ ដល់កុមារ យុវជន ឪពុកម្តាយ គ្រូបង្រៀន សមាជិកសហគមន៍ អាជ្ញាធរមូលដ្ឋាន ក្រុមហ៊ុនឯកជន និងឧស្សាហកម្មអ៊ីនធឺណិត។ ដោយទទួលបានកិច្ចសហការ និងការសម្របសម្រួលពីភាគីពាក់ព័ន្ធ បានរៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹង វគ្គបណ្តុះបណ្តាល សិក្ខាសាលា និងយុទ្ធនាការ ដោយមានអ្នកចូលរួមសរុប ៥ ៨៧៦នាក់ (ស្រី ៣ ១៧៥ និង LGBTIQ ១២) ដោយមានកុមារ (អាយុតិចជាង១៨ឆ្នាំ) សរុបចំនួន ៣ ៤៩៨នាក់ (ស្រី ១ ៩៥៩ និង LGBTIQ ១១នាក់) និងមនុស្សពេញវ័យ (អាយុចាប់ពី១៨ឆ្នាំ) សរុបចំនួន ២ ៣៧៨នាក់ (ស្រី ១ ២១៦ និង LGBTIQ០១នាក់)។ យុទ្ធនាការផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ លើទំព័រហ្វេសប៊ុករបស់អង្គការសកម្មភាពដើម្បីកុមារ បានទៅដល់សាធារណជនទូទៅចំនួន ៣៨៤ ៨២៧នាក់។

**៦. អង្គការមូលនិធិហាការអន្តរជាតិ** (Hagar International Foundation)

២០៤. នៅឆ្នាំ២០២៣ អង្គការមូលនិធិហាការអន្តរជាតិ (Hagar International Foundation) បានជួយជនរងគ្រោះ ដែលជាអតិថិជនសរុបទាំងថ្មី និងចាស់បន្តរពីឆ្នាំមុនចំនួន ៤២៩នាក់ (ស្រី ៣៤៧នាក់) ដែលក្នុងនោះមានអតិថិជនថ្មីចំនួន ១៤១នាក់(ស្រី ១២០នាក់)។ ក្នុងចំណោមអតិថិជនសរុបទាំង ៤២៩នាក់ ក្នុងនោះ៖

- អតិថិជនចំនួន ២៧៧នាក់ (ស្រី ២៤៧នាក់) ជាជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនានា (ផ្អែកទៅលើការវិភាគ និងការកំណត់អត្តសញ្ញាណបឋមរបស់មន្ត្រីសង្គមកិច្ចនៃអង្គការហាការ តាមទម្រង់បែបបទរបស់សង្គមកិច្ច និងការសន្ទត់ជាបឋមរបស់មន្ទីសង្គមកិច្ច និងការិយាល័យសង្គមកិច្ច និងសុខមាលភាពសង្គម ក្រុង ស្រុក)

- អតិថិជនចំនួន ៦១នាក់(ស្រី ១៦នាក់)ជាជនរងគ្រោះដោយការបោកបញ្ឆោតតាមប្រព័ន្ធអ៊ីនធឺណិត
- អតិថិជនចំនួន ៥១នាក់ (ស្រី ៤៧នាក់) ជាជនរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទភាគច្រើនជាអនីតិជន
- អតិថិជនចំនួន ១៩នាក់ (ស្រី ១៦នាក់) ជាជនរងគ្រោះដោយអំពើរហិង្សាក្នុងគ្រួសារ និង
- អតិថិជនចំនួន ២១នាក់ (ស្រី ២១នាក់) ជាជនរងគ្រោះដោយសាររំលោភបំពានផ្សេងៗ។

២០៥. គម្រោងបានធ្វើសមាហរណកម្មអតិថិជនចំនួន ៦៩នាក់ (ស្រី ៦៧នាក់) ពីការថែទាំជំនួសនៅតាមសហគមន៍ ដូចជា គ្រួសារធម៌ សាច់ញាតិ និងដៃគូរ ត្រលប់ទៅសហគមន៍ និងក្រុមគ្រួសាររបស់ពួកគាត់វិញ បន្ទាប់ពីបានសហការនឹងបន្តរគាំទ្រជនរងគ្រោះទាំងនោះ និងអជ្ញាធរមូលដ្ឋានបន្តទៀត។ ក្រុមការងារបានចុះធ្វើការប៉ាន់ប្រមាណអតិថិជន និងក្រុមគ្រួសារ ជាមួយអាជ្ញាធរដែនដី បានបិទករណីអតិថិជនចំនួន ៧៣នាក់ (ស្រី ៧១នាក់) ដោយជោគជ័យក្រោមកិច្ចសហការជាមួយមន្ត្រីសង្គមកិច្ចគ្រប់ជាន់ថ្នាក់ និងអ្នកពាក់ព័ន្ធផ្សេងទៀត។

២០៦. តាមដាន និងប្រឹក្សាយោបល់ជាមួយអតិថិជនសរុបចំនួន ៨៤១នាក់ បានផ្តល់ជូនអតិថិជនចំនួន ១៣៥នាក់ (ស្រី ១២៥នាក់) នូវការប្រឹក្សាយោបល់ដោយជួបផ្ទាល់ និងតាមទូរស័ព្ទ។ ផ្អែកតាមឧបករណ៍វាយតម្លៃ ៧៦,៩% នៃអតិថិជន ដែលទទួលកាប្រឹក្សាយោបល់ មានភាពល្អប្រសើរចំពោះភាពធន់ និងភាពស៊ាំនឹងការប៉ះទង្គិចផ្លូវចិត្ត។ អតិថិជនចំនួន ៨២នាក់ (ស្រី ៧៤នាក់) បានបញ្ចប់ការផ្តល់ការប្រឹក្សាយោបល់ ដោយពួកគាត់មានភាពល្អប្រសើរទៅលើភាពធន់និង ភាពស៊ាំទៅនឹងការប៉ះទង្គិចផ្លូវចិត្ត។

២០៧. អតិថិជនចំនួន ៨៣នាក់ (ស្រី ៧៤នាក់) បានទទួលការគាំទ្រអាជីវកម្មខ្នាតតូច។ អតិថិជន ២២នាក់ (ស្រី ១៧នាក់) ទទួលបានការគាំទ្រសម្រាប់ការចូលរៀនជំនាញវគ្គខ្លីជាមួយហាង/សាលាដៃគូរ។ អតិថិជនចំនួន ៨៨នាក់ (ស្រី ៨០នាក់) បានទទួលការងារ និងប្រាក់ចំណូលសម្រាប់គាំទ្រជីវភាពគ្រួសារ។ អតិថិជនចំនួន ៥១នាក់ (ស្រី ៤២នាក់) បានទទួលការគាំទ្រសម្រាប់ការចូលរៀននៅសាលារៀន ។

២០៨. ជំនួយផ្នែកច្បាប់៖

- ផ្តល់ជូនជំនួយផ្នែកច្បាប់ជូនអតិថិជនសរុប ១៨៦នាក់ (ស្រី ១៦២នាក់)
- ផ្តល់ជូនការគាំទ្រផ្នែកច្បាប់នៅតុលាការទៅកាន់អតិថិជនចំនួន ១៣៥នាក់ (ស្រី ១២២នាក់)
- បិតករណីដោយជោគជ័យផ្នែកច្បាប់ចំនួន ៧០នាក់ (ស្រី ៦៦នាក់)

២០៩. ការងារបង្ការ ទប់ស្កាត់៖

- អ្នកទទួលផលដោយផ្ទាល់ពីគម្រោងសរុបចំនួន ១៦,២៧២នាក់ (ស្រី ១០,៥០៩នាក់)
- អ្នកទទួលផលដោយប្រយោលពីគម្រោងសរុបចំនួន ៦៥,០៨៨នាក់ (ស្រី ៤២,០៣៦នាក់)

២១០. សហការជាមួយមន្ត្រីបច្ចេកទេសថ្នាក់ជាតិក្រុមប្រឹក្សាជាតិដើម្បីកុមារ (ក.ជ.ក.) គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (គ.ជ.ប.ជ.) មន្ត្រីបច្ចេកទេសថ្នាក់ខេត្តពីមន្ទីសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា មន្ទីកិច្ចការនារី លេខាធិការដ្ឋាន គ.ជ.ប.ជ. ខេត្តគោលដៅ និងមន្ត្រីជំនាញរបស់អង្គការហាការ ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលស្តីពីកិច្ចការការពារកុមារ សិទ្ធិកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព កិច្ចការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ការបញ្ជូនករណីនិងការគ្រប់គ្រងករណី ការចូលរួម

របស់សហគមន៍ និងកុមារដោយផ្ទាល់ អំពីការការពារនិងការប្រយុទ្ធប្រឆាំងការកេងប្រវ័ញ្ច និងការជួញដូរមនុស្សទៅដល់ គ.ក.ស.ក. ស្រុក គ.ក.ន.ក. ឃុំ ក្រុមកុមារនិងយុវជន ក្រុមឪពុកម្ដាយគំរូ ក្រុមអ្នកដឹកនាំសាសនាចម្រុះ ក្រុមសហគមន៍ងាយរងគ្រោះ និងអតិថិជនបានចំនួន ៧១ លើក ក្នុងនោះមានអ្នកចូលរួមជាមុនស្សពេញវ័យសរុបចំនួន ១ ៦២៤នាក់ (ស្រី ៩០២នាក់) ។

២១១. ក្រោមការសហការណ៍ដោយផ្ទាល់ជាមួយមន្ត្រីសង្គមកិច្ចស្រុក ខេត្ត នឹងអជ្ញាធរមូលដ្ឋានថ្នាក់ឃុំ សង្កាត់ ក្នុងការលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ និងក្រុមដែលងាយរងគ្រោះផ្សេងទៀត នៅក្នុងសហគមន៍ អំពីការគោរពសិទ្ធិកុមារ ការការពារកុមារពីរំលោភបំពាននានា ការចិញ្ចឹមកូនបែបវិជ្ជមាន ចំណាកស្រុកដោយសសុវត្ថិភាព ការជួញដូរមនុស្ស និងយន្តការរាយការណ៍អំពីការរំលោភបំពាននានានៅតាមសហគមន៍ តាមរយៈយុទ្ធនាការផ្សព្វផ្សាយចំនួន ១១២ដង នៅតាមភូមិ ឃុំ ដែលមានអ្នកទទួលផលសរុបចំនួន ១១ ៨៧៩នាក់ (ស្រី ៧,៨៩៥នាក់) និងកុមារសរុបចំនួន ៣៥៤នាក់ (កុមារី ១៦៤នាក់)។

**ច. អង្គការសម្ព័ន្ធចាប់ដៃ**

២១២. អង្គការសម្ព័ន្ធចាប់ដៃ អនុវត្តលើគម្រោងចំនួន ៦ រួមមាន៖ ១.គម្រោងអ្នកមានស្នាដៃល្អទប់ស្កាត់ក្នុងសហគមន៍ ២.គម្រោងពង្រឹងប្រព័ន្ធ ៣.គម្រោងសម្ព័ន្ធ ៤.គម្រោងគ្រប់គ្រងករណី ៥.គម្រោងជំនួយផ្លូវច្បាប់ ៦.គម្រោងថែទាំអតិថិជនក្នុងសហគមន៍ ។

២១៣. គម្រោងអ្នកមានស្នាដៃល្អទប់ស្កាត់ក្នុងសហគមន៍ ជាគម្រោងមួយនៃកម្មវិធីទប់ស្កាត់របស់អង្គការសម្ព័ន្ធចាប់ដៃ ដែលមានគោលបំណងធ្វើការផ្សព្វផ្សាយជាសាធារណៈដល់ប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់ការយល់ដឹងទាក់ទងនឹងច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងរាល់ទម្រង់ផ្សេងទៀតនៃការកេងប្រវ័ញ្ចលើស្ត្រី និងកុមារ បញ្ហាប្រឈមក្រោយចំណាកស្រុកដោយប្រថុយប្រថាន និងផ្ដល់ចំណេះដឹងអំពីដំណើរការរៀបចំឯកសារក្នុងការធ្វើចំណាកស្រុកស្របច្បាប់។ តំបន់គោលដៅរបស់គម្រោង គឺស្ថិតនៅខេត្តត្បូងឃ្មុំ ស្រុកតំបែរ៖ រួមមានឃុំចំនួន៥ ដូចជា ឃុំចុងជាច ឃុំនាងទើត ឃុំទឹកជ្រៅ ឃុំត្រពាំងព្រីង និងឃុំសេដា ដែលមាន១៤ភូមិ សម្រាប់ការចុះផ្សព្វផ្សាយមានដូចជា៖ ភូមិស្វាយប៉ាក ពន្លាក ពង្រ នាងទើត សង្គម ត្រពាំងជ្រៃ ចារធំ ក្រសាំង ស្រម៉រ ត្រពាំងព្រីង ប្រឡោះ វាលតូច ស្រែខ្សាច់ និងភូមិកំពង់រាំង។ គម្រោងបានអនុវត្តនូវសកម្មភាពចំនួន ៦លើក ពាក់ព័ន្ធនឹងការបណ្ដុះបណ្ដាល ការផ្សព្វផ្សាយ និងការប្រមូលទិន្នន័យគម្រោង ដែលមានអ្នកចូលរួមចំនួន ៧២៥នាក់ (ស្រី ៥២៩នាក់)។

២១៤. គម្រោងពង្រឹងប្រព័ន្ធ ធ្វើការយ៉ាងជិតស្និទជាមួយស្ថាប័នថ្នាក់ជាតិដែលពាក់ព័ន្ធនានា និងអាជ្ញាធរថ្នាក់ក្រោមជាតិ ជាពិសេសថ្នាក់មូលដ្ឋានតាមស្រុកនៃខេត្តគោលដៅនានារួមមាន៖ ខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម តាមរយៈការផ្ដល់នូវវគ្គបណ្ដុះបណ្ដាលកសាងសមត្ថភាពទាក់ទងនឹងក្រមសីលធម៌ក្នុងការសម្ភាសន៍ និងកំណត់អត្តសញ្ញាណជនរងគ្រោះ និងច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងរាល់ទម្រង់ផ្សេងទៀតនៃការកេងប្រវ័ញ្ចលើស្ត្រី និងកុមារ និងប្រធានបទនានាទាក់ទងនឹងការធ្វើចំណាកស្រុក។ គម្រោងមានគោលបំណង ១.ផ្ដល់ចំណេះដឹង ស្ដីពីនីតិវិធីនៃការស៊ើបអង្កេត និងក្រមសីលធម៌ក្នុងការសម្ភាស និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ២. បង្កើនការយល់ដឹងតាមរយៈការចែករំលែកបទពិសោធន៍ ការអនុវត្តករណីជាក់ស្ដែង និង

ការបង្ក្រាបអំពើជួញដូរមនុស្ស ៣. បង្កើនសមត្ថភាពបន្ថែមក្នុងការបង្រៀន និងផ្សព្វផ្សាយនៅក្នុងសហគមន៍ ក្នុងគោលដៅដើម្បីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ។

២១៥. គម្រោងពង្រឹងប្រព័ន្ធនៅខេត្តកំពង់ចាម បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរមនុស្ស ការសម្ភាសន៍កុមារមេត្រី ការសម្ភាសប្រកបដោយសីលធម៌ និងជនបង្គោល ចំនួន ៣លើក មានអ្នកចូលរួម ៣៥នាក់ (ស្រី ៣៣នាក់)។ បានរៀបចំវេទិកាផ្សព្វផ្សាយស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស រំលោភបំពានគ្រប់ទម្រង់ និងការចំណាកស្រុក ចំនួន ៥លើក ដែលមានអ្នកចូលរួមសរុបចំនួន ៤២៧នាក់ (ស្រី ៣៤៥នាក់)។ បានចុះសម្ភាសន៍ថ្នាក់ដឹកនាំរបស់សិក្ខាកាមចំនួន ១លើក ដែលមានអ្នកចូលរួម ១៩នាក់ (ស្រី ១នាក់)។ បានធ្វើការប្រជុំឆ្លុះបញ្ចាំងជាមួយសិក្ខាកាមចំនួន ១ មានអ្នកចូលរួម ១៩នាក់ (ស្រី ១នាក់)។

២១៦. គម្រោងពង្រឹងប្រព័ន្ធនៅខេត្តត្បូងឃ្មុំ បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរមនុស្ស ការសម្ភាសន៍កុមារមេត្រី ការសម្ភាសប្រកបដោយសីលធម៌ និងជនបង្គោល ចំនួន ៣លើក មានអ្នកចូលរួម ៣៤នាក់ (ស្រី ២៣នាក់)។ បានរៀបចំវេទិកាផ្សព្វផ្សាយស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស រំលោភបំពានគ្រប់ទម្រង់ និងការចំណាកស្រុក ចំនួន ៦លើក ដែលមានអ្នកចូលរួមសរុបចំនួន ៦៧០នាក់ (ស្រី ៤៣៧នាក់)។ បានចុះសម្ភាសន៍ថ្នាក់ដឹកនាំរបស់សិក្ខាកាមចំនួន ១លើក ដែលមានអ្នកចូលរួម ១៩នាក់ (ស្រី ១នាក់)។ បានធ្វើការប្រជុំឆ្លុះបញ្ចាំងជាមួយសិក្ខាកាមចំនួន ១ មានអ្នកចូលរួម ៣០នាក់ (ស្រី ២០នាក់)។

២១៧. គម្រោងសម្ព័ន្ធ មានបុគ្គលិកចំនួន ៥នាក់ (ស្ត្រីចំនួន ៣នាក់) យើងធ្វើការពង្រឹងសមត្ថភាពអង្គការដៃគូ និងជាសមាជិកមានសមត្ថភាពក្នុងការបំពេញការងាររបស់ខ្លួន ក្នុងបញ្ហាដែលទាក់ទងទៅនឹងការជួញដូរមនុស្សពីការរំលោភបំពាន និងការកេងប្រវ័ញ្ច ព្រមទាំងការភ្ជាប់បណ្តាញ និងដៃគូ ជាមួយអង្គការនានានៅក្នុង និងក្រៅប្រទេសកម្ពុជា ដើម្បីរួមគ្នាក្នុងការដោះស្រាយ ដែលមានអ្នកទទួលផលចំនួន ១០៩៧នាក់ (ស្រី ៦៣៧នាក់) និងអង្គការចំនួន ៨។

២១៨. គម្រោងគ្រប់គ្រងករណី ផ្តល់សេវាក្នុងការទទួលការហៅទូរស័ព្ទពីជនរងគ្រោះទាក់ទងនឹងករណីផ្សេងៗ ដូចជា៖ ករណីជួញដូរមនុស្ស ជួញដូរផ្លូវភេទ និងរំលោភសេពសន្ថវៈ ហើយបន្ទាប់មកកំណត់អត្តសញ្ញាណជនរងគ្រោះ។ គម្រោងក៏មានសកម្មភាពជួយដល់ជនរងគ្រោះទាំងក្នុង និងក្រៅប្រទេសផងដែរ ដោយការធ្វើការទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធដូចជា ស្ថានទូត និងអគ្គកុងស៊ុលកម្ពុជានៅបរទេស ដើម្បីជួយដល់ជនរងគ្រោះ និងឧបត្ថម្ភក្នុងការធ្វើមាតុភូមិនិវត្តន៍។ ជាមួយគ្នានេះផងដែរ គម្រោងមានផ្តល់សេវាប្រឹក្សាយោបល់ដល់ជនរងគ្រោះបន្ទាប់ពីកំណត់អត្តសញ្ញាណរួច។ គម្រោងគ្រប់គ្រងករណីបានអន្តរាគមន៍សរុបចំនួន ១២៦ករណី (ករណីជួញដូរមនុស្សចំនួន ៦៨ករណី និងករណីរំលោភសេពសន្ថវៈចំនួន ៥៨ករណី) ដែលស្ថិតនៅក្នុងខេត្តគោលដៅចំនួន ២១រាជធានី ខេត្ត រួមមាន៖ ព្រះវិហារ ស្វាយរៀង កណ្តាល សៀមរាប កំពង់ចាម ត្បូងឃ្មុំ បន្ទាយមានជ័យ កំពង់ស្ពឺ កំពង់ធំ កំពត កំពង់ឆ្នាំង កោះកុង ស្ទឹងត្រែង ក្រចេះ រតនៈគីរី មណ្ឌលគីរី ព្រៃវែង ពោធិ៍សាត់ ភ្នំពេញ ព្រះសីហនុ។

២១៩. គម្រោងគ្រប់គ្រងករណី បានតាមដាន និងធ្វើការប៉ាន់ប្រមាណគ្រួសារសរុបចំនួន ៦៣ករណី (ករណីជួញដូរមនុស្សចំនួន ២១ករណី និងករណីរំលោភសេពសន្ថវៈចំនួន ៤២ករណី) ដែលស្ថិតនៅក្នុងខេត្ត

គោលដៅចំនួន ១៣រាជធានី ខេត្ត រួមមាន៖ ព្រះវិហារ ស្វាយរៀង កំពង់ចាម ត្បូងឃ្មុំ បន្ទាយមានជ័យ កំពង់ធំ កំពត កំពង់ឆ្នាំង ក្រចេះ មណ្ឌលគីរី ព្រៃវែង ពោធិ៍សាត់ ភ្នំពេញ។

២២០. សម្របសម្រួលគ្រួសារជនរងគ្រោះដាក់ពាក្យបណ្តឹង ចំនួន ៧៨ករណី។ បានជូនជនរងគ្រោះ និងក្រុមគ្រួសារទៅដាក់លិខិតអន្តរាគមន៍នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំពោះករណីរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ៦៨ករណី។ បានសហការជាមួយមន្ត្រីសង្គមកិច្ច អាជ្ញាធរមូលដ្ឋាន ប៉ូលិស មន្ត្រី គ.ក.ន.ក. ក្នុងការធ្វើសមាហរណកម្មជនរងគ្រោះទៅក្នុងសហគមន៍ចំនួន ៣៦ករណី។ បានអមដំណើរជនរងគ្រោះ និងក្រុមគ្រួសារទៅតុលាការ ចំនួន ១៥ករណី។ បានបិទករណីដោយសហការជាមួយមន្ត្រីសង្គមកិច្ច អាជ្ញាធរមូលដ្ឋាន និងប៉ូលិស ចំនួន ១៣៧ករណ។

២២១. គម្រោងជំនួយផ្លូវច្បាប់ក្នុងអង្គការសម្ព័ន្ធចាប់ដៃ មានគោលដៅផ្តល់យុត្តិធម៌ និងការគាំទ្រផ្លូវច្បាប់ដល់ជនរងគ្រោះ ដែលជាបុរស ស្ត្រី កុមារា និងកុមារី ក្នុងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រំលោភបំពានផ្លូវភេទ ដោយអនុវត្តន៍តាមប្រព័ន្ធច្បាប់នៃប្រទេសកម្ពុជា។ គម្រោងជំនួយផ្លូវច្បាប់បានគាំទ្រផ្លូវច្បាប់សរុបចំនួន ៣៦ករណី (ករណីជួញដូរមនុស្ស ១០ករណី និងករណីរំលោភបំពាន ២៦ករណី) ដែលស្ថិតនៅក្នុងខេត្តគោលដៅចំនួន ៨រាជធានី ខេត្ត រួមមាន៖ ព្រះវិហារ ស្វាយរៀង កំពង់ចាម ត្បូងឃ្មុំ កំពត កំពង់ឆ្នាំង ពោធិ៍សាត់ ភ្នំពេញ។

២២២. គម្រោងថែទាំអតិថិជនក្នុងសហគមន៍ ធ្វើការជាមួយស្ត្រី និងកុមារ ដែលជាជនរួចពីរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ ដើម្បីទទួលបានការស្តារសុខុមាលភាពឡើងវិញ រស់នៅក្នុងភាពប្រក្រតី និងបង្កើតទំនាក់ទំនងល្អឡើងវិញជាមួយគ្រួសារ និងសហគមន៍។ គម្រោងថែទាំអតិថិជនក្នុងសហគមន៍ បានផ្តល់ប្រឹក្សាយោបល់ផ្លូវចិត្តដល់ជនរួចពីរងគ្រោះដោយអំពើជួញដូរ និងរំលោភបំពានសរុបចំនួន ៣២ករណីថ្មី ដែលស្ថិតនៅក្នុងខេត្តគោលដៅចំនួន ១៣ខេត្ត រួមមាន៖ ព្រះវិហារ ស្វាយរៀង កណ្តាល កំពង់ចាម ត្បូងឃ្មុំ កំពត កំពង់ឆ្នាំង ស្ទឹងត្រែង ក្រចេះ រតនៈគីរី មណ្ឌលគីរី ព្រៃវែង តាកែវ។ ជំនួបក្នុងការផ្តល់សេវាប្រឹក្សាយោបល់ផ្លូវចិត្តរបស់គម្រោងថែទាំអតិថិជនក្នុងសហគមន៍ ដល់ជនរួចពីរងគ្រោះក្នុងមួយករណីយ៉ាងហោចណាស់ ៦ជំនួប។ ដូច្នេះ សម្រាប់ការផ្តល់សេវាប្រឹក្សាយោបល់ផ្លូវចិត្តទាំង ៣២ករណី ជំនួបសរុបចំនួន ១៤៨ជំនួប។

**ឆ. អង្គការសង្គ្រោះកុមារ** (Save the Children)

២២៣. អង្គការសង្គ្រោះកុមារ បាននិងកំពុងអនុវត្តគម្រោងចំនួន ៦ ដូចខាងក្រោម៖

- គម្រោងទប់ស្កាត់ និងការកាត់បន្ថយអំពើហិង្សាលើកុមារ និងស្ត្រី តាមរយៈការបង្កើនការចូលរួមរបស់បុរស (RECOVER)
- គម្រោងលុបបំបាត់អំពើហិង្សាលើកុមារនៅសាលារៀន (EVACIS)
- គម្រោងពង្រឹងសមត្ថភាពអង្គការសង្គមស៊ីវិលដើម្បីសិទ្ធិកុមារ(SIDA-CSO Strengthening)
- គម្រោងថែទាំកុមារក្នុងគ្រួសារជាអាទិភាពចម្បង "Family Care First (FCF)"
- គម្រោងសិទ្ធិកុមារ រួមទាំងកុមារដែលមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ (SOGIE)
- គម្រោង SHIFT 360 យុទ្ធនាការសុវត្ថិភាពតាមប្រព័ន្ធអនឡាញ ដឹកនាំដោយយុវជននៅកម្ពុជា

២២៤. អង្គការសង្គ្រោះកុមារបានផ្តល់ការគាំទ្រហិរញ្ញវត្ថុ និងធាតុចូលដល់ក្រសួង ស.អ.យ ក្នុងការកែសម្រួលលើសេចក្តីព្រាងនៃបទដ្ឋានស្តីពីអង្គការសុវត្ថិភាពកុមារ ព្រមទាំងបានចូលរួមសហការកសាងផែនការកិច្ចការពារកុមាររយៈពេល ៣ ឆ្នាំ (២០២៣-២០២៥) នៅថ្នាក់ជាតិ និងក្រោមជាតិ ជាមួយ គ.ក.ស.ក. និង គ.ក.ន.ក. ក្នុងខេត្តគោលដៅចំនួន ៩ មានដូចជា៖ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តកំពង់ធំ រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពត ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង។ អង្គការក៏បានបានសហការជាមួយក្រសួង ស.អ.យ. និងផ្នែកពាក់ព័ន្ធ រៀបចំទិវាសង្គមកិច្ច។

២២៥. អង្គការសង្គ្រោះកុមារបានរៀបចំកិច្ចប្រជុំលេខាធិការដ្ឋានជាប្រចាំ ដោយពិភាក្សាលើប្រធានបទដូចជា (១.) គម្រោងបន្ត ២១ខែ ពីដំណើរការជ្រើសរើសជំនួយ និងការចូលរួមរបស់ក្រសួងស.អ.យ (២.) លក្ខខណ្ឌនៃលក្ខន្តិកៈក្រុមប្រឹក្សាយោបល់ និងលេខាធិការដ្ឋានរបស់គម្រោង FCF (៣.) ព័ត៌មានលម្អិតនៃទស្សនៈកិច្ចសិក្សាពីក្រសួង ស.អ.យ. (៤.) ការស្នើទិន្នន័យអធិការកិច្ចមណ្ឌលថែទាំកុមារនៅខេត្តគោលដៅសម្រាប់រយៈពេល ២១ ខែ (៥.) ស្នើការគាំទ្រពីក្រសួង ស.អ.យ. ដល់មណ្ឌលសុវណ្ណភូមិកុមារ ក្នុងដំណើរការបង្វែរមណ្ឌលថែទាំកុមារ (៦.) ជម្រាបជូនឯកឧត្តមអគ្គនាយកថ្មីនៃនាយកដ្ឋានសេវាសង្គមកិច្ចពីកិច្ចខិតខំប្រឹងប្រែងកន្លងមក និងគម្រោងបន្ត (៧.) បានពិភាក្សាស្នើឱ្យមានការដឹកនាំពីក្រសួងស.អ.យ និងមន្ទីរស.អ.យ ក្នុងភាពជោគជ័យនៃការបង្វែរ ឬការបិទមណ្ឌលថែទាំកុមារ និងសមាហរណកម្ម និង (៨.) ការស្នើពិនិត្យលើអត្ថបទសំណោរការផលិតវីដេអូការថែទាំដោយឪពុកម្តាយធម៌។

២២៦. ក្នុងគម្រោងថែទាំកុមារក្នុងគ្រួសារជាអាទិភាពចម្បង(FCF) អង្គការសង្គ្រោះកុមារបានរៀបចំកិច្ចប្រជុំដៃគូគម្រោង (Learning Summits) ចំនួន ២លើក ដែលមានការចូលរួមពីទីភ្នាក់ងារជំនួយអាមេរិក (USAID) អង្គការ UNICEF អន្តរក្រសួង មន្ទីរ ស.អ.យ. និង គ.ក.ស.ក. ថ្នាក់ខេត្ត មកពីខេត្តគោលដៅចំនួន ៩។ គម្រោង FCF បានធ្វើការសិក្សាស្រាវជ្រាវចំនួន ៣ រួមមាន៖ (១). ការសិក្សាលើរបាយការណ៍ពីសាច់ញាតិ និងការថែទាំជំនួស និងបកប្រែដាក់ជូនក្រសួង ស.អ.យ. ដើម្បីអនុម័ត និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការ (២). ការសិក្សាលើឯកសារដែលមានស្រាប់ វាយតម្លៃការអនុវត្ត ផលប៉ះពាល់នៃការស្រាវជ្រាវ និងអនុសាសន៍លើក្របខ័ណ្ឌគោលនយោបាយច្បាប់ និង (៣). ការស្ទង់មតិភាពជាដៃគូប្រចាំឆ្នាំ និងចែករំលែកផែនការសកម្មភាព ដើម្បីអនុវត្តអនុសាសន៍ជាមួយសមាជិកបណ្តាញគម្រោង ។

២២៧. គម្រោង FCF សហការជាមួយវិទ្យាស្ថានជាតិសង្គមកិច្ច (NISA) រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ ដល់កម្លាំងសេវាសង្គមកម្រិត ១, ២, ៣ និងកម្រិត៤ ដោយបានរៀបចំវគ្គបណ្តុះបណ្តាលចំនួន ៣លើក នៃកម្រិត ១ និងកម្រិត ២ ដល់សិក្ខាកាមចំនួន ៣៣ នាក់។ គម្រោង FCF អង្គការសង្គ្រោះកុមារ និងក្រសួង ស្ថាប័ន ព្រមទាំងអង្គការដៃគូពាក់ព័ន្ធបានប្រជុំពិភាក្សាលើការធ្វើចំណាត់មណ្ឌលថែទាំកុមារ នៅខេត្តបាត់ដំបង ដោយពិនិត្យលើទិដ្ឋភាពទូទៅ នៃឧបករណ៍ចាត់ថ្នាក់មណ្ឌលថែទាំ និងសិក្សាលើលទ្ធភាពនៃការអនុវត្តឧបករណ៍នេះ ជាមួយមន្ទីរ ស.អ.យ. ខេត្តបាត់ដំបង និងខេត្តសៀមរាប។ គម្រោង FCF បានប្រជុំជាប្រចាំជាមួយក្រសួង ស្ថាប័ន និងអង្គការដៃគូរៀងរាល់ ៣ខែម្តង។ គម្រោង FCF ត្រូវបិទបញ្ចប់ក្នុងឆ្នាំ២០២៣ អង្គការសង្គ្រោះកុមារបានរៀបចំកិច្ចប្រជុំបិទបញ្ចប់គម្រោង ដើម្បីជូនដំណឹង និងថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំខេត្ត និង គ.ក.ស.ក. ថ្នាក់ខេត្ត ក្នុងខេត្តចំនួន៧ មានដូចជា៖ រាជធានីភ្នំពេញ កណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ធំ កំពត និងខេត្តបន្ទាយមានជ័យ។

២២៨. អង្គការសង្គ្រោះកុមារបានសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី និងក្រសួង អ.យ.ក. ដើម្បីរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូគម្រោង លើប្រធានបទស្តីពីការលើកកម្ពស់បរិយាប័ន្ន និងកិច្ចការពារកុមារ ដែលត្រូវបានរើសអើងដោយសារនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញអំពីយេនឌ័រ និងលក្ខណៈភេទចម្រុះនៅកម្ពុជា (SOGIESC) ដែលមានអ្នកចូលរួមចំនួន៤៥ នាក់ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។ នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣ អង្គការសង្គ្រោះកុមារបានគាំទ្រដល់ CCYMCR និងអង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា ដើម្បីចូលរួមអបអរសាទរទិវាកុមារអន្តរជាតិ និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (CNCC) ។ ដោយបានឧបត្ថម្ភគាំទ្រដល់កុមារចំនួន ៣៩៩នាក់ (ស្រី ២២៣នាក់) ចូលរួមក្នុងព្រឹត្តិការណ៍សំខាន់ៗនេះ។ នៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០២៣ នៅសណ្ឋាគារប៉ូឡូវ៉េ អង្គការសង្គ្រោះកុមារ និងអង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជាបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ និងកិច្ចប្រជុំជាមួយក្រសួង ស្ថាប័នសំខាន់ៗ ដើម្បីពិនិត្យ និងតាមដានការអនុវត្តរបស់ UNCRC និងអនុសាសន៍ (UPR) ទាក់ទងនឹងសិទ្ធិកុមារ ជាពិសេសកុមារដែលមាន SOGIESC ចម្រុះ ដែលមានអ្នកចូលរួមចំនួន ៤១នាក់ (ស្រី ១២នាក់)។

២២៩. អង្គការសង្គ្រោះកុមារ បានគាំទ្រមូលនិធិដល់អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា (CRC-Cambodia) ដើម្បីសម្របសម្រួល និងបង្កើតសម្ភារៈបែបកុមារមេត្រីជាភាសាខ្មែរសម្រាប់កុមារ នៅលើអនុសាសន៍អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (COB) និងធ្វើឱ្យមានលក្ខណៈងាយស្រួលសម្រាប់កុមារ ដើម្បីធានាថាអនុសាសន៍អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (COB) អាចអនុវត្តបាន និងបរិយាបន្ន។ តាមរយៈការពិគ្រោះយោបល់ជាមួយតំណាងកុមារ និងយុវជន បានបោះពុម្ពកូនសៀវភៅនេះជាមួយនឹងចំនួន ១០១៥ក្បាល និងបានធ្វើការផ្សព្វផ្សាយនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ នៅរាជធានីភ្នំពេញ។

២៣០. អង្គការសង្គ្រោះកុមារ បានគាំទ្រហិរញ្ញវត្ថុដល់អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា ដើម្បីសហការជាមួយ ក្រសួងកិច្ចការនារី រៀបចំវេទិកាសាធារណៈនៅថ្ងៃទី២៣ ខែវិច្ឆិកា នៅវិទ្យាល័យកំបូល ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីអំពើហិង្សាយេនឌ័រ (GBV) លើស្ត្រី និងកុមារី។ វេទិកានេះមានការចូលរួមជាកិត្តិយសពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការសង្គមស៊ីវិល កុមារ និងយុវជន ដោយមានកុមារចំនួន ១៥ នាក់ និងយុវជនចំនួន ៩ នាក់ចូលរួម។ អ្នកចូលរួមក្នុងព្រឹត្តិការណ៍នេះ សរុបចំនួន ២០១នាក់ ក្នុងនោះស្ត្រីប្រមាណ ៥០% បានចូលរួមយ៉ាងសកម្មក្នុងកិច្ចសន្ទនានេះ ដោយទទួលបានការយល់ដឹងកាន់តែប្រសើរឡើងអំពីសារៈសំខាន់នៃការទប់ស្កាត់អំពើហិង្សាលើស្ត្រីវ័យក្មេង និងការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងតំបន់គោលដៅ។

២៣១. នៅថ្ងៃទី២៦ ដល់២៧ ខែមេសា ឆ្នាំ២០២៣ អង្គការសង្គ្រោះកុមារបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីសិទ្ធិកុមារដែមាន SOGIESC ចម្រុះ ដល់អង្គការសង្គមស៊ីវិល ដែលជាសមាជិករបស់អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា។ វគ្គបណ្តុះបណ្តាលនេះមានគោលបំណងកសាងសមត្ថភាពសម្រាប់អង្គការសង្គមស៊ីវិលសិទ្ធិកុមារ និងរួមបញ្ចូលកុមារដែលមាន SOGIESC ចម្រុះ ទៅក្នុងក្របខ័ណ្ឌស្ថាប័នរបស់ពួកគេ ដែលមានអ្នកចូលរួមចំនួន ២៥នាក់ (ស្រី ១២នាក់)។ ទន្ទឹមនេះ ចាប់ពីខែមេសា ដល់ខែវិច្ឆិកា ឆ្នាំ២០២៣ អង្គការសង្គ្រោះកុមារបានគាំទ្រមូលនិធិដល់ CCYMCR ដើម្បីផ្តល់ការបណ្តុះបណ្តាលដល់ CCWC WCCC សមាជិកសហគមន៍ពាក់ព័ន្ធផ្សេងទៀតអំពីគោលគំនិតរបស់កុមារដែលមាន SOGIESC

ចម្រុះ ដើម្បីបង្កើនចំណេះដឹងរបស់ពួកគេ និងទទួលយកអាកប្បកិរិយាវិជ្ជមាន និងការផ្តល់សេវាចំពោះកុមារដែលមាន SOGIESC ចម្រុះ។ វគ្គបណ្តុះបណ្តាលនេះ មានអ្នកចូលរួម ៦៤នាក់ (ស្រី ៣៩នាក់ ប្រុស ២៥នាក់) ដែលជាក្រុមប្រឹក្សាឃុំ CCWCs គ្រូបង្រៀន និងមាតាបិតា ដែលមានអ្នកទទួលផលចំនួន ៥គោលដៅ នៅឃុំព្រៃករកា ខេត្តកណ្តាល ឃុំឃ្លាំងលើ ខេត្តសៀមរាប នៅឃុំលង្វែក ខេត្តកំពង់ឆ្នាំង នៅឃុំស្លា ខេត្តតាកែវ នៅឃុំស្ពុក ខេត្តកំពង់ស្ពឺ។

២៣២. អង្គការសង្គ្រោះកុមារបានសម្របសម្រួលកិច្ចការមួយចំនួន រួមមាន៖

- កុមារ ២៧ នាក់បានសមាហរណកម្មទៅគ្រួសារផ្ទាល់
- កុមារ ៤១ នាក់ត្រូវបានទុកដាក់ក្នុងការថែទាំដោយគ្រួសារសាច់ញាតិ
- កុមារ ៣៣ នាក់ត្រូវបានទុកដាក់ក្នុងការថែទាំដោយឪពុកម្តាយធម៌
- ករណីកុមារចំនួន ២,៩៤៥ ត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងកិច្ចការពារកុមារ OSCaR
- អ្នកប្រើប្រាស់ចំនួន ៨ បានបង់ថ្លៃសេវាប្រព័ន្ធ OSCaR បង្កើនដល់និរន្តរភាពនៃការវិនិយោគរបស់ម្ចាស់ជំនួយទៅលើប្រព័ន្ធអូស្កា (OSCaR)
- កុមារ ២៨ នាក់បានសមាហរណកម្មទៅកាន់គ្រួសារដើម ឬទុកដាក់ក្នុងការថែទាំជំនួស ទទួលបានការគ្រប់គ្រងករណីតាមដាន
- ការចុះសួរសុខទុក្ខតាមដានចំនួន ៨៦៣លើក ត្រូវបានធ្វើឡើងដើម្បីធ្វើសមាហរណកម្មកុមារ ហើយកុមារត្រូវបានទុកដាក់ក្នុងការថែទាំជំនួស។

២៣៣. អង្គការសង្គ្រោះកុមារបានឧបត្ថម្ភថវិកាដល់អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា ដើម្បីសហការជាមួយ ក.ជ.ក. រៀបចំសិក្ខាសាលាស្តីពីផែនការថវិកា និងការឆ្លុះបញ្ចាំងលើការអនុវត្តអនុសាសន៍អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (COB) នៅខេត្តកំពង់ចាម ដែលមានអ្នកចូលរួមសរុបចំនួន ៥៦នាក់ (ស្រី ១៤នាក់) មកពីអង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បណ្តាញកុមារ និងយុវជន (CYLNs) សមាជិកអង្គការសង្គមស៊ីវិល និងដៃគូ ម្ចាស់ជំនួយ និងក្រសួងពាក់ព័ន្ធដែលមានកាតព្វកិច្ចអនុវត្ត COB។ គោលបំណងនៃសិក្ខាសាលាគឺការធ្វើបច្ចុប្បន្នភាព និងពង្រឹងការអនុវត្ត COB ចែករំលែកបទពិសោធន៍ និងមេរៀនល្អៗដែលបានមកពីការធ្វើសមាហរណកម្ម COB និងពង្រឹងការចូលរួមរបស់ក្រសួង អង្គការក្រៅរដ្ឋាភិបាល និងCYLNs នៅក្នុងការឆ្លើយតបនិង COB ។

២៣៤. នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣ ដោយមានការគាំទ្រថវិកាពី អង្គការសង្គ្រោះកុមារ អង្គការវ៉ូមែន បានធ្វើការលើកកម្ពស់ការយល់ដឹងអំពីអនុសាសន៍អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារ(COB) ដល់សមាជិកក្លឹបកុមារនៅសាលប្រជុំសាលាស្រុកព្រះស្តេច។ មានប្រធានក្លឹបកុមារចំនួន ២២នាក់ (ស្រី ១៥ នាក់) បានចូលរួមក្នុងសិក្ខាសាលានេះ។ គោលបំណងនៃសិក្ខាសាលានេះគឺដើម្បីលើកកម្ពស់ការយល់ដឹងអំពី អនុសាសន៏អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ដល់ថ្នាក់ដឹកនាំក្លឹបកុមាររបស់យើង។

២៣៥. បានបណ្តុះបណ្តាលតាមសាលាបឋមសិក្សាចំនួន ៤៣ ក្នុងស្រុកកងមាស ដល់ក្រុមប្រឹក្សាកុមារ និងសិស្សានុសិស្សចំនួន ១២៨៣នាក់ ស្រី ៨១៣នាក់។ វគ្គបណ្តុះបណ្តាលបណ្តុះបណ្តាលទាំងនេះសម្របសម្រួលដោយគ្រូបង្គោលចំនួន ១២នាក់ មកពីក្រសួង អ.យ.ក. មន្ទីរអប់រំខេត្តកំពង់ចាម និងការិយាល័យអប់រំស្រុកកងមាស។ របៀបវារៈរួមមានសិទ្ធិកុមារ និងទម្រង់នៃអំពើហិង្សាលើកុមារ និងការគេងប្រវ័ញ្ច

កុមារ ការលើកកម្ពស់សមភាពយេនឌ័រ និងសុច្ចរិតភាពនៅសាលារៀន និងវិធានការទប់ស្កាត់អំពើហិង្សាលើកុមារ និងការកេងប្រវ័ញ្ចកុមារ។ ក្រុមប្រឹក្សាកុមារនៃបឋមសិក្សាទាំង៤៣ បានបន្តផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងដល់សិស្ស ឪពុកម្ដាយ និងសហគមន៍ អំពីសិទ្ធិកុមារ ទម្រង់នៃអំពើហិង្សាលើកុមារ យេនឌ័រ និងសមភាពយេនឌ័រនៅក្នុងសាលារៀន នៅថ្ងៃបើកបវេសនកាលឆ្នាំសិក្សាថ្មី ២០២៣-២០២៤។ អ្នកចូលរួមក្នុងកម្មវិធីនេះមានមាតាបិតា លោកគ្រូ អ្នកគ្រូ គណៈកម្មការគ្រប់គ្រងសាលា សិស្សានុសិស្ស សប្បុរសជន អាជ្ញាធរមូលដ្ឋាន និងមន្ត្រីអប់រំស្រុក សរុបចំនួន ៤៣៦៥ នាក់ ស្រី ២៥០៩ នាក់ ក្នុងនោះសិស្សានុសិស្សចំនួន ២៧៦៣ នាក់ ស្រី ១៥២៩ នាក់។ ក្រុមប្រឹក្សាកុមារតាមបឋមសិក្សាទាំង ៤៣ ក៏នៅតែបន្តផ្សព្វផ្សាយ និងអនុវត្តជាប្រចាំដល់សិស្ស និងមិត្តភក្តិ។

២៣៦. បណ្តុះបណ្តាលតាមសាលាបឋមសិក្សាចំនួន ៤៣ ក្នុងស្រុកកងមាស ដល់គណៈកម្មការគ្រប់គ្រងចំនួន ៤៦៨នាក់ ស្រី ២៥៨នាក់។ ការបណ្តុះបណ្តាលផ្តោតលើ ទិដ្ឋភាពទូទៅនៃក្របខ័ណ្ឌគតិយុទ្ធទាក់ទងនឹងការការពារកុមារ ទម្រង់នៃអំពើហិង្សា និងការកេងប្រវ័ញ្ចលើកុមារ ការសង្គ្រោះផ្លូវចិត្តបឋម វិន័យវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព និងការលើកកម្ពស់យេនឌ័រ និងបរិយាបន្ននៅក្នុងសាលារៀន។

២៣៧. ក្រោមការឧបត្ថម្ភថវិកា និងជំនួយបច្ចេកទេសពីអង្គការសង្គ្រោះកុមារ សម្ព័ន្ធសិទ្ធិកុមារកម្ពុជាបាបើកវគ្គបណ្តុះបណ្តាលការកសាងសមត្ថភាពរយៈពេល ២ថ្ងៃ សម្រាប់សមាជិកគណៈកម្មាធិការដឹកនាំដោយកុមារនិងយុវជន និងដៃគូគម្រោងនៅរាជធានីភ្នំពេញ នៅថ្ងៃទី៣០-៣១ ខែមីនា ឆ្នាំ២០២៣។ វគ្គបណ្តុះបណ្តាលនេះផ្តោតលើការត្រួតពិនិត្យសិទ្ធិកុមារ ការតស៊ូមតិ ការចូលរួមជាមួយសមាជិក CYLN និងយន្តការគណនេយ្យភាពសម្រាប់កុមារ។ វគ្គបណ្តុះបណ្តាលនេះមានអ្នកចូល ២៨នាក់ (ស្រី ១១នាក់) មកពីអង្គការក្រៅរដ្ឋាភិបាលចំនួនប្រាំមួយ រួមមាន SIDA Partners (អង្គការសង្គ្រោះកុមារ, CCYMCR, CDPO, CCC, អង្គការវ៉ូមែន, GADC) គណៈកម្មាធិការដឹកនាំ CYLN និងសមាជិក CADDP ។

២៣៨. ដោយមានការគាំទ្រថវិកាពីអង្គការសង្គ្រោះកុមារ នៅថ្ងៃទី ១៧-១៨ ខែមិថុនា ឆ្នាំ២០២៣ អង្គការវ៉ូមែនបានផ្តល់ការបណ្តុះបណ្តាលដល់អ្នកដឹកនាំក្លឹបកុមារ ស្តីពីការកាត់តវីដេអូឃ្លីបដោយប្រើទូរសព្ទឆ្លាតវៃ និងតែងរឿងខ្លីៗ ដែលមានអ្នកចូលរួមជាប្រធានក្លឹបកុមារចំនួន ៤៦ (ស្រី ៣១ នាក់)។ នៅថ្ងៃទី ១៩-២០ និង ២៦-២៧ ខែសីហា និងថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២៣ បានគាំទ្រអង្គការវ៉ូមែនបានធ្វើការបណ្តុះបណ្តាលរយៈពេលប្រាំថ្ងៃជាមួយនឹងអ្នកដឹកនាំក្លឹបកុមារចំនួន ៦២នាក់ (ស្រី ៤៥នាក់) ស្តីពីសិទ្ធិកុមារ ការចូលរួមរបស់កុមារ និងការតស៊ូមតិ។ នៅថ្ងៃទី២០-២១ ខែកក្កដា ឆ្នាំ២០២៣ បានគាំទ្រថវិកាដល់អង្គការវ៉ូមែន ធ្វើសិក្ខាសាលាបណ្តុះបណ្តាលរយៈពេល ២ថ្ងៃស្តីពីការត្រួតពិនិត្យសិទ្ធិកុមារ និងរបាយការណ៍ស្តីពីសិទ្ធិកុមារផ្តោតលើ UNCRC ដែលមានអ្នកចូលរួមចំនួន ៣៤ នាក់ (ស្រី ២៦ នាក់) ។ បានគាំទ្រថវិកាដល់អង្គការវ៉ូមែន ដើម្បីគាំទ្រអ្នកដឹកនាំកុមារឱ្យចូលរួមក្នុងកិច្ចប្រជុំ WCCC ដែលរៀបចំនៅសាលប្រជុំសាលាស្រុកព្រះស្តេច នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣។ គោលបំណងនៃកិច្ចប្រជុំនេះគឺដើម្បីធ្វើបច្ចុប្បន្នភាពវឌ្ឍនភាពនៃការងារ WCCC និងចែករំលែកព័ត៌មាន។ បច្ចុប្បន្នភាពវឌ្ឍនភាពនេះរួមមាន ការលែងលះក្នុងគ្រួសារ ការធ្វើចំណាកស្រុករបស់មនុស្សក្នុងការទំនាក់ទំនង សុវត្ថិភាពតាមអ៊ីន

ធីណិត ការរំលោភបំពានផ្លូវភេទលើកុមារតាមរយៈអ៊ីនធីណិត ការថែទាំសុខភាព និងសន្តិសុខសង្គម។ ដែលមានអ្នកចូលរួមជា អាជ្ញាធរ ១៨នាក់ (ស្រី ១២នាក់) រួមទាំងអ្នកដឹកនាំក្លឹបកុមារ ២នាក់។

២៣៩. អង្គការសង្គ្រោះកុមារ សហការជាមួយសម្ពន្ធសិទ្ធិកុមារកម្ពុជាបានផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកអង្គការដៃគូ ដើម្បីក្លាយជាអ្នកសម្របសម្រួលយុទ្ធនាការ SHIFT 360s ប្រកបដោយភាពច្នៃប្រឌិត កាលពីថ្ងៃទី៨ ដល់ថ្ងៃទី៩ ខែសីហា នៅរាជធានីភ្នំពេញ សម្រាប់អង្គការដៃគូ SIDA និងសមាជិករបស់សម្ពន្ធសិទ្ធិកុមារកម្ពុជានៅក្នុងភ្នំពេញ ដោយមានអ្នកចូលរួមសរុបចំនួន ២៥នាក់ (ស្រី ៥នាក់ បុរសដែលមានពិការភាព ២នាក់)។

២៤០. នៅថ្ងៃទី២៨-២៩ ខែមីនា ឆ្នាំ២០២៣ នៅរាជធានីភ្នំពេញ អង្គការសង្គ្រោះកុមារបានសហការ CCYMCR បានផ្តល់ការកសាងសមត្ថភាពលើការចូលរួមរបស់កុមារដល់ដៃគូរបស់គម្រោង SIDA ដែលមានអ្នកចូលរួម ១១នាក់ (ស្រី ២នាក់ ជនមានពិការភាព ២នាក់) រួមមកពី អង្គការសង្គ្រោះកុមារ, CCC, CDPO, CRC-Cambodia, GADC និងស្ត្រី។ បានគាំទ្រវេទិកាដល់ចលនាកុមារនិងយុវជនដើម្បីសិទ្ធិកុមារ (CCYMCR) ដើម្បីកសាងសមត្ថភាពលើការចូលរួមរបស់កុមារ នៅថ្ងៃទី ២៨-២៩ ខែមីនា ឆ្នាំ ២០២៣ នៅរាជធានីភ្នំពេញ ដែលមានអ្នកចូលរួម ៩នាក់ (ស្រី ៤នាក់) ជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ចំនួន ៤ ក្នុងខេត្តកណ្តាល ក្រចេះ ខេត្តសៀមរាប និងខេត្តពោធិ៍សាត់។ នៅថ្ងៃទី ២៤-២៥ ខែមិថុនា ឆ្នាំ២០២៣ បានគាំទ្រវេទិកាដល់ចលនាកុមារនិងយុវជនដើម្បីសិទ្ធិកុមារ (CCYMCR) រៀបចំវគ្គបណ្តុះបណ្តាលថ្មីស្តីពីការវាយតម្លៃសិទ្ធិកុមារ និងការបណ្តុះបណ្តាលស្តីពីការសរសេររបាយការណ៍ទៅកាន់ក្លឹបកុមារ និងបណ្តាញនានា ដែលមានកុមារ និងយុវជនចូលរួមចំនួន ២៩នាក់ (ស្រី ២០នាក់) មកពីក្លឹបកុមារចំនួន ១៣ នៅខេត្តកណ្តាល តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង កោះកុង ព្រៃវែង រាជធានីភ្នំពេញ ពោធិសាត់ ក្រចេះ សៀមរាប និងព្រះវិហារ។ បានគាំទ្រដល់ចលនាកុមារនិងយុវជនដើម្បីសិទ្ធិកុមារ (CCYMCR) បានបើកវគ្គបណ្តុះបណ្តាលដល់ក្លឹបកុមារស្តីពីការវិនិយោគសាធារណៈលើកុមារ (PIIC) នៅសណ្ឋាគារពូលូវ៉ៃ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ដល់ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៣ ដែលមានអ្នកចូលរួមជាកុមារ និងយុវជនចំនួន ២៥នាក់ (ស្រី ១៦នាក់) មកពីខេត្តកណ្តាល តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង ក្រចេះ និងសៀមរាប។

២៤១. កិច្ចសហប្រតិបត្តិការៈ គម្រោង FCF បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ជំនួយបន្តដល់អង្គការដៃគូរយៈពេល ២១ខែ។ បានធ្វើបទបង្ហាញតាមអនឡាញស្តីពីលទ្ធផលសំខាន់ៗនៃការសិក្សាអំពីការថែទាំដោយគ្រួសារសាច់ញាតិ និងការថែទាំដោយឪពុកម្តាយធម៌ដល់សន្និសីទអន្តរជាតិពីរឆ្នាំលើក៥ ស្តីពីការថែទាំជំនួសសម្រាប់កុមារនៅអាស៊ី (BICON 2023) នៅប្រទេសនេប៉ាល់។ បានចូលរួមក្នុងកិច្ចប្រជុំប្រចាំត្រីមាស វេទិកាកិច្ចការពារកុមារ ដែលបានបង្កើតឡើងនៅដើមឆ្នាំ ២០២១ ដោយអង្គការមិនមែនរដ្ឋាភិបាលដែលផ្តោតលើកម្មវិធីផ្នែកកុមារ។ បានសហការរៀបចំដំណើរទស្សនកិច្ចសិក្សាដល់អង្គការដៃគូ។ បានរៀបចំកិច្ចប្រជុំសហគមន៍នៃការអនុវត្ត (CoP) និងទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ (LEV) រៀបចំកិច្ចប្រជុំក្រុមតូច (TSG) ចំនួន៣លើក បង្ហាញពីវឌ្ឍនភាពនៃការអនុវត្តគម្រោង FCF និងដៃគូ។ បានប្រជុំក្រុមចែករំលែកចំណេះដឹង (KSG) ចំនួន ២ លើក បង្ហាញពីវឌ្ឍនភាពនៃការពិនិត្យលើឯកសារសិក្សាដែលមានស្រាប់។ បានរួមចំណែកបង្ហោះមាតិកាចំនួន ២១៧មាតិកា មានការចូលរួមមតិ ៥៤ និង ២ ៣៦៥ Reactions ទៅកាន់ទំព័រ Facebook ខាងក្នុងគម្រោង FCF។ គេហទំព័របណ្តាញ

សង្គម FCF បានកើនឡើងនៃការចុច Like ពី ១០ ៨០១ ទៅ ១០ ៩៥៦ និងមានអ្នកតាមដាន ១១ ៧១៤។ បានផលិត និងចែកចាយព្រឹត្តិបត្ររបស់គម្រោង FCF ចំនួន ១៨លេខ ផលិតវីដេអូចំនួន ២ ៖ 1). "ហេតុអ្វីខ្ញុំបែកពីគ្រួសារ" និង ២). "ផ្ទះដែលពោពេញដោយក្តីស្រលាញ់" ដោយបានផ្សព្វផ្សាយនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម។

**ជ. អង្គភាពការពារកុមារ** (CPU)

២៤២. អង្គភាពការពារកុមារ (CPU) គឺជាអង្គភាពមួយដែលមានជំនាញខ្ពស់ក្នុងការស៊ើបអង្កេត ធ្វើកោសល្យវិច្ច័យ និងបង្ក្រាបបទល្មើសពាក់ព័ន្ធកុមារ។ នៅឆ្នាំ២០២៣នេះ គឺជាឆ្នាំដែល CPU បានប្រារព្ធពិធីអបអរចំពោះប្រតិបត្តិការរយៈពេល ១០ឆ្នាំ របស់ខ្លួន និងមានមោទនភាពយ៉ាងខ្លាំង ចំពោះលទ្ធផលសម្រេចបានជាច្រើនកន្លងមកក្នុងឆន្ទៈ នៃការការពារដល់អ្នកដែលមិនអាចការពារខ្លួនឯងបានគឺ "កុមារ" ។ បច្ចុប្បន្ននេះ CPU បានសហការបំពេញការងារយ៉ាងជិតស្និទ្ធជាមួយក្រសួងមហាផ្ទៃ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអគ្គស្នងការដ្ឋាននគរបាលជាតិ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

២៤៣. ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ CPU បានធ្វើប្រតិបត្តិការចំនួន ៣៨១ករណី ដែលក្នុងនោះ ៣៦៦ករណី ជាករណីបទឧក្រិដ្ឋ ដែលពាក់ព័ន្ធនឹងឃាតកម្ម ការរំលោភសេពសន្ថវៈ និងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលប្រព្រឹត្តប្រឆាំងនឹងកុមារ។ ជនល្មើសចំនួន ៣៣៩នាក់ ត្រូវបានចាប់ខ្លួន។ ទន្ទឹមនេះ CPU បានស៊ើបអង្កេតលើករណីឃាតកម្មចំនួន ២៦ និងបន្ថែម ២ករណីទៀតពាក់ព័ន្ធនឹងមនុស្សឃាត។ CPU បានធ្វើការស៊ើបអង្កេត ICAC ចំនួន ៦៧ករណី ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងកុមារតាមអ៊ីនធឺណិត។ បានជួយនគរបាលជាតិកម្ពុជា ដើម្បីស៊ើបអង្កេតធ្វើកោសល្យវិច្ច័យចំនួន ៥ករណី។ បានផ្តល់ការគាំទ្រផ្នែកច្បាប់ដោយមិនគិតថ្លៃដល់ជនរងគ្រោះចំនួន ២៤០នាក់។ បានធ្វើទស្សនកិច្ចទៅកាន់ស្នងការដ្ឋាននគរបាលចំនួន ១០ខេត្ត។ បានបញ្ចប់សំណុំរឿងនៅតុលាការចំនួន ៦៧សំណុំរឿង។ បានចូលរួមសហការស៊ើបអង្កេតលើបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរចំនួន ៧ករណី។

**ឈ. អង្គការបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា**

២៤៤. អង្គការបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា (១២៨០)[20] បានអនុវត្តគោលដៅយុទ្ធសាស្ត្រចំនួន 0៤ រួមមាន៖ ១.ការការពារ ២. ការបង្ការ-ទប់ស្កាត់ ៣. ការតស៊ូមតិ ៤. ការអភិវឌ្ឍស្ថាប័ន ។

២៤៥. ការការពារ៖ គឺជាកម្មវិធីដែលមានគោលបំណង ដើម្បីបង្កើតបរិយាកាសអំណោយផលសម្រាប់ការការពារកុមារ និងយុវជន តាមរយៈរចនាសម្ព័ន្ធបណ្តាញជំនួយកុមារ ដោយសម្របសម្រួលក្នុងការប្រើប្រាស់សេវាដែលមានស្រាប់ និងការព្យាបាលផ្លូវចិត្ត-សង្គម ក្នុងនោះរួមមាន៖ ផ្តល់សេវាពិគ្រោះយោបល់តាមទូរស័ព្ទដោយឥតគិតថ្លៃ ២៤/៧ ផ្តល់ការពិគ្រោះយោបល់ដល់គ្រួសារសេវាសុខភាពបឋម និងមនុស្សធម៌ ផ្តល់ជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ ការបញ្ជូនបន្តនិងតាមដាន និងថ្នាលប្រព័ន្ធផ្សព្វផ្សាយសង្គម។

២៤៦. ផ្តល់សេវាពិគ្រោះយោបល់តាមទូរស័ព្ទដោយឥតគិតថ្លៃ ២៤/៧៖ ក្រុមអ្នកពិគ្រោះយោបល់របស់ CHC បានឆ្លើយការហៅចូលទូរស័ព្ទចំនួន ១៩ ៦១៨ដង ក្នុងនោះអតិថិជនចំនួន ២ ៥០៨នាក់ បានទទួល

[20] របាយការណ៍សមិទ្ធផលការងារ ឆ្នាំ២០២២ និងទិសដៅឆ្នាំ២០២៣ របស់អង្គការបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា (CHC)

ការពិគ្រោះយោបល់តាមទូរស័ព្ទ អតិថិជនចំនួន ១២៧ នាក់ បានរាយការណ៍អំពីបញ្ហាទាក់ទងនឹងការការពារកុមារ និងអតិថិជនចំនួន ៥ ៦២៨នាក់ បានទទួលសេវាកម្មអប់រំ និងព័ត៌មានផ្អែកលើបញ្ហា។ ក្នុងចំណោមអតិថិជន ១៩ ៦១៨នាក់ មានស្រី ៦ ៦៦៤នាក់ ប្រុស ៣ ៥៥២នាក់ LGBTIQ ៦០នាក់ មិនអាចកំណត់បាន ៩ ៤០២នាក់ (ក្នុងនោះមានកុមារ ១ ២០៧នាក់ យុវជន ១ ២១២នាក់ មនុស្សពេញវ័យ ៤ ១៩៣នាក់ មិនអាចកំណត់អាយុបាន ១៣ ០០៦នាក់)។

២៤៧. ការពិគ្រោះយោបល់ដល់គ្រួសារ សេវាសុខភាពបឋម និងមនុស្សធម៌ គឺជាកម្មវិធីយុទ្ធសាស្ត្ររបស់ CHC ដែលបង្កើតឡើង ដើម្បីបំបែកវប្បធម៌នៃភាពស្ងៀមស្ងាត់ និងការបិទបាំងការរំលោភបំពាននៅក្នុងសហគមន៍ ដែលក្មេងស្រី និងក្មេងជំទង់ត្រូវបានអប់រំឱ្យនៅស្ងៀម និងរក្សាការសម្ងាត់ចំពោះអំពើហិង្សា និងការរំលោភបំពានដែលសមាជិកគ្រួសារ ឬដៃគូជិតស្និទ្ធបានប្រព្រឹត្តប្រឆាំងនឹងពួកគេ។ ជួយគាំទ្រដល់កុមារក្មេងជំទង់ ក្មេងស្រី និងស្ត្រីដែលរងផលប៉ះពាល់ដោយអំពើហិង្សា និងការរំលោភបំពាន។ CHC បានផ្តល់សេវាប្រឹក្សាគ្រួសារ សេវាសុខភាពបឋម និងសេវាមនុស្សធម៌ដល់ស្ត្រី និងកុមារីចំនួន ១២៧ នាក់ ដែលជាជនរងគ្រោះ/អ្នករួចរស់ពីការរំលោភបំពាន និងអំពើហិង្សា ដើម្បីកាត់បន្ថយបន្ទុកសេដ្ឋកិច្ចគ្រួសារ និងភាពក្រីក្រ។

២៤៨. ផ្តល់ជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ៖ ដើម្បីដោះស្រាយការលំបាក/បញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុក្នុងការដាក់ពាក្យបណ្តឹងនៅតុលាការប្រឆាំងជនល្មើស CHC មានការគាំទ្រផ្នែកហិរញ្ញវត្ថុពីមូលនិធិ L'Oréal សម្រាប់ស្ត្រី ដើម្បីជួយដល់ស្ត្រីនិងកុមារី ដែលជាជនរងគ្រោះនៃអំពើហិង្សា និងការរំលោភបំពានផ្លូវភេទ។ CHC ផ្តល់កញ្ចប់ជំនួយផ្នែកច្បាប់ពេញលេញ ដែលរួមមាន តំណាងផ្លូវច្បាប់ ថ្លៃតុលាការ និងថ្លៃធ្វើដំណើរ ដើម្បីឱ្យស្ត្រី និងកុមារី អាចប្តឹងតវ៉ានៅតុលាការប្រឆាំងនឹងអ្នករំលោភបំពាន/ជនល្មើសផ្លូវភេទ និងអ្នកដែលប្រព្រឹត្តអំពើហិង្សា ហើយធានាថាស្ត្រី និងកុមារីអាចទទួលបានដំណោះស្រាយផ្លូវច្បាប់ និងការផ្សះផ្សា តាមរយៈជំនួយផ្នែកច្បាប់។ នៅឆ្នាំ២០២៣ CHC បានជួយស្ត្រីនិងកុមារី៣នាក់ ដើម្បីដាក់ពាក្យបណ្តឹងផ្លូវច្បាប់នៅតុលាការ ប្រឆាំងនឹងជនល្មើស ៤នាក់។ ដំណើរការផ្លូវច្បាប់នៅកំពុងបន្ត ហើយក្រុមអ្នកប្រឹក្សារបស់ CHC នៅតែបន្តធ្វើការតាមដាន និងផ្តល់ជំនួយផ្លូវចិត្តដល់ស្ត្រី និងកុមារី ទាំង ៤នាក់នោះ។

២៤៩. ការបញ្ជូនបន្ត និងតាមដាន CHC មានគោលការណ៍ដើម្បីការពារការសម្ងាត់របស់អតិថិជន និងគោរពការសម្រេចចិត្តរបស់អតិថិជនក្នុងការបញ្ជូនបន្ត។ អតិថិជនចំនួន ១០០នាក់ ដែលត្រូវបានបញ្ជូនបន្តដោយផ្អែកលើការយល់ព្រមរបស់ពួកគេសម្រាប់សេវាផ្ទាល់ និងអន្តរាគមន៍ភ្លាមៗជាមួយដៃគូអង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរមានសមត្ថកិច្ច។ ក្នុងចំណោមអតិថិជន ដែលបានបញ្ជូនបន្តចំនួន ១០០នាក់ អតិថិជន៣០នាក់(ស្រី២១នាក់)គឺជាកុមារ យុវជន៣៧នាក់(ស្រី២៧នាក់ និងអ្នកស្រលាញ់ភេទដូចគ្នា១នាក់) និងមនុស្សពេញវ័យ៣៣នាក់(ស្រី២១នាក់)។ ក្នុងចំណោម១០០ករណី មាន១២ករណីជាអំពើហិង្សាលើកុមារ ២០ករណីជាអំពើហិង្សាលើស្ត្រី ៣ករណីជាការធ្វើចំណាកស្រុកគ្មានសុវត្ថិភាព ៥ករណីជាកុមារបាត់ខ្លួន ៩ករណីកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ និង ៥១ករណីទៀតជាបញ្ហាផ្សេងៗ។ អតិថិជនចំនួន១ ២១៨នាក់ ត្រូវបានតាមដាន ដើម្បីធានាថាពួកគេមានសុវត្ថិភាព និងរស់នៅក្នុងបរិយាកាសការពារ។

២៥០. ថ្នាលប្រព័ន្ធផ្សព្វផ្សាយសង្គម៖ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ទំព័រ Facebook របស់ Child Helpline Cambodia មាន អ្នក Likes ច្រើនជាង ៦៣១ ៧៥៣ និង Followers ១ ០៦២ ៣៣៤ (ស្រី ៥១% និងប្រុស ៤៨.៤%)។ ភាគច្រើននៃអ្នកតាមដានមានអាយុចន្លោះពី១៣ ទៅ៣៤ឆ្នាំ។ នៅឆ្នាំ ២០២៣ ក្រុមអ្នកពិគ្រោះយោបល់ CHC បានផ្តល់សេវាប្រឹក្សាតាមអនឡាញដល់យុវជនចំនួន ១ ១០៤នាក់ និងព័ត៌មានផ្នែកលើបញ្ហាដល់យុវជនចំនួន ៤ ១៥៨នាក់ តាមរយៈកម្មវិធីផ្ញើសារសន្ទនា Facebook។

២៥១. ការបង្ការ-ទប់ស្កាត់គឺកម្មវិធីដែលមានគោលបំណង ដើម្បីទប់ស្កាត់អំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ច តាមរយៈ ការចូលរួមពីសហគមន៍ ភ្នាក់ងារផ្លាស់ប្តូរសង្គម និងអាជ្ញាធរមូលដ្ឋានក្នុងការបង្កើតបរិយាកាស សុវត្ថិភាព ការចូលរួម និងគាំទ្រដល់កុមារ និងយុវជន ដើម្បីឱ្យពួកគេយល់ដឹងពីសិទ្ធិ និងឈានដល់សក្តានុពលពេញលេញ ក្នុងនោះរួមមាន៖ យន្តការរាយការណ៍ និងការឆ្លើយតបបញ្ហារបស់កុមារ (CRRM) យុវជនប្រេសិតរបស់បណ្តាញទូរស័ព្ទជំនួយកុមារ ស្វ័យសិក្សា Chatbot/Autobot កម្មវិធីអេបសុខភាពយុវវ័យ (Youth Health Mobile App) កម្មវិធីអេប "ធ្វើដំណើរឆ្លងដែនរបស់ខ្ញុំ" (My Journey Mobile App) កម្មវិធីអេប "សុវត្ថិភាព" (GBV Safe App) បន្ទប់សុខភាពសិក្សា( School Health Rooms)។

២៥២. យន្តការរាយការណ៍ និងការឆ្លើយតបបញ្ហារបស់កុមារ (CRRM) CHC បានបណ្តុះបណ្តាលមន្ត្រីរាជការនៅមូលដ្ឋានចំនួន ២៧០នាក់ (ស្រី១៦៣នាក់) រួមមាន សមាជិក គ.ក.ន.ក. អភិបាលរងស្រុក មន្ត្រីមកពីមន្ទីរសង្គមកិច្ច នគរបាល មេភូមិ ប្រធានមណ្ឌលសុខភាព និងនាយកសាលា នៅខេត្តសៀមរាប រតនៈគីរី ក្រចេះ និងខេត្តព្រៃវែងក្នុងឆ្នាំ២០២៣ ដោយផ្តោតលើសិទ្ធិកុមារ អំពើហិង្សាលើកុមារ កិច្ចអន្តរាគមន៍ ការបញ្ជូនបន្ត ការគ្រប់គ្រងករណី និងសង្គ្រោះសុខភាពផ្លូវចិត្តបឋម។

២៥៣. យុវជនប្រេសិតរបស់បណ្តាញទូរស័ព្ទជំនួយកុមារ៖ CHC បានបណ្តុះបណ្តាលកុមារ យុវជន និងក្មេងស្រីជំទង់ចំនួន៥០៧នាក់ (ស្រី៣៤៨នាក់) ជាសមាជិកជើងឯកនៃការផ្លាស់ប្តូរ (CCFP) ស្តីពីសិទ្ធិកុមារ ការការពារកុមារ អំពើហិង្សាលើកុមារ ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ សុខភាពផ្លូវភេទ និងសិទ្ធិបន្តពូជ ស្វ័យការពារ និងជំនាញសម្របសម្រួល នៅខេត្តសៀមរាប រតនៈគីរី ក្រចេះ និងខេត្តព្រៃវែង។

២៥៤. ស្វ័យសិក្សា Chatbot/Autobot៖ នៅខែមិថុនា ឆ្នាំ២០២៣ CHC ដោយមានជំនួយផ្នែកហិរញ្ញវត្ថុពីភ្លែនអន្តរជាតិ បានរៀបចំ បណ្តាញទំនាក់ទំនងសង្គម (Social Media)។ សៀវភៅណែនាំការស្វ័យសិក្សាប្រព័ន្ធ chatbot ដែលលក្ខណៈមេត្រីសម្រាប់កុមារ អំពីសិទ្ធិកុមារ បច្ចេកទេសស្វ័យការពារ ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ សមភាពយេនឌ័រ អំពើហិង្សាលើកុមារ និងសិទ្ធិផ្លូវភេទ និងសុខភាពបន្តពូជ។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ មានអ្នកប្រើប្រាស់ ៥ ០៩៩នាក់ (ស្រី ១ ២៥៦នាក់ មិនស្គាល់ភេទ១០១នាក់ និងកំណត់ភេទផ្សេងទៀត ៦២នាក់) បានចូលប្រើថ្នាលសន្ទនា Chatbot សម្រាប់ស្វ័យសិក្សា។Chatbot សម្រាប់ស្វ័យសិក្សាអាចចូលមើលបាននៅទីនេះ https://web.facebook.com/chc1280chatbot។

២៥៥. កម្មវិធីអេបសុខភាពយុវវ័យ (Youth Health Mobile App)៖ "សុខភាពយុវជន" គឺជាកម្មវិធីទូរស័ព្ទដែលងាយស្រួលសម្រាប់យុវវ័យដោយឥតគិតថ្លៃ ជាភាសាខ្មែរ ដែលផ្តល់ឱ្យកុមារ វ័យជំទង់ និងយុវជនកម្ពុជានូវព័ត៌មាន និងសេវាកម្មសំខាន់ៗ ដែលអាចទុកចិត្តបាន និងជាក់ស្តែងលើព័ត៌មាន និងសេវាសុខភាពបន្តពូជផ្លូវភេទ (SRHR) ការអប់រំផ្លូវភេទទូលំទូលាយ (CSE) យេនឌ័រ និងសុខភាពផ្លូវចិត្ត និងជំនួយផ្លូវចិត្ត (MHPSS) និងវីដេអូកម្សាន្តអប់រំ។ សុខភាពយុវជនត្រូវបានបង្កើតឡើងដើម្បីឱ្យកុមារ ក្មេងជំទង់ និងយុវជនអាចធ្វើការជ្រើសរើសបានកាន់តែប្រសើរ និងអនុវត្តសិទ្ធិរបស់ពួកគេ។ វាក៏មានតំណភ្ជាប់ទៅកាន់គ្លីនិក ឬអ្នកផ្តល់សេវា និងបណ្តាញជំនួយឥតគិតថ្លៃដោយផ្ទាល់ពីកម្មវិធីទូរស័ព្ទ។ គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៣ មានការទាញយកច្រើនជាង ៤៤ ៥០០ សម្រាប់ Android និងការទាញយក ១១៩៣២ សម្រាប់ iOS។ Youth Health Mobile App អាចទាញយកបាននៅទីនេះ https://bit.ly/3Ek744T (Android) or https://apple.co/3Cagf6G (iOS)។

២៥៦. កម្មវិធីអេប "ធ្វើដំណើរឆ្លងដែនរបស់ខ្ញុំ" (My Journey Mobile App) ត្រូវបានបង្កើតឡើងក្នុងគោលបំណងផ្តល់សិទ្ធិអំណាច ដល់ស្ត្រីចំណាកស្រុកឱ្យទទួលបានព័ត៌មាន ដែលអាចឱ្យពួកគេជ្រើសរើសដោយខ្លួនឯងសម្រាប់ការធ្វើការងារចំណាកស្រុក។ កម្មវិធីអេប "ធ្វើដំណើរឆ្លងដែនរបស់ខ្ញុំ" មានផ្នែកសំខាន់ៗចំនួន៤ រួមមាន៖ ការធ្វើដំណើររបស់អ្នកសុវត្ថិភាពរបស់អ្នក ការស្វែងរកជំនួយ និងរឿងរ៉ាវរបស់អ្នក ដែលផ្តល់ព័ត៌មានសំខាន់ៗសម្រាប់អ្នកប្រើប្រាស់ និងស្ត្រីចំណាកស្រុក។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ មានការទាញយកច្រើនជាង ៤០៧០។ កម្មវិធីអេបដំណើរ ឆ្លងដែនរបស់ខ្ញុំ My Journey Mobile App អាចទាញយកបាននៅទីនេះ http://bit.ly/myjourney mobileapp។

២៥៧. កម្មវិធីអេប "សុវត្ថិភាព"(GBV Safe App) បានផ្តួចផ្តើមឡើង ដោយក្រសួងកិច្ចការនារី ហើយទទួលបានការគាំទ្រពីUNFPA និងបានអនុវត្តដោយបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា។ អេបសុវត្ថិភាព គឺជាថ្នាលឌីជីថល ដែលគាំទ្រ និងការពារជនរងគ្រោះនៃអំពើហិង្សាយេនឌ័រ។ គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២៣ មានអ្នកប្រើប្រាស់ច្រើនជាង ២ ០០០នាក់ ដែលអ្នកប្រើប្រាស់ទាំងអស់នោះ មានស្ត្រីដែលកំពុងបំរើការក្នុងឧស្សាហ៍កម្មកាត់ដេរ និងសិស្សានុសិស្ស ដែលកំពុងធ្វើការ និងរស់នៅក្នុងទីក្រុងភ្នំពេញ។ កម្មវិធីអេបសុវត្ថិភាពបានផ្តួចផ្តើមដោយ ក្រសួងកិច្ចការនារី ហើយត្រូវបានគាំទ្រដោយមូលនិធិ Wesley តាមរយៈ UNFPA ក្នុងកិច្ចសហការណ៍ជាមួយ និងបណ្តាញទូរស័ព្ទជំនួយកុមារ និង GLEAN ASIA។

២៥៨. បន្ទប់សុខភាព គឺជាយន្តការដែលបានផ្តួចផ្តើម និងសម្ពោធឱ្យប្រើប្រាស់ដោយក្រសួងអប់រំ យុវជន និងកីឡា ហើយទទួលបានការគាំទ្រពី UNFPA តាមរយៈការធ្វើការជាដៃគូ នៅក្នុងប្រទេសកម្ពុជា ក្នុងគោលបំណងផ្តល់នូវឧបករណ៍ប្រើប្រាស់ ដើម្បីដោះស្រាយបញ្ហាសុខភាព និងផ្សព្វផ្សាយសមភាពយេនឌ័រ នៅក្នុងសាលារៀន។ បន្ទប់សុខភាពបានដំណើរការចំនួន ៨សាលា នៅក្នុងខេត្តចំនួន៨ ក្នុងប្រទេសកម្ពុជា។ ឧបករណ៍ និងនីតិវិធីបណ្តុះបណ្តាលការប្រើប្រាស់បន្ទប់សុខភាពត្រូវបានបង្កើត ដើម្បីណែនាំទៅដល់គណៈកម្មការបន្ទប់សុខភាព និងក្រុមមិត្តអប់រំមិត្ត។ ក្រុមមិត្តអប់រំមិត្តចំនួន ១៨៩នាក់ (ស្រី ១១៨នាក់) ត្រូវបានបំពាក់បំប៉ននូវចំណេះដឹង និងជំនាញទាក់ទងនឹងសុខភាព សិទ្ធិបន្តពូជ ការអប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយ ការសង្គ្រោះបឋម មូលដ្ឋានគ្រឹះនៃការពិគ្រោះយោបល់ និងជំនាញសម្របសម្រួលវគ្គ ដើម្បីឱ្យពួកគេអាចបន្តទៅដល់សិស្សានុសិស្សប្រហែល ១៧០ ០០០នាក់ផ្សេងទៀត និងយុវជននៅក្នុងតំបន់ដាច់ស្រយាល។ សិស្សចំនួន៥៧៣នាក់ (ស្រី៤២៧នាក់) បានទទួលការសង្គ្រោះបឋមលើ

របួសរាងកាយ សុខភាព និងសិទ្ធិបន្តពូជ ក៏ដូចជាអប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយ តាមរយៈអេបសុខភាព យុវជន និងការពិគ្រោះយោបល់ផ្ទាល់។

២៥៩. ការតស៊ូមតិ៖ គឺជាកម្មវិធីដែលមានគោលបំណង ដើម្បីបញ្ចុះបញ្ចូល តស៊ូមតិដោយផ្ទាល់ និងតាមរយៈសម្ព័ន្ធជាប្រព័ន្ធសម្រាប់កែទម្រង់គោលនយោបាយ និងបទបញ្ញត្តិ ដែលលើកកម្ពស់ប្រព័ន្ធការយល់ដឹង និងពង្រឹងការពារកុមារ ក្នុងការលើកកម្ពស់សិទ្ធិរបស់កុមារ យុវជន និងក្រុមគ្រួសាររបស់ពួកគេ។ ក្នុងកម្មវិធីនេះផ្តោតលើការទំនាក់ទំនង និងបោះពុម្ពផ្សាយ។

២៦០. ការទំនាក់ទំនង និងយុទ្ធនាការសាធារណៈរបស់ទំព័រហ្វេសប៊ុក Child helpline Cambodia (CHC) មានអ្នកតាមដានជាង ៦៣១ ៧៥៣នាក់ (ស្រី ៥១.៦% និងប្រុស ៤៨.៤%) ដែលមានអាយុចន្លោះពី ១៣ ទៅ៣៤ ឆ្នាំ។ បុគ្គលិក CHC ត្រូវបានអញ្ជើញឱ្យធ្វើជាវាគ្មិនក្នុងព្រឹត្តិការណ៍សាធារណៈនៃការបូកសរុបលទ្ធផល និងវេទិកាចែករំលែក និងកម្មវិធីវិទ្យុក្នុងប្រធានបទ ការថែទាំខ្លួន និងពិគ្រោះយោបល់។ CHC បានផលិតវិឌីអូចំនួន២ សម្រាប់យុទ្ធការអនឡាញលើ "ការគំរាមកំហែងតាមប្រព័ន្ធអនឡាញ" និង "ការកេងបន្លំ"។ នៅក្នុងចំណោមចំនួនមនុស្ស ១១៦ ៨៦៦នាក់ មានអ្នកចូលទៅទស្សនាចំនួន ៨២៦ ០៤១នាក់ អ្នកបង្ហាញចំណាប់អារម្មណ៍ចំនួន ១៣៥ ៨៦៧នាក់ បង្ហាញការចូលចិត្ត ១៤០នាក់ ផ្តល់យោបល់ ៣២នាក់ និងធ្វើការចែករំលែក ៣០នាក់។ នៅក្នុងចំណោម ៣២នាក់ ការផ្តល់យោបល់ពីអ្នកទស្សនិកជន មានកុមារ និងយុវជន ធ្វើការពិភាក្សា និងចែករំលែកចំណេះដឹងអំពី ការបៀតបៀនតាមប្រព័ន្ធឡាញ ការសម្លុតគំរាមកំហែង និងរំលោភបំពានកេងប្រវ័ញ្ចផ្លូវភេទ។

២៦១. CHC បានផលិត១ វិឌីអូ សម្រាប់យុទ្ធនាការអនឡាញលើ "ការប្រាស្រ័យទាក់ទងនៅក្នុងគ្រួសារដោយគ្មានអំពើហិង្សា"។ នៅក្នុងនោះមានមនុស្ស ៨០ ៤៦០នាក់ មានអ្នកចូលទៅទស្សនាចំនួន១ ០០៩ ៦២៨នាក់ អ្នកបង្ហាញចំណាប់អារម្មណ៍ ៨៦ ៨៣១នាក់ អ្នកបង្ហាញការចូលចិត្ត ៣២៩នាក់ អ្នកផ្តល់យោបល់ ៤៤នាក់ និងចែករំលែក ៥១នាក់។ វីឌីអូនេះបានលើកទឹកចិត្តដល់ឪពុកម្តាយ អ្នកថែទាំ អ្នកអាណាព្យាបាល ធ្វើការផ្លាស់ប្តូរឥរិយាបថ និងអាកប្បកិរិយា ផ្នត់គំនិត ដើម្បីបញ្ឈប់ការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ និងចាប់ផ្តើមអនុវត្តការដាក់វិន័យបែបវិជ្ជមាន ក្នុងការចិញ្ចឹមកូនៗរបស់ពួកគេ។

**ញ. អង្គការជីវិតថ្លៃថ្នូរ** (Life With Dignity-LWD)

២៦២. អង្គការជីវិតថ្លៃថ្នូរ (Life With Dignity_LWD) បាននិងកំពុងអនុវត្តកម្មវិធីចំនួន៥ រួមមាន៖

- កម្មវិធីការចិញ្ចឹមជីវិត និងកសិកម្មប្រកបដោយនិរន្តភាព
- កម្មវិធីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងបម្រែបម្រួលអាកាសធាតុ
- កម្មវិធីអនាម័យ (WASH) អាហារូបត្ថម្ភ និងសុខភាព
- កម្មវិធីការអប់រំ (កម្រិតមត្តេយ្យ និងបឋមសិក្សា)
- កម្មវិធីការចូលរួមសហគមន៍សង្គម។

២៦៣. ការចិញ្ចឹមជីវិត និងកសិកម្មប្រកបដោយនិរន្តរភាព ៖ ជាគម្រោងដែលមានគោលបំណងបង្កើតភ្នាក់ងារទីផ្សារផលិតផល បណ្តុះបណ្តាលកសិករខ្នាតតូច និងសហករណ៍កសិកម្ម បង្កើតផែនការអាជីវកម្ម កសាងសមត្ថភាពប្រមូលធនធាន និងបង្កើនការយល់ដឹងក្នុងចំណោមសហគមន៍ចំនួន ១ ៧៣៩ ក្នុងនោះស្រី

១ ១៧៣នាក់ អំពីការការពារ និងការពារខ្លួនពីការជួញដូរមនុស្ស ការធ្វើចំណាកស្រុកគ្មានសុវត្ថិភាព និងការកេងប្រវ័ញ្ច។

២៦៤. ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ៖ ឆ្នាំនេះបានបណ្តុះបណ្តាលកសាងសមត្ថភាពលើការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដល់សមាជិកសហគមន៍ចំនួន ១ ៨៦៣នាក់ (ស្រី ៩៥៨នាក់) សិស្សសាលាចំនួន ២ ៣៨៨នាក់ (ស្រី ១ ០២៣នាក់) ៤៦០នាក់ (ស្រី ២៤២នាក់) និងស្ត្រី ៧៧នាក់ មកពីគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ខេត្ត ក្រុង ស្រុក និងឃុំ។ បានជួយគាំទ្រដល់ការបង្កើតផែនការរបស់ឃុំចំនួន ៣ និងសាលារៀនចំនួន ៤១ ក្នុងការចាត់វិធានការយ៉ាងសកម្ម ដើម្បីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងធ្វើអោយប្រសើរឡើងនូវសុវត្ថិភាព ពេលវេលាឆ្លើយតប និងភាពធន់។

២៦៥. កម្មវិធីអនាម័យ (WASH) អាហារូបត្ថម្ភ និងសុខភាព៖ នៅឆ្នាំនេះបានបណ្តុះបណ្តាលបង្កើនចំណេះដឹង និងជំនាញអាហារូបត្ថម្ភ និងការចិញ្ចឹមបីបាច់ថែរក្សា ដល់ម្តាយ ២ ១៩១នាក់ ដែលមានកូនអាយុក្រោម ៥ឆ្នាំ និងបណ្តុះបណ្តាលដល់ឪពុកម្តាយ ឬអ្នកថែទាំចំនួន ១២៧នាក់ អំពីធ្វើបបរគ្រប់គ្រឿងចម្រុះ។ បានបណ្តុះបណ្តាលស្តីពីសុវត្ថិភាព និងទឹកស្អាត ការគ្រប់គ្រងទឹក និងការថែទាំ ដល់អ្នកចូលរួមចំនួន ៥៤៦នាក់ ក្នុងនោះស្រី ៣៣៥នាក់។ ពលរដ្ឋចំនួន ៤៤៨នាក់ មកពីសហគមន៍បានបង្ហាញពីការប្រើប្រាស់ត្រឹមត្រូវ នៃទឹកដែលមានសុវត្ថិភាព និងអនាម័យ។ បានបណ្តុះបណ្តាលស្តីពីអនាម័យ និងអនាម័យបាន ៩២៥គ្រួសារ។

២៦៦. ការអប់រំ (មត្តេយ្យសិក្សា និងបឋមសិក្សា)៖ បានទទួលការកសាងសមត្ថភាពលើ STEM ការអានកម្រិតដំបូង និងការវាយតម្លៃគណិតវិទ្យា ដល់គ្រូបឋមសិក្សា ២០នាក់ និងគ្រូមត្តេយ្យសិក្សា ១៧៣នាក់។

២៦៧. ការចូលរួមសហគមន៍សង្គម៖ បានបណ្តុះបណ្តាលដើម្បីបង្កើនទំនួលខុសត្រូវសង្គម វិមជ្ឈការ និងជំនាញវិសហមជ្ឈការ ដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនចំនួន ១៨៥នាក់។ លើសពីនេះ ក៏បានបណ្តុះបណ្តាលអំពីអភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គម ដល់សមាជិកសហគមន៍ចំនួន ២២០នាក់ ក្នុងនោះស្រី ១៤៤នាក់ ។

២៦៨. ក្រៅពីកម្មវិធីធំៗទាំង ៥ ខាងលើ អង្គការជីវិតថ្លៃថ្នូរក៏មានគម្រោងបន្ថែមមួយចំនួនទៀត ដូចជា៖ គម្រោងកិច្ចសហប្រតិបត្តិការអភិវឌ្ឍសេដ្ឋកិច្ចស្ត្រីជំហានទី ៣ (CWED III) គម្រោងដោះស្រាយវិវាទជំនួសក្នុងតំបន់ (LADR) គម្រោងការអភិវឌ្ឍន៍រួមសម្រាប់ភាពពេញលេញនៃជីវិត (HDFL) គម្រោងសមាហរណកម្មកុមារ/យុវជននៅក្នុងការគ្រប់គ្រងការអភិវឌ្ឍន៍សហគមន៍ និងការគ្រប់គ្រងការអភិវឌ្ឍន៍ភូមិ គម្រោងមត្តេយ្យសហគមន៍ គម្រោងកម្ពុជាប្រឆាំងការជួញដូរមនុស្ស គម្រោងការកែលម្អខ្សែសង្វាក់តម្លៃកសិកម្មនៅក្នុងខេត្តកំពង់ស្ពឺ ប្រទេសកម្ពុជា (IAGRO) គម្រោងជំនួយត្រៀម និងឆ្លើយតបបន្ទាន់ដល់សហគមន៍ក្នុងស្រុកភ្នំស្រួច ប្រទេសកម្ពុជា (EPRS) គម្រោងបសុបក្សីនៃមោទនភាពជាតិ (PPNP) គម្រោងការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃបន្លែនៅកម្ពុជា (CVCD) គម្រោងភាពពេញលេញនៃជីវិតសម្រាប់កុមារ និងយុវជននៅទីក្រុង (FLUCY) និងគម្រោងអំពូលភ្លើងព្រះអាទិត្យ (មូលនិធិ JELA និង Panasonic)។ល។

### ឆ. អង្គការសម្ព័ន្ធដើម្បីសិទ្ធិកុមារកម្ពុជា

២៦៩. នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៣ អង្គការសម្ព័ន្ធសិទ្ធិកុមារកម្ពុជា បានបើកវគ្គបណ្តុះបណ្តាលលើប្រធានបទអំពីរបៀបដែលការប្រែប្រួលអាកាសធាតុប៉ះពាល់ដល់កុមារ។ វគ្គបណ្តុះបណ្តាលនេះមានការចូលរួមពីកុមារ និងក្មេងជំទង់ចំនួន ១៩នាក់ ក្នុងនោះមានកុមារីចំនួន ១២នាក់ ដែលមានអាយុចាប់ពី ១៤-២៤ឆ្នាំ។ គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះ គឺដើម្បីបង្កើនការយល់ដឹងអំពីរបៀបដែលការប្រែប្រួលអាកាសធាតុប៉ះពាល់ដល់កុមារ និងលើកកម្ពស់ការយល់ដឹងរបស់អ្នកចូលរួមអំពីសិទ្ធិកុមារចំពោះបរិស្ថានដែលមានសុវត្ថិភាព។

២៧០. នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៣ អង្គការសម្ព័ន្ធសិទ្ធិកុមារកម្ពុជា បានគាំទ្រយុវជនតំណាងចំនួន ០៥នាក់ ស្រី០៣ ដើម្បីចូលរួមក្នុងកិច្ចសន្ទនាថ្នាក់តំបន់តាមអ៊ីនធឺណិត ស្តីពីសិទ្ធិកុមារជាមួយកុមារនៅក្នុងតំបន់អាស៊ី។ ក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នេះ យុវជនបានលើកឡើងពីកង្វល់ និងបញ្ហាសំខាន់ៗមួយចំនួន ដែលពួកគេបានជួបប្រទះ និងសង្កេតឃើញនៅក្នុងសហគមន៍ ដូចជាការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង ឬស្រាបៀរនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ឬទូរទស្សន៍ ដែលប៉ះពាល់ដល់ការអភិវឌ្ឍន៍ និងសុវត្ថិភាពកុមារ។ លើសពីនេះ ពួកគេក៏បានលើកឡើងផងដែរថា បច្ចុប្បន្ននេះ ប្រព័ន្ធផ្សព្វផ្សាយសង្គមមានកម្មវិធីសប្បាយៗជាច្រើន និងខ្លឹមសារមិនសូវល្អ (វីដេអូខ្លីសិចស៊ី បៀតបៀន) ដែលអាចប៉ះពាល់ដល់ការអប់រំ និងអារម្មណ៍របស់កុមារ។

២៧១. នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៣ អង្គការសម្ព័ន្ធសិទ្ធិកុមារកម្ពុជា បានគាំទ្រកុមារនិងមនុស្សវ័យជំទង់ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ អំពីសេចក្តីសន្និដ្ឋានលើការអង្កេតចុងក្រោយស្តីពីសិទ្ធិកុមារតាមរយៈអ៊ីនធឺណិត។ សិក្ខាសាលានេះ មានគោលបំណងផ្សព្វផ្សាយដល់កុមារ និងមនុស្សវ័យជំទង់អំពីអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារ ដាក់ជូនរដ្ឋាភិបាលសម្រាប់ការអនុវត្តសម្រាប់នៅក្នុងជុំបន្ទាប់។ មួយទៀតគឺការលើកទឹកចិត្តកុមារនិងក្មេងជំទង់ឱ្យចូលរួមក្នុងការអនុវត្តអនុសាសន៍ទាំងនោះផងដែរ។ ដែលមានកុមារ និងក្មេងជំទង់ប្រមាណ ៣៥នាក់ ក្នុងនោះមានក្មេងស្រី ១៩នាក់។

២៧២. នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៣ អង្គការសម្ព័ន្ធសិទ្ធិកុមារកម្ពុជាបានគាំទ្រ កុមារនិងយុវជនចំនួន ២៤នាក់ ស្រី ១៥នាក់ ដើម្បីចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការការពារអនាម័យតាមអនឡាញជាមួយក្រសួង ស.អ.យ. នៅការិយាល័យយូនីសេហ្វក្នុងរាជធានីភ្នំពេញ។ ជាលទ្ធផលក្រុមកុមារ និងយុវជនបានទទួលចំណេះដឹងលើប្រព័ន្ធផ្សព្វផ្សាយសង្គម (Tik Tok, Telegram, Instagram, Facebook, Youtube, Line...)។ លើសពីនេះ ពួកគេក៏បានបង្កើនទំនុកចិត្តក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម (ឧបករណ៍វាស់ស្ទង់) ក៏ដូចជាការការពារហានិភ័យពីការរំលោភបំពានលើកុមារតាមអ៊ីនធឺណិតផងដែរ។

២៧៣. នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៣ អង្គការសម្ព័ន្ធសិទ្ធកុមារកម្ពុជាបានគាំទ្រកុមារនិងយុវជនចំនួន ០៥នាក់ ស្រី ០៤នាក់ ដើម្បីចូលរួមក្នុងព្រឹត្តិការណ៍ស្តីពីសិទ្ធិកុមារអាស៊ីប៉ាស៊ីហ្វិក ។ ព្រឹត្តិការណ៍នេះត្រូវបានបង្កើតឡើងក្នុងគោលបំណងផ្តល់ឱកាសពិសេសមួយសម្រាប់កុមារមកពីប្រទេសផ្សេងៗ ក្នុងការចែករំលែកទស្សនៈ និងបទពិសោធន៍របស់ពួកគេទាក់ទងនឹងបញ្ហាកុមារ។ ជាលទ្ធផល មានកុមារាម្នាក់របស់កម្ពុជាត្រូវបានអញ្ជើញជាតំណាងកុមារ និងយុវជនក្នុងការចែករំលែកបទពិសោធន៍ និងទស្សនៈរបស់គាត់ទាក់ទងនឹងបញ្ហាកុមារនៅកម្ពុជា។

២៧៤. នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៣ អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជាបានគាំទ្រកុមារ និងយុវជនចំនួន ០២ នាក់ ស្រី ០១នាក់ ដើម្បីចូលរួមក្នុងព្រឹត្តិការណ៍ស្តីពីការបំបៅកូនដោយទឹកដោះម្តាយពិភពលោក នៅសណ្ឋាគារកាំបូឌីយ៉ាណា។ ជាមួយនឹងការរៀនពីព្រឹត្តិការណ៍នេះ តាមរយៈរបាយការណ៍របស់ក្រុមតំណាងកុមារនិងយុវជន ពួកគេបានរៀនអំពីសារៈសំខាន់នៃការបំបៅកូនដោយទឹកដោះម្តាយ។ ដោយសារព្រឹត្តិការណ៍នេះមានសារៈសំខាន់ ពួកគេបានស្នើឱ្យរៀបចំព្រឹត្តិការណ៍ដ៏ល្អនេះ ដូចជាការលើកកម្ពស់ការយល់ដឹងនៅសហគមន៍មូលដ្ឋាន ដើម្បីឲ្យប្រជាពលរដ្ឋ ជាពិសេសស្ត្រីដឹងពីសារៈសំខាន់នៃការបំបៅកូនដោយទឹកដោះម្តាយ។

២៧៥. ចាប់ពីថ្ងៃទី១៦-២១ ខែសីហា ឆ្នាំ២០២៣ អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជាបានគាំទ្រតំណាងកុមារនិងយុវជនចំនួន ០២នាក់ ស្រី ០១នាក់ ដើម្បីចូលរួមកិច្ចប្រជុំកុមារថ្នាក់តំបន់នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ដែលរៀបចំឡើងក្នុងគោលបំណងភ្ជាប់ទំនាក់ទំនង និងលើកកម្ពស់ការចូលរួមរបស់កុមារក្នុងតំបន់អាស៊ីក្នុងការការពារ និងលើកកម្ពស់សិទ្ធិកុមារ។

២៧៦. នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣ អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជាបានគាំទ្រកុមារនិងយុវជនចំនួន ២៤ នាក់ ស្រី ១១នាក់ ដើម្បីចូលរួមក្នុងការដាក់ឱ្យដំណើរការស្តីពីគោលការណ៍ណែនាំស្តីពីការការពារកុមារតាមអ៊ីនធឺណិតសម្រាប់ឧស្សាហកម្មបច្ចេកវិទ្យាឌីជីថល នៅក្រសួងទូរគមនាគមន៍ និងប្រៃសណីយ៍។ ដោយក្រសួងបានបង្ហាញពីដំណើរការបង្កើតគោលការណ៍ណែនាំនោះ និងអត្ថប្រយោជន៍នៃគោលការណ៍ណែនាំនោះសម្រាប់កុមារ និងយុវជន នៅពេលពួកគេចូលប្រើថ្នាលកម្មវិធីអនឡាញផងដែរ។

២៧៧. នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៣ អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជាបានសម្របសម្រួលជាមួយកុមារ និងយុវជន ចំនួន ០៤នាក់ ស្រី ០២នាក់ ដើម្បីធ្វើជាវាគ្មិនស្វែងរកសម្រាប់កម្មវិធីអនឡាញក្នុងអំឡុងទិវាសិទ្ធិនារី ។ កម្មវិធីផ្សាយផ្ទាល់នេះត្រូវបានបង្កើតឡើងក្នុងគោលបំណងចែករំលែកបទពិសោធន៍នៃការពង្រឹងសិទ្ធិស្ត្រី និងរបៀបលើកកម្ពស់សិទ្ធិស្ត្រី ទាំងការងារ និងបរិយាកាសគ្រួសារ។

២៧៨. នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា បានគាំទ្រកុមារ និងយុវជន ចំនួន ១២ នាក់ ស្រី ០៣នាក់ ដើម្បីធ្វើកិច្ចសន្ទនាជាមួយបណ្ឌិត្យសភានគរបាលកម្ពុជា ស្តីពីសិទ្ធិកុមារ និងការការពារកុមារ ដើម្បីផ្តល់ឱកាសដល់កុមារនិងយុវជនក្នុងការបញ្ចេញមតិ និងការលើកឡើងនូវសំណូមពរ។ ក្នុងអំឡុងពេលកិច្ចសន្ទនា កុមារ និងយុវជនបានលើកឡើងនូវកង្វល់សំខាន់ៗមួយចំនួនដូចជាមនុស្សពេញវ័យ និងសហគមន៍មានការរើសអើង យន្តការអន្តរាគមន៍ និងការឆ្លើយតបថ្នាក់មូលដ្ឋាននៅមានកម្រិត អំពើហិង្សាលើកុមារនៅតែកើតមានឡើង ខ្វះចន្លោះយន្តការនិងឱកាសសម្រាប់កុមារងាយរងគ្រោះក្នុងការចូលរួម និងបញ្ចេញនូវកង្វល់របស់ពួកគេ។ ជាលទ្ធផល សំឡេងរបស់កុមារនិងយុវជន ត្រូវបានស្តាប់ និងទទួលយកដោយបណ្ឌិត្យសភានគរបាលជាតិកម្ពុជា។

២៧៩. ចាប់ពីថ្ងៃទី២៤-២៥ ខែមិថុនា ឆ្នាំ២០២៣ បណ្តាញដែលដឹកនាំដោយកុមារនិងយុវជនចំនួន ៣៣នាក់ ស្រី ១៦នាក់ បានសហការគ្នាធ្វើសន្និសិទប្រចាំឆមាសរបស់ពួកគេនៅរាជធានីភ្នំពេញ។ គោលបំណងនៃព្រឹត្តិការណ៍នេះ គឺដើម្បីឆ្លុះបញ្ចាំងពីសមិទ្ធផលពាក់កណ្តាលឆ្នាំ ការរៀនសូត្រពីការអនុវត្តល្អៗ បញ្ហាប្រឈម និងដំណោះស្រាយ រួមទាំងការលើកកម្ពស់សមត្ថភាពរបស់សមាជិកគណៈកម្មាធិការដឹកនាំ។ ជាពិសេស ដើម្បីធ្វើបច្ចុប្បន្នភាពផែនការតស៊ូមតិ និងការអនុវត្តសកម្មភាពសម្រាប់រយៈពេលប្រាំមួយ

ខែខាងមុខ ដើម្បីបន្តពង្រឹង និងកែលម្អមុខងារ នៃបណ្តាញដឹកនាំកុមារ និងយុវជន ព្រមទាំងកិច្ចសហប្រតិបត្តិការរវាងគ្នានឹងគ្នា ដែលអាចឱ្យពួកគេចូលរួមយ៉ាងជិតស្និទ្ធ។

២៨០. គាំទ្រកុមារ និងយុវជន ០២នាក់ ស្រី ០១នាក់ បានចូលរួមកិច្ចប្រជុំជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្រី និងកុមារ នៅស្រុកសង្កែ និងខេត្តបាត់ដំបង ដើម្បីលើកយកបញ្ហាសំខាន់ៗទាក់ទងនឹងកុមារ និងកុមារវ័យជំទង់ ដើម្បីស្វែងរកកិច្ចអន្តរាគមន៍ និងការគាំទ្រពីអាជ្ញាធរមូលដ្ឋាន។ ជាលទ្ធផលសំឡេងរបស់ពួកគេត្រូវបានឮ និងទទួលយក។

២៨១. នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣ អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជាបានសហការជាមួយអង្គការ Tdh Germany និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិសិទ្ធិមនុស្ស ដើម្បីគាំទ្រដល់កុមារចំនួន ០២នាក់ (កុមារី ០១នាក់ អាយុ ១៥ឆ្នាំ) នៅខេត្តរតនគិរី ដើម្បីផលិតសេចក្តីថ្លែងការណ៍ជាវីដេអូខ្លីមួយ ដែលផ្តោតលើបរិស្ថាន និងការប្រែប្រួលអាកាសធាតុ សម្រាប់ដាក់តាំងបង្ហាញក្នុងពិធីសម្ពោធជាផ្លូវការនូវមតិទូទៅទី២៦ (General Commend 26) ស្តីពីសិទ្ធិកុមារ និងបរិស្ថាន ដែលផ្តោតជាពិសេសលើការប្រែប្រួលអាកាសធាតុ។ វីដេអូនេះត្រូវបានរួមបញ្ចូលជាមួយកុមារមកពីប្រទេសអាល្លឺម៉ង់ និងហ្ស៊ីមបាវ៉េ ដែលមានរយៈពេលពី ២.៥ ទៅ ៣ នាទី ដោយបង្ហាញសាររបស់កុមារអំពីសារៈសំខាន់ នៃការចូលរួមរបស់កុមារនៅក្នុងដំណើរការសម្រេចចិត្តទាក់ទងនឹងសិទ្ធិ បរិស្ថាន និងសកម្មភាពបម្រែបម្រួលអាកាសធាតុ។ ជាលទ្ធផល វីដេអូនេះត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅទីក្រុងហ្សឺណែវ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៣ ហើយបានចាក់ផ្សាយ (ផ្សាយផ្ទាល់) ក្នុងកិច្ចប្រជុំលើកទី២៧៤៧ សម័យប្រជុំលើកទី៩៤ គណៈកម្មាធិការសិទ្ធិកុមារ។

២៨២. អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជាបានគាំទ្រកុមារនិងយុវជនចំនួន ៥១នាក់ ស្រី ៣៣នាក់ ដើម្បីចូលរួមក្នុងព្រឹត្តិការណ៍សំខាន់ៗចំនួន ០៤ ទាំងថ្នាក់ជាតិ និងតំបន់ ដើម្បីបង្ហាញពីកង្វល់របស់ពួកគេ ព្រមទាំងលើកកម្ពស់សមត្ថភាពទាក់ទងនឹងសិទ្ធិកុមារ ការការពារកុមារ និងសមភាពយេនឌ័រ។ ជាក់ស្តែងកាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២៣ មានក្មេងស្រី ០១នាក់ មកពីបណ្តាញដែលដឹកនាំដោយកុមារនិងយុវជនត្រូវបានអញ្ជើញ ជាវាគ្មិនក្នុងអំឡុងការសម្ពោធថ្នាក់តំបន់នៃមតិទូទៅទី២៦ ក្នុងប្រទេសថៃ ស្តីពីសិទ្ធិកុមារក្នុងបរិស្ថានដែលមានសុខភាពល្អដែលផ្តោតលើការប្រែប្រួលអាកាសធាតុ។ លើសពីនេះ អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា ក៏បានគាំទ្រកុមារយុវជនចំនួន ១២នាក់ (ស្រី ០៧នាក់) ជួបជាមួយគណៈកម្មាធិការសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ ដើម្បីពិភាក្សាអំពីស្ថានភាពកុមារ និងយុវជននៅកម្ពុជា និងបង្ហាញនូវសំណូមពរផងដែរពាក់ព័ន្ធនឹងអំពើហិង្សាលើកុមារ គុណភាពក្នុងវិស័យអប់រំ និងការចូលរួម។ លើសពីនេះ គម្រោងក៏បានជួយគាំទ្រកុមារនិងយុវជនចំនួន ០៧នាក់ ស្រី ០៥នាក់ ដែលមានអាយុពី ១២-១៧ឆ្នាំ ដើម្បីចូលរួមក្នុងសិក្ខាសាលាស្តីពីសកម្មភាពអាកាសធាតុរបស់កុមារនៅអាស៊ីនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងបានធ្វើយុទ្ធនាការរយៈពេល ១៦ថ្ងៃ ដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រីវ័យក្មេង ចាប់ពីថ្ងៃទី២៥ ខែវិច្ឆិកា ដល់ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៣។

### ៤. សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ

២៨៣. នៅថ្ងៃទី២៨-២៩ ខែមីនា ឆ្នាំ២០២៣ នៅសណ្ឋាគាប៉ូឡូវ៉េ រាជធានីភ្នំពេញ សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារបានរៀបចំសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការចូលរួមរបស់កុមារ ដល់

អជ្ញាធរឃុំ និងអង្គការដៃគូ ចំនួន២៥នាក់ ក្នុងនោះមានស្រី១០នាក់ និងអ្នកមានពិការភាព ២នាក់ ក្នុងគោលបំណង បង្កើនចំណេះដឹងដល់សិក្ខាកាមលើការលើកកម្ពស់ការចូលរួមរបស់កុមារ និងរៀបចំផែនការសកម្មភាពសម្រាប់លើកកម្ពស់ការចូលរួមរបស់កុមារក្នុងដំណើរការអភិវឌ្ឍន៍ឃុំ-សង្កាត់។

២៨៤. នៅថ្ងៃទី១៦-១៧ ខែឧសភា ឆ្នាំ២០២៣ នៅសណ្ឋាគារសិនសូវីផាកភ្នំពេញ សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីយុទ្ធនាការ និងការផលិតវីដេអូខ្លី ដល់កុមារ និងយុវជន ចំនួន២៦នាក់ ក្នុងនោះមានស្រី១៥នាក់ ប្រុស៩នាក់ និងអ្នកប្លែងយេនឌ័រ ២នាក់ ក្នុងគោលបំណងបង្កើនការយល់ដឹងដល់កុមារ និងយុវជន វិធីសាស្រ្ត ឧបករណ៍ របៀបរៀបចំផែនការយុទ្ធនាការ ការធ្វើយុទ្ធនាការ ការប៉ាន់ប្រមាណហានិភ័យ និងគោលការណ៍សុវត្ថិភាព ព្រមទាំងបង្កើនចំណេះដឹងដល់កុមារយុវជនក្នុងការផលិតវីដេអប់រំតាមទូរស័ព្ទដៃផងដែរ។

២៨៥. នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣ នៅសាលមហោស្រពនៃមជ្ឈមណ្ឌលសន្និបាត និងពិព័រកោះពេជ្រ សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ បានសហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រៀបចំប្រារព្ធពិធី ខួបលើកទី៧៤ ទិវាកុមារអន្តរជាតិ១មិថុនា និងខួបលើកទី២២ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជា ក្រោមប្រធានបទ "យើងរួមគ្នាថែរក្សាការពារ និងអភិវឌ្ឍកុមារគ្រប់រូប ក្រោមម្លប់សន្តិភាពក្នុងយុគសម័យឌីជីថល" និងខួបលើកទី២២ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា ក្រោមប្រធានបទ "យុត្តិធម៌សង្គមសម្រាប់គ្រប់គ្នាដើម្បីបញ្ចប់ពលកម្មកុមារ"។ សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ បានសម្របសម្រួលកុមារ ២រូប កុមារាម្នាក់ និងកុមារីម្នាក់ ដើម្បីឡើងថ្លែងសន្ទរកថា ព្រមទាំងដឹកនាំការចូលរួមរបស់កុមារ និងយុវជនចំនួន ៥៨នាក់ (ស្រី៣៩នាក់) មកពីរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តតាកែវ។

២៨៦. នៅថ្ងៃទី២៤-២៥ ខែមិថុនា ឆ្នាំ២០២៣ នៅសណ្ឋាគារសិនសូវីផាក រាជធានីភ្នំពេញ សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារបានរៀបចំនូវវគ្គបណ្តុះបណ្តាល ស្តីពីការវិភាគស្ថានភាពសិទ្ធិកុមារ និងការសរសេរបាយការណ៍ ដល់កុមារ និងយុវជនចំនួន ២៦នាក់ (ស្រី១៨នាក់) ក្នុងគោលបំណងដើម្បីឲ្យកុមារយល់ដឹងអំពីការវិភាគស្ថានភាពសិទ្ធិកុមារ ឧបករណ៍ទាំងបី (ផែនទីដងខ្លួន ដើមឈើវិភាពបញ្ហា និងបាតដៃសំណូមពរ) និងយល់ដឹងអំពីរបៀបសរសេររបាយការណ៍។ ជាមួយគ្នានេះផងដែរ សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ ក៏បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយកុមារ និងយុវជនចំនួន ២៨នាក់ (ស្រី១៥នាក់) លើការកសាងផែនការយុទ្ធសាស្រ្តរបស់សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ ក្នុងគោលបំណងប្រមូលធាតុចូលរបស់កុមារ យុវជនទាំងបីបណ្តាញ (CCYMCR, CAN និងAYRG) ក្នុងការកសាងផែនការយុទ្ធសាស្រ្ត។

២៨៧. នៅថ្ងៃទី៧-៨ ខែកក្កដា ឆ្នាំ២០២៣ នៅរាជធានីភ្នំពេញ សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារបានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីយុទ្ធនាការ និងការផលិតវិដេអូលើកទី២ ដល់កុមារ និងយុវជន ចំនួន១៩នាក់ (ស្រី ១២នាក់) ក្នុងគោលបំណងបង្កើនការយល់ដឹងដល់កុមារ និងយុវជន វិធីសាស្រ្ត ឧបករណ៍ របៀបរៀបចំផែនការយុទ្ធនាការ ការធ្វើយុទ្ធនាការ ការប៉ាន់ប្រមាណហានិភ័យ និងគោលការណ៍សុវត្ថិភាព ព្រមទាំងបង្កើនចំណេះដឹងដល់កុមារយុវជនក្នុងការផលិតវីដេអូអប់រំតាមទូរស័ព្ទដៃផងដែរ។

២៨៨. នៅថ្ងៃទី២៩-៣០ ខែកក្កដា ឆ្នាំ២០២៣ នៅក្កាតរីស៊ត ខេត្តកំពត សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារបានរៀបចំនូវវគ្គបណ្តុះបណ្តាល ស្តីពីការស្វែងរកមតិគាំទ្រដល់កុមារ និងយុវជនចំនួន ៣១នាក់ (ស្រី ១៨នាក់) ក្នុងគោលបំណងបង្កើនការយល់ដឹងដល់កុមារនិងយុវជនពីការស្វែងរកមតិគាំទ្រ ដើម្បីអោយពួកគេចេះពីរបៀបស្វែងរកមតិគាំទ្រពីអ្នកពាក់ព័ន្ធក្នុងការដោះស្រាយបញ្ហារបស់កុមារ។

២៨៩. នៅថ្ងៃទី២៣-២៤ ខែកញ្ញា ឆ្នាំ២០២៣ នៅសណ្ឋាគារប៉ូឡូវែ រាជធានីភ្នំពេញ សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការលើកកម្ពស់ការចូលរួមរបស់កុមារ ក្នុងកម្មវិធីវិនិយោគឃុំ ដល់កុមារ និងយុវជនចំនួន ២៥នាក់ (ស្រី ១៦នាក់) មកពីខេត្តកណ្តាល តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង ក្រចេះ និងសៀមរាប ក្នុងគោលបំណងដើម្បីបង្កើនការយល់ដឹងដល់កុមារលើដំណើរការវិនិយោគជាសាធារណៈសម្រាប់កុមារ និងលើកកម្ពស់ការចូលរួមរបស់កុមារក្នុងកម្មវិធីវិនិយោគឃុំ។

២៩០. នៅថ្ងៃទី១៧-១៨ ខែធ្នូ ឆ្នាំ២០២៣ នៅសណ្ឋាគារខេមរាអង្គរ ខេត្តសៀមរាប សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ បានរៀបចំសន្និបាតប្រចាំឆ្នាំ២០២៣ ជាមួយនិងសមាជិកបណ្តាញ ក្នុងគោលបំណង ដើម្បីបូកសរុប និងឆ្លុះបញ្ចាំងពីលទ្ធផលសម្រេចបាន បញ្ហាប្រឈម ដំណោះស្រាយប្រចាំឆ្នាំ២០២៣របស់សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ និងសមាជិកបណ្តាញ ព្រមទាំងរៀបចំផែនការសកម្មភាពឆ្នាំ២០២៤ របស់សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ និងសមាជិកបណ្តាញ ដែលមានអ្នកចូលរួមសរុបចំនួន ៤៦នាក់ (ស្រី ២៦នាក់) មកពីបណ្តាញបណ្តាញសមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ បណ្តាញកុមារអ្នកតស៊ូមតិ បណ្តាញក្រុមតំណាងយុវវ័យ និងយុវជន និងបណ្តាញគ្មានទេសម្រាម។

២៩១. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៣ នៅសណ្ឋាគារខេមរា ខេត្តសៀមរាប សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ បានរៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងប្រចាំឆ្នាំ២០២៣ រវាងសមាជិកបណ្តាញ និងអាជ្ញាធរឃុំ ក្នុងគោលបំណង ឆ្លុះបញ្ចាំងពីលទ្ធផល បញ្ហាប្រឈម ដំណោះស្រាយ សំណូមពរ និងផែនការបន្តរបស់បណ្តាញដែលដឹកនាំដោយកុមារ និងអាជ្ញាធរ។ នៅក្នុងកម្មវិធីនេះ មានអ្នកចូលរួម ៦១នាក់ (ស្រី ៣៩នាក់) ដែលមានកុមារ និងយុវជន ចំនួន ៣៣នាក់ (ស្រី ១៩នាក់) និងអជ្ញាធរឃុំ ១៦នាក់ (ស្រី ១២នាក់) គណៈកម្មាធិការប្រតិបត្តិ ៧នាក់ (ស្រី៥នាក់) បុគ្គលិកអង្គការសង្គ្រោះកុមារកម្ពុជា ១នាក់ ក្រុមប្រឹក្សា ៤នាក់ (ស្រី១នាក់)។

២៩២. សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ បានរៀបចំនូវវគ្គបណ្តុះបណ្តាលស្តីអំពីនិន្នាការភេទ អត្តសញ្ញាយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ទៅដល់កុមារ យុវជន អជ្ញាធរឃុំ និងសហគមន៍ ក្នុងគោលបំណងលើកកម្ពស់ចំណេះដឹងអ្នកចូលរួមអំពីនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ព្រមទាំងលើកកម្ពស់ចំណេះដឹងអ្នកចូលរួមអំពីសិទ្ធិកុមារ រួមបញ្ចូលកុមារដែលមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រផ្សេងៗ ដោយមានអ្នកចូលរួមសរុប ១៣០នាក់ ស្រី៨០នាក់ និងប្រុស៥០នាក់ដែលស្ថិតនៅចំនួន៥ទីតាំងរួមមាន ឃុំព្រែករកា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ថ្ងៃទី ២៣ មេសា ២០២៣ ឃុំក្លាំងហាយ ស្រុកស្រីស្នំ ខេត្តសៀមរាប ថ្ងៃទី២៩ មេសា ២០២៣ ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ថ្ងៃទី ១៩ សីហា ២០២៣ ឃុំស្លា ស្រុកសំរោង ខេត្តតាកែវ ថ្ងៃទី២៣ តុលា ២០២៣ និងឃុំស្ពុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ថ្ងៃទី៣ វិច្ឆិកា ២០២៣។

២៩៣. សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ បាកគាំទ្រក្រុមដែលដឹកនាំដោយកុមារ និងយុវជន ចំនួន ១២ក្រុម នៅថ្នាក់ក្រោមជាតិ ដឹកនាំក្រុមរបស់ពួកគេធ្វើគំនិតផ្តួចផ្តើមយុទ្ធនាការ ចំនួន ១៣លើក នៅក្នុងសហគមន៍ ក្រោមប្រធានបទ ការលុបបំបាត់ការរើសអើងលើកុមារដែលមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រផ្សេងៗ ការទប់ស្កាត់កុមារប្រើប្រាស់គ្រឿង និងគ្រឿងស្រវឹង ផលប៉ះពាល់នៃប្លាស្ទិកទៅដល់បរិស្ថាន ការផ្សព្វផ្សាយពីផលប៉ះពាល់នៃការបោះបង់ចោលការសិក្សា និងផលប៉ះពាល់នៃការរៀបការវ័យក្មេង។ យុទ្ធនាការទាំងអស់នោះ មានការចូលរួមពី កុមារ យុវជន ប្រជាពលរដ្ឋក្នុងសហគមន៍ អជ្ញាធរ និងគ្រូបង្រៀន ចំនួន ១០៥១ នាក់ ស្រី៦៣៣នាក់ ប្រុស៤១៣នាក់ និងផ្សេងៗ៥នាក់។

២៩៤. ដើម្បីលើកកម្ពស់ការចូលរួមរបស់កុមារក្នុងការធ្វើសេចក្តីសម្រេចចិត្ត សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ ក៏បានផ្តល់ការគាំទ្រថវិកាដល់ឃុំចំនួន៤ ដើម្បីដំណើរការកិច្ចប្រជុំប្រចាំខែគណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារឃុំ (គ.ក.ន.ក.) ព្រមទាំងផ្តល់ការគាំទ្រដល់កុមារចូលរួមកិច្ចប្រជុំ គ.ក.ន.ក. ផងដែរ ដើម្បីអោយកុមារទទួលបានព័ត៌មានពីស្ថានភាពឃុំរបស់ពួកគេ បានលើកឡើងការព្រួយបារម្ភ និងមតិយោបល់របស់ពួកគេទៅកាន់អ្នកមានកាតព្វកិច្ច។

## III. បញ្ហាប្រឈម

២៩៥. ទោះបីគោលនយោបាយ កម្មវិធីជាតិ និងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ បាននិងកំពុងអនុវត្តល្អគួរឲ្យកត់សម្គាល់ក៏ដោយ ក៏ស្ថានភាពកុមារនៅមានភាពប្រឈមនៅឡើយ។ ប្រជាជនយើងភាគច្រើនជាកសិករ កូនៗដែលនៅក្នុងបន្ទុកគ្រួសារ ត្រូវចូលរួមការងារស្រែចម្ការជាមួយឪពុកម្តាយរបស់ពួកគេតាំងពីដើមរៀងមកដើម្បីជីវភាព។ គ្រួសារមួយចំនួនទៀត បានចំណាកស្រុក ដែលនាំឱ្យប៉ះពាល់ដល់កុមារ ជាពិសេសការរៀនសូត្រ សុខភាពជាដើម។ លើសពីនេះទៀត ផលប៉ះពាល់ចំពោះកុមារនាពេលបច្ចុប្បន្ន គឺការប្រើប្រាស់គ្រឿងញៀន ដែលបាននិងកំពុងរីករាលដាលពីទីក្រុងទៅជនបទ។ល។

២៩៦. ការអនុវត្តច្បាប់ លិខិតបទដ្ឋាន ផែនការជាតិ យុទ្ធសាស្រ្តជាតិ អនុសញ្ញាស្តីពីសិទ្ធិកុមារនិងពិធីសារបន្ថែម និងលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធស្តីពីការការពារកុមារ ការកាត់បន្ថយ និងការលុបបំបាត់ពលកម្មកុមារ កុមារប្រើប្រាស់សារធាតុញៀន អំពើជួញដូរកុមារ អំពើហិង្សា ការកេងប្រវ័ញ្ចគ្រប់រូបភាព ការសុំកូនអន្តរប្រទេស ។ល។ និងការធានាការពារកុមារឱ្យរីកលូតលាស់មានសុខុមាលភាពកុមារ មិនទាន់បានផ្សព្វផ្សាយឱ្យបានទូលំទូលាយនៅឡើយ ពិសេសការអនុវត្តរាល់លិខិតបទដ្ឋានទាំងនេះនៅមានកម្រិតនៅឡើយ។

២៩៧. បញ្ហាប្រឈមក្នុងវិស័យសុខាភិបាល ទាំងបញ្ហាសុខភាពរបស់ប្រជាជន និងបញ្ហាក្នុងប្រព័ន្ធសុខាភិបាលក្នុងពេលចំពោះមុខ និងក្នុងបណ្តាឆ្នាំខាងមុខ រួមមាន៖

- បន្ទុកជំងឺមិនឆ្លងកំពុងកើនឡើង រួមជាមួយឥរិយាបទប្រឈមនឹងកត្តាហានិភ័យនៃជំងឺ ខណៈដែលកម្ពុជាកំពុងស្ថិតនៅលើផ្លូវឆ្ពោះទៅកាន់សង្គមដែលមានមនុស្សចាស់កាន់តែច្រើន។
- សុខភាពបន្តពូជ សុខភាពមាតា ទារក និងកុមារ និងអាហារូបត្ថម្ភត្រូវបានរំពឹងខ្ពស់ថា កាន់តែមានភាពប្រសើរឡើង។
- ជំងឺឆ្លង និងជំងឺតំបន់ត្រូពិក នៅតែជាបញ្ហាសុខភាពសាធារណៈ ប៉ុន្តែការគ្រប់គ្រងឬការលុបបំបាត់ជំងឺឆ្លង/ជំងឺតំបន់ត្រូពិកចម្បងៗ មួយចំនួនគឺជាគោលដៅដែលអាចសម្រេចបាន ដោយផ្អែកលើភាពរឹងមាំនៃអន្តរាគមន៍សុខភាពសាធារណៈ។
- ការគ្របដណ្តប់ប្រជាជនដោយរាប់បញ្ចូលទាំងជនចំណាកស្រុក នៃប្រព័ន្ធគាំពារសង្គម ការគ្របដណ្តប់នៃសេវាសុខាភិបាល និងបន្ទុកចំណាយលើការថែទាំសុខភាព។
- ការគម្រាមកំហែងសុខភាពសាធារណៈ និងសកម្មភាពសង្គម ដែលបណ្តាលមកពីជំងឺឆ្លង ដែលកំពុងលេចឡើង ឬលេចឡើងសារជាថ្មី។
- ការគ្របដណ្តប់គុណភាព និងសុវត្ថិភាពសេវាសុខាភិបាលនៅមិនទាន់ឆ្លើយតបនឹងតម្រូវការរបស់ប្រជាជន។
- ការកែលម្អភាពប្រឈមប្រទាក់ក្រឡាឱ្យប្រសើរឡើងថែមទៀត ដូចជាការកែលម្អស្ថានភាពអាហារូបត្ថម្ភ កត្តាបរិស្ថាន សង្គមនិងសេដ្ឋកិច្ច ដែលមានឥទ្ធិពលលើសុខភាព។

២៩៨. ទន្ទឹមនឹងសមិទ្ធផលវិស័យអប់រំ ក៏មានបញ្ហាប្រឈមមួយចំនួន មានដូចជា៖

- ការអប់រំកុមារតូច៖ ការចុះឈ្មោះចូលរៀនរបស់កុមារអាយុ ៣ឆ្នាំ ទៅ ៥ឆ្នាំ គ្រប់រូបភាពនៅមានកម្រិត។ ការអនុវត្តលិខិតបទដ្ឋានគតិយុត្តគាំទ្រការគាំពារ និងអភិវឌ្ឍន៍កុមារតូចនៅមិនទាន់ឆ្លើយតបបានពេញលេញ។ ការអនុវត្តកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា និងសៀវភៅ

សិក្សាគោលសម្រាប់មត្តេយ្យសិក្សាមិនទាន់បានពេញលេញ។ ពុំទាន់មានលិខិតបទដ្ឋានគតិយុត្តគាំទ្រការបង្កើតទារកដ្ឋាន និងការអភិវឌ្ឍកុមារតូច ១ ០០០ ថ្ងៃដំបូង។ សមត្ថភាពបុគ្គលិកអប់រំផ្នែកអប់រំកុមារតូចនៅមិនទាន់ឆ្លើយតបតាមក្របខណ្ឌគុណវុឌ្ឍិ។

- ការអប់រំបឋមសិក្សា៖ មានកត្តាបួនធំៗ ដែលពាក់ព័ន្ធនឹងការអប់រំបឋមសិក្សា រួមមាន ១) កត្តាសាលារៀន៖ អភិបាលកិច្ចសាលារៀននៅមានកម្រិត, គណៈគ្រប់គ្រងសាលាភាគមួយចំនួនមិនទាន់ទទួលបានការបណ្តុះបណ្តាល, សាលារៀនដំណើរការតែមួយពេល ខ្វះអគារសិក្សានិងបន្ទប់សម្រាប់រៀបចំបណ្ណាល័យ បន្ទប់ពិសោធន៍ ទីចាត់ការ និងបន្ទប់កុំព្យូទ័រជាដើម, ខ្វះហេដ្ឋារចនាសម្ព័ន្ធសុខភាពសិក្សា និងការយល់ដឹងអំពីអនាម័យនៅតាមសាលារៀន, ខ្វះហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារបរិក្ខារបម្រើឱ្យការរៀននិងបង្រៀន និងការអប់រំឌីជីថល, ការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ និងកម្មវិធីអាហារូបករណ៍ មិនទាន់ឆ្លើយតបតាមតម្រូវការនៅក្នុងសហគមន៍, ការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនមានផ្ទះបាយ និងកន្លែងទទួលទានអាហារតាមស្តង់ដា មិនទាន់បានឆ្លើយតបទៅនឹងតម្រូវការសិស្សសាលារៀនផ្អាកដំណើរការដោយសារករណីប្រធានសក្តិ ដូចជា រលកកម្តៅ ទឹកជំនន់ ជំងឺរាតត្បាតនានា។ ២) កត្តាគ្រូបង្រៀន៖ សមត្ថភាពគ្រូបង្រៀននៅមានកម្រិត, ការរៀបចំវគ្គវិក្រឹតការគ្រូបង្រៀន មិនបានទៀងទាត់និងជាប់ជាប្រចាំ, និយ័តភាពនិងវិន័យក្នុងការបំពេញការងាររបស់គ្រូនៅមានកម្រិត, គ្រូបង្រៀនមួយចំនួនមានបញ្ហាសុខភាព, គ្រូបង្រៀនអវត្តមានដោយមូលហេតុផ្សេងៗ មិនមានគ្រូបង្រៀនជំនួស, ការលើកទឹកចិត្តដល់គ្រូបង្រៀនដែលបំពេញការងារបានល្អ មិនទាន់ត្រូវបានអនុវត្តឱ្យបានពេញលេញ។ ៣) កត្តាសិស្ស៖ សិស្សមួយចំនួនមិនបានឆ្លងកាត់ថ្នាក់មត្តេយ្យ, សិស្សមានបញ្ហាសុខភាព និងកង្វះអាហារូបត្ថម្ភ, សិស្សមានពិការភាព, សិស្សមករៀនមិនទៀងទាត់ អវត្តមានញឹកញាប់។ ៤) កត្តាគ្រួសារ៖ ភាពក្រីក្រ, ខ្វះចំណេះដឹង, ចំណាកស្រុក, មានអំពើហិង្សា, ជនជាតិដើមភាគតិច, តំបន់ជនបទដាច់ស្រយាល។
- ការអប់រំមធ្យមសិក្សា៖ គ្រឹះស្ថានមធ្យមសិក្សាលើស ឬខ្វះគ្រូតាមនិយាមឯកទេសនៅមិនទាន់បំពេញបានតាមតម្រូវការជាក់ស្តែងរបស់សាលារៀន។ គ្រឹះស្ថានមធ្យមសិក្សាភាគច្រើនមិនទាន់មានបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ បណ្ណាល័យ សម្ភារឧបទេស ស្របតាមកម្មវិធីសិក្សា។ ការអនុវត្តកម្មវិធីអប់រំស្វែមមិនទាន់បានពេញលេញ។ ខ្វះអ្នកឯកទេសជំនាញបច្ចេកវិទ្យាព័ត៌មាន។ ការបំប៉នសមត្ថភាពមន្ត្រីលើការគ្រប់គ្រងសៀវភៅសិក្សាគោល និងបណ្ណាល័យនៅមានកម្រិត។ ការផ្សព្វផ្សាយឯកសារណែនាំគ្រូ ការអនុវត្តកម្មវិធីសិក្សាថ្មី វិធីសាស្ត្របង្រៀន និងការកសាងសម្ភារឧបទេស នៅមានកម្រិត។ ការអប់រំបរិស្ថាននិងការប្រែប្រួលអាកាសធាតុមិនទាន់អនុវត្តបានទូលំទូលាយ។ ការគ្រប់គ្រងនិងការអនុវត្តការងារបណ្ណាល័យនៅតាមសាលារៀនមិនទាន់បានល្អ។ ការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ការអនុវត្តកម្មវិធីអប់រំបច្ចេកទេស និងកម្មវិធីអប់រំបំណិនជីវិត មិនទាន់បានទូលំទូលាយ។ ខ្វះគ្រូបង្រៀនផ្នែកអប់រំបច្ចេកទេស សមត្ថភាពគ្រូលើការប្រើប្រាស់សម្ភារបរិក្ខារគាំទ្រការបង្រៀននិងរៀន វិធីសាស្ត្របង្រៀន និងខ្វះសម្ភារបរិក្ខារគាំទ្រការបង្រៀននិងរៀន។ ខ្វះគ្រូជំនាញអប់រំពិសេស។

២៩៩. បញ្ហាប្រឈមក្នុងវិស័យសង្គមកិច្ច៖ បញ្ហាអំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារអហ្វឡាញ ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើប្រព័ន្ធអនឡាញបានចាប់ផ្តើមកើតឡើង និងរីករាលដាលយ៉ាងឆាប់រហ័ស ស្របតាមការវិវត្តនៃបច្ចេកវិទ្យាឌីជីថល ដែលទាមទារឱ្យអ្នកផ្តល់សេវាកិច្ចការពារ

កុមារ ត្រូវពង្រឹងសមត្ថភាពបន្ថែមទៀត ដើម្បីឱ្យស្របតាមបរិបទថ្មីនេះ។ ដំណើរការកសាងប្រព័ន្ធកិច្ចការពារ និងថែទាំកុមារមិនទាន់បានសម្រេចតាមគោលដៅទាំងស្រុងនៅឡើយទេ។ កំណែទម្រង់ច្បាប់ និងគោលនយោបាយមិនទាន់មានលក្ខណៈសុខដុមនីយកម្ម និងនៅមានភាពភ័ន្តច្រឡំនៅជុំវិញនីតិវិធី តួនាទី និងការទទួលខុសត្រូវនានា។ បន្ថែមពីនេះ យន្តការសម្របសម្រួលនៅមានភាពខ្វះចន្លោះពាក់ព័ន្ធនឹងបែងចែកមុខងារ និងការទទួលខុសត្រូវផ្នែកកិច្ចការពារកុមារ។ ការផ្ទេរមុខងារ និងថវិកាពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការនៅមានបញ្ហាប្រឈមដែលធ្វើឱ្យការឆ្លើយតបទៅនឹងការងារកិច្ចការពារកុមារ នៅមិនទាន់ល្អប្រសើរ។ មណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល ដែលមិនមានលិខិតអនុញ្ញាត និងវិញ្ញាបនបត្រទទួលស្គាល់នៅមានចំនួនច្រើន។

៣០០. ភាពមិនប្រាកដប្រជានៃប្រព័ន្ធមូលដ្ឋានទិន្នន័យថ្នាក់ជាតិជាក់លាក់ ស្តីពីកុមាររងគ្រោះ និងងាយរងគ្រោះ បានបង្កឱ្យភាពរាំងស្ទះក្នុងការប្រើប្រាស់សម្រាប់ធ្វើការវិភាគ និងកំណត់អាទិភាពកិច្ចការពារកុមារ ខណៈពេលដែលប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ កំពុងស្ថិតក្នុងដំណើរការ។ ជាមួយគ្នានេះ ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងករណីតាមបច្ចេកទេស Primero នៅមិនទាន់ដំណើរការដោយរលូន ដោយសារកត្តាខ្វះធនធានមនុស្សក្នុងគ្រប់គ្រង និងការប្រើប្រាស់ចំណេះដឹងផ្នែកបច្ចេកវិទ្យា ហើយប្រព័ន្ធនេះនៅមិនទាន់បានបន្សុីគ្នាជាមួយប្រព័ន្ធផ្សេងទៀត ដូចជាប្រព័ន្ធ OSCaR ជាដើម។

៣០១. ការកំណត់គោលដៅសមាហរណកម្មប្រកបដោយមហិច្ឆិតា ប៉ុន្តែមិនទាន់សម្រេចបាននៅក្នុងរយៈពេលដំបូងដែលមានកំណត់នៅក្នុងផែនការសកម្មភាព ដោយសារកង្វះនីតិវិធីសម្រាប់សមាហរណកម្ម និងលក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់ការធ្វើសមាហរណកម្ម និងយន្តការតាមដានត្រួតពិនិត្យលើកុមារដែលបានសមាហរណកម្ម ជាលទ្ធផល ការអនុវត្តផែនការនេះ បានបង្ហាញនូវភាពខុសគ្នាទាក់ទងនឹងគុណភាពនៃដំណើរការសមាហរណកម្ម និងក្តីបារម្ភទាក់ទងនឹងភាពសមស្រប និងភាពគ្រប់គ្រាន់ នៃសេវាគាំទ្រដែលផ្តល់ដល់កុមារ និងគ្រួសារ។

៣០២. ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស៖ ត្រូវការពង្រឹងសមត្ថភាពដល់មន្ត្រីដែលត្រូវទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សអំពីបទល្មើសថ្មីៗ ជាពិសេស ដល់មន្ត្រីថ្មីមួយចំនួន ដែលមានការផ្លាស់ប្តូរមកទទួលតួនាទីភារកិច្ច។ ការមិនយល់ស្របគ្នាក្នុងការកំណត់ឯកតាសម្រាប់ទិន្នន័យ នៃរបាយការណ៍។ ជនល្មើសនៅតែបន្តរកកលល្បិចជ្រៀតជ្រែកចូលមកធ្វើសកម្មភាពខុសច្បាប់។ ប្រជាពលរដ្ឋមួយចំនួននៅមិនទាន់យល់ និងមិនទាន់មានភាពរឹងមាំក្នុងការការពារខ្លួនពីកលល្បិចជនល្មើស។

៣០៣. ការផ្លាស់ប្តូរឥរិយាបទសាធារណជនទូទៅ ជាពិសេសឪពុកម្តាយ ដែលគិតថា ការទុកដាក់កុមារថែទាំក្នុងមណ្ឌលជាជម្រើសល្អ ដែលជាហេតុធ្វើឱ្យការជំរុញ និងលើកកម្ពស់ការថែទាំកុមារនៅតាមគ្រួសារ និងសហគមន៍ និងការទប់ស្កាត់ និងការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ នៅមានបញ្ហាប្រឈម។ ទន្ទឹមនឹងនេះ សមត្ថភាព បទពិសោធន៍ និងគុណភាពនៃការផ្តល់សេវាសង្គមនៅថ្នាក់មូលដ្ឋាន នៅតែជាឧបសគ្គចំពោះការពង្រឹងប្រព័ន្ធកិច្ចការពារ និងការថែទាំកុមារ។ ការគ្របដណ្តប់ នៃសេវាសុខុមាលភាពកុមារ និងកិច្ចគាំពារសង្គមនៅមានកម្រិត រួមជាមួយនឹងសេវារបស់អង្គការមិនមែនរដ្ឋាភិបាលមានទំហំតូចៗ និងផ្តោតលើតំបន់គោលដៅរៀងៗខ្លួន បង្កឱ្យមានការគាំទ្រ និងលទ្ធផលខុសគ្នាស្រឡះសម្រាប់កុមារ។ ហានិភ័យនេះមានលក្ខណៈគួរឱ្យកត់សម្គាល់ចំពោះកុមារមានពិការភាព កុមារមានតម្រូវការពិសេស និងកុមារមកពីសហគមន៍ដាច់ស្រយាល ដែលតម្រូវការរបស់ពួកគេមិនត្រូវបានចាត់ជាអាទិភាព និងមិនសមស្របតាមគោលការណ៍សមធម៌។

៣០៤. វិបត្តិសេដ្ឋកិច្ចសកល និងជំងឺកូវីដ-១៩ បានដាក់សំពាធលើការប្រកួតប្រជែងនាំចេញកាន់តែតានតឹង និងការឆ្លើយតបលក្ខខណ្ឌការងារកាន់តែរឹតបន្តឹង ដែលតម្រូវឱ្យវិធានការទប់ស្កាត់ពលកម្មកុមារកាន់តែមានលក្ខណៈបុរេសកម្ម និងនវានុវត្តន៍ទៅលើសេវាការងាររហ័ស។ លក្ខខណ្ឌការងារ លក្ខខណ្ឌសុវត្ថិភាពនិងសុខភាពការងារ មិនទាន់ត្រូវបានអនុវត្តពេញលេញ និងគ្របដណ្តប់នៅគ្រប់សកម្មភាពសេដ្ឋកិច្ច និងសហគ្រាស គ្រឹះស្ថាននៅឡើយ។ ការយល់ដឹងរបស់សាធារណជន និងការផ្លាស់ប្តូរឥរិយាបថសហគមន៍នៃការប្រើប្រាស់ពលកម្មកុមារនៅមានកម្រិត។ ការយល់ដឹងរបស់និយោជក និងកម្មករនិយោជិត អំពីសិទ្ធិ និងកាតព្វកិច្ចដែលមានចែងនៅក្នុងច្បាប់ និង បទប្បញ្ញត្តិពាក់ព័ន្ធវិស័យការងារ នៅមានកម្រិតជាពិសេសការប្រើប្រាស់កម្មករនិយោជិតវ័យក្មេង។

៣០៥. ការអនុវត្តកម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈមានភាពបត់បែន និងគ្របដណ្តប់គ្រប់ទិដ្ឋភាព និងធានាភាពពធន់ នៃកម្លាំងពលកម្មនៅមិនទាន់ឆ្លើយតបបានល្អនៅក្នុងបដិវត្តន៍ឧស្សាហកម្ម ៤.0 សេដ្ឋកិច្ច និងសង្គមឌីជីថល និងសេដ្ឋកិច្ចបៃតង ខណៈចំនួនសិក្ខាកាម សិស្ស និស្សិតដែលទទួលបានការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈនៅមានចំនួនតិចនៅឡើយ។

## IV. ទិសដៅអនុវត្តបន្ត

៣០៦. ក.ជ.ក. បន្តសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិនិងក្រោមជាតិ ដោយប្រើប្រាស់យន្តការដែលមានស្រាប់ ធ្វើការបណ្តុះបណ្តាល ផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹងអំពីច្បាប់ លិខិតបទដ្ឋាន ផែនការជាតិ យុទ្ធសាស្ត្រជាតិ អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធិសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ និងលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធ។ ជាពិសេសជំរុញការអនុវត្តសារាចរលេខ០៦ សរ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ ឱ្យមានប្រសិទ្ធភាពខ្ពស់។

៣០៧. លើសពីនេះទៀត ក.ជ.ក. នឹងពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ដោយជំរុញការរៀបចំបង្កើតប្រព័ន្ធទិន្នន័យ នៃការអនុវត្តសិទ្ធិកុមារ ព្រមទាំងត្រូវបំពេញតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាល ជាច្រកចេញចូលតែមួយក្នុងការពិនិត្យ និងរាយការណ៍ពាក់ព័ន្ធនឹងវិស័យការងារកុមារ។ សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្ត និងដាក់បញ្ចូលអនុសាសន៍ នៃសេចក្តីសង្កេតចុងក្រោយទៅក្នុងផែនការយុទ្ធសាស្ត្ររបស់ក្រសួងស្ថាប័នសាមី។ កាត់បន្ថយ និងលុបបំបាត់អំពើជួញដូរ អំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ចគ្រប់រូបភាពមកលើកុមារ។ បន្តពង្រឹង និងពង្រីក ក.ជ.ក. នៅគ្រប់លំដាប់ថ្នាក់ ដើម្បីជាយន្តការសម្របសម្រួលជួយដល់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្នុងការអនុវត្តភារកិច្ចលើវិស័យការងារកុមារ ឱ្យមានប្រសិទ្ធភាព។ ពង្រីកការចូលរួមរបស់កុមារតាមរយៈព្រឹត្តិការណ៍ជាតិ ក្រោមជាតិ តំបន់ និងថ្នាក់អន្តរជាតិនានា។ រាល់មតិយោបល់របស់កុមារ ត្រូវយកមកពិចារណា និងដាក់បញ្ចូលទៅក្នុង ផែនការសកម្មភាពនានាសម្រាប់ការអភិវឌ្ឍសិទ្ធិរបស់ពួកគេ។

៣០៨. វិស័យសុខាភិបាលបានផ្តោតលើអាទិភាពជាយុទ្ធសាស្ត្រ រួមមាន៖ ការពង្រីកការគ្រប់ដណ្តប់នៃសេវាសុខាភិបាល ការលើកកម្ពស់គុណភាពសេវាសុខាភិបាល ការពង្រីកការគ្រប់ដណ្តប់នៃប្រព័ន្ធគាំពារសុខភាពសង្គម ការពង្រឹងប្រព័ន្ធសន្តិសុខសុខភាព និងការពង្រឹងហេដ្ឋារចនាសម្ព័ន្ធគ្រឹះនៃប្រព័ន្ធសុខាភិបាល ដែលគ្រប់ដណ្តប់លើ ការអភិវឌ្ឍស្ថាប័ន ការអភិវឌ្ឍធនធានមនុស្ស ការលើកកម្ពស់ការគ្រប់គ្រងធនធានហិរញ្ញវត្ថុ ការគ្រប់គ្រងធនធានជាសារវន្តផ្សេងទៀត ការអភិវឌ្ឍទិន្នន័យប្រព័ន្ធសុខាភិបាល សុខាភិបាលឌីជីថល និងនវានុវត្តន៍។

៣០៩. វិស័យអប់រំ រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកការអភិវឌ្ឍមូលធនមនុស្សជាអាទិភាពទី១ នៅក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដោយផ្តោតលើការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ ដោយផ្តោតលើគន្លឹះ ៤ចំណុច រួមមាន៖ ទី១. ការពង្រឹងអភិបាលកិច្ចសាលារៀន ទី២. ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស ទី៣. ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈ កម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួតពិនិត្យ គុណភាពចំណីអាហារនៅតាមសាលា និងទី៤. ការជំរុញ និងលើក ទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ស្របតាមពាក្យស្លោក ភាពជាដៃគូរដ្ឋ និងសហគមន៍ ដើម្បីការអប់រំ។

៣១០. វិស័យសង្គមកិច្ច លើកកម្ពស់ការពារកុមារ ក្រសួង ស.អ.យ. បានបន្តពង្រឹងការលើកកម្ពស់សេវាកិច្ចការពារកុមារ ទាំងអហ្វឡាញ និងអនឡាញ ដោយពន្លឿនការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារ

កុមារ ពង្រឹងសមត្ថភាព និងគុណភាពនៃការគ្រប់គ្រងមណ្ឌលថែទាំកុមារ ពង្រឹងការអនុវត្តប្រព័ន្ធទិន្នន័យអធិការកិច្ចកន្លែងថែទាំកុមារ និងប្រព័ន្ធទិន្នន័យគ្រប់គ្រងករណីកុមារ Primero លើកកម្ពស់ការថែទាំកុមារតាមគ្រួសារ និងសហគមន៍ ព្រមទាំងពង្រឹង និងពង្រីកកម្មវិធីទុកដាក់កុមារជាអចិន្ត្រៃយ៍តាមរយៈសុំកូនក្នុងប្រទេស។

៣១១. លើកកម្ពស់ការអប់រំ ផ្សព្វផ្សាយ និងធ្វើការជាមួយអ្នកពាក់ព័ន្ធ ដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ និងការទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ និងសម្របសម្រួលផ្តល់សេវាដល់កុមារតាមម្តាយក្នុងពន្ធនាគារ។ បន្តជំរុញឱ្យអង្គការដៃគូដាក់ពាក្យស្នើសុំវិញ្ញាបនបត្រទទួលស្គាល់មណ្ឌលថែទាំជំនួសចំពោះកុមារ និងពង្រឹងនិងពង្រីកកម្មវិធីបណ្តុះបណ្តាលផ្តល់ការទទួលស្គាល់គុណវុឌ្ឍិន៍ នៃអង្គការសុវត្ថិភាពកុមារ។ បន្តគាំទ្របច្ចេកទេសពាក់ព័ន្ធនឹងកិច្ចការពារកុមារដល់រដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តមុខងារ និងសហការជាមួយក្រសួងមហាផ្ទៃ ដើម្បីអនុវត្តនីតិវិធីប្រតិបត្តិកិច្ចការពារកុមារសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ លើកកម្ពស់កិច្ចការគ្រួសារ និងសេវាគាំពារជនរងគ្រោះ ដោយបន្តសហការជាមួយ ក្រសួង ស្ថាប័ន អង្គការ និងសមាគមពាក់ព័ន្ធនានា ដើម្បីសម្របសម្រួល និងផ្តល់សេវាដល់មុខសញ្ញា ដែលជាជនរងគ្រោះ និងងាយរងគ្រោះ ដោយអំពើជួញដូរមនុស្ស។

៣១២. បន្តលើកកម្ពស់សេវាស្តារនីតិសម្បទាអនីតិជន ដោយពង្រឹងការគ្រប់គ្រងមណ្ឌលយុវនីតិសម្បទា ការគ្រប់គ្រងករណីអនីតិជនក្រោយពេលធ្វើសមាហរណកម្ម និងពង្រីកកម្មវិធីបង្វែរកុមារចេញពីប្រព័ន្ធតុលាការ។ លើកកម្ពស់សេវាស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដោយផ្តោតលើការលើកកម្ពស់ការគ្រប់គ្រងមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ការគ្រប់គ្រងករណីអ្នកញៀនគ្រឿងញៀនក្រោយពេលធ្វើសមាហរណកម្ម និងការតាមដានគុណភាពស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។

៣១៣. លើកកម្ពស់សុខុមាលភាពជនមានពិការភាព ដោយប្រមូលផ្តុំលើការលើកកម្ពស់សិទ្ធិការងារ និងសេវាយុត្តិធម៌ជនមានពិការភាព ការគាំទ្រសកម្មភាពកីឡា សិល្បៈនិងវប្បធម៌ជនពិការ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបង្កើតបរជូនជនពិការ ព្រមទាំងផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនមានពិការភាព ដូចជា ការផ្តល់សេវាស្តារលទ្ធ ភាពពលកម្មកាយសម្បទា និងសេវាស្តារវេជ្ជសាស្ត្រជូនជនពិការ ការផលិតឧបករណ៍សិប្បនិម្មិត រណប ដាក់ហិបសប្បុរសធម៌ ការផ្តល់របបគោលនយោបាយជួយឧបត្ថម្ភជនពិការ និងការលើកកម្ពស់ការ គ្រប់គ្រងមជ្ឈមណ្ឌលជាតិជនពិការកម្ពុជា។

៣១៤. ជំរុញការអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ និងគោលការណ៍ណែនាំស្តីពីក្របខណ្ឌកិច្ចគាំពារសង្គមឆ្លើយតបនឹងគ្រោះអាសន្ន ដែលរាជរដ្ឋាភិបាលបានប្រកាសជាផ្លូវការនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ ២០២៣ នឹងត្រូវចាប់ផ្តើមចាប់ពីខែមេសា ឆ្នាំ២០២៤ តទៅ។ រៀបចំកម្មវិធីស្ពានចម្លងសេវាសង្គមដល់គ្រួសារក្រីក្រ តាមរយៈការអនុវត្តកម្មវិធីស្ពានចម្លងសេវាសង្គមដល់គ្រួសារក្រីក្រ ជាពិសេសគ្រួសារដែលមានកុមារកំព្រា កុមារដែលគេបោះបង់ចោល មនុស្សវ័យចាស់គ្មានទីពឹង ជនមានពិការភាព ជនអនាថា និងអ្នកញៀនគ្រឿងញៀន។

៣១៥. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់ចេញទិសដៅអនុវត្តបន្តដូចខាងក្រោម៖

- បន្តការធ្វើសមាហរណកម្ម និងទំនើបកម្មការធ្វើអធិការកិច្ចការងារ សំដៅលើកកម្ពស់លក្ខខណ្ឌការងារឱ្យកាន់តែប្រសើរឡើង ដោយបានបន្តពង្រឹងយន្តការក្រុមអធិការកិច្ចការងារតែមួយ, ពង្រឹងគុណភាព និងប្រសិទ្ធភាពអធិការកិច្ចការងារដោយចុះអធិការកិច្ចផ្អែកលើកម្រិតហានិភ័យរបស់រោងចក្រ សហគ្រាសនីមួយៗ និងវិធីសាស្ត្រអធិការកិច្ចប្រកបដោយវិជ្ជាជីវៈ និងចុះអធិការកិច្ចការងារតែ ១ដង/ឆ្នាំ
- បន្តជំរុញការអនុវត្ត "វប្បធម៌អនុលោមភាពការងារ" តាមរយៈការពង្រឹងប្រព័ន្ធអធិការកិច្ចការងារតាមបែបបុរេសកម្មដែលមានប្រសិទ្ធភាព និងពង្រឹងយន្តការគាំទ្រគម្រោងរោងចក្រ កាន់តែប្រសើរនៅកម្ពុជា
- បន្តចាត់វិធានការយ៉ាងម៉ឺងម៉ាត់តាមច្បាប់ក្នុងការផាកពិន័យ និងវិធានការដទៃទៀត ដោយមិនមានការលើកលែងចំពោះសហគ្រាស គ្រឹះស្ថាន ដែលមិនបានអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ
- រៀបចំប្រព័ន្ធទទួលបណ្ដឹងតាមប្រព័ន្ធព័ត៌មានវិទ្យាពាក់ព័ន្ធនឹងការមិនអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ ដែលត្រូវដាក់លើគេហទំព័ររបស់ក្រសួងនិងផ្សព្វផ្សាយដល់សាធារណជន
- ជំរុញយុទ្ធនាការស្ដីពី "សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ" ទៅជាចលនាជាតិមួយនៅកន្លែងធ្វើការងារដែលគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសកម្មករនិយោជិត និងនិយោជក ត្រូវចូលរួមអនុវត្ត ដើម្បីបង្កើតនូវវប្បធម៌អនុលោមភាពតាមច្បាប់ សុខុដុមនីយកម្មក្នុងទំនាក់ទំនងវិជ្ជាជីវៈ និងទំនួលខុសត្រូវផ្នែកសង្គម និងសហគ្រាស
- បន្តលើកកម្ពស់លក្ខខណ្ឌការងារ លក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារនៅកន្លែងធ្វើការ ដើម្បីសុខភាព និងសុខុមាលភាពរបស់កម្មករនិយោជិត ដោយបន្តអនុវត្តឱ្យកាន់តែល្អប្រសើរ កាត់បន្ថយឱ្យបានជាអតិបរមានូវបញ្ហាគ្រោះថ្នាក់ការងារ និងហានិភ័យនានា
- ជំរុញការអនុវត្តផែនការសកម្មភាពដើម្បីកាត់បន្ថយពលកម្មកុមារ និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (២០១៦-២០២៥) ដើម្បីទប់ស្កាត់ និងការពារកុមារពីគ្រប់ទម្រង់នៃពលកម្មកុមារ និងផ្ដល់ឱកាសឱ្យកុមារ និងក្រុមគ្រួសាររបស់ពួកគេទទួលបានការអប់រំ បណ្ដុះបណ្ដាលជំនាញ និងបង្កើនជីវភាពរស់នៅ។
- ពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ចការងារ ស្ដីពីការទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុត នៃពលកម្មកុមារ និងការងារដោយបង្ខំ។
- បាននិងកំពុងធ្វើបច្ចុប្បន្នភាពលើផែនការសកម្មភាពជាតិដំណាក់កាលទី២ និងរៀបចំកសាងផែនការសកម្មភាពជាតិដំណាក់កាលទី៣
- បង្កើតក្រុមការងារអន្តរាគមន៍ចំនួន ៦ និងគោលការណ៍ណែនាំស្ដីពីកិច្ចអន្តរាគមន៍ អំពីការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- បន្តអនុវត្តកម្មវិធីបណ្ដុះបណ្ដាលជំនាញបច្ចេកទេសវិជ្ជាជីវៈ ដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស។
- ជំរុញការរៀបចំទារកដ្ឋាន និងមត្តេយ្យសហគមន៍នៅក្នុងតំបន់ប្រមូលផ្ដុំរោងចក្រ និង/ឬសួនឧស្សាហកម្ម/តំបន់សេដ្ឋកិច្ចពិសេស ត្រូវបានរៀបចំ និងកែលម្អ ឱ្យបានយ៉ាងតិច ១២ ត្រឹមឆ្នាំ ២០២៨

- បន្តពង្រឹងការផ្តល់សេវារបស់ ប.ស.ស. ដោយធានាបាននូវការទទួលទិន្នន័យរបស់កម្មករនិយោជិត ដែលបានទទួលសេវា ប.ស.ស. និងគ្រប់កម្មករនិយោជិតទាំងអស់ ត្រូវទទួលបានផលប្រយោជន៍ដែលមានចែងក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវា ប.ស.ស. ដោយសហការជាមួយក្រសួងសុខាភិបាល និងក្រុមប្រឹក្សាគាំពារសង្គម
- ពិនិត្យការកំណត់អាយុរបស់កុមារ ក្នុងការបម្រើការងារនៅតាមសហគ្រាស គ្រឹះស្ថាននានា និងវិស័យនាំចេញ ព្រមទាំងធានាឱ្យបានថា មិនមានក្មេងអាយុក្រោម១៥ឆ្នាំធ្វើការក្នុងវិស័យនាំចេញ
- ពង្រឹងយន្តការ តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពក្នុងការជ្រើសរើសការបណ្តុះបណ្តាល និងការបញ្ជូនពលករទៅធ្វើការនៅបរទេស ព្រមទាំងពង្រឹងយន្តការគ្រប់គ្រង និងសេវាគាំពារនៅតាមប្រទេសទទួលដល់ពលករទេសន្តរប្រវេសន៍កម្ពុជា ដែលស្នាក់នៅនិងកំពុងធ្វើការនៅប្រទេសគោលដៅ។

៣១៦. ក្រសួងកិច្ចការនារី បន្តបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិលើឧបករណ៍ឯកទេស (កម្រិតទី៣) ស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន។ ផ្តល់កិច្ចអន្តរាគមន៍ជំនួយផ្នែកច្បាប់និងសេវាសង្គម ការសម្របសម្រួល គាំទ្រស្ត្រីនិងក្មេងស្រីរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើរំលោភបំពានផ្លូវភេទ។ ទប់ស្កាត់អាពាហ៍ពិពាហ៍វ័យក្មេង និងការមានផ្ទៃពោះវ័យជំទង់ អំពើហិង្សាក្នុងគ្រួសារ។

៣១៧. បន្តពង្រីកកិច្ចសហការជាមួយបណ្តាប្រទេសក្នុងតំបន់ និងអន្តរជាតិ ដើម្បីពង្រីកការអនុវត្តច្បាប់អន្តរជាតិ និងកិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ សហគមន៍ ប្រជាពលរដ្ឋ មាតាបិតា អាណាព្យាបាល សំដៅជំរុញលើកកម្ពស់ការអនុវត្តសិទ្ធិកុមារ។

# V. សេចក្តីសន្និដ្ឋាន

៣១៨. ការរក្សាបាននូវសន្តិភាព និងការពង្រឹងស្ថិរភាពសង្គម នយោបាយ បានចូលរួមចំណែកយ៉ាងធំធេង ក្នុងការធ្វើឱ្យរក្សាបានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងធានាបាននូវកំណើនសេដ្ឋកិច្ចរបស់កម្ពុជាគួរឱ្យកត់សម្គាល់។ តាមរយៈការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៩-២០២៣ ប្រកបដោយចក្ខុវិស័យច្បាស់លាស់ កម្ពុជាបានឈានដល់ឋានៈ ជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបកាលពីឆ្នាំ២០១៥ និងមានគោលដៅសម្រេចឱ្យបានជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ វឌ្ឍនភាពគួរជាទីមោទនៈនេះ គឺជាការបង្ហាញនូវជំហរ និងជំហានយុទ្ធសាស្ត្រដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ក្នុងការដឹកនាំនិងអភិវឌ្ឍប្រទេសប្រកបដោយសុខដុម។

៣១៩. ស្របគ្នានេះ ស្ថានភាពរបស់កុមារក៏បានប្រសើរឡើងជាលំដាប់ តាមរយៈការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហាប្រឈមនានារបស់កុមារ ក៏ដូចជាប្រជាពលរដ្ឋទូទៅ។ ការពង្រឹងវិស័យសុខាភិបាល មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដោយបានអនុវត្តកម្មវិធីលើកកម្ពស់សុខភាពបន្តពូជ សុខភាពមាតា ទារក កុមារ និងការកែលម្អកង្វះអាហារូបត្ថម្ភ ដែលធ្វើឱ្យអត្រាមរណភាពរបស់មាតា ទារក កុមារ មានការធ្លាក់ចុះគួរឱ្យកត់សម្គាល់។ គួរកត់សម្គាល់ថា មរណភាពទារក និងកុមារអាយុក្រោម ៥ឆ្នាំ សម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ មុនកាលកំណត់ ៨ ឆ្នាំ។ អន្តរាគមន៍នៃសេវាបង្ការ និងគ្រប់គ្រងជំងឺមិនឆ្លងចម្បងៗត្រូវបានពង្រឹង និងពង្រីកការគ្របដណ្តប់ បានកាត់បន្ថយអត្រាឈឺ និងអត្រាស្លាប់បណ្តាលមកពីជំងឺឆ្លងចម្បងៗ ដូចជាមេរោគអេដស៍/ជំងឺអេដស៍ ជំងឺគ្រុនចាញ់ គ្រុនឈាម និងជំងឺរបេងជាដើម។ រីឯគុណភាពសេវា ក៏ត្រូវបានកែលម្អជាប្រចាំ តាមរយៈការវាយតម្លៃគុណភាពនៃការងារគ្រប់គ្រង និងគុណភាពនៃសេវាថែទាំប្រចាំត្រីមាស។

៣២០. ក្រសួង អ.យ.ក. និងអ្នកពាក់ព័ន្ធបានរួមគ្នាសម្រេចកិច្ចការធំៗគួរឱ្យកត់សម្គាល់ ដូចជា ការបង្កើនការចូលរៀនប្រកបដោយសមធម៌នៅគ្រប់ភូមិសិក្សា ជាពិសេសការ អប់រំកម្រិតមូលដ្ឋាន ៩ឆ្នាំ តាមរយៈការបង្កលក្ខណៈសម្បត្តិអនុគ្រោះឱ្យកូនចៅប្រជាជន ដែលជួបការលំបាកមានលទ្ធភាពចូលរៀន រៀនបន្ត ការពង្រឹងអភិបាលកិច្ចនៅតាមគ្រឹះស្ថានសិក្សា ការដោះស្រាយការខាតបង់ការសិក្សាក្នុងបរិបទកូវីដ១៩ និងការបង្កើនអាហារូបករណ៍សម្រាប់សិស្ស និងនិស្សិតមកពីគ្រួសារក្រីក្រ។ល។ គុណភាព និងភាពឆ្លើយតបរបស់សេវាអប់រំក៏ត្រូវបានពង្រឹង តាមរយៈការលើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀន និងការលើកទឹកចិត្ត ព្រមទាំងបង្កើនស្វ័យភាព គណនេយ្យភាព និងភាពជាអ្នកដឹកនាំក្នុងការគ្រប់គ្រងសេវាអប់រំគ្រប់លំដាប់ថ្នាក់។ល។

៣២១. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បន្តការយកចិត្តទុកដាក់ការពារកុមារពីការរំលោភបំពាន និងកេងប្រវ័ញ្ចគ្រប់រូបភាព រួមទាំងការជួញដូរកុមារ ការប្រើប្រាស់អំពើហិង្សាលើកុមារ។ កុមារគ្រប់រូប មានសិទ្ធិក្នុងការធំលូតលាស់នៅក្នុងបរិយាកាសដោយសុវត្ថិភាព និងការចិញ្ចឹមបីបាច់គ្មាន អំពើហិង្សា និងការកេងប្រវ័ញ្ច។ ដោយសារការគាំទ្រ និងការវិនិយោគមានការកើនឡើងសម្រាប់វិស័យ កិច្ចការពារកុមារ កុមារនៅកម្ពុជាទទួលបាននូវកិច្ចការពារកាន់តែប្រសើរឡើងជាងមុន តាមរយៈ ការពង្រឹងការអនុវត្តច្បាប់ បទដ្ឋានគតិយុត្ត និងសេវាឆ្លើយតបសមស្រប និងទាន់ពេលវេលា។ ជាមួយគ្នា នេះដែរ

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ កម្ពុជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៅក្នុងការបង្កើតកម្មវិធីជំនួយសង្គម យន្តការជាមូលដ្ឋានសម្រាប់កិច្ចការពារកុមារ ការធ្វើសមាហរណកម្មកុមារចេញពីមណ្ឌលថែទាំជំនួស ការប្រយុទ្ធប្រឆាំងដើម្បីបញ្ឈប់អំពើហិង្សាលើកុមារ រួមទាំងក្លាយជាប្រទេសជាសមាជិកនៃប្រទេសដៃគូដើម្បីបញ្ចប់អំពើហិង្សាលើកុមារ។

៣២២. ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ដើម្បីបញ្ចប់ពលកម្មកុមារ ត្រូវបានបង្ហាញតាមរយៈការតាមដាន និងអនុវត្តលើអនុសញ្ញាអន្តរជាតិខាងការងារដែលបានផ្តល់សច្ចាប័ន ការដាក់ចេញនូវច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងពលកម្មកុមារ។ ទោះបីពលកម្មកុមារ គឺជាបាតុភូតសេដ្ឋកិច្ចសង្គមដ៏ស្មុគស្មាញក្តី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាននិងកំពុងបន្តកិច្ចខិតខំប្រឹងប្រែងអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការពង្រឹង និងលើកកម្ពស់សិទ្ធិជាមូលដ្ឋានរបស់កុមារ ដើម្បីធានាបាននូវឧត្តមប្រយោជន៍សម្រាប់កុមារ តាមរយៈការធ្វើឱ្យកាន់តែប្រសើរឡើងនូវស្ថានភាពទីផ្សារការងារ ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ លក្ខខណ្ឌការងារ លក្ខខណ្ឌសុវត្ថិភាពនិងសុខភាពការងារ សុខដុមនីយកម្មក្នុងទំនាក់ទំនងវិជ្ជាជីវៈ និងរបបសន្តិសុខសង្គម។

៣២៣. សមិទ្ធផលទាំងនេះ គឺជាការឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញាស្មារតីប្រកបដោយទំនួលខុសត្រូវខ្ពស់ របស់គ្រប់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាត ដែលមានមនសិការមុតមាំក្នុងការពុះពារគ្រប់បញ្ហាប្រឈម ដើម្បីលើកកម្ពស់សុខុមាលភាព និងឧត្តមប្រយោជន៍របស់កុមារ តាមរយៈការពង្រឹងការអនុវត្តសិទ្ធិកុមារ។ ក.ជ.ក. នឹងបន្តសម្របសម្រួលក្រសួង ស្ថាប័ន ដើម្បីបង្ការ ទប់ស្កាត់ និងអន្តរាគមន៍ចំពោះអំពើហិង្សាលើកុមារ ព្រមទាំងដាក់ចេញនូវយន្តការឆ្លើយតបចាំបាច់នានា ដើម្បីសម្រេចបានតាមគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ឆ្នាំ ២០៣០។

៣២៤. ក.ជ.ក. សូមសម្តែងនូវអំណរគុណដល់គ្រប់ក្រសួង ស្ថាប័នជាតិ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការ អង្គការជាតិ-អន្តរជាតិ ដៃគូអភិវឌ្ឍនានា ប្រជាជន សហគមន៍ ព្រះសង្ឃ ព្រឹទ្ធាចារ្យ មាតាបិតា អ្នកអាណាព្យាបាល និងកុមារខ្លួនឯងផ្ទាល់ ដែលបានចូលរួមចំណែកក្នុងការអនុវត្តសិទ្ធិកុមារនៅកម្ពុជាឲ្យមានការរីកចម្រើនស្របតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ។

-----------------------